R E V

បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

# អំណាចនៃការសម្រាក

O L U

ហ្គារី ឃីស៊ី

GARY KEESEE

T I O N

បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

# អំណាចនៃការសម្រាក

ហ្គារី ឃីស៊ី

GARY KEESEE

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក**
*អំណាចនៃការសម្រាក*

រក្សាសិទ្ធិ © ២០១៨ ដោយ ហ្គារី ឃីស៊ី (Gary Keesee)

សម្រាប់សម្រង់ខគម្ពីរគឺបានដកស្រង់ចេញពីព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន ឆ្នាំ២០០៥ ដោយ សមាគមព្រះគម្ពីរកម្ពុជា ©រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ២០០៥ - ដកស្រង់ ដោយមានការអនុញ្ញាត។

សៀវភៅនេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាងក្រោមច្បាប់ស្តីអំពីសិទ្ធិអ្នកនិពន្ធអន្តរជាតិ។ សម្រាប់មាតិកា និង/ឬក្របសៀវភៅនេះនឹងមិនត្រូវផលិតឡើងវិញទាំងស្រុង ឬតាមផ្នែក នៅក្នុងទម្រង់ណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគ្រឹះស្ថានបោះពុម្ពផ្សាយឡើយ។

លេខ ISBN: 978-1-945930-03-4

បោះពុម្ពផ្សាយដោយ Free Indeed Publishers ។
ធ្វើការចែកចាយដោយ Faith Life Now

Faith Life Now
P.O. Box 779
New Albany, OH 43054
1-(888)-391-LIFE

អ្នកអាចទំនាក់ទំនងទៅកាន់ព័ន្ធកិច្ច Faith Life Now តាមប្រព័ន្ធអ៊ីនធឺណិតតាមគេហទំព័រ www.faithlifenow.com

ខ្ញុំចង់ឧទ្ទិសសៀវភៅនេះជូនចំពោះ ឌ្រិនដា (Drenda) ភរិយារបស់ខ្ញុំ ដោយសារតែសៀវភៅនេះបានកើតឡើងដោយសារតែមានការលើកទឹកចិត្តពីគាត់ ចិត្តឆេះឆួលរបស់គាត់ចំពោះរឿងរ៉ាវរបស់ព្រះជាម្ចាស់ និងសេចក្ដីស្រលាញ់របស់គាត់ចំពោះក្រុមគ្រួសាររបស់គាត់ និងខ្ញុំជាអ្វីដែលបានជំរុញទឹកចិត្តដល់ខ្ញុំក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ ជាមួយគ្នានេះ យើងបានបញ្ជាក់ឱ្យឃើញថាសុបិនពិតជាអាចក្លាយជាការពិតបានមែន!

ហ្គារី ឃីស៊ី

# បញ្ជីមាតិកា


សេចក្តីផ្តើម.......................................................................................................1

ជំពូក ១ មូលដ្ឋានគ្រឹះនៃការសម្រាក.........................................................................7

ជំពូក ២ សិទ្ធស្របច្បាប់........................................................................................23

ជំពូក ៣ ព្រះរាជ្យនៃព្រះគឺជាចម្លើយរបស់អ្នក ..........................................................45

ជំពូក ៤ ខ្ញុំរកឃើញកូនសោសំខាន់ នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ...........................69

ជំពូក ៥ ការហោះប្រសើរជាងការដើរ.....................................................................85

ជំពូក ៦ មានរឿងល្អជាច្រើនចំពោះជីវិត ជាងការបង់ថ្លៃចំណាយផ្សេងៗទៅទៀត!
.............................................................................................................................105

ជំពូក ៧ មិនអាចទៅរួចទេ! ..................................................................................119

ជំពូក ៨ ចំណែកទ្វេដង.........................................................................................133

ជំពូក ៩ បរិបូរហូរហៀរ!.........................................................................................149

ជំពូក ១០ អាថិកំបាំងនៃចំណែកទ្វេដង ...................................................................175

# សេចក្ដីផ្ដើម

ថ្ងៃដែលយើងបានចាកចេញពីផ្ទះចាស់ក្នុងដីចម្ការរបស់យើងគឺជាថ្ងៃមួយដ៏ជូរចត់។ យើងបានរស់នៅក្នុងផ្ទះដ៏ចាស់តូចមួយ និងជាផ្ទះស្រុកស្រែដ៏ចាស់ទ្រុឌទ្រោមនេះ អស់រយៈពេលដល់ទៅជិតប្រាំបួនឆ្នាំមកហើយ ហើយឥលូវនេះខ្ញុំកំពុងតែលើកហិបដាក់អីវ៉ាន់ចុងក្រោយទៅដាក់នៅលើឡានដឹកទំនិញរបស់យើង។ ខ្ញុំកំពុងតែធ្វើដំណើរឆ្ពោះទៅផ្ទះថ្មីរបស់យើងដែលយើងបានឱ្យគេសាងសង់វាតាមគំរូដែលយើងចង់បាន មានទំហំប្រមាណជាង ៧០០ម៉ែត្រការេ ជាតួមិគ្រឹះម៉ូតបុរាណ (Georgian home) នៅលើដីដែលមានទំហំជាង ២២ហិចតា លើដីចម្ការដ៏ស្រស់ស្អាតក្នុងរដ្ឋ អូហាយ៉ូជាមួយនឹងព្រៃឈើក៏ដូចជាបឹងនៅជុំវិញ លើដីទំហំប្រមាណ ៨ហិចតាផងដែរ។ វាធ្លាប់ជាសុបិនដែលពិបាកនឹងស្រមៃដល់ណាស់ក្នុងរយៈពេលត្រឹមតែពីរបីឆ្នាំមុននេះប៉ុណ្ណោះ។

ទោះបីជាយើងកំពុងតែចាកចេញពីផ្ទះនៅស្រុកស្រែរបស់យើងក៏ដោយក៏ខ្ញុំស្រលាញ់ផ្ទះចាស់នោះណាស់។ មែនហើយ ទោះជាផ្ទះនោះមាន កញ្ចក់បង្អួចបាក់បែក មានបន្ទប់ដាក់អីវ៉ាន់សុទ្ធតែធូលីដី និងតែងតែមានសត្វឃ្មុំវាយប្រហារមកលើយើងជាញឹកញាប់ពេលដែលយើងរស់នៅទីនោះក៏ដោយ។ មានការចងចាំជាច្រើនបានចូលមកក្នុងគំនិតរបស់ខ្ញុំ។ កូនៗរបស់ខ្ញុំពីរនាក់ក្នុងចំណោមកូនទាំងប្រាំនាក់បានចាប់កំណើតក្នុងផ្ទះ នេះ។

ពួកយើងធ្លាប់មានពេលវេលាដ៏ល្អជាច្រើននៅទីនោះ ក៏ប៉ុន្តែយើងក៏មានពេលវេលាជាច្រើនដែលយើងជួបប្រទះភាពតានតឹង និងក្ដីអស់សង្ឃឹមខាងផ្នែកហិរញ្ញវត្ថុ។ មានរឿងជាច្រើនដែលយើងត្រូវរៀននៅទីនោះ។ ទោះបីជាយ៉ាងណាក៏យើងនៅតែពិបាកក្នុងការស្រមៃដល់ណាស់ថាពេលដែលយើងទើបតែរើមករស់នៅក្នុងផ្ទះចាស់នោះកាលពី ៩ឆ្នាំមុននោះយើងសឹងតែគ្មានលុយសម្រាប់បង់ថ្លៃផ្ទះចំនួន៣០០ដុល្លារក្នុងមួយខែបានផង។ ឡានទាំងពីរដែលយើងមាន ពិតជាចាស់ៗណាស់ទៅហើយយើងបានប្រើប្រាស់វាធ្វើដំណើរអស់ចម្ងាយជាច្រើនពាន់គីឡូម៉ែត្រតែឡានទាំងពីរនេះនៅតែជាឡានដែលយើងប្រើទាំងនៅជាប់បំណុលនៅឡើយ។ ក្នុងពេលនោះវាហាក់ដូចជាពេលដែលយើងជំពាក់លុយមនុស្ស គ្រប់គ្នាអីចឹង។ យើងមានកាតក្រេឌីតដែលបានប្រើដល់ចំនួនកំណត់ និងកាតដែលត្រូវគេលុប

ចោលដល់ទៅ ១០កាតឯណោះ យើងជាប់បំណុលលុយកម្ចីក្នុងក្រុមហ៊ុនហិរញ្ញវត្ថុដល់ទៅពីរ ហើយជាការពិតណាស់យើងក៏ត្រូវបង់លុយសម្រាប់ឡានទាំងពីររបស់យើងផង បំណុលជំពាក់បំណុលពន្ធអាករ (IRS) ផង និងលុយរាប់ម៉ឺនដែលយើងបានខ្ចីពីសាច់ញាតិយើងផង ហើយបញ្ជីបំណុលរបស់យើងក៏នៅតែមានច្រើនជាងអ្វីដែលបានរៀបរាប់នេះទៅទៀត។ យើងបានរស់នៅក្នុងជីវិតដែលត្បិតត្បៀតបំផុតខាងផ្នែកហិរញ្ញវត្ថុ។ ជួនកាលយើងយករបស់របរទៅបញ្ចាំ គ្រាន់តែដើម្បីយកទៅទិញអាហារខ្លះសម្រាប់បរិភោគប៉ុណ្ណោះ។ របស់របរផ្ទាល់ខ្លួនរបស់យើងសុទ្ធតែចាស់ៗខ្លាំងណាស់ ហើយជារបស់ដែលបាក់បែក ដែលយើងបានទិញមកក្នុងសភាពចាស់ៗស្រាប់ទៅហើយ។

ស្ថានភាពផ្នែកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងររបស់យើងក្នុងពេលនោះ ធ្វើឱ្យយើងមានក្តីសង្ឃឹមតិចតួចណាស់ចំពោះអនាគតដ៏ភ្លឺស្វាងមួយ។ និយាយដោយស្មោះទៅចុះខ្ញុំពិតជាមើលមិនឃើញក្តីសង្ឃឹមច្រើនទេថា អ្វីៗអាចនឹងមានការផ្លាស់ប្តូរ។ ខ្ញុំស្រលាញ់ក្រុមគ្រួសារខ្ញុំណាស់ ហើយខ្ញុំមានភរិយាដ៏ស្រស់ស្អាតម្នាក់ ក៏ប៉ុន្តែពេលនោះខ្ញុំហាក់ដូចជាកំពុងទាញពួកគេឱ្យធ្លាក់ចូលក្នុងស្ថាននរកនៃហិរញ្ញវត្ថុអីចឹង!

ពេលនោះខ្ញុំបានប្រើប្រាស់ថ្នាំរម្ងាប់អារម្មណ៍ដើម្បីដោះស្រាយជាមួយនឹងការវាយប្រហារផ្សេងៗពីភាពស្លន់ស្លោ ហើយភាពភ័យខ្លាចបានលេបត្របាក់ជីវិតខ្ញុំជារៀងរាល់ថ្ងៃ។ ពេលនោះអាចគ្រាន់តែនិយាយថា ខ្ញុំមិនមែនជាមនុស្សដែលសប្បាយរីករាយបំផុតដែលគេចង់នៅក្បែរនោះទេ។ ខ្ញុំគឺជាអ្នកលក់ធានារ៉ាប់រងដែលផ្គត់ផ្គង់ជីវភាពតាមរយៈកម្រៃជើងសារ ហើយយើងចេញទៅណាមិនរួចសោះ ក្រៅតែអំពីចូលកាន់តែជ្រៅទៅៗក្នុងអន្លង់នៃកង្វះខាតខាងផ្នែកហិរញ្ញវត្ថុ។ ជារឿយៗយើងកាន់តែលង់ខ្លួនជ្រៅទៅៗនៅក្នុងបំណុលរហូតទាល់តែផ្លូវដែលយើងអាចជំពាក់បំណុលតទៅទៀតគ្មាននៅសេសសល់សម្រាប់យើងឡើយ។ និយាយមកដល់ត្រឹមចំណុចនេះ អារម្មណ៍ខ្ញុំក៏បានបែកខ្ញែកខ្ទេចខ្ទី។ ភាពស្លន់ស្លោ និងភាពភិតភ័យបានគ្របដណ្តប់លើចិត្តគំនិតរបស់ខ្ញុំ។ ខ្ញុំខ្លាចមិនហ៊ានសូម្បី តែចេញពីផ្ទះ ហើយការធ្វើបែបនេះវាមិនល្អទេចំពោះកម្រៃជើងសារដែល បានពីការលក់។

ភរិយារបស់ខ្ញុំគិតថានឹងគាត់នឹងអាចបាត់បង់ប្តីរបស់គាត់ ហើយគាត់ភ័យខ្លាចថាគាត់នឹងត្រូវចិញ្ចឹមកូនទាំងបួននាក់របស់យើងតែម្នាក់ឯង។ គំនិតនេះបានលងបន្លាចគាត់នៅពេលនោះ។ ក៏ប៉ុន្តែគាត់គឺជាមនុស្សដែលមានជំនឿរឹងមាំម្នាក់លើអំណាចនៃសេចក្តីអធិស្ឋាន និងមិនបោះបង់ខ្ញុំចោលឡើយ។ យើងបានអធិស្ឋានរួមគ្នា ហើយបន្ទាប់យើងបាន

រៀបចំ គម្រោងដើម្បីស្វែងយល់អំពីគោលការណ៍ផ្សេងៗនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ក្នុងពេលដែលយើងបានស្វែងរកព្រះជាម្ចាស់ដើម្បីទទួលបានចម្លើយ និងគោលការណ៍ផ្សេងៗ ក្តីសង្ឃឹមក៏បានចាប់ផ្តើមរះឡើងនៅក្នុងដួងចិត្តយើង ក្នុងពេលដែលយើងបានឃើញការអស្ចារ្យកើតឡើងមួយហើយមួយទៀត ពេលយើងអនុវត្តនូវអ្វីដែលព្រះជាម្ចាស់បានបង្ហាញដល់យើង។

ពេលវេលាដែលមិនអាចបំភ្លេចបានមួយបានកើតឡើង ក្នុងយប់មួយដែលព្រះជាម្ចាស់បានបង្ហញខ្ញុំថា ខ្ញុំនឹងបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួនមួយក្នុងវិស័យហិរញ្ញវត្ថុ ដែលជួយដល់មនុស្សឱ្យចាកចេញពីបំណុល និងបង្រៀនពួកគេនូវគោលការណ៍ផ្សេងៗដែលទ្រង់បានបង្ហាញឱ្យខ្ញុំឃើញនេះ។ ពេលនោះដែរ ការចាប់ផ្តើមបង្កើតក្រុមហ៊ុនមួយដែលបង្ហាញប្រាប់មនុស្សពីរបៀបចាកចេញពីបំណុល មើលទៅហាក់ដូចជាចម្លែកសម្រាប់យើង ដោយសារតែយើងកំពុងតែរស់នៅជាមួយបំណុលជាច្រើននៅឡើយទេ។ យើងបានអធិស្ឋានអំពីរឿងនេះ ក៏ប៉ុន្តែព្រះអម្ចាស់បានប្រាប់យើងថាក្នុងពេលដែលយើងហ៊ានឈានជើងចេញដំណើរ និងចាប់ផ្តើមបង្រៀនអំពីគោលការណ៍របស់ទ្រង់ យើងក៏នឹងស្វែងរកឃើញសេរីភាពឱ្យខ្លួនឯងដែរ។ ការចាប់ផ្តើមបង្កើតក្រុមហ៊ុនមួយ គឺជាដំណើរនៅក្នុងជំនឿ ដោយហេតុថាយើងមិនដឹងថានឹងត្រូវធ្វើកិច្ចការនោះដោយរបៀបណាទេ ក៏ប៉ុន្តែយើងបានស៊ូទ្រាំធ្វើវា។ ក្រុមហ៊ុនដែលបានបង្កើតឡើងនោះបានរីកចម្រើន ហើយលុយដែលរកបាន បាននាំក្រុមគ្រួសារយើងចេញពីបំណុលក្នុងរយៈពេលពីរឆ្នាំកន្លះ។ ខ្ញុំនឹងនិយាយប្រាប់បន្ថែមទៀតអំពីក្រុមហ៊ុនរបស់យើង នៅក្នុងជំពូកបន្ទាប់ តែពេលនេះអ្វីដែលអ្នកអាចដឹងបាននោះគឺថាជីវិតយើងបានផ្លាស់ប្តូរយ៉ាងខ្លាំង! គ្មានវិធីអ្វីដែលយើងអាចពន្យល់បានពីអារម្មណ៍របស់យើងចំពោះការមានសេរីភាព អំពីអារម្មណ៍ដែលយើងបានដើរទៅកន្លែងលក់រថយន្ត និងបានទិញឡានថ្មីមួយមកដោយសាច់លុយនោះទេ។ យើងមិនអាចពន្យល់ពីអារម្មណ៍នៅពេលដែលធ្វើការរចនា សាងសង់ និងបង់លុយសម្រាប់ផ្ទះថ្មីរបស់យើងនោះទេ។ អ្វីដែលធ្វើឱ្យយើងរីករាយខ្លាំងបំផុត គឺវាលើសពីអ្វីៗដែលយើងធ្លាប់បានស្រមៃដល់។

ពិតមែនហើយដែលផ្ទះចាស់នៅចម្ការរបស់យើងបានរក្សាទុកនូវអនុស្សាវរីយ៍ច្រើនគួរសម។ ក្នុងពេលដែលខ្ញុំបានដើរទៅរកហិបដាក់អីវ៉ាន់ចុងក្រោយចេញពីផ្ទះនោះមក ខ្ញុំបានដើរកាត់តិរិយារបស់ខ្ញុំ ពេលដែលគាត់កំពុងឈរនៅក្នុងបន្ទប់ទទួលទានអាហារដ៏តូចនៅក្នុងផ្ទះ។ គាត់បានសម្លឹងមើលខ្ញុំទាំងទឹកភ្នែក។ ទឹកភ្នែកនោះមិនមែនជាទឹកភ្នែកទុក្ខ

**ក្នុងពេលដែលយើងបានស្វែងរកព្រះជាម្ចាស់ ដើម្បីទទួលបាន ចម្លើយ និងគោលការណ៍ផ្សេង។ ក្តីសង្ឃឹមក៏បានចាប់ផ្តើមរះឡើងនៅក្នុងដួងចិត្តយើង ក្នុងពេលដែលយើងបានឃើញការអស្ចារ្យកើតឡើងមួយហើយមួយទៀត ពេលយើងអនុវត្តនូវអ្វីដែលព្រះជាម្ចាស់បានបង្ហាញដល់យើង។**

សោកទេ គឺជាទឹកភ្នែកនៃអំណរ ហើយក៏ជាទឹកភ្នែកដែលចេញពីអារម្មណ៍ ដែលគាត់បានចងចាំពីអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានបង្រៀនយើងនៅទីនេះ។ ខ្ញុំក៏បានទប់ទឹកភ្នែកដែរ ក្នុងពេលដែលខ្ញុំសម្លឹងមើលទៅក្នុងបន្ទប់នោះជាលើកចុងក្រោយ ហើយចងចាំអារម្មណ៍លាយគ្នាពីអ្វីគ្រប់យ៉ាងដែលបានកើតឡើងនៅទីនោះ។ កាលនោះយើងបានជ្រើសរើសទំព័រមួយនៅក្នុងជីវិតរបស់យើង និងបានធ្វើដំណើរចូលទៅក្នុងទឹកដីថ្មី។ តើមានអ្វីដែលនៅស្ថិតនៅខាងមុខយើងក្នុងពេលនេះ? ដំណើរមួយនេះបាននាំយើងចេញពី ភាពតានតឹងចិត្ត ដែលគ្មានក្តីសង្ឃឹម ទៅកាន់អនាគតដែលពេញដោយសេចក្តីសង្ឃឹម។ ពេលខ្ញុំដើរចេញក្រៅដោយមានកាន់ហិបដាក់ចុងក្រោយផងនោះ ខ្ញុំបានឈប់បន្តិច និងបានងាកក្រោយមើលទៅផ្ទះចាស់នោះជាមួយនឹងស្នាមញញឹម។

«ទេ ខ្ញុំនឹងមិននឹកនាដល់ឯងទេ។ ខ្ញុំមានផ្ទះថ្មីដែលប្រសើរជាងនេះហើយ។»

**អ្វីដែលឲ្រិនដា និងខ្ញុំបានរកឃើញគឺជាអ្វីដ៏ច្រើនដែលអ្នកអាចរកបាន ដូចជាយើងអាច រកបានមកនេះដែរ។**

ពិតប្រាកដណាស់ថា វាជាអ្វីដែលគួរឱ្យរំភើបយ៉ាងខ្លាំងក្នុងការរើទៅនៅផ្ទះថ្មីរបស់យើង។ ក៏ប៉ុន្តែអ្វីដែលល្អបំផុតនៅក្នុងដំណើរផ្សងព្រេងរបស់យើងនោះគឺថានៅទីបំផុតយើងពិតជាបានសម្រាក។ ខ្ញុំអាចគិតពីអនាគតរបស់ខ្ញុំ ហើយមិនត្រឹមតែគិតតែអំពីការបង់លុយវិក្កយបត្រចំណាយផ្សេងៗនោះទេ។ អស់រយៈពេលជាច្រើនឆ្នាំនៃការរស់នៅក្នុងការសម្រាករបស់ទ្រង់ គឺជាក្តីស្រមៃដ៏ពិតប្រាកដមួយ! ការដែលមានលុយសម្រាប់ចំណាយទិញឡានគឺជាការសម្រាក។ ការដែលមិនជាប់បំណុលគឺជាការសម្រាក។ ការមានលុយសម្រាប់ចំណាយលើផ្ទះក្នុងក្តីស្រមៃរបស់យើងលើដីទំហំជាង ២២ហិចតា គឺជាការសម្រាក។ ការមើលឃើញស្នាមញញឹមនៅលើថ្ពាល់របស់ភរិយាខ្ញុំពេលដែលគាត់ចេញទៅក្រៅដើរផ្សារ និងមិនចាំបាច់ត្រូវព្រួយបារម្ភគឺជាការសម្រាក។ ក្រៅ

ពីការមានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ មានលុយគ្រប់គ្រាន់ដើម្បីអាចផ្ដល់លុយរាប់សែនដុល្លារទៅកាន់អ្នកដទៃ និងឧបត្ថម្ភដល់ការផ្សាយដំណឹងល្អគឺជាការសម្រាក។ ក៏ប៉ុន្តែប្រហែលជាការផ្លាស់ប្រែដ៏ធំជាងគេបំផុត ក្នុងជីវិតរបស់ខ្ញុំនោះ គឺ ការមិនធ្វើដំណើរជារៀងរាល់ថ្ងៃ ទៅរកភាពតានតឹងចិត្ត និងភាពភ័យខ្លាចដែលនៅហ៊ុំព័ទ្ធជីវិតរបស់យើង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងនោះទេ។ ការដែលអាចមានការស្រមៃម្ដងទៀត អំពីអ្វីៗដែលល្អៗជំនួសឱ្យការដែលគ្រាន់តែស្រមៃពីការធ្វើយ៉ាងណាឱ្យតែបានរស់មួយសប្ដាហ៍បន្ថែមទៀតគឺជាការសម្រាក។

ពិតមែនហើយ នៅថ្ងៃដែលខ្ញុំបានរៀបចំអីវ៉ាន់ចុងក្រោយដាក់ហិប ដាក់ចូលទៅក្នុងឡានដឹកទំនិញដើម្បីដឹកទៅផ្ទះថ្មីរបស់យើង គឺជាថ្ងៃដ៏ជូរចត់។ ក៏ប៉ុន្តែសូមជឿខ្ញុំចុះ ភាពផ្អែមល្ហែមនៃការសម្រាកដែល ឌ្រិនដា និងខ្ញុំបានរកឃើញ គឺពិតជាមានអំណាចជាងភាពល្វីងជូរចត់នៃការបោះបង់ចោលការចងចាំទាំងនោះ ដែលយើងធ្លាប់មានអារម្មណ៍ដូចជាក្មេងវិទ្យាល័យពីរនាក់ជាថ្មីម្ដងទៀត ដោយមានសំណើច និងក្ដីស្រមៃជាថ្មីម្ដងទៀតរួមគ្នា។

ខ្ញុំដឹងពីអ្វីដែលអ្នកកំពុងតែគិត។ ខ្ញុំចង់មានអ្វីៗដូចនេះដែរ។ ខ្ញុំចង់ឱ្យខ្លួនឯងមានបទពិសោធ សំណើចសប្បាយ និងអាចផ្ដោតអារម្មណ៍លើអ្វីផ្សេងបានដែរ ក្រៅពីគ្រាន់តែផ្ដោតលើការបង់វិក្កយបត្រចំណាយផ្សេងៗ។ ទោះបីជាអ្នកអាចនឹងពិបាកក្នុងការជឿ ត្រង់ចំណុចនេះនៅក្នុងសៀវភៅ ខ្ញុំសូមអះអាងចំពោះអ្នកថាអ្វីដែល ឌ្រិនដា និងខ្ញុំបានរកឃើញគឺជាអ្វីដ៏ច្រើនដែលអ្នកអាចរកបាន ដូចជាយើងអាចរកបានមកនេះដែរ។ ខ្ញុំអធិស្ឋានសូមឱ្យរឿងដែលយើងបានចែកចាយ អ្នកនឹងទទួលបានការលើកទឹកចិត្តដើម្បីនឹងអនុវត្តច្បាប់ និងគោលការណ៍របស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នកផ្ទាល់ផងដែរ។

វាពិតជាមិនពិបាកខ្លាំងពេកទេ និយាយដោយសាមញ្ញទៅអ្នកត្រូវការរកឱ្យឃើញនូវអំណាចនៃការសម្រាក!

> *អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសម្រាក។ ចូរយកនឹម របស់ខ្ញុំដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ អ្នករាល់គ្នាមុខជាបានស្ងប់ចិត្តមិនខាន ដ្បិតខ្ញុំស្លូត និងមានចិត្តសុភាព។ នឹមរបស់ខ្ញុំស្រួល ហើយបន្ទុកដែលខ្ញុំដាក់លើអ្នករាល់គ្នាក៏ស្រាលដែរ។*

ម៉ាថាយ ១១៖២៨-៣០

# ជំពូក ១

# មូលដ្ឋានគ្រឹះនៃការសម្រាក

**ការសម្រាក** - គឺជាការដែលត្រូវបានដាក់ ឬគាំទ្រឱ្យស្ថិតនៅក្នុងទីតាំងដែលបានកំណត់ជាក់លាក់មួយ ជាស្ថានភាព ឬពេលវេលាសម្រាកមួយ ឬការឈប់ចូលរួមនៅក្នុងសកម្មភាពដ៏លំបាក ឬពេញដោយការតានតឹងចិត្តផ្សេងៗ។ (ដកស្រង់ពី Google)

តើអ្នកហត់នឿយមែនទេ? តើអ្នកមានអារម្មណ៍ថាទទួលច្រើនលើសលប់ស្ទើរតែរាល់ថ្ងៃ និងមិនដែលអាចទៅមុខទាន់គេសោះមែនទេ? តើតម្រូវការផ្នែកថវិការបស់អ្នកកំពុងតែជំរុញដល់ការសម្រេចចិត្តរបស់អ្នកនៅលើកន្លែងដែលអ្នកធ្វើការ ឬរបៀបធ្វើការ ឬរយៈពេលដែលអ្នកធ្វើការមែនទេ? តើវាមើលទៅហាក់ដូចជាអ្នកកំពុងតែរស់នៅក្នុងជីវិតនៃការប្រណាំងប្រជែងដែលមិនចេះចប់មិនចេះហើយមែនទេ? ប្រសិនបើនេះជាស្ថានភាពរបស់អ្នក នោះមានន័យថាមិនមែនមានតែអ្នកទេ ដែលជួបរឿងនេះ។

តើអ្នកធ្លាប់បានឃើញកង់រង្វង់របស់សត្វកណ្ដុរបាវាំង (Hamster) ដែរឬទេ? ខ្ញុំដឹងច្បាស់ថាអ្នកធ្លាប់បានឃើញ ក៏ប៉ុន្តែក្នុងករណីដែលអ្នកមិនដែលឃើញវាទេ វាជាកង់រង្វង់ដែលគេយកទៅដាក់នៅក្នុងទ្រុងរបស់សត្វកណ្ដុរបាវាំង។ សត្វកណ្ដុរអាចឡើងទៅលើរង្វង់នោះបាន និងរត់ហើយរត់ទៀត រហូតដល់វាអស់កម្លាំង។ ក៏ប៉ុន្តែវាមានបញ្ហាមួយនៅក្នុងរង្វង់នោះ។ មិនថាសត្វកណ្ដុរនោះរត់លឿន ឬរត់យូរប៉ុណ្ណានោះទេ ពេលដែលវានៅសុខសប្បាយធម្មតា ហើយអស់កម្លាំង និងចុះពីរង្វង់នោះ វាក៏ស្ថិតនៅកន្លែងដដែល ជាកន្លែងដែលបានចាប់ផ្ដើមរត់នោះឯង។ គ្មានអ្វីផ្លាស់ប្ដូរឡើយ។ វាអាចជូតញើសដែលហូរនៅលើមុខដ៏តូចរបស់វាបាន ដោយមានអារម្មណ៍ថាពេញចិត្ត។ ក៏ប៉ុន្តែគ្មានអ្វីដែលសម្រេចបានជាលទ្ធផល ជាប្រយោជន៍ដល់ស្ថានភាពនៅក្នុងជីវិតរបស់វាសោះ វានៅតែជាប់នៅក្នុងទ្រុងហើយគ្មានសេរីភាពដដែល។ ទោះបីជារឿងនេះមិនមែនជាឧទាហរណ៍របស់មនុស្សភាគច្រើន តែវាអាចលើកយកមកប្រើជាឧទាហរណ៍ទាក់ទងនឹងហិរញ្ញវត្ថុក្នុងជីវិតរបស់មនុស្ស

មួយចំនួនធំបានដែរ។ មនុស្សទាំងនោះខិតខំប្រឹងប្រែងធ្វើការអស់រយៈពេលពេញមួយសប្ដាហ៍ ហើយធ្លាក់ខ្លួនអស់កម្លាំងល្វិតល្វៃនៅថ្ងៃសម្រាកចុងសប្ដាហ៍របស់គេ ក៏ប៉ុន្តែនៅពេលថ្ងៃច័ន្ទវិលត្រលប់មកវិញ ពួកគេឃើញថាខ្លួនគេស្ថិតនៅក្នុងទីតាំងដដែល ដែលពួកគេបាននៅកាលពីសប្ដាហ៍មុន។ អ្វីៗដែលពួកគេសម្រេចបាននោះគឺការនៅរស់រួចបានមួយសប្ដាហ៍ទៀត។

រឿងនេះធ្លាប់ជារូបភាពដែលបង្ហាញពីជីវិតរបស់ខ្ញុំអស់រយៈពេល ៩ឆ្នាំដ៏លំបាកលំបិន។ ខ្ញុំបានចំណាយពេលពី ១៥ ទៅ ១៨ម៉ោងក្នុងមួយថ្ងៃ ខ្ញុំឧស្សាហ៍ព្យាយាម ហើយបានខិតខំប្រឹងប្រែងធ្វើការ ក៏ប៉ុន្តែបន្ទាប់ពីខ្ញុំបានថ្វាយតង្វាយមួយភាគដប់ ចំណាយលើថ្លៃវិក្កយបត្រផ្សេងៗ ក៏ដូចជាបង់ពន្ធរួចហើយនោះ ខ្ញុំគ្មាននៅសល់អ្វីទៀតឡើយ។ ជាធម្មតាអ្វីដែលខ្ញុំត្រូវការគឺនៅសេសសល់តិចតួចណាស់ ហើយមិនយូរប៉ុន្មានខ្ញុំចាប់ផ្តើមធ្លាក់ខ្លួនមានទម្លាប់ខ្ចីពីអ្នកដទៃដើម្បីបន្តរស់នៅ។ ពេលដែលមានសម្ពាធផ្នែកហិរញ្ញវត្ថុកើនឡើង ខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើការកាន់តែខ្លាំង ក៏ប៉ុន្តែវាហាក់ដូចជាគ្មានទទួលបានផលប្រយោជន៍អ្វីពីការខំប្រឹងនោះសោះ។ ពេលខ្ញុំឈប់បន្តិច និងធ្វើការវាយតម្លៃលើដំណើរការងាររបស់ខ្ញុំ ខ្ញុំហាក់ដូចជានៅតែធ្វើដំណើរត្រលប់ទៅក្រោយជានិច្ច។

ជាការពិតណាស់ អ្វីដែលខ្ញុំធ្វើនេះបានដឹកនាំខ្ញុំទៅរកផលវិបាកផ្នែកអារម្មណ៍ដ៏ធ្ងន់ធ្ងរជាច្រើន។ ការធ្លាក់ទឹកចិត្ត និងភាពភ័យខ្លាចដែលខ្ញុំបានតតាំងជារៀងរាល់ថ្ងៃបានប៉ះពាល់ដល់ចិត្តគំនិត និងរូបកាយរបស់ខ្ញុំបន្តិចម្តងៗ។ ទាំងការស្លន់ស្លោ ភាពភ័យខ្លាចដ៏តឹងតែង និងភាពស្ពឹកស្រពន់ ចាប់ផ្តើមលេបត្របាក់រូបកាយរបស់ខ្ញុំបន្តិចម្តងៗ។ ភាពភ័យខ្លាចក៏បានបំផ្លាញការគិតរបស់ខ្ញុំ ដែលធ្វើឱ្យខ្ញុំមិនដឹងទេថាតើខ្ញុំនឹងអាចនៅរស់បន្ត ឬក៏នឹងស្លាប់នោះទេ។ ការរស់នៅដោយសារតែពឹងលើការបញ្ចាំរបស់ និងការខ្ចីលុយពីសាច់ញាតិយើង បាននៅបន្តរហូតដល់ទៅរយៈពេលជិត ៩ឆ្នាំ! ក្នុងពេលមួយនោះយើងគ្មានអ្វីនៅសេសសល់ដើម្បីនឹងយកទៅបញ្ចាំទៀតទេ ហើយការគោរពចំពោះខ្លួនឯងរបស់ខ្ញុំក៏នៅសល់កាន់តែតិចទៅៗ។ កាលនោះខ្ញុំហាក់មានអារម្មណ៍ថាខ្ញុំអស់កម្លាំងហើយ។ អ្នកសឹងតែអាចប្រមូលយកការគោរពចំពោះខ្លួនឯងរបស់ខ្ញុំ ដោយប្រើឧបករណ៍ចូកធូលីដីមួយបានដោយចូកវាទៅជាមួយនឹងអំណរដែលខ្ញុំមាននៅសល់ក្នុងជីវិតក្នុងពេលនោះបាន។

ម្ចាស់បំណុលជាច្រើនបានតម្រង់ជួរដើម្បីដាក់ពាក្យប្តឹងខ្ញុំ ហើយពេលនោះហើយជាពេលដែលរឿងនេះបានកើតឡើង។ ជាមួយនឹងក្តីអស់សង្ឃឹមដែលឱបក្រសោបជាប់គ្រប់

ដង្ហើមចេញចូលរបស់ខ្ញុំក្នុងពេលនោះ មានទូរស័ព្ទមួយខ្សែបានខលចូលមក។ ទូរស័ព្ទដែលខលចូលនោះមិនខុសអ្វីពីការខលចូលភាគច្រើននៅពេលព្រឹកឡើយដោយមានសំឡេងបែបនេះថា «លោកឃីស៊ី ដូចដែលលោកបានដឹងស្រាប់ហើយថាលោកបានជំពាក់លុយអតិថិជនខ្ញុំចំនួនប៉ុននេះ (ចំនួនដែលជំពាក់)។ តើពេលណាដែលលោកគិតថាលោកអាចសងលុយនោះដល់យើងបាន? និយាយអីចឹង លោកឃីស៊ី លោកបាននិយាយដូច្នេះរួចហើយក្នុងពេលដែលខ្ញុំខលទៅលោកបីដងចុងក្រោយនេះ។ ប្រសិនបើលោកគ្មានលុយសងយើងក្នុងរយៈពេលបីថ្ងៃនេះទេ អថិជនយើងនឹងដាក់ពាក្យប្តឹងលោកហើយ។ តើលោកយល់ទេ លោកឃីស៊ី? មានពេលតែបីថ្ងៃប៉ុណ្ណោះ។ ជម្រាបលា»។

ទូរស័ព្ទដែលខលចូលនោះប្រៀបដូចជាដុំឥដ្ឋមួយគោនគប់មកខ្ញុំ។ មិនមែនថាខ្ញុំមិនបានដឹងពីស្ថានភាពដ៏យ៉ាប់យឺនផ្នែកហិរញ្ញវត្ថុរបស់យើងនោះទេ។ កាលនោះខ្ញុំគ្មានលុយទាល់តែសោះ។ អ្វីគ្រប់យ៉ាងដែលខ្ញុំមានសុទ្ធតែជារបស់ដែលបានខូចបាក់បែក។ នៅក្នុងទូរទឹកកករបស់ខ្ញុំកាលនោះគឺទទេស្អាត។ ក្រុមគ្រួសារដ៏ស្រស់ស្អាតរបស់ខ្ញុំត្រូវគេងនៅខាងមុខចង្រ្កានកម្តៅក្នុងផ្ទះ ដើម្បីឱ្យបានកក់ក្តៅ ដោយសារតែយើងគ្មានលុយទិញប្រេងចាក់មាស៊ីនកម្តៅឡើយ។ គ្មានកន្លែងណាមួយដែលខ្ញុំអាចសុំជំនួយបានទេ។ ទាំងមិត្តភក្តិនិងក្រុមគ្រួសាររបស់ខ្ញុំធុញទ្រាន់ក្នុងការបង់លុយជំនួសយើងទៅហើយ។ ដោយមានអារម្មណ៍ច្របូកច្របល់ ខ្ញុំបានដើរយឺតៗឡើងទៅជាន់លើទៅបន្ទប់គេងរបស់ខ្ញុំ និងបានទម្លាក់ខ្លួនដេកលើគ្រែ។ ខ្ញុំបានយំស្រែកអង្វរដល់ព្រះអម្ចាស់ឱ្យជួយដល់ខ្ញុំ។

ខ្ញុំគិតថា កាលនោះខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលព្រះអម្ចាស់បានឆ្លើយតបមកខ្ញុំយ៉ាងឆាប់រហ័ស។ វាមិនមែនជាសំឡេងដែលអាចស្តាប់ឮបានផ្ទាល់នឹងត្រចៀកឡើយ ក៏ប៉ុន្តែជាសំឡេងដែលស្រាប់តែចេញពីវិញ្ញាណរបស់ខ្ញុំ ហើយចូលទៅក្នុងគំនិតរបស់ខ្ញុំខ្លាំងៗ។ រឿងដំបូងដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំនោះគឺថា រឿងរ៉ាវរញ៉េរញ៉ៃដែលខ្ញុំជួបប្រទះនេះគ្មានអ្វីពាក់ព័ន្ធនឹងទ្រង់ទេ។ ខ្ញុំគិតថាទ្រង់មានបន្ទូលមកដូច្នេះដោយសារតែខ្ញុំបានច្របូកច្របល់បន្តិចមែន ហើយចេញពីទស្សនៈរបស់ខ្ញុំ តើថាហេតុអ្វីបានជាទ្រង់មិនជួយដល់យើងសោះដូច្នេះ។ យើងបានទៅចូលរួមក្នុងក្រុមជំនុំដ៏ធំមួយ យើងមានចិត្តសប្បុរសពេលដែលយើងអាចផ្តល់ជំនួយ ហើយយើងបានថ្វាយតង្វាយមួយភាគដប់ស្ទើរតែគ្រប់ពេល។ ផ្ទុយទៅវិញ ទ្រង់មានបន្ទូលថាមូលហេតុដែលខ្ញុំស្ថិតនៅក្នុងស្ថានភាពរញ៉េរញ៉ៃដូច្នេះគឺដោយសារតែខ្ញុំមិនបានដឹងពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។ ទ្រង់មានបន្ទូល

មកខ្ញុំថាព្រះរាជ្យទ្រង់មិនដំណើរការ ដូចជាដំណើរការរបស់លោកីយ៍នេះទេពាក់ព័ន្ធរឿងរ៉ាវអំពីលុយកាក់នេះ ហើយទ្រង់មានបន្ទូលថាខ្ញុំនឹងត្រូវការរៀនសូត្រពីប្រព័ន្ធរបស់ព្រះរាជ្យរបស់ទ្រង់ ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ ប្រសិនបើខ្ញុំចង់មានសេរីភាព។

ខ្ញុំនៅចាំបានថាខ្ញុំបានរត់ចុះទៅក្រោម និងបានចាប់ដៃឌ្រិនដា ហើយប្រាប់នាងថាព្រះអម្ចាស់ទើបតែមានបន្ទូលមកខ្ញុំ និងប្រាប់ខ្ញុំថាអ្វីដែលជាចម្លើយនោះគឺព្រះរាជ្យរបស់ទ្រង់។ ជាការពិតណាស់ពេលនោះយើងហាក់ដូចជាច្របូកច្របល់បន្តិច ដោយសារតែយើងបានគិតថាយើងបានស្គាល់ព្រះរាជ្យរបស់ទ្រង់រួចទៅហើយ។ ក្រៅពីនោះគឺដូចអ្វីដែលខ្ញុំបាននិយាយរួចមកហើយថា យើងបានចូលរួមនៅក្នុងក្រុមជំនុំដ៏ធំមួយ យើងទាំងពីរនាក់ស្រលាញ់ព្រះជាម្ចាស់ ហើយយើងក៏ដឹងថាយើងទាំងពីរនឹងធ្វើដំណើរទៅស្ថានសួគ៌។ ក៏ប៉ុន្តែពេលនោះទើបយើងរកឃើញថា យើងពិតជាបានដឹងតិចតួចណាស់ពីព្រះរាជ្យរបស់ទ្រង់ និងរបៀបដែលព្រះរាជ្យមានដំណើរការ។

កាលនោះខ្ញុំពិតជារំភើបចិត្តណាស់ដែលព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំ ហើយទ្រង់បានបង្ហាញពីចម្លើយអំពីព្រះរាជ្យរបស់ទ្រង់ផងដែរ។ ថ្វីត្បិតថាខ្ញុំមិនទាន់បានយល់ច្បាស់ពីអត្ថន័យ ក៏ប៉ុន្តែខ្ញុំទទួលបានការលើកទឹកចិត្ត។ អ្វីដែលជាការពិតនោះគឺថាខ្ញុំមិនដឹងអ្វីសោះពីអត្ថន័យនៃព្រះបន្ទូលទ្រង់ចំពោះពាក្យថា *ព្រះរាជ្យ* ។ ពីពេលនោះខ្ញុំនឹងរកឃើញថា នៅក្នុងពាក្យមួយនោះមានចម្លើយពិតប្រាកដដែលឌ្រិនដា និងខ្ញុំបានរង់ចាំ និងបានស្វែងរក។

ថ្ងៃនោះឌ្រិនដា និងខ្ញុំបានចាប់ដៃគ្នាអធិស្ឋាន។ ជាដំបូងយើងបានសុំការអភ័យទោសចំពោះព្រះជាម្ចាស់ សម្រាប់ការដែលយើងមិនចំណាយពេលរៀនពីព្រះបន្ទូលទ្រង់ និងរបៀបដែលព្រះរាជ្យរបស់ទ្រង់មានដំណើរការទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ។ ទីពីរ ខ្ញុំបានសុំការអភ័យទោសចំពោះគាត់ ក្នុងនាមជាមេគ្រួសារ សម្រាប់ការដែលនាំយើងទាំងអស់គ្នាចូលមកក្នុងស្ថានភាពរញ៉េរញ៉ៃដូចនេះ។ យើងទាំងពីរបានអធិស្ឋាន និងបានយល់ស្របគ្នាថាយើងនឹងប្ដេជ្ញាចិត្តក្នុងរៀនពីរបៀបដែលព្រះរាជ្យមានដំណើរការ និងរបៀបរស់នៅក្នុងជីវិតដែលមានភាពខុសប្លែកពីជីវិតដែលយើងធ្លាប់រស់នៅអស់រយៈពេល ៩ឆ្នាំកន្លងមកនេះ។

វិធីដ៏ល្អបំផុតក្នុងការបរិយាយពីអ្វីដែលបានកើតឡើងបន្ទាប់មកទៀតនោះគឺការមើលទៅកុងតាក់បើកបិទភ្លើង។ សូមដើរចូលទៅក្នុងបន្ទប់មួយដែលងងឹត ហើយគ្រាន់តែ

ចុចកុងតាក់បើកបិទភ្លើងតាមធម្មតា។ ពន្លឺ! ជាអ្វីដែលអ្នកអាចមើលឃើញ។ វាមានសភាព បែបនោះឯង ពេលដែលព្រះជាម្ចាស់បានចាប់ផ្ដើមបង្រៀនយើងពីព្រះរាជ្យរបស់ទ្រង់។ វា ប្រៀបដូចជាមាននរណាម្នាក់ចុចកុងតាក់បើកភ្លើង ហើយយើងអាចមើលឃើញអ្វីៗដែល យើងមិនធ្លាប់បានឃើញពីមុនមកសោះ។ យើងបានចាប់ផ្ដើមយល់ថា ព្រះរាជ្យរបស់ព្រះជា ម្ចាស់ប្រៀបដូចជារដ្ឋាភិបាលមួយដែលមានច្បាប់ មិនប្រែប្រួលមួយ។ យើងបានដឹងថា យើងអាចរៀនពីច្បាប់ទាំងនោះ និងអាចទាញយកផលប្រយោជន៍ពីអំណាច និងព្រះប្រាជ្ញា ញាណរបស់ព្រះជាម្ចាស់បាន ដើម្បីបង្កើតជាទ្រព្យសម្បត្តិដែលយើងត្រូវ ការ។

យើងពិតជាមានក្ដីរំភើបណាស់ ក៏ប៉ុន្តែយើងក៏នៅតែមានការច្របូកច្របល់ខ្លាំង ណាស់ដែរ។ មានរឿងដ៏អស្ចារ្យមួយចំនួន ដែលបានកើតឡើងក្នុងពេលដែលព្រះជាម្ចាស់ ចាប់ផ្ដើមបង្រៀនយើងរបៀបដែលព្រះរាជ្យរបស់ទ្រង់មានដំណើរការ។ ខ្ញុំនឹងមិននិយាយ គ្របដណ្ដប់រឿងកើតឡើងដំបូងៗជាច្រើននៅទីនេះទេ ដោយសារតែរឿងទាំងនោះត្រូវបាន គ្របដណ្ដប់នៅក្នុងសៀវភៅទីមួយនៃសៀរីសៀវភៅនេះ ដែលមានចំណងជើងថា *បដិវត្តន៍ ផ្នែកហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃភក្ដីភាព។* អ្នកអាចទាញយកសៀវភៅនេះបានចេញពី គេហទំព័រ garyieesee.com ឬ Amazon.com បាន។ អ្នកក៏នឹងត្រូវការមើលសៀវភៅមួយ ក្បាលទៀតរបស់ខ្ញុំដែលមានចំណងជើងថា *Faith Hunt* ផងដែរដែលនឹងនាំអ្នកទៅកាន់ ការចាប់ផ្ដើមដំបូងបង្អស់ ដែលព្រះជាម្ចាស់បានចាប់ផ្ដើមបង្រៀនខ្ញុំពីរបៀបប្រមូលផលពី ការផ្គត់ផ្គង់ តាមរយៈការប្រមាញ់សត្វក្ដាន់របស់ខ្ញុំ។ ក៏ប៉ុន្តែដើម្បីសង្ខេបរឿងឱ្យខ្លីបន្តិច សូម អនុញ្ញាតឱ្យខ្ញុំលើកឧទាហរណ៍មួយនៅទីនេះចុះ។

ដូចដែលខ្ញុំបានរៀបរាប់ប្រាប់អ្នកថា យើងទាំងពីរនាក់រវល់ខ្លាំងណាស់ដោយសារ តែរឿងបំណុលដែលគ្មានច្រកចេញរបស់យើង។ យើងមានទាំងបំណុលជំពាក់បំណុលពន្ធ អាករ (IRS) ទាំងបំណុលហាងបញ្ចាំ កាតក្រេឌីតលើសកំណត់ និងបានលុបចោលទាំង ១០ ក៏ដូចជាលុយកម្ចីពីក្រុមហ៊ុនហិរញ្ញវត្ថុទាំងពីរ ដែលមានការប្រាក់យ៉ាងហោចណាស់ ២០% ដែរ។ យើងជំពាក់ទាំងពេទ្យធ្មេញ ថ្លៃបោកគក់សម្លៀកបំពាក់ ជំពាក់ទាំងឪពុកម្ដាយ និង មិត្តភក្ដិរបស់យើងផង។ យើងបានជំពាក់ពួកគេច្រើនណាស់។ ប្រសិនបើមើលទៅតាមធម្ម តា ហាក់ដូចជាគ្មានក្ដីសង្ឃឹមអ្វីសោះក្នុងពេលនោះ។ អាជីវកម្មផ្នែកលក់សេវាហិរញ្ញវត្ថុរបស់ ខ្ញុំដូចជាដំណើរការមិនសូវល្អសោះ ទោះបីជាខ្ញុំខំប្រឹងប្រែងធ្វើការយ៉ាងណាក្ដី។ ក៏ប៉ុន្តែតលូវ

នេះ បន្ទាប់ពីការមើលឃើញថាព្រះរាជ្យនៃព្រះបានធ្វើកិច្ចការដ៏អស្ចារ្យមួយចំនួនធំ (ជាថ្មីម្តងទៀត សូមអានរឿងនៅក្នុងសៀវភៅពីរក្បាលដែលខ្ញុំបានលើកឡើងមកនៅខាងលើ) យើងបានទទួលការលើកទឹកចិត្តថាព្រះរាជ្យគឺជាចម្លើយដែលយើងស្វែងរក។ យើងមិនបានដឹងពីមុនទេថាវាមានរបៀបយ៉ាងណា ក៏ប៉ុន្តែយើងមានទំនុកចិត្តថា យើងកំពុងដើរលើផ្លូវដ៏ត្រឹមត្រូវ។

បន្ទាប់មកមានយប់មួយព្រះជាម្ចាស់បានប្រទានសុបិនមួយមកខ្ញុំ និងបានបង្ហាញខ្ញុំនៅក្នុងសុបិននោះថា ខ្ញុំនឹងចាកចេញពីក្រុមហ៊ុនដែលខ្ញុំកំពុងតែធ្វើការក្នុងពេលនេះ ដែលខ្ញុំបានធ្វើការអស់រយៈពេល ៩ឆ្នាំចុងក្រោយនេះ ហើយនឹងចាប់ផ្តើមក្រុមហ៊ុនផ្ទាល់ខ្លួនមួយ ទ្រង់បង្ហាញឱ្យខ្ញុំធ្វើបែបនេះ ដើម្បីជួយដល់មនុស្សជាច្រើនឱ្យចេញពីការជាប់បំណុល! ខ្ញុំដឹងថា វាស្តាប់ទៅដូចជារាងឆ្កួតឡប់បន្តិច មែនទេ? ខ្ញុំចង់មានន័យថា បើខ្ញុំដឹងពីវិធីចេញពីការជាប់បំណុលនោះ ខ្ញុំមុខជានឹងប្រើវិធីនោះតាំងពីប៉ុន្មានឆ្នាំមុននេះឯណោះ។ ក៏ប៉ុន្តែទ្រង់ពិតជាមានព្រះបន្ទូលបែបនេះពិតមែន។ ជាការពិតណាស់ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខ្ញុំមិនចេះបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួនទេ ហើយក៏មិនដឹងថាកិច្ចការនេះមានពាក់ព័ន្ធនឹងអ្វីខ្លះដែរ។ ក៏ប៉ុន្តែក្រុមហ៊ុនដែលខ្ញុំត្រូវបង្កើតនោះគឺដើម្បីជួយដល់មនុស្សឱ្យរួចផុតពីការជាប់បំណុលមែនឬ? ព្រះអើយ ខ្ញុំត្រូវការនរណាម្នាក់ដែលអាចប្រាប់ខ្ញុំពីរបៀបធ្វើវា!

ពេលខ្ញុំចាប់ផ្តើមអធិស្ឋានអំពីរឿងនេះ ខ្ញុំទទួលបានបទពិសោធផ្លាស់ប្តូរជីវិតមួយជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធពាក់ព័ន្ធនឹងរបៀបដែលអាចធ្វើឱ្យរឿងនេះកើតឡើងបាន។ រឿងនេះបានចាប់ផ្តើមកើតឡើងនៅពេលអតិថិជនម្នាក់បានទូរស័ព្ទមកខ្ញុំ ដើម្បីនិយាយពីអាជីវកម្មធានារ៉ាប់រងរបស់ខ្ញុំ។ អូហ៍មែនហើយ ខ្ញុំភ្លេចប្រាប់អ្នកថាខ្ញុំធ្វើការនៅក្នុងអាជីវកម្មសេវាហិរញ្ញវត្ថុលក់ធានារ៉ាប់រង និងលុយធានាផងដែរក្នុងពេលដែលរឿងនេះបានកើតឡើង។ ខ្ញុំដឹងថា រឿងនេះប្រៀបដូចជារឿងរបស់ជាងជួសជុលទុយោទឹក ដែលមានក្បាលរ៉ូប៊ីណេស្រក់ទឹកម្នាក់ ដែលធ្វើការជួសជុលបញ្ហាទុយោទឹកឱ្យមនុស្សគ្រប់គ្នា ក៏ប៉ុន្តែមានការធ្វេសប្រហែសមិនបានជួសជុលបញ្ហាដែលខ្លួនកំពុងតែមាន។ ទោះបីជាពេលនោះខ្ញុំកំពុងតែបរាជ័យបន្តិចម្តងៗ ក្នុងតំណែងជាបុគ្គលិកផ្នែកសេវាហិរញ្ញវត្ថុ និងបទពិសោធដែលខ្ញុំទទួលបានជាទូទៅនៅក្នុងវិស័យនោះក្នុងរយៈពេលជាង ៩ឆ្នាំកន្លងមក បានក្លាយជាអ្វីដែលមានសារៈសំខាន់ក្នុងពេលឥលូវនេះ ចំពោះអ្វីដែលព្រះជាម្ចាស់នឹងបង្ហាញឱ្យខ្ញុំបានឃើញនៅពេលនោះ។

ពេលខ្ញុំកំពុងអង្គុយជាមួយនឹងអតិថិជនរបស់ខ្ញុំ និងភរិយារបស់គាត់នៅឯតុក្នុងផ្ទះបាយរបស់គាត់ យើងបាននិយាយគ្នាដោយប្រើបទបង្ហាញទូទៅ ដែលបានបង្ហាញពីរូបភាពមួយអំពីទីតាំងផ្នែកហិរញ្ញវត្ថុដែលពួកគេកំពុងស្ថិតនៅ តាមរយៈការសួរសំណួរផ្សេងៗជាច្រើន និងការបំពេញសន្លឹកកិច្ចការដែលយើងឱ្យឈ្មោះថាជាសន្លឹកបំពេញទិន្នន័យ។ ទិន្នន័យដែលទទួលបាននេះត្រូវបានយកមកប្រើប្រាស់ដើម្បីកំណត់ពីទំហំនៃការធានារ៉ាប់រងអាយុជីវិតដែលពួកគេគួរតែមាន។ ក្នុងពេលដែលយើងពិនិត្យមើលបញ្ជីបំណុលរបស់ពួកគេ ពួកគេទាំងពីរចាប់ផ្តើមមិនសប្បាយចិត្ត ហើយភរិយាគាត់ក៏ចាប់ផ្តើមយំឡើងក្នុងពេលដែលពួកគេរៀបរាប់ពីអារម្មណ៍អស់សង្ឃឹមដែលពួកគេមាន។ ពួកគេទាំងពីរនាក់ធ្វើការងារពេញម៉ោង ហើយជារៀងរាល់ខែពួកគេតែងតែមានការខ្វះខាត។

ឥលូវនេះ បន្ទាប់ពីរស់នៅក្នុងរបៀបបែបនោះអស់ពេល ៩ឆ្នាំមកនេះ ហើយជាមួយនឹងការដែលព្រះជាម្ចាស់ចាប់ផ្តើមបង្រៀនគ្រិនដា និងខ្ញុំអំពីព្រះរាជ្យ អ្នកអាចស្រមៃបានថាខ្ញុំមានអារម្មណ៍បែបណាចំពោះពួកគេ។ ដូចជាគ្រិនដា និងខ្ញុំដែរ ពួកគេគឺជាគ្រិស្តបរិស័ទ ក៏ប៉ុន្តែពួកគេគ្មានចំណេះដឹងពីរបៀបដែលព្រះរាជ្យនៃព្រះមានដំណើរការ។ ក្នុងពេលនោះខ្ញុំមិនអាចពន្យល់បានច្រើនទេទាក់ទងនឹងព្រះរាជ្យនៃព្រះ លើកលែងតែរឿងដំបូងៗដែលព្រះជាម្ចាស់បានបង្ហាញដល់យើងរួចហើយតែប៉ុណ្ណោះ ដែលខ្ញុំអាចចែករំលែកជាមួយពួកគេ ហើយជាការពិតណាស់ ខ្ញុំបានចែករំលែកនូវរឿងដ៏អស្ចារ្យមួយចំនួនដែលយើងបានឃើញថាវាកើតឡើងនៅក្នុងស្ថានភាពរបស់យើង។

ជាការពិតណាស់ ខ្ញុំអាចប្រាប់បានថាការធានារ៉ាប់រងអាយុជីវិតមិនមែនជាបញ្ហាធំរបស់ពួកគេទេ។ ខ្ញុំបានចំណាយពេលខ្លះដើម្បីពន្យល់ពីអ្វីដែលព្រះជាម្ចាស់កំពុងតែបង្រៀនយើងក្នុងពេលនោះ ទាក់ទងនឹងព្រះរាជ្យនៃព្រះ ក៏ប៉ុន្តែខ្ញុំបានរង់ចាំអ្វីម្យ៉ាងដែលខ្ញុំអាចធ្វើបាន ដើម្បីផ្តល់នូវចម្លើយផ្នែកហិរញ្ញវត្ថុពិតប្រាកដ ដោយផ្អែកលើស្ថានភាពរបស់ពួកគេផងដែរ។

នៅឯការិយាល័យក្នុងយប់នោះ ពេលដែលខ្ញុំពិនិត្យមើលឡើងវិញពីកិច្ចការក្នុងថ្ងៃនេះ និងតម្រៀបគំនរឯកសារតាមលំដាប់ដូចធម្មតា ក៏ដូចជាពិនិត្យមើលសារជាច្រើនដែលត្រូវការឆ្លើយតប ខ្ញុំស្រាប់តែមានគំនិតមួយ។ ចុះប្រសិនបើខ្ញុំមើលរំលងបញ្ហានៃការធានារ៉ាប់រងអាយុជីវិត ហើយពិនិត្យមើលកាន់តែឃ្លាំចំពោះរូបភាពផ្នែកហិរញ្ញវត្ថុទាំងមូលរបស់ពួកគេវិញនោះ? តើមានអ្វីដែលខ្ញុំអាចធ្វើបានដែរឬទេ? ចុះប្រសិនបើខ្ញុំស្វែងរកលុយ

វិញនោះ? អ្វីដែលខ្ញុំចង់និយាយនោះគឺថា ចុះប្រសិនបើខ្ញុំអាចរកវិធីចំណាយតិចជាងនេះ ដើម្បីធ្វើអ្វីៗដែលពួកគេបានធ្វើរួចមកហើយវិញនោះ? គោលដៅរបស់ខ្ញុំគឺសាមញ្ញទេ គឺស្វែងរកវិធីផ្សេងៗដែលចំណាយតិចជាងនេះ ដើម្បីធ្វើអ្វីដែលពួកគេបានធ្វើរួចមកហើយ ហើយបន្ទាប់មកយកលុយចំនួនណាមួយមកអនុវត្តចំពោះអ្វីដែលខ្ញុំបានរកឃើញក្នុងលំហូរសាច់លុយ និងបំណុលរបស់ពួកគេ។ ស្តាប់ទៅវាដូចជាការធ្វើសំណើរសាមញ្ញមួយ ក៏ប៉ុន្តែខ្ញុំពិតជាមិនដឹងអ្វីច្រើនអំពីវិស័យហិរញ្ញវត្ថុផ្សេងក្រៅពីវិស័យធានារ៉ាប់រងអាយុជីវិតទេ។ ហើយខ្ញុំត្រូវតែប្រាប់អ្នកឱ្យបានដឹងថា រឿងនេះបានកើតឡើងមុនសម័យដែលមានអ៊ីនធឺណិត។ រាល់ការស្រាវជ្រាវដែលខ្ញុំត្រូវការធ្វើ គឺត្រូវធ្វើឡើងក្នុងរបៀបបុរាណហួសសម័យ និងតាមរយៈការហៅទូរស័ព្ទ និងសៀវភៅលឿងណែនាំពីអាជីវកម្ម។

ខ្ញុំធ្វើការស្រាវជ្រាវនេះអស់រយៈពេលពេញមួយសប្តាហ៍ ដោយសារតែខ្ញុំណាត់ជួបអតិថិជនដដែលនេះម្តងទៀតក្នុងសប្តាហ៍បន្ទាប់។ ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ជាមួយនឹងលុយដែលខ្ញុំអាចជួយសន្សំឱ្យពួកគេបានក្នុងមួយខែៗ ពេលខ្ញុំស្រាវជ្រាវលើហិរញ្ញវត្ថុគ្រប់ផ្នែកយ៉ាងយកចិត្តទុកដាក់។ ពេលដែលខ្ញុំបញ្ចប់ការស្រាវជ្រាវ ចំនួនទឹកលុយសរុបមានដល់ទៅរាប់ពាន់ដុល្លារក្នុងមួយខែ។ ផ្អែកលើការគណនាហិរញ្ញវត្ថុរបស់ខ្ញុំ ខ្ញុំបានសរុបចំនួនបំណុលទាំងអស់របស់ពួកគេ ហើយបន្ទាប់មកខ្ញុំបានប្រើប្រាស់លុយដែលខ្ញុំអាចជួយសន្សំឱ្យពួកគេបាន មកផ្សំជាមួយប្រាក់ខែប្រចាំខែរបស់ពួកគេ។ ពេលដែលខ្ញុំចុចកុំព្យូទ័រ ខ្ញុំបានសម្លឹងមើលទៅចម្លើយនៅលើអេក្រង់កុំព្យូទ័រ នោះគឺ ៦.២ ឆ្នាំ។ ចម្លើយនោះគឺរយៈពេល ៦.២ឆ្នាំ គឺរយៈពេលសរុបដែលអតិថិជនរបស់ខ្ញុំត្រូវចំណាយដើម្បីសងបំណុលអស់ រួមទាំងលុយកម្ចីទិញផ្ទះរបស់គាត់បាន ដោយមិនចាំបាច់មានការផ្លាស់ប្តូរលុយចំណូលរបស់គាត់ឡើយ។ ពិតណាស់ អ្វីដែលអ្នកបានអាននេះមិនខុសទេ ចម្លើយគឺដោយមិនចាំបាច់មានការផ្លាស់ប្តូរលុយចំណូលប្រចាំខែរបស់គាត់ទេ។ កាលនោះខ្ញុំភ្ញាក់ផ្អើលខ្លាំង និងគិតថាប្រហែលជាខ្ញុំច្រឡំទេ ដូច្នេះហើយទើបខ្ញុំគិតលេខម្តងហើយម្តងទៀត រហូតដល់ខ្ញុំជឿជាក់ថាខ្ញុំរកឃើញចម្លើយត្រឹមត្រូវហើយ។ តើរឿងនេះអាចទៅរួចទេ? ហេតុអ្វីបានជាគ្មានអ្នកដឹងពីរឿងនេះ?

កាលនោះខ្ញុំឆ្ងល់ណាស់ថាតើអតិថិជនរបស់ខ្ញុំនឹងឆ្លើយតបយ៉ាងដូចម្តេចទៅចំពោះព័ត៌មានដែលពួកគេនឹងទទួលបាននេះ។ សម្រាប់ជំនួបដែលនឹងចូលមកដល់មួយនេះ ខ្ញុំបានសម្រេចចិត្តសរសេរចំនួនតួលេខចូលទៅក្នុងបទបង្ហាញសាមញ្ញមួយទំព័រ។

គោលបំណងរបស់ខ្ញុំគឺចង់ផ្ដល់ក្ដីសង្ឃឹមដ៏សាមញ្ញមួយដល់ពួកគេ។ ខ្ញុំមិនទទួលបានផលប្រយោជន៍អ្វីពីនេះឡើយ ដោយសារខ្ញុំក៏ដឹងដែរថាមើលទៅដូចជាមិនអាចលក់ការធានារ៉ាប់រងអាយុជីវិតបានទេ។ ក៏ប៉ុន្តែខ្ញុំក៏ដឹងដែរថា ពួកគេមុខជាចង់ឮពីអ្វីដែលខ្ញុំបានរកឃើញ។ នៅសប្ដាហ៍បន្ទាប់ ខ្ញុំបានពិនិត្យមើលការគណនារបស់ខ្ញុំជាថ្មីម្ដងទៀត ហើយខ្ញុំច្បាស់ក្នុងចិត្តថាវាត្រឹមត្រូវហើយ។

ពេលខ្ញុំចុចកណ្ដឹងទ្វារផ្ទះ ខ្ញុំមានអារម្មណ៍ភ័យផងអរផងចំពោះជំនួបរបស់យើង។ ពេលអង្គុយចុះនៅឯតុក្នុងផ្ទះបាយ ខ្ញុំបានប្រាប់ពួកគេពីអ្វីដែលខ្ញុំបានធ្វើពេញមួយសប្ដាហ៍ ជាមួយនឹងចំនួនលុយរបស់ពួកគេ។ ខ្ញុំបានពន្យល់ពួកគេបន្តិចម្ដងៗពីចំនួនតួលេខដែលខ្ញុំបានសរសេរ និងធ្វើការពន្យល់ពីវិធីដែលខ្ញុំបង្កើតឱ្យមានលុយដែលខ្ញុំអាចជួយសន្សំឱ្យពួកគេបាន រួមជាមួយនឹងឈ្មោះក្រុមហ៊ុនណាមួយ និងចំនួនដែលត្រូវការដើម្បីយកមកអនុវត្តវិធីដែលខ្ញុំបានបង្ហាញដល់ពួកគេ។ ខ្ញុំអាចមើលដឹងថាពួកគេចាប់ផ្ដើមរំភើបពេលឃើញលុយដែលខ្ញុំអាចជួយសន្សំឱ្យពួកគេបាន ចេះតែកើនឡើង។ ក៏ប៉ុន្តែពេលខ្ញុំធ្វើការសន្និដ្ឋានពីការដែលអាចរួចផុតពីបំណុលទាំងស្រុងក្នុងរយៈពេល ៦.២ឆ្នាំ រួមទាំងបំណុលទិញផ្ទះរបស់ពួកគេ ដោយពឹងលើលុយចំណូលបច្ចុប្បន្នរបស់ពួកគេ ពួកគេទាំងពីរចាប់ផ្ដើមយំ តែលើកនេះគឺយំដោយអំណរ។ ពួកគេអង្គុយនៅត្រង់នោះ ស្រក់ទឹកភ្នែកលើផ្ទៃមុខ ហើយនៅតែនិយាយថាពួកគេភ្ញាក់ផ្អើលខ្លាំងប៉ុណ្ណាចំពោះលទ្ធផលដែលពួកគេបានឃើញនេះ។ ពួកគេបានលោតឡើង និងបានឱបខ្ញុំ ហើយយើងទាំងអស់គ្នាមានពេលវេលាអបអរដ៏អស្ចារ្យមួយក្នុងយប់នោះ។

សូមនិយាយដោយស្មោះត្រង់បន្តិច៖ តើភ្នាក់ងារពន្ធដារ (IRS) នឹងប្រាប់អ្នកពីរបៀបបង់ពន្ធក្នុងចំនួនតិចដែរឬទេ? តើមានបុគ្គលិកធនាគារណាម្នាក់នឹងប្រាប់អ្នកពីរបៀបជៀសវាងការបង់ការប្រាក់ដែរឬទេ? គឺគ្មានទេ ប្រព័ន្ធទាំងមូលនេះគឺបានរៀបចំឡើងដើម្បីយកលុយពីអ្នក មិនមែនការពារលុយរបស់អ្នកទេ។ ខ្ញុំបានដឹងថាអ្វីដែលខ្ញុំបានរកឃើញនេះ ត្រូវតែយកទៅបង្រៀនដល់គ្រប់ក្រុមគ្រួសារក្នុងប្រទេសអាមេរិក! យប់នោះពិតជាមានការប៉ះពាល់ខ្លាំងណាស់មកលើខ្ញុំ ហើយខ្ញុំចង់ធ្វើរឿងដូចគ្នានេះសម្រាប់អតិថិជនម្នាក់ៗដែលខ្ញុំបានជួប។

ហេតុដូច្នេះហើយ ដោយមានព័ត៌មាននោះនៅជាប់ជាមួយ ហើយរួមជាមួយការបញ្ជាក់អំពីសុបិនដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ ឌ្រីនដា និងខ្ញុំបានលាឈប់ពីក្រុម

ហ៊ុនធានារ៉ាប់រងអាយុជីវិត ដែលខ្ញុំធ្លាប់ធ្វើការជាមួយ និងបានចាប់ផ្ដើមបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួនរបស់យើង ហើយគ្រាន់តែចាប់ផ្ដើមធ្វើអ្វីដែលខ្ញុំបានធ្វើ ជាមួយនឹងអតិថិជនម្នាក់នោះ។ នៅក្នុងឆ្នាំដំបូងៗ យើងបានដាក់ឈ្មោះក្រុមហ៊ុនរបស់យើងថា «ហិរញ្ញវត្ថុគ្រួសារដែលពេញដោយជំនឿ (Faith-Full Family Finances)»។ ឈ្មោះក្រុមហ៊ុននេះប្រាប់យ៉ាងច្បាស់ពីអ្វីៗទាំងអស់អំពីយើង នោះគឺប្រសិនបើអ្នកបានយល់ពីព្រះរាជ្យនៃព្រះ និងជំនឿនោះផ្នែកហិរញ្ញវត្ថុរបស់អ្នកនឹងបានពេញលេញ។ ខ្ញុំយល់ស្របថាវាមិនមែនជាឈ្មោះពិរោះណាស់ណាទេ សម្រាប់ក្រុមហ៊ុនមួយ សាកល្បងនិយាយឈ្មោះនេះ ១០ដងសាកមើល តែឈ្មោះនេះអាចប្រើបាន។ ក្រោយមកយើងបានដូរឈ្មោះមកថា Forward Financial Group ជាឈ្មោះដែលយើងប្រើសព្វថ្ងៃនេះ ហើយឈ្មោះដែលនៅតែមានដំណើរការរឹងមាំ។

និយាយដោយស្មោះទៅចុះ ចំពោះផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់យើងគឺមិនទាន់មានភាពពេញលេញនៅឡើយទេ។ កាលនោះយើងក៏នៅតែត្រូវសងបំណុលទាំងនោះ ក៏ប៉ុន្តែយើងដឹងថាយើងបានរកឃើញផ្លូវដែលយើងត្រូវដើរបន្តទៅមុខទៀត។ ពេលដែលយើងចាប់ផ្ដើមក្រុមហ៊ុនថ្មីរបស់យើង យើងមានចិត្តរំភើប និងមានអារម្មណ៍ភ័យៗបន្តិចក្នុងពេលតែមួយ។ យើងមានអ្វីជាច្រើនដែលត្រូវរៀនសូត្រអំពីការរៀបចំ និងការដំណើរការក្រុមហ៊ុនមួយ ក៏ប៉ុន្តែបញ្ហាដ៏ធំជាងគេបំផុតដែលយើងបានជួបប្រទះនោះគឺរបៀបរកលុយដោយការធ្វើកិច្ចការនេះ។ ឧបសគ្គរបស់យើងនោះគឺ យើងមានអារម្មណ៍ថាយើងមិនអាចរកលុយបានទេ ហើយយើងមិនចង់បង់លុយដើម្បីឱ្យយើងជួយពួកគេឱ្យរួចពីបំណុលទេ។ នេះគឺជាឧបសគ្គដ៏ធំដែលយើងត្រូវពុះពារ និងបានចំណាយពេលរាងច្រើនបន្តិចដើម្បីអធិស្ឋានអំពីវា និងមើលទៅកាន់ជម្រើសផ្សេងៗដែលយើងមាន។ ដោយគ្មានការពន្យល់លម្អិតអ្វីសោះ ព្រះអម្ចាស់បានបង្ហាញយើងនូវយុទ្ធសាស្ត្រដ៏អស្ចារ្យមួយដើម្បីបង្កើតក្រុមហ៊ុនឡើង និងបានប្រើវាដើម្បីរកលុយដោយមិនតម្រូវឱ្យអតិថិជនធ្វើការបង់លុយឡើយ។

ក្រោយមកយើងត្រូវស្វែងរកវិធីមួយដើម្បីពន្លឿនការគណនាដ៏វែងអន្លាយដែលខ្ញុំធ្លាប់បានធ្វើដោយប្រើទិន្នន័យរបស់អតិថិជនដែលខ្ញុំទទួលបានមក។ ខ្ញុំដឹងថាខ្ញុំនឹងត្រូវសរសេរកម្មវិធីកុំព្យូទ័រផ្ទាល់ខ្លួន ដើម្បីធ្វើកិច្ចការដែលយើងកំពុងធ្វើនេះ ក៏ប៉ុន្តែខ្ញុំមិនចេះអ្វីសោះដែលពាក់ព័ន្ធនឹងកុំព្យូទ័រ ហើយក៏មិនដឹងពីវិធីដើម្បីស្វែងរកអ្នកដែលមានសមត្ថភាពធ្វើវាដែរ។ ជាថ្មីម្ដងទៀត ព្រះជាម្ចាស់បានធ្វើកិច្ចការដ៏អស្ចារ្យមួយចំនួន។ ខ្ញុំបានទទួលទូរស័ព្ទពីមនុស្សម្នាក់ ដែលរស់នៅឆ្ងាយពីយើងគួរសមហើយបានឮអំពីអ្វីដែលយើងធ្វើ។ គាត់ចង់

ឃើញអ្វីដែលបានធ្វើ ហើយមកក្នុងនាមជាអតិថិជនម្នាក់។ គាត់ចូលចិត្តអ្វីដែលយើងធ្វើ ហើយពេលដែលយើងកំពុងសន្ទនាគ្នានោះ ខ្ញុំបានដឹងថាគាត់គឺជាអ្នកសរសេរកម្មវិធីកុំព្យូទ័រម្នាក់ ហើយគាត់មានក្រុមហ៊ុនផ្ទាល់ខ្លួនមួយជាការងារបន្ថែមក្រៅម៉ោង។ ខ្ញុំបាននិយាយប្រាប់គាត់អំពីតម្រូវការរបស់យើង ហើយគាត់បាននិយាយដោយមានចិត្តរំភើបយ៉ាងខ្លាំងថាគាត់ចង់ជួយយើងនូវអ្វីដែលយើងកំពុងតែធ្វើនោះ។ ខ្ញុំបានប្រាប់គាត់ថាយើងទើបតែបានចាប់ផ្តើមបង្កើតក្រុមហ៊ុន ហើយយើងនៅមិនទាន់ប្រាក់ខែសម្រាប់ចំណាយលើកិច្ចការដែលគាត់នឹងជួយធ្វើនោះទេ ទោះបីជាគាត់បានផ្តល់ការបញ្ចុះតម្លៃជាច្រើនសម្រាប់កិច្ចការដែលគាត់នឹងបំពេញឱ្យយើងក៏ដោយ។ គាត់នៅតែចង់ធ្វើកិច្ចការនោះ ហើយប្រាប់ខ្ញុំថាអាចបើកលុយឱ្យគាត់នៅពេលណាក៏បាន ដែលខ្ញុំទទួលបានលុយចំណូល។ ដូច្នេះយើងក៏ធ្វើកិច្ចការតាមរបៀបនោះទៅ។

មនុស្សជាច្រើនស្រលាញ់អាជីវកម្មរបស់ខ្ញុំ។ និយាយទៅ រឿងអីដែលថាពួកគេមិនស្រលាញ់វានោះ? បើវាជាសេវាឥតគិតថ្លៃ ហើយមនុស្សម្នាចូលចិត្តការរកលុយ និងការរួចពីបំណុល។ អាជីវកម្មនេះបានចាប់ផ្តើមដោយមានការលូតលាស់យ៉ាងឆាប់រហ័ស ហើយយើងអាចមានសេរីភាពពីការជាប់បំណុលបានក្នុងរយៈពេល ២ឆ្នាំកន្លះ។ មិនយូរប៉ុន្មានក្រោយពីនោះយើងមានអ្នកតំណាងដល់ទៅជាង ៣០០នាក់ធ្វើការចែកចាយផែនការរបស់យើងនៅជុំវិញផ្ទៃប្រទេស។ ក្រោយពីការដែលអាចធ្វើការចំណាយដោយបង់លុយសុទ្ធទិញឡានរបស់យើង យើងក៏បានបន្តធ្វើការសាងសង់ និងចំណាយលុយដើម្បីមានផ្ទះក្នុងក្តីស្រមៃរបស់យើងផងដែរ។ ក្រុមហ៊ុនរបស់យើងបានរីកចម្រើន និងបានជួយដល់យើងឱ្យអាចផ្តល់លុយរាប់រយពាន់ដុល្លាដើម្បីជួយគាំទ្រដល់ដំណឹងល្អ និងមនុស្សជាច្រើនក្នុងរយៈពេលច្រើនឆ្នាំមកនេះ។

«ផែនការដោះបំណុល» ជាឈ្មោះដែលយើងបានដាក់ឱ្យផែនការនេះ គឺនៅតែទទួលបានការបង្កើតឡើងដោយឥតគិតថ្លៃ សព្វថ្ងៃនេះស្មើនឹងរយៈពេល ៣០ឆ្នាំក្រោយពីយើងបានចាប់ផ្តើមធ្វើវា។ ក្រុមហ៊ុនមានការរីកចម្រើននៅក្នុងបេសកកម្មរបស់ខ្លួន ប្រៀបដូចជាពេលវេលាដែលចេះតែរំកិលទៅមុខ។ យើងបានបន្តធ្វើកិច្ចការដើម្បីផ្តោតលើការវិនិយោគសម្រាប់ការចូលនិវត្តន៍បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំ ២០០១ ហើយជាការពិតណាស់ បន្ទាប់មកទៀតមានវិបត្តិហិរញ្ញវត្ថុនេះក្នុងឆ្នាំ ២០០៨ ដែលមានមនុស្សរាប់លាននាក់បានបាត់បង់លុយសន្សំសម្រាប់ការចូលនិវត្តន៍របស់ពួកគេពី ៥០% ដល់ ៨០%។ យើង

បានធ្វើការស្រាវជ្រាវអំពីជម្រើសនៃការវិនិយោគដោយសុវត្ថិភាពមួយចំនួន និងបានដាក់ឱ្យប្រើប្រាស់នូវទស្សនៈវិស័យមួយនោះ របស់អាជីវកម្មយើងនៅក្នុងឆ្នាំ ២០០១។ ខ្ញុំពិតជាមានមោទនភាពណាស់ក្នុងការនិយាយថា ក្នុងចំនួនច្រើនជាងមួយរយលានដុល្លារដែលយើងកំពុងគ្រប់គ្រងឱ្យអតិថិជនរបស់យើង គ្មានអតិថិជនណាម្នាក់របស់យើងបានបាត់បង់សូម្បីតែមួយកាក់មួយសេននៅក្នុងការវិនិយោគរបស់ពួកគេ ក្នុងរយៈពេលច្រើនជាង ១៦ឆ្នាំមុនពេលកើតមានវិបត្តិហិរញ្ញវត្ថុនៅក្នុងប្រទេសយើង និងនៅក្នុងពិភពលោក។ ហើយដូចជានៅក្នុងផែនការរបស់យើងនេះ គឺគ្មានការគិតលុយទេ គ្មានការគិតលុយសេវារដ្ឋបាល ឬលុយកម្រៃជើងសារអ្វីពាក់ព័ន្ធតាំងពីពេលចាប់ផ្តើម ឬជាប្រចាំឆ្នាំចំពោះអតិថិជនវិនិយោគរបស់យើងទេ។ ប្រសិនបើអ្នកមានការហត់នឿយក្នុងការប្រថុយលេងល្បែងជាមួយនឹងលុយចូលនិវត្តន៍របស់អ្នក អ្នកអាចទាក់ទងមកក្រុមហ៊ុន Forward Financial Group តាមរយៈលេខទូរស័ព្ទ១(៨០០) ៨១៥ ០៨១៨ ឬតាមរយៈគេហទំព័រ Forwardfinancial-group.com សម្រាប់ព័ត៌មានបន្ថែម។

តើស្តាប់ទៅដូចជាអស្ចារ្យណាស់មែនទេ? គំនិតដ៏សាមញ្ញមួយដែលបានពីព្រះវិញ្ញាណដ៏វិសុទ្ធបានផ្លាស់ប្តូរជីវិតរបស់យើងជារៀងរហូត! ត្រូវហើយ យើងត្រូវតែឈានជើងដើរទៅ ក៏ប៉ុន្តែព្រះជាម្ចាស់បានបង្ហាញយើងពីទីកន្លែងដែលយើងត្រូវដើរ។ «លោកហ្គារី តើលោកមានអារម្មណ៍ដូចម្តេចដែរដែលបានរួចផុតពីការជំពាក់បំណុល?» អារម្មណ៍សុខសាន្ត! ការសម្រាក! សូមគិតមើលអំពីវាចុះ។ យើងបានចេញពីស្ថានភាពច្របូកច្របល់ផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរទៅរកស្ថានភាពដែលរួចផុតពីការជំពាក់បំណុលទាំងស្រុង មានលុយចំណាយទិញឡាន ទិញផ្ទះ និងអ្វីៗផ្សេងៗទៀតដែលយើងត្រូវការ។ សម្រាប់រយៈពេល ៩ឆ្នាំខ្ញុំរស់នៅក្រោមសម្ពាធដ៏ធ្ងន់ធ្ងរគ្រប់នាទីជារៀងរាល់ថ្ងៃ។ ខ្ញុំមិនដែលបានសម្រាកទេ មិនថាវាជាថ្ងៃអ្វីនៃសប្តាហ៍នីមួយៗ ឬជាថ្ងៃឈប់សម្រាកនោះទេ។ ខ្ញុំគ្មានសេចក្តីសុខសាន្តទេ។ បញ្ហាផ្នែកហិរញ្ញវត្ថុរបស់ខ្ញុំ ដេញតាមខ្ញុំគ្រប់ទីកន្លែងដែលខ្ញុំទៅ។ ខ្ញុំតែងតែទ្រាំទ្រចំពោះភាពអាម៉ាស និងការប្រមាថមើលងាយជានិច្ច ដោយសារតែស្ថានភាពហិរញ្ញវត្ថុដែលយើងបានជួបប្រទះ។ ភាពភ័យខ្លាចតែងតែនៅកំដរខ្ញុំជានិច្ច ហើយការវាយប្រហារពីភាពស្លន់ស្លោ និងការប្រើថ្នាំរម្ងាប់អារម្មណ៍គឺជាវិធីដែលខ្ញុំអាចធ្វើដើម្បីបន្តរស់ ក្នុងខណៈពេលដែលខ្ញុំស្ថិតក្នុងស្ថានភាពអស់សង្ឃឹមខ្លាំងបំផុត។

**គំនិតដ៏សាមញ្ញមួយដែលបានពីព្រះវិញ្ញាណដ៏វិសុទ្ធ បានផ្លាស់ប្តូរជីវិតរបស់យើងជារៀងរហូត! ត្រូវហើយ យើងត្រូវតែឈានជើងដើរទៅ ក៏ប៉ុន្តែព្រះជាម្ចាស់បានបង្ហាញយើងពីទីកន្លែងដែលយើងត្រូវដើរ។**

ដោយមានការផ្លាស់ប្តូរក្នុងផ្នែកហិរញ្ញវត្ថុគ្រប់យ៉ាង ហើយជាការពិតណាស់ការដែលយើងមានអ្វីៗដែលយើងត្រូវការនៅក្នុងជីវិតរៀបរយហើយ អ្នកអាចនឹងជួបការល្បួងឱ្យគិតថានៅក្នុងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុរបស់យើងផ្ទាល់ខ្លួន គឺជាជ័យជម្នះរបស់យើង។ ពិតមែនហើយ ការដែលនៅទីបំផុតយើងមានអ្វីគ្រប់យ៉ាងដែលយើងត្រូវការ នោះហើយគឺជាជ័យជម្នះដ៏ធំធេងមួយ ក៏ប៉ុន្តែសេចក្តីរំភើបពិតប្រាកដនោះគឺ ការមើលឃើញពីដំណើរការរបស់ព្រះរាជ្យនៃព្រះជាម្ចាស់។ ពេលដែលឌ្រិនដា និងខ្ញុំបានមើលឃើញព្រះរាជ្យបំពេញមុខងារ ម្តងហើយម្តងទៀត នោះយើងនឹងតែងតែនិយាយថា «តើបង/អូនឃើញដែរទេ?» វាប្រៀបដូចជាកុងតាក់ភ្លើងត្រូវបានចុចបើក យើងអាចមើលឃើញអ្វីៗបានច្បាស់ដោយសារមានពន្លឺ ហើយអ្នកអាចមើលវាឃើញ។ ការដែលអាចមើលឃើញបន្ទាប់ពីអ្នកធ្លាប់បានងងឹតភ្នែក និងរស់នៅដោយមិនដឹងពីអ្វីដែលជាចម្លើយ គឺជាបទពិសោធមួយដ៏អស្ចារ្យ។ ការស្វែងរកទ្រព្យសម្បត្តិពិតប្រាកដរបស់យើងដែលជាព្រះរាជ្យនៃព្រះ ពិតជាអស្ចារ្យខ្លាំងណាស់។ ដើម្បីឱ្យអាចប្រាប់អ្នកបានដោយសាមញ្ញពីអារម្មណ៍របស់ខ្ញុំ នោះគឺសាមញ្ញទេថា នោះគឺជាលើកដំបូងហើយក្នុងជីវិតខ្ញុំ ដែលខ្ញុំទទួលបានការសម្រាក!

រឿងរ៉ាវរំជួលចិត្តបានបញ្ចប់! កាលពីអតីតកាល ប្រសិនយើងបែកកង់ឡាន នោះវានឹងក្លាយទៅជាវិបត្តិផ្លូវចិត្តដ៏ធំមួយរបស់យើងមិនខាន។ «តើឱ្យយើងទៅយកលុយមកពីណាទៅ? តើមានកាតណាខ្លះរបស់យើងដែលនៅប្រើបាន?» តែសម្រាប់សព្វថ្ងៃនេះវិញ ប្រសិនបើឡានយើងខូចខ្ញុំមុខជាគ្រាន់តែសួរទៅតរិយាខ្ញុំថា «តើលើកនេះអូនចង់បានឡានពណ៌អ្វីដែរ?» តែប៉ុណ្ណោះ។ គ្មានអ្វីរំជួលចិត្ត គ្មានការស្លន់ស្លោ គ្មានបំណុលទៀតទេ មានតែការសម្រាក។ យើងអាចនៅតែបន្តធ្វើកិច្ចការរបស់យើង និងផ្តោតលើគោលបំណងរបស់យើងតែប៉ុណ្ណោះ។ យើងមិនចាំបាច់រស់នៅក្នុងជីវិតដែលតស៊ូឱ្យតែបានរស់ទៀតទេ យើងមានពេលនិយាយគ្នាពីជីវិតយើងបាន!

*ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នា កុំឱ្យខ្វល់ខ្វាយអំពីម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត ឬសម្លៀកបំពាក់សម្រាប់បិទបាំងកាយឡើយ។ ជីវិតមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយក៏មានតម្លៃលើសសម្លៀកបំពាក់ទៅទៀត។ ចូររំពៃមើលបក្សាបក្សីនៅលើមេឃ វាមិនដែលសាបព្រោះ មិនដែលច្រូតកាត់ មិនដែលប្រមូលស្រូវដាក់ជង្រុកឡើយ ប៉ុន្តែ ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ ព្រះអង្គចិញ្ចឹមវា។ រីឯអ្នករាល់គ្នា អ្នករាល់គ្នាមានតម្លៃលើសបក្សាបក្សីទាំងនោះទៅទៀត។*

ម៉ាថាយ ៦៖២៥-២៦

អស់រយៈពេល ៣៦ឆ្នាំមកនេះ ខ្ញុំបានអង្គុយជាមួយមនុស្សរាប់ពាន់នាក់នៅឯតុបាយក្នុងផ្ទះបាយរបស់ពួកគេ និងពិភាក្សាពីហិរញ្ញវត្ថុរបស់ពួកគេនៅកម្រិតមួយបែបផ្ទាល់ខ្លួនខ្លាំងណាស់ ខ្ញុំបាននិយាយទៅកាន់ហ្វូងមនុស្សរាប់ពាន់នាក់នៅជុំវិញពិភពលោក ហើយមានរឿងមួយដែលខ្ញុំបានស្វែងរកឃើញនៅគ្រប់ទីកន្លែង ដែលខ្ញុំមើលឃើញនោះគឺថា អ្នកគ្រប់គ្នាកំពុងស្វែងរកការសម្រាក!!!!! មនុស្សម្នាក់ៗរង់ចាំឱ្យដល់ថ្ងៃឈប់សម្រាក រង់ចាំវិស្សមកាល ឬរង់ចាំថ្ងៃចូលនិវត្តន៍មកដល់ គឺរង់ចាំដើម្បីបានឈប់ និងសម្រាក។

ការសិក្សាថ្មីៗមួយចំនួនដែលខ្ញុំបានអាន បានរកឃើញថាមានជនជាតិអាមេរិកប្រមាណ ៧០% មិនចូលចិត្តការងាររបស់ពួកគេទេ ហើយនៅក្នុងចំណោមមនុស្ស ៧០%នោះមាន ២០% មិនរីករាយ ហើយត្រូវបានគេធ្វើការសន្និដ្ឋានថាស្អប់ការងាររបស់ពួកគេ។ តើហេតុអ្វីពួកគេបង្ហាញខ្លួននៅកន្លែងដែលពួកគេស្អប់? តើពួកគេរស់នៅក្រោមភាពតានតឹងចិត្តប្រភេទណា ដែលធ្វើឱ្យពួកគេទទួលយកការឈឺចាប់ផ្លូវអារម្មណ៍ដ៏ធ្ងន់ធ្ងរជារៀងរាល់ថ្ងៃបែបនេះ? និយាយដោយស្មោះត្រង់ទៅចុះ ពួកគេដូចជាទាសករអ៊ីចឹង។ (យើងទាំងអស់គ្នាក៏ធ្លាប់បែបនោះដែរ។ យើងបានធំធាត់ឡើងនៅក្នុងពិភពលោកដែលវិធីតែមួយដើម្បីអាចចម្រុងចម្រើនបាននោះគឺធ្វើយ៉ាងណាឱ្យមានប្រាក់ដើម្បីអាចមានជម្រើសច្រើន។ ក៏ប៉ុន្តែសម្រាប់មនុស្សភាគ

**ការរស់នៅក្នុងជីវិតពេញដោយភាពតានតឹងផ្លូវចិត្តក្នុងផ្នែកហិរញ្ញវត្ថុ... វាមិនមែនជាគម្រោងរបស់ព្រះជាម្ចាស់តាំងពីដើមដំបូងនោះទេ ហើយមិនមែនជាគម្រោងរបស់ព្រះជាម្ចាស់សម្រាប់អ្នកក្នុងថ្ងៃនេះដែរ។**

ច្រើន ពួកគេមិនស្ថិតក្នុងករណីនេះទេ។) សុបិនរបស់ពួកគេអំពីភាពចម្រុងចម្រើនបាន បាត់បង់ទៅឆ្ងាយបន្តិចម្តងៗក្លាយទៅជាជីវិត ដែលរស់នៅដើម្បីឱ្យតែបានរស់ ពេលពួកគេ ឃើញថាខ្លួនពួកគេ កំពុងតែធ្វើការងារដដែល គ្មានដំណើរការទៅមុខក្នុងអាយុ ៣០ ឬ៤០ និងរហូតដល់ ៥០ឆ្នាំផងក៏មាន។

ក្នុងស្ថិតិកាលពីពេលថ្មីៗនេះមួយបានបញ្ជាក់ថា មានប្រជាជនអាមេរិក ៦៩% មិន ទាំងមានប្រាក់សន្សំដល់មួយពាន់ដុល្លារផង។[1] ភាពតានតឹងចិត្ត និងការបាក់ស្បាតផ្លូវ អារម្មណ៍ដែលមនុស្សភាគច្រើនកំពុងរស់នៅជាមួយ បាននាំឱ្យការយល់ដឹងរបស់ពួកគេ អំពីអត្តសញ្ញាណ និងគុណតម្លៃរបស់ខ្លួនគេបានបាត់បង់។ ពួកគេបានទុកសុបិនទាំងនោះ ចោល ដើម្បីតែតម្រូវការចាំបាច់ផ្សេងៗ និងការខកបំណងដ៏អួរអាប់មួយបានគ្របបាំងលើ សុបិនទាំងនោះទៅហើយ។ អំណររបស់ពួកគេក៏រសាត់បាត់ទៅ។

ខ្ញុំនៅចាំបានពីការសន្ទនារបស់ខ្ញុំជាមួយគ្រូគង្វាលម្នាក់នៅថ្ងៃមួយអំពីរឿងហិរញ្ញ ហិរវត្ថុ។ គាត់បានប្រាប់ខ្ញុំថាគាត់ស្រលាញ់ព័ន្ធកិច្ច និងស្រលាញ់មនុស្ស ក៏ប៉ុន្តែរាល់ថ្ងៃគាត់ តែងក្រោកពីដំណេកដោយមានចិត្តរំភើប ហើយក្តីរំភើបនោះបានរសាត់បាត់ទៅពេលគាត់ នឹកឃើញពីស្ថានភាពហិរញ្ញវត្ថុរបស់គាត់។ គាត់បានប្រាប់ខ្ញុំថា វាប្រៀបដូចជាដុំពពកខ្មៅដ៏ ធំមួយ ដែលបានបាំងពន្លឺព្រះអាទិត្យជិតតែម្តង ប្រៀបដូចជាគំនិតនៃការបាក់ទឹកចិត្តជា ច្រើនបានផ្តុំគ្នាឡើងនៅក្នុងចិត្តគំនិតរបស់គាត់ និងបានឃុំគាត់ទុកនៅក្នុងផ្នត់គំនិតតស៊ូ ដើម្បីតែរស់ ក្តីអស់សង្ឃឹមផ្នែកហិរញ្ញវត្ថុ និងភាពជាទាសករដែលគ្មាននិមិត្ត។

ការឈរមើលអ្នកដទៃឈ្នះ បានក្លាយទៅជាអ្វីដែលមនុស្សយកមកជំនួសឱ្យការ រស់នៅក្នុងជីវិតពួកគេ។ ក្រុមហ៊ុនហូលីវូតរកចំណូលបានដល់ខ្ទង់ពាន់លាន ក្នុងការបញ្ចាំង ពីជ័យជម្នះរបស់មនុស្សជាច្រើនផ្សេងទៀតនៅលើអេក្រង់ដ៏ធំរបស់ពួកគេ។ មនុស្សជាច្រើន ដែលមិនអាចមើលឃើញពីជ័យជម្នះរបស់ខ្លួនដោយផ្ទាល់ បានស្វែងរកពេលពីរបីនាទី ដើម្បីគេចចេញពីការងារដែលមិនសូវសំខាន់របស់ពួកគេ និងរស់នៅតាមសុបិនដោយការ មើលការរស់នៅរបស់មនុស្សដែលល្អឥតខ្ចោះ ចាក់បញ្ចាំងនៅអេក្រង់ធំមួយនោះ។

---

1 Niall McCarthy, "ការស្ទង់មតិ ៖ មានប្រជាជនអាមេរិក ៦៩% មិនទាំងមានប្រាក់សន្សំដល់មួយពាន់ដុល្លារ" ទស្សនាវដ្តី Forbes ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦
https://www.forbes.com/sites/niallmccarthy/2016/09/23/survey-69-of-americans-have-less-than-1000-in-savingsinfographic/#30d27351ae67.

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

វិស័យកីឡាក្នុងពេលបច្ចុប្បន្ននេះ រកចំណូលបានខ្ទង់ពាន់លានដុល្លារក្នុងមួយឆ្នាំពីទស្សនិកជននៅជុំវិញពិភពលោក។ ក្នុងឆ្នាំ ២០១៧ កីឡាបាល់បោះ NFL បានរកចំណូលដល់ទៅជាង ៧.៨ពាន់លានដុល្លារ ឯកីឡាបាល់បោះ Super Bowl រកចំណូលបានប្រមាណ ១៥.៩ពាន់លានដុល្លារ ហើយចំណូលនោះរកបានត្រឹមតែក្នុងការប្រកួតម្តងប៉ុណ្ណោះ! [2] [3] មនុស្សពិតចូលចិត្តអបអរចំពោះក្រុមដែលពួកគេចូលចិត្តខ្លាំងណាស់ ពេលក្រុមនោះទទួលបានជ័យជម្នះ។

ក៏ប៉ុន្តែអ្វីដែលយើងចាំបាច់ត្រូវតែយល់នោះគឺថាយើងគ្រប់គ្នាត្រូវបានបង្កើតមក និងរៀបចំដើម្បីឈ្នះ ដើម្បីឱ្យជួបឧបសគ្គ ដើម្បីស្ថិតនៅក្នុងការប្រកួត ហើយចុងក្រោយនោះគឺដើម្បីឈ្នះ។ ក្តីអស់សង្ឃឹមផ្នែកហិរញ្ញវត្ថុគឺជាបទដ្ឋានមួយ មិនមែនជាករណីលើកលែងសម្រាប់មនុស្សភាគច្រើននោះទេ ដូច្នេះហើយវិធីចាកចេញពីវាតែមួយគត់នោះគឺការរស់នៅក្នុងជីវិតដែលយើងទាំងអស់គ្នាសុបិនចង់រស់នៅតាមរយៈជីវិតអ្នកដទៃ។ តើអ្វីទៅជាអន្ទាក់ទាក់ចិត្តអំពីការឈ្នះឆ្នោត? ហេតុអ្វីបានជាកម្មវិធីទូរទស្សន៍ដែលមានឈ្មោះថា *តើនរណាចង់ក្លាយជាសេដ្ឋី*មានការពេញនិយមម្លេះ? ហេតុអ្វីបានជាការបោកប្រាស់ថាមនុស្សនឹងអាចក្លាយទៅជាអ្នកមាន នៅតែជាការល្បួងក្នុងពេលសព្វថ្ងៃនេះ? តើអ្នកមានចម្លើយដែរទេ? សូមសម្រាក! មនុស្សគ្រប់គ្នាហត់នឿយក្នុងការរត់ ហត់នឿយក្នុងក្រោកពីដំណេកជាមួយនឹងទម្ងន់នៃការរកឃើញថា គ្មានអ្វីដែលបានដូចបំណងរបស់ពួកគេទាល់តែសោះ។ ក៏ប៉ុន្តែការរស់នៅក្នុងជីវិតដែលមានភាពតានតឹងផ្នែកហិរញ្ញវត្ថុមិនមែនជាអ្វីថ្មីទេ ជាក់ស្តែងវាបានកើតមានយូរមកហើយចាប់តាំងពីមនុស្សកើតមកលើផែនដី។ ទោះជាយ៉ាងណាក៏ដោយវាមិនមែនជាផែនការរបស់ព្រះជាម្ចាស់តាំងពីដើមដំបូងនោះទេ ហើយមិនមែនជាផែនការរបស់ព្រះជាម្ចាស់សម្រាប់អ្នកក្នុងថ្ងៃនេះដែរ។

---

2 Michael David Smith, “សៀវភៅរបស់លោក Packers បង្ហាញថាបណ្តាក្រុមដែលប្រកួតក្នុង NFL រកចំណូលបាន $៧.៨ ពាន់លាននៅក្នុងចំណូលជាតិ” ទូរទស្សន៍ NBC Sports, http:// profootballtalk.nbcsports.com/2017/07/12/packers-books-show-nfl-teams-split-7-8-billion-in-national-revenue/.

3 Joe D’Allegro, “ប្រាក់ពាន់លានរបស់កីឡា Super Bowl ៖ អាជីវកម្មដ៏ធំធេងនៅក្រោយការប្រកួតដ៏ធំបំផុតប្រចាំឆ្នាំ” ទូរទស្សន៍ CNBC, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៧, ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧ https://www.cnbc.com/2017/01/20/super-bowl-billions-the-big-business-behind-the-big-game.html.

# ជំពូក ២

# សិទ្ធស្របច្បាប់

គួរឱ្យអស់សង្ឃឹមណាស់ - នេះជាអ្វីដែលខ្ញុំចង់ពណ៌នាអំពីជីវិតរបស់ពួកយើង មុនពេលពួកយើងបានឈ្វេងយល់អំពីរបៀបសម្រាក។ ពេលវេលាប្រាំបួនឆ្នាំ គឺជាពេលដ៏យូរវែងអន្លាយមួយដែលពួកយើងបានរស់នៅក្នុងជីវិតបែបរីករវរ និងពេញដោយអារម្មណ៍តានតឹងក្នុងផ្នែកហិរញ្ញវត្ថុ។ ខ្ញុំនៅចាំបានថា មានពេលជាច្រើនដងដែលខ្ញុំបានឈរសម្លឹងមើលដីចម្ការ ទំហំប្រមាណ ៣៩ ហិកតា ដែលលពួកយើងជួលក្នុងតម្លៃ ៣០០ដុល្លារក្នុងមួយខែ ដោយប្រឹងបង់ថ្លៃឈ្នួលទាំងលំបាក ដែលតាមពិតតម្លៃនោះគឺថោកណាស់ ហើយខ្ញុំក៏ចេះតែស្រមៃថាតើខ្លួនអាចនឹងមានលទ្ធភាពធ្វើជាម្ចាស់ដីបែបនេះបានដែរឬទេ។

ម្ចាស់ដីនេះគ្រោងនឹងសង់ទីលានកីឡាវាយកូនហ្គោលនៅលើដីនេះ ហើយគ្រាន់តែចង់ឱ្យមាននរណាម្នាក់រស់នៅទីនេះ គ្រាន់នឹងបានចាំដីនោះរហូតដល់ពួកគេចាប់ផ្ដើមគម្រោងនេះប៉ុណ្ណោះ ហើយគម្រោងនេះនឹងធ្វើឡើងក្នុងរយៈពេលប្រមាណជាបីឆ្នាំ ទៅប្រាំឆ្នាំខាងមុខ។ ផ្ទះចាស់បែបស្រុកស្រែនេះ «ជាផ្ទះដ៏ចាស់ទ្រុឌទ្រោមនៅលើដីនេះស្រាប់» ហើយម្ចាស់ផ្ទះមិនចេញថ្លៃចំណាយលើការជួសជុលណាមួយឡើយក្នុងពេលនោះ។ ពួកយើងក៏ទទួលយកផ្ទះនោះតាមដំណើរ ហើយបន្ទាប់ពីធ្វើការលាបពណ៌យ៉ាងស្អាត និងសម្អាតបានស្អាតបាត ផ្ទះកញ្ចាស់នេះក៏ប្រែមានលក្ខណៈស្រស់ស្អាតពិសេសម្យ៉ាង។ ពួកយើងមានផែនការរស់នៅទីនោះរយៈពេលបីឆ្នាំ តែក្រោយមកក៏បន្តរស់នៅទៀត រហូតរស់នៅទីនោះអស់រយៈពេលប្រាំបីឆ្នាំ តែពួកយើងនៅតែហាក់ដូចមិនមានសល់អ្វីសោះ។

ក្រោយពេលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំអំពីព្រះរាជ្យរបស់ទ្រង់ ពេលនោះពួកយើងក៏បានចាប់ផ្ដើមសិក្សា និងអនុវត្តគោលការណ៍ និងច្បាប់នៃព្រះរាជ្យរបស់ព្រះ ហើយអ្វីៗក៏ចាប់ផ្ដើមមានការផ្លាស់ប្ដូរ។ ពីដំបូងឡើយ គឺនៅពេលដែលពួកយើងចាប់ផ្ដើមមានប្រាក់គ្រាន់បើជាងមុន ពួកយើងក៏មានចិត្តរីករាយជាខ្លាំងជាមួយនឹងជ័យជម្នះដ៏តូច

បំផុតនេះ។ ខ្ញុំនៅចាំថា ពេលនោះពួកយើងក៏បានទិញម៉ាស៊ីនលាងចានដាក់ក្នុងផ្ទះចាស់នៅដីចម្ការនោះ ហើយគ្រីនដា និងខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ ជាពិសេសគឺនាងតែម្តង! ទោះបីជាពេលខ្លះខ្ញុំបានជួយលាងចានក៏ពិតមែន ប៉ុន្តែខ្ញុំក៏មានភាពមមាញឹកនឹងរឿងផ្សេងៗដែរ។ នាងត្រូវរវល់លាងចានជាញឹកញាប់ទោះបីជាមានកូនប្អូននាក់ត្រូវមើលថែនៅឯផ្ទះក្តី។ ខ្ញុំចាំថា នៅពេលពួកយើងបានទិញម៉ាស៊ីនលាងចានថ្មីមក ពេលនោះខ្ញុំបាននិយាយថា «អូនហ្អា៎ មិនគួរឱ្យជឿសោះថាយើងទើបនឹងបានយកលុយទិញម៉ាស៊ីនលាងចានថ្មី!» ខ្ញុំដឹងថា អ្នករាល់គ្នាកំពុងថា «យី...គ្រាន់តែរឿងទិញម៉ាស៊ីនលាងចានសោះ ម្តេចក៏ធំដុំម្ល៉េះ?» ហ្នឹងហើយ តែបើលោកអ្នកក្រឡេកមើលសម្ភារៈនានាក្នុងផ្ទះបាយនៅផ្ទះដ៏ទ្រុឌទ្រោមខ្ញុំនៅចម្ការនោះវិញ នោះនឹងបានយល់ជាមិនខាន។ ទាំងចង្ក្រានហ្គាស និងទូរទឹកកកករបស់យើងសុទ្ធតែចាស់គំរិលអស់ហើយ ពួកវាមានអាយុកាល២៥ឆ្នាំហើយ។ ហើយបើប្រៀបធៀបគ្នាទៅ គឺថាការម៉ាស៊ីនលាងចាននេះគឺជាជោគជ័យដ៏ធំមួយសម្រាប់ពួកយើង។

នៅក្នុងជំពូកមុន ខ្ញុំបានចែកចាយអំពីរបៀបដែលព្រះជាម្ចាស់ប្រទាននូវនិមិត្តមកកាន់ខ្ញុំ និងផែនការមួយឱ្យខ្ញុំចាប់ផ្តើមអាជីវកម្មដែលនឹងឆ្លើយតបនូវបញ្ហាវិករផ្នែកហិរញ្ញវត្ថុរបស់ខ្ញុំ។ អ្នកអាចនឹងគិតថា «ខ្ញុំសង្ឃឹមថាព្រះជាម្ចាស់ក៏នឹងមានបន្ទូលមកខ្ញុំបែបនេះដែរ។» ចំណុចល្អនោះគឺថា ទ្រង់ចង់ធ្វើដូច្នេះដែរ ប៉ុន្តែមានអ្វីមួយដែលអ្នកត្រូវដឹងទាក់ទងនឹងរបៀបដែលព្រះរាជ្យរបស់ព្រះមានដំណើរការ មុននឹងអាចចូលមកដល់ផ្នែកនេះ។ ការចង្អុលបង្ហាញដែលខ្ញុំទទួលបាននៅក្នុងសុបិនថ្ងៃនោះ គឺបានកើតឡើងដោយសារតែជាអ្វីដែលព្រះជាម្ចាស់ទ្រង់កំពុងបង្រៀនពួកយើងអំពីព្រះរាជ្យរបស់ទ្រង់ និងជាលទ្ធផលដោយផ្ទាល់នៃការអនុវត្តតាមអ្វីដែលទ្រង់បានបង្ហាញដល់យើងប៉ុណ្ណោះ។ ទោះបីជាខ្ញុំនិយាយបកស្រាយអំពីព្រះរាជ្យនៃព្រះដោយលម្អិតយ៉ាងណានៅក្នុងសៀវភៅបោះពុម្ពចុងក្រោយរបស់ខ្ញុំក្តី ក៏ខ្ញុំចាំបាច់ត្រូវតែរំឭកវាឡើងវិញនៅក្នុងអត្ថបទនេះម្តងទៀតដើម្បីបង្ហាញជាគំរូដល់យើងពីអ្វីដែលវាអាចដំណើរការទៅបាន។

មានគេសួរខ្ញុំថាតើពាក្យថាព្រះរាជ្យនៃព្រះនោះមានន័យដូចម្តេច។ បើទោះបីជាពេលនោះខ្ញុំជាគ្រិស្តបរិស័ទក៏ដោយ ក៏ពេលនោះខ្ញុំគ្មានចំណេះដឹងអ្វីអំពីព្រះរាជ្យនៃព្រះឡើយ។ ខ្ញុំគ្រាន់តែដឹងថា ពេលស្លាប់ទៅ ខ្ញុំនឹងបានទៅនគរស្ថានសួគ៌ ប៉ុន្តែខ្ញុំមិនមានការយល់ដឹងអំពីព្រះរាជ្យនៃព្រះ និងរបៀបដែលព្រះរាជ្យទ្រង់មានដំណើរការបែបណានោះឡើយ។ ដើម្បីយល់អំពីគំនិតនេះ អ្នកត្រូវយល់អំពីអត្ថន័យនៃពាក្យ ព្រះរាជ្យ ។ នៅក្នុងន័យតាម

បែបអក្សរសាស្ត្រ វាមានន័យថាជាការត្រួតត្រាដោយស្តេច។ រាជ្យរបស់ស្តេចមួយអង្គ ត្រូវបានត្រួតត្រាចាត់ចែងដោយបន្ទូលរបស់ស្តេច។ បន្ទូលរបស់ទ្រង់ក្លាយជាច្បាប់ដែលគ្រប់គ្រងដែននគរ និងជីវិតប្រជានុរាស្ត្ររបស់ទ្រង់។ ទស្សនៈមួយផ្សេងទៀតដែលពាក់ព័ន្ធនឹងព្រះរាជ្យនោះគឺថា មិនមែនឱ្យតែមានមនុស្សមួយលាននាក់គឺបង្កើតបានជាព្រះរាជ្យនគរមួយនោះទេ។ ព្រះរាជ្យនគរមួយគឺរួមមាននូវរាជរដ្ឋាភិបាលដោយបង្កើតឱ្យមានច្បាប់ ដែលត្រូវយកច្បាប់របស់ស្តេចទៅអនុវត្តចំពោះប្រជានុរាស្ត្រស្របច្បាប់នៅក្នុងរាជាណាចក្រនោះ។ គំនិតដែលថាព្រះជាម្ចាស់មាននូវព្រះរាជ្យមួយ ដែលបានបង្កើតនូវច្បាប់ដែលមានស្រាប់សម្រាប់ប្រជានុរាស្ត្រគ្រប់គ្នានៅក្នុងព្រះរាជ្យរបស់ទ្រង់នោះ គឺហាក់ត្រូវបានគ្រិស្តបរិស័ទភាគច្រើនគេចវេះទៅវិញ។ គ្រិស្តបរិស័ទភាគច្រើនជឿថាព្រះជាម្ចាស់សម្រេចព្រះហឫទ័យលើការអធិស្ឋានអ្វីមួយ ឬចំពោះអ្នកអធិស្ឋានណាម្នាក់ដែលទ្រង់សព្វព្រះហឫទ័យ។ ពួកគេជឿថា ប្រសិនបើខ្លួនអធិស្ឋានតមអាហាររយៈពេលយូរ ឬធ្វើកិច្ចការជាច្រើនអំពីផ្នែកព្រលឹងវិញ្ញាណ នោះពួកគេនឹងទទួលបានការសព្វព្រះហឫទ័យពីទ្រង់។ បងប្អូនអើយ តាមពិតទ្រង់សព្វព្រះហឫទ័យនឹងអ្នករាល់គ្នារួចស្រេចទៅហើយ។

> *ហេតុនេះ បងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។*
>
> អេភេសូ ២៖១៩

អ្នកមិនត្រឹមតែជាប្រជារាស្ត្រនៅក្នុងនគររបស់ទ្រង់តែប៉ុណ្ណោះទេ តែអ្នកថែមទាំងជាសមាជិកនៃក្រុមគ្រួសាររបស់ទ្រង់ថែមទៀតផង គឺជាបុត្រាបុត្រីរបស់ស្តេច។ នៅក្នុងគម្ពីរកាឡាទីជំពូក៤ បានបង្ហាញយ៉ាងច្បាស់អំពីអត្ថន័យនេះចំពោះអ្នកនិងខ្ញុំ។

> *ខ្ញុំសូមជម្រាបថា ដរាបណាកូនដែលត្រូវទទួលមត៌កនៅក្មេងនៅឡើយ គេមិនខុសពីខ្ញុំបម្រើទេ ថ្វីដ្បិតតែគេជាម្ចាស់លើទ្រព្យសម្បត្តិទាំងអស់ក៏ដោយ ក៏កូននោះនៅក្រោមការឃុំគ្រងរបស់អ្នកអាណាព្យាបាល និងអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិ រហូតដល់ពេលដែលឪពុកបានកំណត់ទុក។ រីឯយើងវិញក៏ដូច្នោះដែរ កាលនៅក្មេងខ្ចី នៅឡើយ យើងធ្វើជាខ្ញុំបម្រើនៃអ្វីៗជាអរូបដែលមានឥទ្ធិពលលើលោកីយ៍នេះ ប៉ុន្តែ លុះដល់ពេលកំណត់ហើយ ព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គឱ្យមកប្រសូតចេញពីស្ត្រី ហើយប្រសូតក្រោមអំណាចរបស់វិន័យផង ដើម្បីលោះអស់អ្នកដែលស្ថិតនៅក្រោមអំណាចវិន័យ*

*និងឱ្យយើងទទួលឋានៈជាបុត្ររបស់ព្រះអង្គ។ បងប្អូនពិតជាបុត្ររបស់ព្រះជាម្ចាស់មែន ព្រោះព្រះអង្គបានចាត់ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គ ឱ្យមកសណ្ឋិតក្នុងចិត្តយើង គឺព្រះវិញ្ញាណនេះហើយ ដែលបន្លឺព្រះសូរសៀងឡើងថា « អប្បា ! ឱព្រះបិតា» ។ ដូច្នេះ អ្នកមិនមែនជាខ្ញុំបម្រើទៀតទេ គឺអ្នកជាបុត្ររបស់ព្រះអង្គវិញ។ បើអ្នកជាបុត្រមែន អ្នកក៏ត្រូវទទួលមតិកដែលព្រះជាម្ចាស់ប្រទានឱ្យនោះដែរ។*

កាឡាទី៤៖១-៧

លោកអ្នកគឺជាបុត្រាបុត្រីដែលជាអ្នកស្នងមតិកនៃទ្រព្យសម្បត្តិទាំងមូល ហើយអ្នកមានសិទ្ធិស្របច្បាប់ជាប្រជារាស្ត្រនៃនគររបស់ទ្រង់! សូមគិតពីចំណុចនេះបន្តិច - លោកអ្នកមានអ្វីៗទាំងអស់រួចរាល់ទៅហើយ។ គឺគ្មានអ្វីមួយដែលអ្នកត្រូវការដែលខ្លួនមិនទាន់មាននោះទេ។ ដូចនេះ សូមឈប់ទទូចសុំ និងឈប់ស្រែកឃំទៅ។ អ្នកមិនអាចទទូចសុំនូវអ្វីដែលអ្នកមានវារួចទៅហើយនោះទេ។

**អារម្មណ៍យល់ឃើញផ្សេង។ ពិតជាល្អណាស់ ហើយខ្ញុំចូលចិត្តមានអារម្មណ៍ដឹងពីព្រះវត្តមានរបស់ព្រះជាម្ចាស់ ប៉ុន្តែនៅពេលនិយាយអំពីបញ្ហាផ្លូវច្បាប់ ខ្ញុំមិនចាំបាច់មានអារម្មណ៍ថាខ្លួនត្រូវបានសង្គ្រោះដើម្បីទទួលបានការសង្គ្រោះនោះទេ។ វាជារឿងផ្លូវច្បាប់។**

ព្រះជាម្ចាស់មិនធ្វើការសម្រេចព្រះទ័យតាមករណីនីមួយៗម្តងមួយៗថាតើនរណាដែលទ្រង់នឹងជួយ ហើយនរណាទ្រង់មិនជួយនោះទេ។ អស់អ្នកណាដែលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ សុទ្ធតែមាននូវជំនួយពីព្រះអង្គរួចទៅហើយ។

ខ្ញុំសូមប្រៀបធៀបចំណុចនេះទៅនឹងភាពជាពលរដ្ឋនៃប្រទេសអាមេរិកវិញ។ ប្រសិនបើអ្នកជាពលរដ្ឋម្នាក់ នោះអ្នកមានការគាំពារពីរាជរដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីអនុវត្តអ្វីដែលច្បាប់មានចែងទុករួចស្រេចទៅហើយ។

អត្ថប្រយោជន៍ត្រូវបានដាក់បញ្ចូលទៅក្នុងភាពជាពលរដ្ឋរបស់អ្នករួចជាស្រេច។ ដូចនេះ អ្នកមិនអាចតមអាហារ និងអធិស្ឋានរយៈពេលយូរល្មមដើម្បីទទួលបានជំនួយពីទ្រង់

ឡើយ។ ព្រះអង្គបានប្រទានមកដល់អ្នកដោយឥតគិតថ្លៃ តាមរយៈអ្វីដែលព្រះយេស៊ូបានធ្វើ។ ដូច្នេះចូររីករាយនឹងវាចុះ! វាជាកម្មសិទ្ធិរបស់អ្នកហើយ!

> *ព្រះអង្គបានប្រោសយើងឱ្យរស់ឡើងវិញ រួមជាមួយព្រះគ្រិស្តយេស៊ូ និងឱ្យយើងអង្គុយលើបល្ល័ង្កនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ។ ព្រះអង្គបង្ហាញព្រះហឫទ័យសប្បុរសចំពោះយើង ក្នុងអង្គព្រះគ្រិស្តយេស៊ូដូច្នេះ ដើម្បីបង្ហាញឱ្យមនុស្សគ្រប់ជំនាន់ខាងមុខ ស្គាល់ព្រះគុណដ៏ប្រសើរលើសលប់បំផុតរបស់ព្រះអង្គ។*

អេភេសូ ២៖៦-៧

ឃ្លានេះ «*យើងអង្គុយលើបល្ល័ង្កនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ*» កំពុងនិយាយអំពីឋានៈស្របច្បាប់នៅក្នុងព្រះរាជ្យរបស់ព្រះ។ ព្រះយេស៊ូគង់នៅខាងស្តាំព្រះវរបិតា ហើយអ្នកក៏ដូចគ្នាដែរ ព្រោះអ្នកក៏ជារូបកាយរបស់ព្រះគ្រិស្ត។ ដូចនេះ អ្នកជាអ្នកស្នងមតិកដែលព្រះជាម្ចាស់មាន រួមជាមួយព្រះយេស៊ូ។ ខ្ញុំដឹងថា ការគិតបែបនេះជារឿងមិនគួរឱ្យជឿតែនេះជាការពិត។ អ្នកមានគ្រប់យ៉ាង អ្នកជាគ្រួសារ ហើយវាជាកិច្ចការក្នុងគ្រួសារ! ប៉ុន្តែដោយសារតែវិញ្ញាណអាក្រក់បានព្យាយាមលាក់បាំងពីលក្ខណៈរបស់អ្នកគ្រប់យ៉ាង និងអ្វីគ្រប់យ៉ាងដែលអ្នកមាន នោះមនុស្សភាគច្រើន សូម្បីតែគ្រិស្តបរិស័ទ បានរស់នៅដូចជាមនុស្សដែលនៅជាប់ប្រព័ន្ធចំណងបណ្តាសានៃការរស់រានលើផែនដីនេះ!

គន្លឹះដែលបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំគឺនៅពេលដែលខ្ញុំដឹងថាព្រះរាជ្យគឺជារដ្ឋមួយដែលធ្លាប់មានច្បាប់ពីមុន និងមាននៅពេលនេះ ហើយក្នុងនាមជាប្រជាពលរដ្ឋមួយរូប ខ្ញុំមានសិទ្ធិស្របច្បាប់ និងទទួលអត្ថប្រយោជន៍នៅក្នុងព្រះរាជ្យនេះ។ អារម្មណ៍យល់ឃើញផ្សេងៗពិតជាល្អណាស់ ហើយខ្ញុំចូលចិត្តមានអារម្មណ៍ដឹងពីព្រះវត្តមានរបស់ព្រះជាម្ចាស់ ប៉ុន្តែនៅពេលនិយាយអំពីបញ្ហាផ្លូវច្បាប់ ខ្ញុំមិនចាំបាច់មានអារម្មណ៍ថាខ្លួនត្រូវបានសង្គ្រោះ ដើម្បីទទួលបានការសង្គ្រោះនោះទេ។ វាជារឿងផ្លូវច្បាប់។ ខ្ញុំមិនចាំបាច់មានអារម្មណ៍ថាខ្លួនឯងជាពលរដ្ឋនៃប្រទេសសហរដ្ឋអាមេរិកដើម្បីទទួលបានភាពជាពលដ្ឋនៃប្រទេសនេះនោះទេ។ ខ្ញុំបានដឹងរួចស្រេចទៅហើយថា វាជារឿងផ្លូវច្បាប់ដែលខ្ញុំមាន ដោយការពិតដែលខ្ញុំបានកើតនៅទីនេះ។ នៅពេលដែលអ្នកកំពុងឈរដោយមានសិទ្ធិ ដោយនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ហើយជីវិតរបស់អ្នកពឹងអាងលើច្បាប់ ជាជាងការដែលអ្នកមានអារម្មណ៍យល់ឃើញ នោះអ្វីៗនឹងមានការផ្លាស់ប្តូរ!

*ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថាប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថាព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថាយើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*

១យ៉ូហាន ៥៖១៤-១៥

សូមជញ្ជឹងគិតអំពីខគម្ពីរនេះមួយនាទីសិន វាជាខគម្ពីរមួយដែលខ្ញុំពេញចិត្ត។ ប្រសិនបើខ្ញុំទូលសុំអ្វីមួយស្របតាមបំណងរបស់ទ្រង់ នោះខ្ញុំដឹងថាទ្រង់ព្រះសណ្ដាប់ពីការទូលសុំនោះ! នេះមិនមែនសំដៅលើសំឡេងចាក់ផ្សាយដែលអ្នកគ្រាន់តែស្ដាប់ឮនឹងត្រចៀកនោះទេ។ នេះគឺជាសេចក្ដីប្រកាសស្របច្បាប់មួយ។ ចូរគិតដល់ចៅក្រម និងសាលចៅក្រម។ ប្រសិនបើចៅក្រមសម្រេចថាស្ដាប់រឿងក្ដីមួយ នោះវាមានន័យថា គាត់បានឯកភាពដោះស្រាយបញ្ហាមួយដែលស្របតាមអ្វីដែលច្បាប់បានចែងមកហើយ។ នៅក្នុងចំណុចរឿងរ៉ាវរបស់យើង ដោយសារយើងបានទូលសុំតាមច្បាប់នៃព្រះរាជ្យនៃព្រះ នោះយើងបានដឹងរួចទៅហើយថាទ្រង់នឹងអនុវត្តច្បាប់របស់ព្រះអង្គជាមិនខាន។ ដូចនេះយើងមាននូវការជឿជាក់ចំពោះលទ្ធផលនោះ ដោយមិនចេះតែស្មានទុកឡើយ។

ជាឧទាហរណ៍ សហរដ្ឋអាមេរិកមិនមែនជារាជាណាក្រទេ ដ្បិតប្រទេសនេះមិនមានស្ដេចទេ ប៉ុន្តែជាប្រទេសដែលគ្រប់គ្រងដោយច្បាប់ដែលប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើភាព និងមានសម្រាប់ពលរដ្ឋស្របច្បាប់គ្រប់រូប។ ក្នុងរបៀបស្រដៀងគ្នានេះ ព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏ត្រូវបានគ្រប់គ្រងដោយច្បាប់ដែរ ដែលច្បាប់ទាំងមានមានសម្រាប់ពលរដ្ឋគ្រប់រូបដោយមិនលម្អៀង។ រឿងរ៉ាវដែលយើងបានអាននៅក្នុងព្រះគម្ពីរ មិនមែនគ្រាន់តែដើម្បីធ្វើឱ្យយើងស្ញប់ស្ញែងប៉ុណ្ណោះទេ តែដើម្បីបើកបង្ហាញឱ្យឃើញច្បាប់ទាំងនោះសម្រាប់ពួកយើងដែរ ដើម្បីឱ្យយើងអាចរៀនពីវាបាន និងប្រើប្រាស់ច្បាប់ទាំងនោះ។ ព្រះយេស៊ូបានប្រើបន្ទូលមួយឃ្លាថា «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបដូចជា» ដោយប្រើឃ្លានេះច្រើនដង នៅពេលដែលព្រះអង្គកំពុងពន្យល់មនុស្សអំពីរបៀបដែលព្រះរាជ្យរបស់ព្រះដំណើរការ។ ព្រះយេស៊ូកំពុងមានបន្ទូលសំដៅលើច្បាប់បញ្ញត្តិនៃព្រះរាជ្យនៃព្រះ នៅពេលដែលទ្រង់មានបន្ទូលអំពីប្រស្នា ដោយបានបើកបង្ហាញរូបភាពច្បាស់ៗអំពីរបៀបដែលច្បាប់បញ្ញត្តិដំណើរការ ឬធ្វើការបញ្ជាក់ពីមូលហេតុដែលមានអ្វីមួយកើតឡើង។ ជាថ្មីម្ដងទៀង

ដោយមូលហេតុខ្លះ មនុស្សមិនមានទស្សនៈអ្វីទាំងអស់អំពីព្រះរាជ្យនៃព្រះក្នុងការមានច្បាប់ដែលគ្រប់គ្រងដំណើរការនៃព្រះរាជ្យនេះ។ មនុស្សជាច្រើនក៏គិតថា ព្រះជាម្ចាស់អាចធ្វើអ្វីៗដែលទ្រង់ចង់ធ្វើនៅពេលដែលទ្រង់សព្វព្រះហឫទ័យដោយសារទ្រង់គឺជាព្រះ។ យ៉ាងណាក្តីព្រះអង្គទ្រង់មានដែនកំណត់ដោយច្បាប់បញ្ញត្តិរបស់ទ្រង់។ ខ្ញុំដឹងថាចំណុចនេះស្តាប់ទៅហាក់ចម្លែកចំពោះអ្នក ប៉ុន្តែដើម្បីបញ្ជាក់ពីការលើកឡើងរបស់ខ្ញុំ ចូរយើងអានគម្ពីរម៉ាកុសជំពូក៦។

> *ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតា គេមើលងាយព្យាការីតែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ»។ នៅទីនោះ ព្រះអង្គពុំអាចធ្វើការអស្ចារ្យអ្វីឡើយ បានត្រឹមតែដាក់ព្រះហស្តលើអ្នកជំងឺខ្លះ ដើម្បីប្រោសគេឱ្យជាប៉ុណ្ណោះ។ ព្រះអង្គនឹកឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។*
>
> *ម៉ាកុស ៦៖៤-៦*

នៅពេលអ្នកអានអត្ថបទគម្ពីរនេះ អ្នកគួរតែអាចមានការគិតដល់រឿងមួយចំនួនក្រៅពីអ្វីដែលបានសរសេរក្នុងទំព័រនេះដែលបានធ្វើឱ្យអ្នកយល់ដឹងខ្លះអំពីដំណើរការនៃព្រះរាជ្យព្រះ។

### ទ្រង់<u>មិនអាច</u>ធ្វើរឿងអស្ចារ្យណាមួយឡើយ....

ជាដំបូង គ្រិស្តបរិស័ទជាច្រើនមិនទាន់បានឃើញបទគម្ពីរនេះ ហើយអាចនឹងឈ្លោះប្រកែកនឹងអ្នកថាអ្នកខុសហើយ ប្រសិនបើអ្នកពោលថា នៅក្នុងព្រះគម្ពីរមានចែងនូវស្ថានភាពមួយចំនួនដែលព្រះយេស៊ូមិនអាចព្យាបាលបាន។ ប៉ុន្តែអ្នកឃើញទេ ទ្រង់មិនអាចធ្វើបានទេ។ នៅពេលដែលអ្នកមានការយល់ដឹងថា ព្រះរាជ្យនៃព្រះត្រូវបានគ្រប់គ្រងដោយច្បាប់បញ្ញត្តិ នោះអ្នកក៏ចាប់ផ្តើមក្រឡេកមើលយ៉ាងស៊ីជម្រៅចំពោះសាច់រឿងនេះ។ ការយល់ដឹងតាមលក្ខណៈស្តង់ដាសម្រាប់គ្រិស្តបរិស័ទភាគច្រើនអាចជាការដែលថា ព្រះយេស៊ូសម្រេចព្រះហឫទ័យមិនព្យាបាលពួកគេ។ ប្រសិនបើលោកអ្នកមិនមានការយល់ដឹងអំពីភាពស្របច្បាប់នៃព្រះរាជ្យព្រះ នោះការពោលបែបនេះស្តាប់ទៅជាទំនងម្យ៉ាងដែរ។ ការដឹងថាព្រះយេស៊ូមានព្រះចេស្តាប្រោសឱ្យជា តែបែរជាមិនបានប្រោសពួកគេឱ្យជា ដោយការដឹងនេះមិនមានការឈ្វេងយល់អំពីយុត្តាធិការ (ប្រព័ន្ធគ្រប់គ្រងអនុវត្តច្បាប់) ផ្នែកច្បាប់ នោះ

អ្នកច្បាស់ជានឹងមានការសន្និដ្ឋានដោយងាយថា ទ្រង់សម្រេចព្រះហឫទ័យមិនប្រោសឱ្យជា។ តើអាចមានហេតុផលអ្វីផ្សេងទៀតទេ?

អ្នកប្រហែលជាធ្លាប់បានឮនរណាម្នាក់ពោលថា «ព្រះជាម្ចាស់អនុញ្ញាតឱ្យការនេះកើតឡើង» ឬ «ព្រះជាម្ចាស់ជ្រាបយ៉ាងច្បាស់បំផុត» ឬ «ព្រះជាម្ចាស់គ្រប់គ្រងលើអ្វីៗគ្រប់យ៉ាង» ឬ ពាក្យពោលបែបនេះនៅពេលដែលនរណាម្នាក់កំពុងលើកឡើងពីបញ្ហា ឬភាពលំបាកអ្វីមួយ មិនថាពួកគេ ឬមិត្តភក្តិកំពុងឆ្លងកាត់។ សម្រាប់គ្រិស្តបរិស័ទទូទៅ នេះជាចំណុចដែលពួកគេឈប់។ ពួកគេត្រឹមតែបានសន្និដ្ឋានដោយមិនបានដឹងពីច្បាប់បញ្ញត្តិនៃព្រះរាជ្យនៃព្រះ និងអ្វីដែលបានរាំងស្ទះដល់ព្រះយេស៊ូ ដោយថាវាប្រាកដជាមិនមែនជាព្រះបំណងរបស់ព្រះក្នុងការព្យាបាលពួកគេទេ។ បងប្អូនអើយ ព្រះគម្ពីរមិនបានចែងថា ទ្រង់សម្រេចព្រះហឫទ័យមិនព្យាបាលឯណា។ ព្រះគម្ពីរចែងថា ទ្រង់មិនអាចព្យាបាលពួកគេដោយសារតែពួកគេខ្វះជំនឿ។ នៅពេលដែលអ្នកដឹងថាការរាំងស្ទះក្នុងការព្យាបាលនៅក្នុងសាច់រឿងនេះមិនមែនជាកង្វះនៃព្រះហឫទ័យព្យាបាលរបស់ព្រះក្នុងការធ្វើកិច្ចការនេះ តែវាជាច្បាប់បញ្ញត្តិផ្នែកព្រលឹងវិញ្ញាណនៃយុត្តាធិការដែលបញ្ឈប់អំណាចរបស់ព្រះជាម្ចាស់។

នៅក្នុងសាច់រឿងផ្សេងៗទៀត អ្នកនឹងបានដឹងថា មាននូវមូលហេតុស្របច្បាប់ដែលអំណាចរបស់ព្រះជាម្ចាស់មានយុត្តាធិការក្នុងការនាំយកនូវបំណងព្រះហឫទ័យ និងព្រះទ័យរបស់ទ្រង់ចូលក្នុងស្ថានភាពនោះឬអត់ គឺដូចទៅនឹងសាច់រឿងមួយនេះដែរ។ ដូចនេះ វាជារឿងបន្ទាន់ខ្លាំងមួយ ដែលអ្នករកឃើញពីរបៀបដែលច្បាប់បញ្ញត្តិនៃព្រះរាជ្យនៃព្រះដំណើរការ។ នៅថ្ងៃណាមួយ នៅពេលអ្នកអាចត្រូវការការប៉ះពាល់ពីស្ថានសួគ៌ នោះអ្នកមិនចង់ឱ្យអំណាចស្ថានសួគ៌មានលក្ខណៈស្ទើរដើមស្ទើរចុងទេ តែបែជាចង់បាននូវសេរីភាពដើម្បីបង្កើតនូវបំណងព្រះហឫទ័យរបស់ព្រះនៅក្នុងជីវិតរបស់អ្នកវិញ។ នេះហើយទើបជាមូលហេតុពិតប្រាកដដែលខ្ញុំបានតាក់តែងសៀវភៅនេះឡើង។

ដើម្បីចាប់ផ្តើមដំណើររបស់អ្នក ខ្ញុំសូមផ្តល់ជាអនុសាសន៍ថាអ្នកគួរចាប់ផ្តើមជាមួយគំនិតស្អាតជ្រះស្រឡះសិន និងទទួលស្គាល់ថាអ្នកត្រូវបោះចោលចម្លើយចាស់ៗអំពីសាសនាដែលអ្នកបានឮពេញមួយជីវិតរបស់អ្នក ទាក់ទងនឹងមូលហេតុដែលព្រះជាម្ចាស់ធ្វើ ឬមិនធ្វើកិច្ចការអ្វីមួយ។ ខ្ញុំសង្ឃឹមថា ពេលនេះអ្នកបានដឹងថាខ្លួនឯងត្រូវបដិសេធចំពោះសេចក្តីពន្យល់ទូទៅដែលគេតែងលើកឡើងនៅពេលនិយាយពីមូលហេតុដែលក្មេងប្រុសចននីបានស្លាប់នៅអាយុក្មេងខ្ចី៖

«ព្រះជាម្ចាស់ទ្រង់ជ្រាបសព្វការទាំងអស់ ព្រះអង្គគ្រប់គ្រងលើអ្វីៗទាំងអស់» ។ល។ ទេ អ្នកត្រូវ**ដឹង**ពីមូលហេតុដែលព្រះយេស៊ូមិនអាចព្យាបាល និងដឹងពីច្បាប់បញ្ញត្តិដែលបានគ្រប់គ្រងលើលំហូរនៃព្រះចេស្ដារបស់ព្រះជាម្ចាស់នៅក្នុងពិភពផែនដីនេះ។ អ្នកត្រូវដឹងពីចម្លើយសម្រាប់សំណួរដែលចោទសួរថា «ហេតុអ្វីបានជាព្រះយេស៊ូមិនអាចព្យាបាលគេបាន?» សម្រាប់មនុស្សភាគច្រើន ការពិតដែលខ្ញុំថែមទាំងបានពោលថាមាននូវចម្លើយចំពោះសំណួរនោះ បានបណ្ដាលឱ្យមនុស្សមានភាពអាន់អន់ចិត្ត។ ខ្ញុំគ្រាន់តែកំពុងប្រាប់លោកអ្នកពីអ្វីដែលព្រះគម្ពីរបានចែងតែប៉ុណ្ណោះ ហើយខ្ញុំសូមបញ្ជាក់ប្រាប់ជាថ្មីថា អ្នក**ត្រូវតែ**ដឹងពីចម្លើយនៃសំណួរនោះ។

**សេចក្ដីសន្យារបស់ទ្រង់បានផ្ដល់ឱ្យពួកយើងនូវការសន្យាអំពីការព្យាបាល ការស្ដារឡើងវិញ ការចម្រុងចម្រើនផ្នែកហិរញ្ញវត្ថុ និងសេចក្ដីសន្យាជាច្រើនទៀត - មិនមែនគ្រាន់តែមានសមត្ថភាពក្នុងការរងទុក្ខឆ្លងកាត់ភាពលំបាក ឬគ្រោះមហន្ដរាយនោះទេ។**

ចម្លើយដ៏សាមញ្ញ និងខ្លីដែលធ្វើការពន្យល់ពីមូលហេតុដែលព្រះយេស៊ូមិនអាចព្យាបាលនៅក្នុងសាច់រឿងនោះគឺថា ស្ថានសួគ៌មិនមាននូវយុត្តាធិការស្របច្បាប់ដើម្បីធ្វើវាទេ។ យុត្តាធិការនោះគឺទទួលបានដោយជំនឿមនុស្សប្រុសស្រីនៅលើពិភពផែនដី ដែលមានការញ៉ាំងឱ្យស្ថានសួគ៌ស្ដែងវាឡើង។ ទោះបីជាពួកយើងទាំងពីរឯកភាពថាព្រះយេស៊ូមានព្រះចេស្ដា និងមានព្រះទ័យចង់ព្យាបាលមនុស្សនោះក្ដី ក៏ទ្រង់មិនអាចធ្វើដែរ។ ព្រះយេស៊ូមានព្រះបន្ទូលដោយផ្ទាល់ថាការបរាជ័យក្នុងការព្យាបាលគឺមិនមែនដោយសារភាពខ្សោយរបស់ទ្រង់ទេ តែវាគឺដោយសារតែមនុស្សមិនមានជំនឿ។ ចូរកត់ចំណាំចំណុចនេះទុកចុះ! ចំណុចនេះជាគន្លឹះ! ជំនឿ!

នៅក្នុងសៀវភៅដែលបោះពុម្ពលើកមុនរបស់ខ្ញុំ ខ្ញុំបានចំណាយពេលយ៉ាងច្រើនធ្វើការពន្យល់ពីរបៀបដែលវាដំណើរការ ពីមូលហេតុដែលយើងត្រូវការជំនឿ និងរបៀបដែលយើងដឹងថាតើយើងកំពុងស្ថិតនៅក្នុងជំនឿដែរឬទេ។ វាជាការនិយាយមើលស្រាលដែលនិយាយថាការយល់ដឹងរបស់អ្នកអំពីច្បាប់បញ្ញត្តិគ្រឹះនៃព្រះរាជ្យនៃព្រះគឺមានសារៈសំខាន់ណាស់។ វាជារឿងស្លាប់រស់!

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

ថ្មីៗនេះខ្ញុំបានទទួលនូវសារព័ត៌មានអំពីព័ន្ធកិច្ចគ្រិស្តបរិស័ទដ៏ល្បីមួយ។ ខ្លឹមសារព័ត៌មាននេះនិយាយអំពីអ្វីដែលគ្រិស្តបរិស័ទភាគច្រើនជឿ ពិតជាគួរឱ្យសោកស្ដាយណាស់។ ខ្ញុំសូមអនុញ្ញាតចែករំលែកខ្លះៗ។

វាបានចាប់ផ្ដើមជាមួយនឹងបន្ទូលដែលមានចែងក្នុងគម្ពីរ **ទុតិយកថា ៣១៖៦** ៖

*ចូរមានកម្លាំង និងចិត្តក្លាហានឡើង! កុំភ័យខ្លាច ឬតក់ស្លុតនៅចំពោះមុខពួកគេឱ្យសោះ ដ្បិតព្រះអម្ចាស់ផ្ទាល់ ជាព្រះរបស់អ្នក នឹងយាងទៅជាមួយអ្នក។ ព្រះអង្គមិនបោះបង់ចោលអ្នកជាដាច់ខាត!*

បន្ទាប់មកការសែតព័ត៌មាននេះក៏បន្តសរសេរថា...

«ហេតុអ្វីបានជាព្រះជាម្ចាស់មិនបញ្ឈប់ភេរវកម្ម និងការរងទុក្ខនានា? ហេតុអ្វីបានជាទ្រង់បណ្ដោយឱ្យមនុស្សស្លាប់? សំណួរនានានេះក៏កើតមានជាហូរហែរ ហើយសេចក្ដីពិតគឺថា យើងពិតជាមិនដឹងពីចម្លើយទាំងអស់ឡើយ។ យើងមិនដឹងពីមូលហេតុដែលព្រះជាម្ចាស់បណ្ដោយឱ្យមានរឿងមួយចំនួនកើតឡើងឡើយ។ អ្វីដែលយើងដឹងនោះគឺថា សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់គឺឥតខ្ចោះ។ របៀបរបស់ទ្រង់ខ្ពស់ឧត្តមជាងរបៀបរបស់យើង។ យើងត្រូវតែទុកចិត្តលើសេចក្ដីសន្យារបស់ព្រះអង្គដែលបានប្រាប់យើងថា មិនមែនព្រះអង្គនឹងមិនប្រទានអ្វីកើតឡើងដែលហួសពីការដែលយើងអាចទ្រាំទ្របាននោះទេ ប៉ុន្តែអ្វីៗដែលព្រះអង្គប្រទានមកយើងហើយ នោះទ្រង់នឹងគង់នៅជាមួយយើងគ្រប់ជំហាននៃមាគ៌ានោះ។»

ខុសហើយ ខុសហើយ ខុសហើយ! តាមការពិត ព្រះគម្ពីរបានប្រាប់យើងពីអ្វីដែលខុសគ្នាស្រឡះ។

*គ្មានការល្បួងណាមួយកើតមានដល់បងប្អូន ក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ ព្រះអង្គមិនបណ្ដោយឱ្យមារល្បួងបងប្អូនហួសពីកម្លាំងបងប្អូនទេ ប៉ុន្តែនៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយឱ្យបងប្អូនចេញរួច និងឱ្យបងប្អូនអាចទ្រាំទ្របាន។*

១កូរិនថូស ១០៖១៣ (គខប)

សេចក្តីសន្យារបស់ទ្រង់បានផ្តល់ឱ្យយើងនូវការសន្យាអំពីការព្យាបាល ការស្តារឡើងវិញ ការចម្រុងចម្រើនផ្នែកហិរញ្ញវត្ថុ និងសេចក្តីសន្យាជាច្រើនទៀត - មិនមែនគ្រាន់តែមានសមត្ថភាពក្នុងការរងទុក្ខឆ្លងកាត់ភាពលំបាក ឬគ្រោះមហន្តរាយនោះទេ។ សេចក្តីស្រលាញ់ដែលឥតខ្ចោះផ្តល់នូវដំណោះស្រាយ។ ខ្ញុំអាចបន្តទៅមុខបាន ប៉ុន្តែគួរឱ្យស្តាយនេះជាអ្វីដែលមនុស្សមួយភាគធំជឿអំពីព្រះជាម្ចាស់។ របៀបដែលនរណាម្នាក់ថែមទាំងគិតថាព្រះជាម្ចាស់ (ដែលទ្រង់មានសេចក្តីស្រលាញ់ល្អឥតខ្ចោះ) នឹងប្រទាននូវជំងឺមហារីកដល់មនុស្សម្នាក់ដើម្បីព្យាបាលពួកគេនៅពេលទ្រង់មានព្រះចេស្តាធ្វើវានោះ គឺលើសពីអ្វីដែលខ្ញុំគិតដល់ទៅទៀត។ ពេលសាកសួរអំពីចំណុចនេះ ជាថ្មីម្តងទៀត នោះចម្លើយឆ្លើយតបជាធម្មតារបស់គេនោះគឺ របៀបរបស់ទ្រង់មិនដូចរបៀបយើងយើង។ តើអ្នកកំពុងនិយាយលេងសើចមែនទេ? ពួកយើងមិនមានសេចក្តីស្រលាញ់ដែលឥតខ្ចោះទេ ហើយយើងក៏នឹងមិនធ្វើបែបនេះដាក់កូនៗរបស់យើងដែរ! ផ្ទុយមកវិញ ព្រះអង្គរៀបចំផ្លូវរបស់ទ្រង់យ៉ាងមានរបៀបសាមញ្ញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។

កាសែតព័ត៌មាននោះបានបញ្ជាក់ថាអ្វីៗដែលទ្រង់ប្រទានមកយើង នោះទ្រង់នឹងគង់នៅជាមួយគ្រប់ជំហាននៃផ្លូវនោះ នៅពេលដែលយើងរងទុក្ខលំបាកឆ្លងកាត់វា។ តើព្រះជាម្ចាស់នឹងប្រទានអ្វីដែលអាក្រក់ដល់ពួកយើងឬ? ទេ។ នៅពេលព្រះគម្ពីរប្រាប់យើងថាទ្រង់គង់ជាមួយយើង និងមិនដែលចាកចេញពីយើង នោះវាមានន័យថា ព្រះជាម្ចាស់គង់នៅជាមួយយើងដើម្បីស្តារសេចក្តីសន្យារបស់ទ្រង់! បងប្អូនអើយ គោលលទ្ធិនេះដែលថាព្រះជាម្ចាស់ជាសត្រូវរបស់យើងនោះគឺមិនមែនជាសេចក្តីមកពីព្រះជាម្ចាស់ទេ។ គោលលទ្ធិនេះមិនតំណាងឱ្យព្រះដែលខ្ញុំបម្រើទេ ហើយខ្ញុំសង្ឃឹមថាអ្នកនឹងមិនស៊ូទ្រាំនៅជាមួយវាដែរ។ ប្រសិនបើក្រុមជំនុំអ្នកបង្រៀនពីសេចក្តីមិនល្អនេះ អ្នកគួរតែចាកចេញពីទីនោះទៅ!

ព្រះជាម្ចាស់ជាសេចក្តីស្រលាញ់ ហើយព្រះបន្ទូលរបស់ទ្រង់ចែងថា សេចក្តីស្រលាញ់មិនដែលធ្លាក់ចុះឡើយ។ យ៉ាងណាក្តី អ្វីដែលធ្លាក់ចុះនោះគឺយុត្តិការរបស់ព្រះជាម្ចាស់ សមត្ថភាពរបស់ទ្រង់ក្នុងការជ្រៀតជ្រែកនៅក្នុងពិភពផែនដី ដែលបង្កើតឡើងដោយជំនឿរបស់យើង។ ជាថ្មីម្តងទៀត នេះជារឿងផ្លូវច្បាប់ មិនមែនជារឿងគួរឱ្យព្រឺសម្បុរ ជារឿងនៃការមានអារម្មណ៍លើអ្វីមួយ ឬអ្វីផ្សេងនោះទេ។ វាគ្រាន់តែជារឿងផ្លូវច្បាប់ដែលអ្នកត្រូវដឹង។ ដោយសារមនុស្សមាននូវយុត្តាធិការនៅក្នុងពិភពផែនដី នោះព្រះជាម្ចាស់មិនអាចគ្រាន់តែធ្វើអ្វីដែលទ្រង់សព្វព្រះទ័យចង់បាននោះទេ គឺដូចខ្ញុំបានចែកចាយរួចមកហើយអី

ចឹង។ ការឯកភាពរបស់អ្នកជាមួយស្ថានសួគ៌ ជំនឿរបស់អ្នក ចាំបាច់ត្រូវផ្តល់ឱ្យយុត្តាធិការស្ថានសួគ៌ដើម្បីនាំយកនូវព្រះចេស្តារបស់ព្រះជាម្ចាស់ចូលទៅក្នុងស្ថានភាព និងបង្កើតនូវសេចក្តីសុចរិត។ បងប្អូនអើយ អ្នក**<u>ត្រូវតែ</u>**ដឹងថាជំនឿជាអ្វី និងមូលហេតុដែលចាំបាច់ត្រូវមានជំនឿដើម្បីទទួលបានពីព្រះជាម្ចាស់។

ខ្ញុំសូមបង្ហាញត្រួសៗអំពីជំនឿជាអ្វី ក្រែងលោលោកអ្នកមិនទាន់បានអានសៀវភៅមុនរបស់ខ្ញុំ *(បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃភក្តីភាព)*។ ទោះបីជាអ្នកអាចសន្និដ្ឋានថា គ្រិស្តបរិស័ទស្ទើរគ្រប់គ្នាកំពុងប្រើពាក្យជំនឿ អាចដឹងថាជំនឿនេះជាអ្វីក៏ដោយ នោះក៏ការយល់ឃើញនេះអាចនឹងខុសផងដែរ។ យើងត្រូវតែរៀនមេរៀនប្រវត្តិសាស្រ្តខ្លះៗ ដើម្បីអាចស្វែងយល់ពីទស្សនៈព្រះរាជ្យនៃព្រះយ៉ាងសំខាន់ដែលទាក់ទងទៅនឹងយុត្តាធិការស្របច្បាប់។

ចូរយើងក្រឡេកមើលគម្ពីរ **រ៉ូម ៤៖១៨-២១៖**

> *ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏លោកអប្រាហាំនៅតែមានសង្ឃឹម និងមានជំនឿ ហើយលោកក៏បានទៅជាឪពុករបស់ជាតិសាសន៍ជាច្រើន ស្របតាមព្រះបន្ទូលដែលមានថ្លែងទុកមកថា «ពូជពង្សរបស់អ្នកនឹងមានច្រើនយ៉ាងនេះ»។ កាលណោះ លោកមានអាយុជិតមួយរយឆ្នាំហើយ ទោះបីលោកមើលមករូបកាយរបស់លោកឃើញថាជិតស្លាប់ និងមើលទៅលោកយាយសារ៉ាឃើញថាពុំអាចបង្កើតកូនបានសោះនោះក៏ដោយ ក៏ជំនឿរបស់លោកមិនអន់ថយដែរ។ លោកមិនបាត់ជំនឿ ហើយក៏មិនសង្ស័យនឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ឡើយ ផ្ទុយទៅវិញ ជំនឿរបស់លោកធ្វើឱ្យលោកមានកម្លាំងចិត្ត និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ព្រោះលោកជឿប្រាកដក្នុងចិត្តថា បើព្រះជាម្ចាស់សន្យាធ្វើអ្វី ព្រះអង្គពិតជាមានឫទ្ធានុភាពនឹងសម្រេចតាមបានមិនខាន។*

អប្រាហាំត្រូវបានទទួលស្គាល់ថាជាបិតានៃជំនឿ។ លោកជឿជាក់ទាំងស្រុងថា ព្រះជាម្ចាស់មាននូវព្រះចេស្តាដើម្បីធ្វើអ្វីដែលទ្រង់បានសន្យា។ ការដែលជឿជាក់ទាំងស្រុងដោយមានការឯកភាពជាមួយព្រះជាម្ចាស់នោះហៅថាជំនឿ។ ដោយគ្មានការឯកភាពនោះទេ ព្រះជាម្ចាស់មិនអាចប៉ះពាល់នៅក្នុងពិភពផែនដីនេះឡើយ។ ដូចនេះអ្នកអាចនឹងចោទសួរថា «ហេតុអ្វីបានជាព្រះជាម្ចាស់ត្រូវការនរណាម្នាក់ឱ្យធ្វើអ្វីមួយដែលនឹងអនុញ្ញាតឱ្យ

ទ្រង់ធ្វើអ្វីមួយ ឬរារាំងទ្រង់ពីការធ្វើអ្វីដែលទ្រង់ជ្រើសរើសធ្វើវា? ព្រះអង្គជាព្រះ។» ដើម្បីឆ្លើយសំណួរនោះ យើងចាំបាច់ក្រឡេកមើលទៅគ្រាដំបូងបង្អស់ គឺនៅក្នុងសម័យអដាំវិញ។

> *«ព្រះអង្គបានធ្វើឱ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឱ្យនៅក្រោមជើងរបស់គេ»។ ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ <u>ឥតទុកឱ្យមានអ្វីមួយនៅសល់ ដែលពុំបានចុះចូលនោះឡើយ</u>។ ប៉ុន្តែ នៅពេលនេះ យើងពុំឃើញថា អ្វីៗសព្វសារពើសុទ្ធតែបានចុះចូលនឹងអំណាចរបស់មនុស្សហើយនោះទេ។*
>
> *ហេប្រឺ ២៖៧-៨*

អត្ថបទគម្ពីរនេះគឺសំដៅលើអដាំ និងអេវ៉ានៅពេលបង្កើតផែនដីឡើង។ សូមចាំថា គ្មានអ្វីដែលនៅលើផែនដីនេះដែលមិនស្ថិតក្រោមយុត្តាធិការស្របច្បាប់របស់ពួកគេឡើយ។ អដាំត្រូវបានប្រទានឱ្យមានជីវិតលើផែនដីនេះ ដើម្បីត្រួតត្រាលើផែនដីដោយទទួលបានការចាត់តាំងសិទ្ធិអំណាចដែលតំណាងឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។ លោកបានត្រួតត្រាលើផែនដីទាំងមូល។

> *ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងបង្កើតមនុស្ស ជាតំណាងរបស់យើង មានលក្ខណៈដូចយើង ដើម្បីឱ្យគេ<u>មានអំណាចលើ</u>ត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ លើសត្វស្រុកនៅលើផែនដីទាំងមូល និងលើសត្វទាំងប៉ុន្មានដែលលូនវារនៅលើដី»។*
>
> លោកុប្បត្តិ ១៖២៦

ជាថ្មីម្តងទៀត យើងឃើញថាអដាំត្រួតត្រាផែនដីដោយសិទ្ធិអំណាចដែលត្រូវបានចាត់តាំង និងបំពាក់សិរីរុងរឿង (ការចាក់ប្រេងតាំង ឬឫទ្ធានុភាព) និងកិត្តិយស (តួនាទីនៃសិទ្ធិអំណាច)។ គ្មានអ្វីដែលមិនស្ថិតនៅក្រោមដែនត្រួតត្រារបស់លោកឡើយ។ តាមការពិតប្រសិនបើអ្នកអានអំពីអ្វីដែលទាក់ទងនឹងការបង្កើតផែនដី អដាំបានដាក់ឈ្មោះឱ្យសត្វ ដ្បិតគាត់ត្រួតត្រាលើតពផែនដីទាំងមូល។ ដូចដែលយើងទាំងអស់គ្នាបានដឹង អដាំបានបាត់បង់នូវសិទ្ធិអំណាចរបស់ខ្លួនលើសាតាំង ដែលសាតាំងនេះបានបញ្ឆោតអេវ៉ា និងបានល្បួងអដាំឱ្យក្បត់នឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលគាត់ពិតជាធ្វើតាមមែន។ លោកប៉ូលបាន

កត់ត្រានៅក្នុងគម្ពីរ ២កូរិនថូស ៤៖៤ ថា តាមរយៈការក្បត់របស់អដាំ សាតាំងបានក្លាយជាព្រះនៃលោកិយនេះ។ វិញ្ញាណរបស់មនុស្សដែលត្រូវបានបង្កើតមកឱ្យដើររួមនឹងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ពេលនេះបែជាត្រូវបានញែកចេញពីទ្រង់ទៅវិញ។ មនុស្សក៏បានចាប់ផ្ដើមដើរតាមការយល់ឃើញ តាមគំនិត បំណង និងអារម្មណ៍របស់ខ្លួន។

> *មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញនគរទាំងប៉ុន្មាននៅលើផែនដីឱ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឱ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឱ្យអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*
>
> លូកា ៤៖៥-៧

អ្នកនឹងកត់សម្គាល់ឃើញថាសាតាំងនិយាយថា ឋានៈដែលវាកាន់កាប់ពិភពផែនដីនេះ «**ត្រូវបានប្រគល់ឱ្យ**» វា។ ប្រាកដណាស់ យើងដឹងថា ម្នាក់ដែលបានប្រគល់ឱ្យវានោះ គឺជាអ្នកដែលជាម្ចាស់លើវាដោយស្របច្បាប់តាំងពីដើមទៀយម្ល៉េះ នោះគឺអដាំ។ ចំណុចនេះសំខាន់ណាស់។ ការពិត ប្រសិនបើសាតាំងបានព្យាយាមជ្រៀតចូលក្នុងពិភពផែនដីនេះដោយខុសច្បាប់ នោះវាប្រាកដជាត្រូវបានបោះទម្លាក់ភ្លាមៗ និងដោយបង្ខំផង។ អ្នកអាចនឹងមានគំនិតល្អយល់ពីមូលហេតុដែលខ្ញុំកំពុងនិយាយថាសាតាំងនឹងត្រូវបានបណ្ដេញទាំងបង្ខំ ប្រសិនបើអ្នកគិតដល់រឿងមន្ត្រីប៉ូលីសកំពុងហៅរកជំនួយ។ ស័ក្កិដែលមន្ត្រីនោះពាក់បានបញ្ជាក់ថា កម្លាំងនិងអំណាចទាំងអស់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកត្រៀមខ្លួននៅចាំជួយតាមពាក្យស្នើរបស់គាត់ជានិច្ច។

មកុដដែលអដាំពាក់ (តួនាទីដែលគាត់កាន់កាប់) ដែលកំពុងត្រួតត្រាដោយជំនួសឱ្យការគ្រប់គ្រងរបស់ព្រះជាម្ចាស់ បាននាំនូវអំណាចទាំងអស់របស់ព្រះជាម្ចាស់ឱ្យជួយដល់លោក។ ដោយសារតែតួនាទីរបស់អដាំនៅលើផែនដី នោះសាតាំងគ្មានយុត្តាធិការអ្វីនៅលើពិភពផែនដីនេះឡើយ។ វាត្រូវបានអដាំ និងអេវ៉ាត្រួតត្រា។ ភាពស្របច្បាប់តែមួយដែលសាតាំងគឺមានន័យថា ដើម្បីទទួលបាននូវយុត្តាធិការនៅលើពិភពផែនដីនេះគឺតម្រូវឱ្យអដាំដោះមកុដរបស់គេចេញ ដែលសាតាំងគ្មានសិទ្ធិអំណាចបង្ខំគាត់ឱ្យធ្វើនោះទេ។ សាតាំងដឹងថា មនុស្សតែម្នាក់ដែលអាចដោះមកុដនោះចេញពីក្បាលអដាំបាននោះគឺមានតែអដាំខ្លួន

ឯងហ្នឹងហើយ។ ហេតុដូចនេះទើបសាតាំងចាំបាច់ប្រើផែនការបោកបញ្ឆោតរបស់វាឡើង។ តើការបោកបញ្ឆោតនោះជាអ្វី? សាតាំងបានអះអាងថា ព្រះជាម្ចាស់មិនគួរឱ្យជឿទុកចិត្តនោះទេ ហើយក៏មិនបានយកចិត្តទុកដាក់ពួកគេខ្លាំងអស់ពីព្រះហឫទ័យដែរ។ វាក៏បានបញ្ចុះបញ្ចូលអេវ៉ាថា ការមិនស្ដាប់បង្គាប់ព្រះជាម្ចាស់នឹងមាននូវគុណប្រយោជន៍ ហើយច្បាប់បញ្ញត្តិទាំងនេះរបស់ព្រះជាម្ចាស់គឺដើម្បីរារាំងមិនឱ្យអដាំ និងអេវ៉ាទទួលបានអ្វីដែលមានប្រយោជន៍ឡើយ។

**សាតាំងត្រូវតែធ្វើឱ្យអដាំ និងអេវ៉ាជឿជាក់ ឬធ្វើឱ្យពួកគេអាស្រ័យតាមវា ជាជាងធ្វើតាមព្រះជាម្ចាស់។**

នៅក្នុងពាក្យគន្លឹះ នេះគឺជាជំនឿ។ ជំនឿអាចត្រូវបានឱ្យនិយមន័យថាជាការ «ត្រូវបានបញ្ចុះបញ្ចូលទាំងស្រុង» នៃអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល។ អដាំ និងអេវ៉ាបានបោះបង់ចោលនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលអាចទុកចិត្តបាន ហើយបានមកយល់ស្របនឹងអ្វីដែលសាតាំងនិយាយទៅវិញ។ បន្ទាប់មកពួកគេប្រព្រឹត្តតាមការយល់ឃើញរបស់ខ្លួន ដែលបានបដិសេធនូវជំហរនៃសិទ្ធិរបស់ខ្លួននៅក្នុងព្រះរាជ្យរបស់ព្រះ និងបានផ្ដល់នូវទីជំហរដល់សាតាំងក្នុងការប្រព្រឹត្តលើមនុស្ស។ ចុះលទ្ធផលវិញទៅជាយ៉ាងណាដែរ? អដាំដែលមានសិទ្ធិអំណាចលើពិភពផែនដី បានបណ្ដេញព្រះជាម្ចាស់ចេញដោយវិញ្ញាណ នៅពេលដែលគាត់បានសម្រុបខ្លួនជាមួយសាតាំង! ដោយការធ្វើបែបនេះ គាត់បណ្ដេញព្រះជាម្ចាស់ចេញពីជីវិតរបស់ខ្លួន។ មានមនុស្សជាច្រើនអាចពោលថា «ទេ វាមិនអាចកើតឡើងទេ អដាំមិនអាចបណ្ដេញព្រះជាម្ចាស់ចេញពីពិភពផែនដីនេះបានទេ!» ប៉ុន្តែនៅពេលដែលគិតដល់រឿងរ៉ាវអំពីមនុស្ស គាត់ប្រាកដជាបានធ្វើវា។ ខ្ញុំសូមពន្យល់ចំណុចនេះទៅកាន់លោកអ្នក។ សូមក្រឡេកមើលគម្ពីរលោកុប្បត្តិ ៣:១៧-១៩ ម្ដងទៀត។ ក្រោយពីអដាំបានប្រព្រឹត្តបាប នោះព្រះជាម្ចាស់បានទៅរកគាត់ ហើយមានព្រះបន្ទូលថា៖

> *នោះដីនឹងត្រូវបណ្ដាសាដោយសារអ្នក អ្នកនឹងរកស៊ីពីដីដោយនឿយហត់អស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញឱ្យអ្នក ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ អ្នកនឹងបានអាហារបរិភោគដោយការបែកញើសរហូតដល់អ្នកត្រឡប់ទៅជាដីវិញ។*

សូមកត់សម្គាល់មើលត្រង់ការចែងដែលថា *«នោះដីនឹងត្រូវបណ្ដាសា<u>ដោយសារអ្នក</u>»។* ការដែលត្រូវបណ្ដាសាមានន័យយ៉ាងសាមញ្ញថា មិនមាននូវព្រះវត្តមាន និងព្រះពរ

របស់ព្រះជាម្ចាស់។ គឺអដាំ ជាអ្នកដែលមាននូវសិទ្ធិអំណាចលើផែនដីនេះហើយដែលបាន កាត់ផ្តាច់នូវយុត្តាធិការស្របច្បាប់របស់ព្រះជាម្ចាស់នៅក្នុងពិភពផែនដី។ និយាយឱ្យស្រួល យល់ ព្រះជាម្ចាស់កំពុងមានបន្ទូលថា «នែ៎អដាំអើយ ដោយសារតែអ្នក ព្រះហស្តរបស់យើង ត្រូវបានជាប់ចំណងហើយ។ យើងមិនអាចជួយអ្នកបានទេ។» បន្ទាប់មកព្រះអង្គក៏មាន បន្ទូលប្រាប់អដាំថា ពេលនេះការរស់រានរបស់គាត់គឺស្រេចតែគាត់ហើយ គឺគាត់នឹងត្រូវធ្វើ ការយ៉ាងលំបាក និងឈឺចាប់។ ខ្ញុំហៅរឿងនេះថាជា «ប្រព័ន្ធបណ្តាសាផែនដី» នៃការរស់រាន។ នេះជាកន្លែងដែលយើងបានធំធាត់ឡើង គឺនៅក្នុងអាណាចក្រដែលមានភាពរស់រាន និងមានភាពភ័យខ្លាច។ យើងបានចេះបារម្ភ ហើយភាពភ័យខ្លាចបានគ្របដណ្តប់គំនិត របស់យើងតាំងពីពេលយើងបានកើតមកម្ល៉េះ។ ខ្ញុំចង់ងាកមកមើលខគម្ពីរនេះបន្តិចទៀត ដើម្បីពិភាក្សាអំពីប្រព័ន្ធបណ្តាសាផែនដីនេះឱ្យស៊ីជម្រៅជាងនេះ ប៉ុន្តែពេលនេះ ខ្ញុំចង់ ប្រាកដថាលោកអ្នកបានយល់ពីរបៀបដែលសាតាំងទទួលបានការចូលមកក្នុងពិភពផែនដី នេះ។ ជាថ្មីម្តងទៀត វាត្រូវស្វែងរកបុរស ឬស្ត្រីណាដែលនៅលើពិភពផែនដីនេះដែលមាននូវ ការប្រទានយុត្តាធិការស្របច្បាប់ពីព្រះជាម្ចាស់នៅក្នុងពិភពផែនដីនេះដើម្បីបើកទ្វារ សម្រាប់វា។ អដាំមាននូវកូនសោនោះ ហើយសាតាំងក៏អាចបោកបញ្ឆោតអដាំឱ្យធ្វើការបើក ទ្វារនោះ។ តោះ សូមយើងក្រឡេកមើលគម្ពីរហេប្រឺ ២៖៧-៨ ម្តងទៀត។

> *ព្រះអង្គបានធ្វើឱ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ។ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ។ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឱ្យនៅក្រោមជើងរបស់គេ។*
>
> *ហេប្រឺ ២៖៧-៨*

ចូរកត់សម្គាល់ថា បទគម្ពីរនេះបានថែងថា ព្រះជាម្ចាស់មិនបានបន្សល់ទុកអ្វីដែល មិនមែនជាកម្មសិទ្ធិគេឡើយ។ ទោះបីជាបទគម្ពីរនេះសំដៅលើព្រឹត្តិការណ៍ពីយូរលង់ណាស់ មកហើយក្តី ក៏វានៅតែប្រើពាក្យថា **ជា** ដែលប្រើប្រាស់នៅក្នុងវេយ្យាករណ៍បច្ចុប្បន្នកាល ដើម្បីពណ៌នាអំពីស្ថានភាពបច្ចុប្បន្នរបស់មនុស្សនៅលើផែនដី។ ទោះបីជាមនុស្សបាន បាត់បង់នូវសិទ្ធិអំណាចផ្នែកព្រលឹងវិញ្ញាណនៅលើពិភពផែនដីនេះតាមរយៈអំពើបាបរបស់ អដាំក្តី មនុស្សមិនបានបាត់បង់មុខរបរស្របច្បាប់នៅលើផែនដីឡើយ ហើយដោយសារតែ បន្ទាយស្របច្បាប់ផ្នែកព្រលឹងវិញ្ញាណរបស់សាតាំងមកលើមនុស្ស នោះព្រះជាម្ចាស់មិន

អាចឃាំងចូលមកក្នុងពិភពផែនដី និងបំពាននូវព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់ បើមិនដូច្នេះ ទេសាតាំងនឹងចោទប្រកាន់ទ្រង់បាន។

ព្រះជាម្ចាស់ត្រូវតែរកបុរស ឬស្ត្រីម្នាក់នៅក្នុងពិភពផែនដីនេះដែលនឹងឯកភាព ស្របតាមទ្រង់ ដែលបើកនូវទ្វារផ្នែកព្រលឹងវិញ្ញាណសម្រាប់ព្រះរាជ្យនៃព្រះដើម្បីឱ្យមាននូវ យុត្តាធិការស្របច្បាប់នៅលើផែនដី។ ព្រះជាម្ចាស់ក៏ត្រូវធ្វើការតាមរយៈបុរស និងស្ត្រី ជាអ្នក យាមច្រកទ្វារផែនដី ដើម្បីផ្តល់នូវយុត្តាធិការនៃព្រះរាជ្យនៃព្រះនៅទីនេះ គឺដូចការដែល សាតាំងបានធ្វើការតាមរយៈអដាំ ជាអ្នកយាមច្រកទ្វារផែនដីដែរ។ ការដែលដួងចិត្ត និង គំនិតរបស់អ្នកត្រូវបានបញ្ចុះបញ្ចូលទាំងស្រុងចំពោះអ្វីដែលស្ថានសួគ៌បានប្រាប់មក នោះ ហៅថាជាជំនឿ។ ជំនឿត្រូវតែមានវត្តមានសម្រាប់ព្រះរាជ្យនៃព្រះ ដើម្បីមាននូវយុត្តាធិការ នៅទីនេះ។ ខ្ញុំនឹងមិនយកពេលបន្ថែមពន្យល់អំពីរបៀបទទួលបានជំនឿ និងរបៀបដឹងថា ខ្លួនឯងកំពុងមានជំនឿនោះទេ។ ចំណុចទាំងអស់នេះមានសរសេរនៅក្នុងសៀវភៅដំបូង របស់ខ្ញុំដែលមានមេរៀនជាខ្សែ។ គោលបំណងនៃការពិភាក្សានេះ ខ្ញុំចង់ធ្វើឱ្យប្រាកដថាអ្នក បានដឹងថាអ្វីជាជំនឿ និងហេតុអ្វីបានជាចាំបាច់ត្រូវឱ្យស្ថានសួគ៌វិលមកលើពិភពផែនដី នេះ។

ឥឡូវ ខ្ញុំសង្ឃឹមថាអ្នកមានការយល់ដឹងកាន់តែច្រើនអំពីមូលហេតុដែលព្រះយេស៊ូ «មិនអាច» ធ្វើការអស្ចារ្យជាច្រើននៅក្នុងស្រុកកំណើតរបស់ទ្រង់ - គឺមនុស្សនៅទីនោះមិន មានជំនឿ។ ដូចនេះ ស្ថានសួគ៌មិនមានយុត្តាធិការស្របច្បាប់ឡើយ។ ខ្ញុំសូមបញ្ចប់ការ ពិភាក្សានេះដោយលើកនូវបទគម្ពីរដ៏អស្ចារ្យមួយដែលនឹងបើកសម្តែងពីអ្វីដែលខ្ញុំកំពុង និយាយ។

គ្រប់គ្នាធ្លាប់បានឮអំពីខគម្ពីររ៉ូម ១០៖១០ ហើយ៖

*ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿនោះ យើងនឹងទទួលការសង្គ្រោះ។*

អត្ថបទគម្ពីរនេះជាផ្នែកមួយដែលគ្រិស្តបរិស័ទបានហៅថា វិថីក្រុងរ៉ូម ជាផ្នែកមួយ នៃបទគម្ពីរទាំងបួនដែលបង្ហាញប្រាប់ពួកយើងពីរបៀបទទួលបានការសង្គ្រោះ។ ប៉ុន្តែ តើ អ្នកពិតជាបានចំណាយពេល និងជញ្ជឹងគិតអំពីដំណើរដែលគម្ពីររ៉ូម ១០៖១០ កំពុងបង្ហាញ មកកាន់អ្នកដែរឬទេ? អ្នកបានជឿវាដោយចេញពីចិត្ត ឬបានយល់ស្របនឹងស្ថានសួគ៌។ ដួង

ចិត្តរបស់អ្នកដែលកំពុងតែយល់ស្របនឹងស្ថានសួគ៌ បានធ្វើវាឱ្យស្ថានសួគ៌មានលក្ខណៈស្របច្បាប់ក្នុងការចូលមកផែនដី។ ខគម្ពីរនេះបានចែងថា នៅពេលដែលអ្នកជឿលើស្ថានសួគ៌ នោះអ្នកនឹងត្រូវបានប្រោសឱ្យសុចរិត។ យុត្តិធម៌គឺជារដ្ឋបាលនៃច្បាប់បញ្ញត្តិ។ ដូចនេះការជឿដោយចេញពីចិត្តបានផ្តល់ឱ្យអ្នកនូវសិទ្ធិស្របច្បាប់នៅចំពោះមុខស្ថានសួគ៌ និងផែនដី ដើម្បីមានអ្វីដែលស្ថានសួគ៌បានចែង ដ្បិតវាបានផ្តល់ឱ្យស្ថានសួគ៌នៅភាពស្របច្បាប់នៅក្នុងពិភពផែនដីនេះ។ ប៉ុន្តែសូមកត់សម្គាល់ថា មិនទាន់មានអ្វីកើតឡើងនៅឡើយទេ។ ខគម្ពីរនេះមាននូវផ្នែកទីពីរទៀតដែលចែងថា *«...ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ្រោះ។»* ឃើញទេ ទោះបីជាដួងចិត្តរបស់អ្នកយល់ស្របតាមស្ថានសួគ៌ក្តី ដែលការយល់ស្របដោយចិត្តនេះធ្វើឱ្យស្ថានសួគ៌មានលក្ខណៈស្របច្បាប់ក្នុងការចូលមកពិភពផែនដី នោះក៏គ្មានអ្វីកើតឡើងដែរ គឺរហូតដល់អ្នកដែលជាបុរស ឬស្ត្រីនៅក្នុងពិភពផែនដីនេះដែលមាននូវយុត្តាធិការលើពិភពផែនដី អាចបញ្ចេញការទាំងនេះចូលមកពិភពផែនដីនេះបាន។ តើហេតុអ្វីទៅ? គឺដោយសារអ្នកមាននូវយុត្តាធិការនៅទីនេះ គឺស្ថានសួគ៌មិនមានវាដោយគ្មានអ្នកឡើយ!

> *ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្វីៗទាំងអស់ដែលអ្នករាល់គ្នាចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នករាល់គ្នាស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយ នៅស្ថានបរមសុខដែរ។*
>
> ម៉ាថាយ ១៨៖១៨

និយាយរួម ខគម្ពីរនេះកំពុងប្រាប់ពីអ្វីដែលខ្ញុំទើបតែបាននិយាយ។ អ្វីដែលអ្នកបានចងនៅលើផែនដីនេះ នោះស្ថានសួគ៌នឹងធ្វើតាម ហើយអ្វីៗដែលអ្នកបានស្រាយនៅផែនដី នោះស្ថានសួគ៌នឹងជួយស្រាយផងដែរ។ ស្ថានសួគ៌មិនអាចធ្វើបានដោយគ្មានអ្នកឡើយ។ ស្ថានសួគ៌កំពុងរង់ចាំលោកអ្នក ហើយមិនអាចធ្វើអ្វីបានលើកលែងតែបុរសនិងស្ត្រីដែលមានជំនឿ ឬយល់ស្របតាមស្ថានសួគ៌ស្រាយបញ្ចេញនូវសិទ្ធិអំណាចមកលើពិភពផែនដីប៉ុណ្ណោះ។

ការយល់ដឹងពីរបៀបត្រូវស្រាយបញ្ចេញសិទ្ធិអំណាចស្ថានសួគ៌ និងឫទ្ធានុភាពចូលមកផែនដី អាចធ្វើឱ្យមានអ្វីកើតឡើងបាន។ វាបានកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំ ហើយវាក៏បានកើតឡើងនៅក្នុងអ៊ីម៉ែលដែលខ្ញុំបានទទួល។

«ជម្រាបសួរ! ប្ដីនាងខ្ញុំ និងខ្ញុំចង់ចែករំលែកអំពីសាច់រឿងដ៏អស្ចារ្យមួយអំពី «ការរកស៊ីដោយជំនឿ» ទៅកាន់លោកគ្រូ! នៅក្នុងឆ្នាំ ២០១១ ពួកយើងកំពុងរស់នៅក្នុង « ផ្ទះនៃក្ដីស្រមៃ» របស់ពួកយើង ប៉ុន្តែពួកយើងរស់នៅដោយរកប្រាក់បានរស់មួយថ្ងៃគិតមួយថ្ងៃប៉ុណ្ណោះ ហើយពេលនេះ ពួកយើងប្រើប្រាស់កាតក្រេឌីតដើម្បីបង់ថ្លៃគ្រឿងទេស និងឧបករណ៍ម៉ាស៊ីនកម្ដៅក្នុងផ្ទះ។ ពួកយើងបានតែមួយរស់ៗ តែមិនរីកចម្រើនមានបានជាងមុនសោះ។ ខ្ញុំគឺជាអ្នកដឹកនាំក្រុមថ្វាយបង្គំនៅក្នុងក្រុមជំនុំរបស់ពួកយើង ប៉ុន្តែជំនឿរបស់ពួកយើងមិនបានផ្សារភ្ជាប់ទៅនឹងផ្នែកហិរញ្ញវត្ថុរបស់ពួកយើងសោះ។ នាងខ្ញុំបានឃើញកម្មវិធីរបស់លោកដែលមានឈ្មោះថា *ការដោះស្រាយបញ្ហាផ្នែកហិរញ្ញវត្ថុ* នៅក្នុងកម្មវិធី Daystar ។ នាងខ្ញុំបានចាប់អារម្មណ៍នឹងកម្មវិធីនេះណាស់ ហើយក៏បានកម្មង់សៀវភៅ *ការដោះស្រាយបញ្ហាផ្នែកហិរញ្ញវត្ថុ* រួមជាមួយនឹងស៊ីឌីស្ដាប់សំឡេងសម្រាប់សៀវភៅ *បដិវត្តន៍ហិរញ្ញវត្ថុ ។* ពួកយើងបានស្ដាប់ស៊ីឌីនោះគ្រប់ពេល និងបានអានសៀវភៅឱ្យគ្នាស្ដាប់ទៅវិញទៅមក។

«ពួកយើងមិនដឹងថាខ្លួនមិនមានជំនឿសោះ! ពួកយើងដឹងថា ដើម្បីរក្សាផ្ទះក្នុងក្ដីស្រមៃនេះបាន យើងត្រូវការចម្លើយមួយចំនួនពីរបៀបដែលលុយបានជួយដល់ដំណើរការនៅក្នុងព្រះរាជ្យនៃព្រះ។ ពួកយើងបានសាបព្រោះគ្រាប់ពូជចំនួន ២០០ដុល្លារចូលទៅក្នុងព័ន្ធកិច្ចជំនឿជីវិត (ដែលនោះអាចនឹងស្មើចំនួន ២០០០ដុល្លារអីចឹង។ នោះជាចំនួនប្រាក់ដ៏ច្រើនណាស់សម្រាប់ពួកយើង!) ហើយក៏បានយល់ស្របជាមួយព្រះជាម្ចាស់ដោយសូមឱ្យទ្រង់បង្ហាញឱ្យមាននូវទីផ្សារពិសេសដែលខ្ញុំអាចធ្វើនៅផ្ទះបាន។

«ព្រះជាម្ចាស់បានប្រទានគំនិតរកស៊ីមួយដល់ខ្ញុំក្នុងការចិញ្ចឹមកូនឆ្កែប្រភេទ Goldendoodle នៅឯផ្ទះ។ ពួកយើងបានទិញកូនឆ្កែប្រភេទនេះពីរក្បាល ឈ្មោះ បេឡា និងហ្វ្រេស៊ី ដោយបានចិញ្ចឹមពួកវាឱ្យមានកូនៗបន្តទៀត ហើយពួកយើងក៏បានសហការជាមួយព្រះជាម្ចាស់។ ពួកយើងដឹងថាពួកយើងមិនអាចបង្កើតកូនឆ្កែបានទេ!! ពួកយើងបានបង្កាត់ពូជឆ្កែប្រភេទDoodle ពីរនេះ ហើយក្នុងឆ្នាំ២០១៤ ពួកយើងមានកូនឆ្កែចំនួន ១៣ក្បាលដែលបានលក់នៅឯផ្សារក្នុងតម្លៃ១,២០០ដុល្លារក្នុងមួយក្បាល។ ឆ្នាំ២០១៥នេះ ពួកយើងមានកូនឆ្កែចំនួន៦៣ក្បាល ដោយឆ្កែទាំងអស់សុទ្ធតែមានសុខភាពល្អ។ ដោយការលក់កូនឆ្កែ ពួកយើងក៏មានសេរីភាពពីបំណុលទាំងអស់ លើកលែងតែផ្ទះរបស់ពួកយើ

ង។ ពេលនេះ ពួកយើងក៏មាននូវប្រាក់បម្រុងគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាបន្ទាន់ផងដែរ។

«អ្វីដែលពួកយើងភ្ញាក់ផ្អើលនោះ គឺម្ដាយនាងខ្ញុំបានសួរពួកយើងដោយសុំឱ្យគាត់បានជួយចិញ្ចឹមឆ្កែប្រភេទ Goldendoodle នេះពីរក្បាលដើម្បីយកកូន ដ្បិតគាត់ត្រូវចូលនិវត្តន៍ពីការងារ! ហើយនៅខែកក្កដា ស្វាមីរបស់នាងខ្ញុំត្រូវបានតែងតាំងជាប្រធានគ្រប់គ្រងវិទ្យាល័យនៅឯតំបន់របស់ពួកយើង!! ក្នុងរយៈពេលមួយឆ្នាំ ចំណូលរបស់ពួកយើងបានកើតឡើងទ្វេដងដល់ចំណុចលេខ៦!! ការរកស៊ីដោយជំនឿពិតជាទៅរួចមែន!! ពួកយើងបានរើសយកបញ្ញត្តិនៃព្រះរាជ្យរបស់ព្រះ។ ពេលនេះ ពួកយើងបានសាបព្រោះលើគ្រប់កិច្ចការនៃព្រះរាជ្យទាំងអស់ និងបានចូលរួមថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យតាមកម្មវិធីអនឡាញរបស់លោកគ្រូ មុនពេលពួកយើងដឹកនាំថ្វាយបង្គំនៅក្រុមជំនុំនៅក្នុងតំបន់របស់ពួកយើង! នាងខ្ញុំសូមអរគុណលោកគ្រូដែលបានបង្រៀនពួកយើងពីរបៀបដែលព្រះរាជ្យនៃព្រះដំណើរការ!»

កាឡា (Karla)

នៅសប្ដាហ៍នេះ ប្ដីប្រពន្ធដដែលនេះក៏បានផ្ញើអ៊ីម៉ែលមកខ្ញុំម្ដងទៀត

«រីករាយថ្ងៃបុណ្យព្រះជន្មរស់! ទ្រង់រស់ឡើងវិញហើយ! ពួកយើងចង់ចែករំលែកនូវព័ត៌មានថ្មីដល់លោកគ្រូហ្គារីដែលជាលោកគ្រូបង្រៀនលើប្រព័ន្ធអនឡាញរបស់ពួកយើង ! សូមជួយឱ្យគាត់បានដឹងផងថា ឆ្នាំនេះពួកយើងបានរៀបចំពិធីថ្ងៃកំណើតព្រះយេស៊ូនៅក្រុងយេរ៉ូសាឡឹម (ពួកយើងបានទិញដោយប្រើលុយសុទ្ធ)។ ពួកយើងក៏មានពរណាស់ដែលមានកូនប្រុសវ័យជំទង់ម្នាក់គឺខាធ័រ (Carter) ដែលបានទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់ ហើយនិងបានថ្វាយបង្គំព្រះជាមួយក្រុមចម្រៀងអូស្ត្រាលី Hillsong នៅឯមាត់សមុទ្រកាលីឡេនៅពេលល្ងាច! ពិតជាអស្ចារ្យណាស់!!! ពិតជាអរព្រះគុណណាស់ដែលពួកយើងបានដោះស្រាយបញ្ហាលុយកាក់នេះ!

ពេលនេះពួកយើងមានកូនឆ្កែចំនួន១២១ក្បាលហើយ។ ពួកយើងបានតម្លើងថ្លៃកូនឆ្កែក្នុងតម្លៃ ២ ៣០០ដុល្លារ ដោយសារតែមានអ្នកចុះឈ្មោះចាំទិញច្រើនពេក! សូមសរសើរតម្កើងព្រះជាម្ចាស់។»

កាឡា (Karla)

នេះជាឧទាហរណ៍ដ៏តតខ្មោះមួយអំពីអ្វីដែលព្រះរាជ្យព្រះនឹងធ្វើនៅក្នុងជីវិតរបស់អ្នក។ សប្តាហ៍នេះ ខ្ញុំបានហៅទូរស័ព្ទទៅកាឡា (Karla) បន្ទាប់ពីទទួលបានសារអ៊ីមែលនេះ ហើយនាងមានចិត្តរំភើបជាខ្លាំង!!! នាងពោលថា ឆ្នាំនេះពួកគេបានបង់ថ្លៃផ្ទះរួចហើយ។ បើអ្នកក្រឡេកមើលអ៊ីម៉ែលដំបូងដែលនាងបានផ្ញើមក នាងរៀបរាប់នៅក្នុងគ្រានោះដូចខាងក្រោម (ដកស្រង់ចេញពីសារអ៊ីម៉ែលខាងលើ)៖

«ពួកយើងរស់នៅដោយរកប្រាក់បានរស់មួយថ្ងៃគិតមួយថ្ងៃប៉ុណ្ណោះ ហើយពេលនេះ ពួកយើងប្រើប្រាស់នូវកាតក្រេឌីតដើម្បីបង់ថ្លៃគ្រឿងទេស និងឧបករណ៍ម៉ាស៊ីនកម្តៅក្នុងផ្ទះ។ ពួកយើងបានតែមួយរស់ៗ តែមិនរីកមានបានជាងមុនសោះ។»

ពេលនេះ ទើបតែពីរឆ្នាំកន្លងផុតសោះ ពួកគេបានបង់ថ្លៃរួចរាល់ទៅហើយឬ? នោះគឺព្រះរាជ្យនៃព្រះ!

# ជំពូក ៣
# ព្រះរាជ្យនៃព្រះគឺជាចម្លើយរបស់អ្នក

មកដល់ពេលនេះអ្នកទទួលបានការយល់ដឹងខ្លះហើយពីរបៀបដែលព្រះរាជ្យនៃព្រះមានដំណើរការ តាមច្បាប់ និងគោលការណ៍ជាច្រើនដែលមិនដែលផ្លាស់ប្តូរ។ ខ្ញុំចង់ចាប់ផ្តើមផ្តោតសំខាន់លើច្បាប់ជាច្រើនដែលពិតជាមានការប៉ះពាល់លើផ្នែកហិរញ្ញវត្ថុរបស់អ្នក និងការសម្រាករបស់អ្នកយ៉ាងខ្លាំង។

ក៏ប៉ុន្តែមុនពេលយើងចូលទៅចំណុចនោះ ខ្ញុំចង់បញ្ជាក់ពីមូលហេតុដែលនាំឱ្យខ្ញុំដាក់ឈ្មោះសៀវភៅនេះថា *អំណាចនៃការសម្រាក* និងអត្ថន័យនៃពាក្យថា *សម្រាក* នៅក្នុងបរិបទហិរញ្ញវត្ថុ និងនៅក្នុងព្រះរាជ្យនៃព្រះ។ វាពិតជាគួរឱ្យភ្ញាក់ផ្អើលណាស់ ខ្ញុំមិនបានបង្កើតគំនិតនេះជាថ្មីទេដោយសារតែព្រះជាម្ចាស់បានប្រទានគំនិតអំពីការសម្រាកដែលទាក់ទងនឹងផ្នែកហិរញ្ញវត្ថុនេះរួចមកហើយ។

> *ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងអ្វីៗទាំងអស់នៅលើមេឃ និងផែនដី ចប់សព្វគ្រប់ហើយ។ នៅថ្ងៃទីប្រាំពីរ ព្រះជាម្ចាស់បង្ហើយកិច្ចការដែលព្រះអង្គបានធ្វើ គឺក្រោយពីបានបញ្ចប់កិច្ចការទាំងនោះមក ព្រះអង្គក៏ឈប់សម្រាកនៅថ្ងៃទីប្រាំពីរ។ ព្រះជាម្ចាស់ប្រទានពរឱ្យថ្ងៃទីប្រាំពីរ និងញែកថ្ងៃនោះឱ្យបានវិសុទ្ធ ដ្បិតថ្ងៃនោះ ព្រះអង្គបញ្ចប់កិច្ចការទាំងប៉ុន្មាន ដែលព្រះអង្គបានបង្កើត។*

លោកុប្បត្តិ ២៖១-៣

ជាដំបូង សូមឱ្យខ្ញុំពន្យល់ឱ្យបានច្បាស់ពីរឿងនេះថា៖ ព្រះជាម្ចាស់មិនបានសម្រាកនៅថ្ងៃទី៧ ដោយសារតែទ្រង់ហត់នឿយអស់កម្លាំងទេ។ ព្រះជាម្ចាស់មិនចេះហត់នឿយអស់កម្លាំងឡើយ។ ទ្រង់បានសម្រាកដោយសារតែដូចជាអ្វីដែលអត្ថបទគម្ពីរចែងថា

អ្វីៗទាំងអស់បានចប់សព្វគ្រប់ហើយ ទ្រង់បានបញ្ចប់កិច្ចការរបស់ទ្រង់ហើយ។ ទ្រង់បានបង្កើតមនុស្សមកនៅចុងបញ្ចប់ថ្ងៃទី៦ នៃកំណើតផែនដី ដើម្បីឱ្យគេរស់នៅក្នុងថ្ងៃទី៧។ នៅថ្ងៃទី៧ គ្មានការគិតពីភាពភ័យខ្លាច ការគិតពីការតស៊ូដើម្បីរស់ ជំងឺ និងគ្មានកិច្ចការធ្ងន់ ឬការហូរញើសដើម្បីទទួលបានការផ្គត់ផ្គង់នោះទេ។ ផ្ទុយទៅវិញគំនិតរបស់លោកអដាំ នឹងផ្តោតតែលើព្រះជាម្ចាស់ ភរិយារបស់គាត់ កិច្ចការរបស់គាត់ និងគោលបំណងរបស់គាត់ប៉ុណ្ណោះ។ អ្វីគ្រប់យ៉ាងដែលគាត់ត្រូវការដើម្បីគាំទ្រដល់កិច្ចការ និងជីវិតរបស់គាត់ត្រូវបានត្រៀមទុករួចរាល់ និងអាចរកបាន ហើយផែនការរបស់ព្រះជាម្ចាស់បានចប់សព្វគ្រប់ហើយ។ មនុស្សជាច្រើនក្នុងពេលបច្ចុប្បន្នស្រមៃចង់បានអ្វីដែលលោកអដាំមាន គឺការរស់នៅដោយមិនចាំបាច់ត្រូវខ្វល់ខ្វាយ និងមានពេលគ្រប់គ្រាន់ដើម្បីផ្តោតអារម្មណ៍លើចំណង់ចំណូលចិត្ត និងទំនាក់ទំនងរបស់គេដោយគ្មានការព្រួយបារម្ភអំពីការផ្គត់ផ្គង់អ្វីឡើយ។ គួរឱ្យសោកស្តាយណាស់ ពេលលោកអដាំបានបះបោរគាត់ក៏បាត់បង់ការផ្គត់ផ្គង់ពីព្រះជាម្ចាស់ ហើយមនុស្សទាំងអស់ក៏ទទួលបានការបង្ខិតបង្ខំឱ្យរត់ (ការខំប្រឹងប្រែងធ្វើការយ៉ាងលំបាកដោយក្តីឈឺចាប់ និងញើសហូរស្រក់) ដេញតាមអ្វីៗដើម្បីបំពេញជីវិតតាំងពីពេលនោះមក។

*ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែល<u>ខំស្វះស្វែងរក</u>របស់ទាំងនោះ។ រីឯព្រះបិតាដែលគង់នៅស្ថានបរមសុខ ព្រះអង្គជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត។*

ម៉ាថាយ ៦៖៣២-៣៣

**ចម្លើយទាំងអស់ដែលអ្នកត្រូវការដើម្បីខិតខំប្រឹងប្រែង និងត្រូវបន្តបំពេញកិច្ចការអនុញ្ញាតឱ្យអ្នកស្វែងរកគោលបំណងរបស់អ្នក គឺស្ថិតនៅក្នុងព្រះរាជ្យនៃព្រះ។**

សេចក្តីលំបាកដោយសារតែការស្វែងរកការផ្គត់ផ្គង់ គឺជាបន្ទុកដ៏ធ្ងន់ និងនាំឱ្យគំនិតរបស់មនុស្សលម្អៀងទៅរកផ្លូវមិនល្អក្នុងជីវិត។ អន្ទាក់នៃ ទ្រព្យសម្បត្តិ ការមានសេរីភាពរួចផុតពីការធ្វើការដ៏លំបាកដោយក្តីឈឺចាប់ និងការទាមទារឱ្យការបង្ហូរញើសដើម្បីតែរស់ គឺជាអ្វីដែលមនុស្សស្រមៃចង់បាន។ មនុស្សជាច្រើនគិតថា ការក្លាយទៅជាមហាសេដ្ឋីមានអត្ថន័យ ដោយសារតែគេជឿថា វាអាចកាត់បន្ថយភាពតានតឹងចិត្ត និងទម្ងន់នៃការស្វែងរកការផ្គត់ផ្គង់ ដែលអាចអនុញ្ញាតឱ្យយើងផ្តោត

អារម្មណ៍លើគោលបំណង និងកិច្ចការរបស់យើង។ ការលេងឆ្នោតមានការពេញនិយមយ៉ាងខ្លាំងដោយ សារតែវាផ្ដល់ការផ្គត់ផ្គង់ ដោយមិនចាំបាច់ជាប់ពាក់ព័ន្ធនឹងការងារបញ្ចេញពលកម្ម និងជាការរត់គេចចេញពីបណ្ដាសារបស់ផែនដីក្នុងប្រព័ន្ធហិរញ្ញវត្ថុ។ ល្បិចបោកបញ្ឆោតឱ្យក្លាយជាអ្នកមានឆាប់រហ័ស សម្បូរកើតមានឡើងក្នុងគ្រប់ទម្រង់ និងនៅតែបន្តធ្វើការផ្សព្វផ្សាយតាមរយៈអ៊ីម៉ែល និងការបង្ហោះតាមហ្វេសប៊ុក។ ហេតុដូច្នេះហើយនៅក្នុងបរិបទហិរញ្ញវត្ថុរបស់យើង យើងត្រូវការឆ្លើយតបនឹងសំណួរមួយថា៖ តើមានផ្លូវណាមួយដែលយើងអាចត្រលប់ទៅរកថ្ងៃទី៧ ជាថ្ងៃដែលអ្វីៗគ្រប់យ៉ាងចប់សព្វគ្រប់ និងឥតសៅហ្មង ហើយមានអ្វីៗដែលយើងអាចរកបានវិញដែរឬទេ? ចម្លើយនោះគឺជាចម្លើយឮថាបាន! របៀបដែលរឿងនោះកើតឡើង និងការយល់ដឹងពីច្បាប់ផ្សេងៗរបស់ព្រះរាជ្យនៃព្រះដែលនឹងបង្កើតជាលទ្ធផលប្រភេទនោះ គឺជាគោលបំណងរបស់សៀវភៅមួយក្បាលនេះ។ ខ្ញុំដឹងថាបទពិសោធរបស់អ្នកជាមួយនឹងជីវិត ឬសូម្បីតែជាមួយនឹងក្រុមជំនុំ និងគ្រិស្តបរិស័ទបានឱបជាប់នូវគំនិតបែបទេវវិទ្យាថា «ភាពក្រីក្រគឺជាភាពវិសុទ្ធ»។ ក៏ប៉ុន្តែខ្ញុំសូមធានាចំពោះអ្នកថា រាល់ចម្លើយដែលអ្នកត្រូវការដើម្បីចម្រើនលូតលាស់ឡើង និងស្ថិតនៅជាប់នឹងកិច្ចការដែលអនុញ្ញាតឱ្យអ្នកធ្វើការរុករកគោលបំណងរបស់អ្នក គឺនៅក្នុងព្រះរាជ្យនៃព្រះ។

*អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ! អ្នកមានសុភមង្គលហើយដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់។*

លូកា ៦៖២០

ចម្លើយឆ្លើយតបទៅកាន់ភាពក្រខ្សត់គឺជាព្រះរាជ្យនៃព្រះ! នេះគឺជាខគម្ពីរដំបូងដែលព្រះជាម្ចាស់បានដឹកនាំខ្ញុំទៅរកពេលដែលទ្រង់ចាប់ផ្ដើមបង្រៀនខ្ញុំអំពីច្បាប់ហិរញ្ញវត្ថុនៃព្រះរាជ្យរបស់ព្រះ។ ជាការពិតណាស់ ដើម្បីកាន់ខ្ជាប់នូវគំនិតនេះ អ្នកនឹងត្រូវការដឹងពីអត្ថន័យនៃគំនិតក្នុងព្រះរាជ្យនៃព្រះ ដែលខ្ញុំបានរៀបរាប់រួចមកហើយនេះ។ ហើយខ្ញុំគិតថាអ្នកត្រូវតែមានការយល់ដឹងច្បាស់លាស់អំពីអ្វីដែលបានកើតឡើងនៅក្នុងសួនឧទ្យានអេដែន ពិតប្រាកដនៅពេលដែលលោកអដាំបានប្រព្រឹត្តិអំពើបាប។ ដូច្នេះសូមអនុញ្ញាតឱ្យខ្ញុំចំណាយពេលបន្តិចដើម្បីរំឭក។

នៅគ្រាដើមដំបូងបង្អស់ លោកអដាំ និងនាងអេវ៉ាគ្មានការបារម្ភពីអ្វីទាំងអស់ ពួកគេគ្មានជំងឺ គ្មានបញ្ហាទាក់ទងនឹងការផ្គត់ផ្គង់ មករំខានដល់គំនិតរបស់ពួកគេជាប្រចាំថ្ងៃ

នោះទេ។ ជារៀងរាល់ថ្ងៃ អ្វីដែលពួកគេត្រូវគិតដល់នោះគឺកិច្ចការរបស់ពួកគេ ជាកិច្ចការស្រលាញ់ព្រះជាម្ចាស់ ស្រលាញ់គ្នាទៅវិញទៅមក និងថែរក្សាផែនដី និងសួនឧទ្យានដែលព្រះជាម្ចាស់បានប្រទានមកពួកគេ។ ភាពភ័យខ្លាចគ្មានវត្តមាននៅក្នុងជីវិតរបស់ពួកគេទេ។ ក៏ប៉ុន្តែពេលដែលលោកអដាំ បានប្រព្រឹត្តអំពើក្បត់នឹងព្រះ ជាការពិតណាស់អ្វីៗបានផ្លាស់ប្ដូរ។ ដូចដែលខ្ញុំបាននិយាយរួចមកហើយថាមារសាតាំងបានក្លាយជាព្រះនៃលោកិយនេះ មនុស្សបានដាច់ចេញពីព្រះជាម្ចាស់ ហើយព្រះជាម្ចាស់បានដាច់ចេញពីការមានសិទ្ធិស្របច្បាប់មកលើមនុស្ស។ លោកអដាំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះការពិតថ្មីមួយអំពីរបៀបដែលជីវិតមានដំណើរការ។ ជាថ្មីម្តងទៀត ខាងក្រោមនេះជាព្រះបន្ទូលដែលព្រះជាម្ចាស់ប្រទានឱ្យលោកអដាំបន្ទាប់ពីលោកបានប្រព្រឹត្តអំពើបាប។

> *ដោយអ្នកបានស្ដាប់តាមពាក្យប្រពន្ធ ហើយបរិភោគផ្លែឈើដែលយើងហាមប្រាមនោះដីនឹងត្រូវបណ្ដាសា ព្រោះតែអ្នក។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ ដូច្នេះ អ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃ អស់មួយជីវិត។*

លោកុប្បត្តិ ៣៖១៧

ការនឿយហត់ពេញដោយក្ដីឈឺចាប់ ញើសហូរស្រក់ ក្ដីបារម្ភ និងគំនិតតស៊ូដើម្បីរស់ បានក្លាយទៅជាអ្វីដែលលេបត្របាក់ការគិតរបស់លោកអដាំ និងនាងអេវ៉ាហើយ។ គោលបំណងរបស់ពួកគេ ជាផែនការដែលព្រះជាម្ចាស់មានសម្រាប់ពួកគេនោះ ឥឡូវនេះបានបាត់បង់នៅតាមផ្លូវរត់ប្រណាំង និងក្នុងសមរភូមិច្បាំងដើម្បីឱ្យតែបានរស់។ កិច្ចការដ៏អស្ចារ្យរបស់លោកអដាំ និងគោលបំណងរបស់គាត់ឥឡូវនេះបានកប់បាត់ទៅដោយសារតែការខ្វល់ខ្វាយពីជីវិត និងតម្រូវការចំពោះការផ្គត់ផ្គង់។ គាត់មើលលែងឃើញថាខ្លួនគាត់ជានរណា។ គោលបំណងតែមួយគត់ដែលគាត់អាចមើលឃើញនៅពេលនេះគឺធ្វើយ៉ាងណាដើម្បីរស់ ដែលតម្រូវឱ្យគាត់ធ្វើការកិច្ចការយ៉ាងលំបាក និងបង្ហូរញើសសស្រាក់ជានិច្ច។ មើលទៅគ្មានអ្វីផ្លាស់ប្ដូរច្រើនទេតាំងពីមុនមកទល់ឥឡូវនេះ។

សព្វថ្ងៃនេះ ក្នុងនាមជាគ្រូគង្វាលម្នាក់ ខ្ញុំបានឃើញថាសំណួរដែលមនុស្សភាគច្រើនបានសួរមកខ្ញុំនោះគឺថា «តើខ្ញុំគួរធ្វើដូចម្តេចទៅចំពោះជីវិតមួយនេះ?» មូលហេតុដែលពួកគេសួរដូច្នេះដោយសារតែក្នុងលោកិយនេះតាំងពីសម័យលោកអដាំមក មនុស្សចាត់ទុកថា ការស្វែងរកការផ្គត់ផ្គង់គឺជាគោលបំណង ដែលគេអាចយកមករាស់ស្ទង់អ្វីៗគ្រប់យ៉ាង

ផ្សេងទៀត។ ការសម្រេចចិត្តផ្សេងៗតែងតែបានធ្វើឡើងផ្អែកលើមូលដ្ឋានរបស់លុយ មិនមែនផ្អែកលើគោលបំណងទេ។ ទាំងលុយ និងតម្រូវការចង់បានលុយ អាចបង្ខំមនុស្សឱ្យព្រមទទួលធ្វើការងារដែលពួកគេស្អប់។ ជាការពិត មនុស្សភាគច្រើនហាក់មិនបានដឹងថាពួកគេជានរណាឱ្យពិតប្រាកដទេ។ សូមកត់សម្គាល់ចំណុចនេះទុកចុះ «ប្រសិនបើអ្នកមិនស្គាល់ព្រះជាម្ចាស់ទេ នោះអ្នកនឹងមិនដឹងពីការរចនារបស់ទ្រង់សម្រាប់ជីវិតអ្នកទេ។ ទ្រង់ជាព្រះដែលបានបង្កើតអ្នក»។

មនុស្សជាច្រើនពិតជាស្រេកឃ្លានចង់ស្វែងរកឱ្យដឹងថា ពួកគេជានរណាខ្លាំងណាស់។ នៅក្នុងលោកិយនេះ ពួកគេហាក់ដូចជាត្រូវបានគេមើលឃើញថាត្រឹមជាចំនួនប៉ុណ្ណោះ ក៏ប៉ុន្តែចំពោះព្រះជាម្ចាស់ពួកគេពិតជាស្នាព្រះហស្តដ៏ពិសេស និងមានភាពខុសប្លែកពីគ្នាមួយ មានជំនាញ និងសក្តានុពលដែលគ្មាននរណាម្នាក់ផ្សេងទៀតមាន។ ក៏ប៉ុន្តែដោយសារតែពួកគេមិនស្គាល់ព្រះជាម្ចាស់ ហើយជាការពិតណាស់ពួកគេមិនស្គាល់ខ្លួនគេទេ ពួកគេស្វែងរកតម្លៃរបស់ខ្លួនឯងនៅកន្លែងដែលមិនត្រឹមត្រូវ។ ពួកគេអនុញ្ញាតឱ្យវប្បធម៌ផ្តល់តម្លៃឱ្យពួកគេ តាមរយៈការទទួលស្គាល់អ្វីដែលមានកំណត់នៅក្នុងវប្បធម៌។ ក៏ប៉ុន្តែរូបភាពនៃរូបថតក្នុងប្រព័ន្ធផ្សព្វផ្សាយ និងក្នុងកញ្ចក់នៃវប្បធម៌ទាំងអស់គឺជាការផ្លាស់ប្តូរនៃស្រមោល។ ក្នុងពេលដែលអ្នកគិតថាអ្នកកំពុងឈានជើងចូលមកតម្រង់ជួរជាមួយនឹងអ្វីដែលគេហៅថាអាចទទួលយកបាន អ្នកនឹងដឹងថាវាបានផ្លាស់ប្តូរ ហើយអ្នកកំពុងស្ថិតនៅពីក្រោយគេរួចទៅហើយ។

ខ្ញុំអាចនៅចាំពីកាលខ្ញុំនៅទីក្រុងប៉ារីស និងបានដើរនៅតាមផ្លូវជាមួយនឹងគ្រិនដា។ ជាការពិតណាស់ ទីក្រុងបារីសល្បីល្បាញខាងម៉ូតពេញនិយម ហើយនៅក្នុងឆ្នាំមួយនោះ ម៉ូតពេញនិយមនៅទីនោះគឺពណ៌ប្រផេះ និងពណ៌ខ្មៅ។ មើលទៅតាមបង្អួចហាងនីមួយៗឃើញសុទ្ធតែពណ៌ប្រផេះ និងខ្មៅ។ ពេលខ្ញុំសម្លឹងមើលទៅតាមផ្លូវ នៅក្នុងទិសទាំងពីរ ខ្ញុំអាចឃើញមនុស្សរាប់រយនាក់កំពុងដើរជាមួយយើង។ ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយមិនឃើញមានពណ៌ណាផ្សេងសូម្បីតែបន្តិចឡើយ។ មនុស្សម្នាក់ៗ ដោយមិនលើកលែងនរណាម្នាក់ឡើយ បានស្លៀកពាក់ ពណ៌ប្រផេះ និងពណ៌ខ្មៅ។ មានមនុស្សដល់ទៅរាប់រយនាក់ ដែលមើលទៅដូចៗគ្នា។ តើពេលណាជាពេលចុងក្រោយ ដែលមនុស្សម្នាក់បានប្រាប់អ្នកថាពួកគេចូលចិត្តពណ៌ប្រផេះ? ក៏ប៉ុន្តែនៅថ្ងៃនោះ មនុស្សជាច្រើននាក់ហាក់ដូចជាច្បាស់ក្នុងចិត្តណាស់ពួកគេចូលចិត្តពណ៌ប្រផេះ ឬពណ៌ខ្មៅ។

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

ដោយសារតែសម្ពាធនៅក្នុងការទទួលបានការផ្គត់ផ្គង់មានការលំបាក និងធ្វើឱ្យយើងបាត់បង់អត្តសញ្ញាណ ចំពោះអ្វីដែលយើងគិតថានឹងជួយដល់យើងក្នុងការស្វែងរកវា និងមានការទទួលស្គាល់ គ្រិនដា និងខ្ញុំបានបង្កើតនូវពាក្យស្លោកមួយ ដែលយើងបានធ្វើការអធិប្បាយជាច្រើនឆ្នាំមកហើយដែលនិយាយថា «បើអ្នកមិនដោះស្រាយរឿងលុយទេ អ្នកនឹងរកមិនឃើញជោគវាសនាខ្លួនឡើយ!» ការធ្លាក់ជាទាសករក្នុងការតស៊ូដើម្បីបានរស់ ផ្តល់ឱ្យអ្នកមានពេលវេលាបន្តិចបន្តួចដើម្បីអង្កេត និងបង្កើតជម្រើសជាច្រើន។ ការពិតនោះគឺ ពេលខ្ញុំបានចែករំលែក មានពេលជាច្រើនមនុស្សធ្វើការសម្រេចចិត្តជុំវិញគោលដៅនៃការស្វែងរក ឬការលាក់ទុកនូវការផ្គត់ផ្គង់។ ពួកគេបានបោះបង់នូវចំណង់ចំណូលចិត្ត ដោយសារតែប្រាក់ខែ និងបោះបង់និមិត្តសម្រាប់តែការផ្គត់ផ្គង់។ ការពិតនោះគឺយើងបានទទួលរងសម្ពាធខ្លាំង ដោយសាតែផ្នត់គំនិតខំឱ្យតែបានរស់របស់យើង នៃការខិតខំធ្វើការយ៉ាងលំបាក និងការងូរញើសដែលបានធ្វើឱ្យយើងឈប់មានសុបិននិមិត្ត។ ភាពភ័យខ្លាចបានឃុំឃាំងសុបិននិមិត្តរបស់យើងទុក ហើយកង្វះខាតការផ្គត់ផ្គង់បានឃុំឃាំងសុបិននិមិត្តរបស់យើងឱ្យជាប់នៅក្នុងសភាពមិនអាចធ្វើអ្វីបាន។

ខ្ញុំអាចនៅចាំបានពេលដែលសុបិនរបស់ខ្ញុំ ដែលធ្លាប់តែចង់បានលុយចាក់សាំងឱ្យគ្រប់គ្រាន់បានបើកឡានដល់ផ្ទះ ដោយបោះបង់នូវអ្វីផ្សេងទៀតដែលជាការសំខាន់បំផុតក្នុងក្នុងការផ្លាស់ប្តូរជីវិតចោល។ នៅពេលនោះ ខ្ញុំមិនបានយកចិត្តទុកដាក់លើនិមិត្តធំៗផ្សេងទៀតឡើយ។ មានតែការបង់ប្រាក់ថ្លៃជួលផ្ទះប្រចាំខែ នោះហើយជាការស្រមើស្រមៃទាំងអស់ដែលខ្ញុំបានផ្តោតលើ។ ខ្ញុំទទួលស្គាល់ថាវាពិបាកក្នុងការមើលឃើញឆ្ងាយជាងការតស៊ូដើម្បីរស់ ពេលអ្នកត្រូវការអាហារជាបន្ទាន់ ឬជួបប្រទះនឹងតម្រូវការចាំបាច់ភ្លាមៗទាក់ទងនឹងហិរញ្ញវត្ថុ។

ពេលលោកអដាំបានបោះបង់ព្រះរាជ្យនៃព្រះចោល មានពិភពលោកថ្មីទាំងស្រុងនៃសេចក្តីស្លាប់ ភាពភ័យខ្លាច ការតស៊ូរស់ និងភាពស្លន់ស្លោបានគ្របដណ្តប់ជីវិតរបស់គាត់។ ខ្ញុំប្រាកដចិត្តណាស់ថាយើងទាំងអស់គ្នាដឹងថាតើភាពភ័យខ្លាចវាមានសភាពបែបណា។ ខ្ញុំអាចរំឮកពីរឿងច្រើនរាប់មិនអស់នៅក្នុងជីវិតផ្ទាល់ខ្លួនខ្ញុំ ដែលពេញដោយភាពស្លន់ស្លោ ភាពអាម៉ាស និងភាពភ័យខ្លាចដោយសារខ្ញុំបានរងទុក្ខអស់រយៈពេល ៩ ឆ្នាំដ៏វែងអន្លាយក្នុងភាពរឹករវផ្នែកហិរញ្ញវត្ថុ ដោយចុងក្រោយខ្ញុំត្រូវដោះស្រាយបញ្ហាដែលខ្ញុំទទួលរងពីភាពស្លន់ស្លោ និងរស់នៅដោយពឹងលើថ្នាំរម្ងាប់អារម្មណ៍។ ការរស់នៅក្នុងប្រព័ន្ធដែល

មានបណ្ដាសាលើផែនដីនៃការតស៊ូដើម្បីរស់ បានបណ្ដុះបណ្ដាលយើងឱ្យឈានទៅរកទស្សនៈវិស័យអវិជ្ជមានមួយអំពីជីវិត។ មនុស្សមួយចំនួនដោះស្រាយនឹងបញ្ហានេះបានប្រសើរជាងអ្នកផ្សេង ក៏ប៉ុន្តែដោយគ្មានព្រះគ្រិស្ត ផ្នត់គំនិតអវិជ្ជមាននេះនឹងនៅបន្តប្រាប់យើងថា យើងមិនល្អគ្រប់គ្រាន់ទេ។

តើអ្នកធ្លាប់ឮនរណាម្នាក់និយាយទេថា «កុំមានសង្ឃឹមពេក» ដែរឬទេ? កាលនៅពីក្មេង ប្រសិនបើខ្ញុំ រំភើបនឹងរឿងណាមួយដែលឪពុកខ្ញុំគិតថាជារឿងឆោតល្ងង់នោះ គាត់មុខជានិយាយថា «ថ្ងៃណាមួយកូននឹងចេះគិតដូចជាមនុស្សពេញវ័យ»។ ដោយសារតែហេតុនេះហើយ ជាធម្មតាខ្ញុំមិនអនុញ្ញាតឱ្យខ្លួនឯងស្រមៃពីអ្វីមួយឡើយ លើកលែងតែវាជាអ្វីដែលឪពុករបស់ខ្ញុំកំណត់ថាជារឿងចាំបាច់។ ខ្ញុំជឿថាឪពុករបស់ខ្ញុំបានទទួលការឈឺចាប់ ដោយសារតែគាត់ធំធាត់នៅក្នុងផ្ទះមួយដែលមានមនុស្សប្រមឹក ហើយនេះជាអ្វីម្យ៉ាងដែលគាត់ត្រូវធ្វើពេលគាត់ធំធាត់ឡើងដែរ។

និយាយដោយស្មោះត្រង់ យើងទាំងអស់គ្នាគឺជាមនុស្សដែលមានជំនាញខាងបារម្ភតាំងពីកំណើតមកម្ល៉េះ។ ភាពភ័យខ្លាចគឺជារឿងធម្មតានៅក្នុងលោកិយនេះទៅហើយ។ ប្រសិនបើអ្នកនឹងយកពេលឈប់បន្តិច ហើយគិតអំពីវា នោះពាក្យថា *ទេ* បានធ្លាក់មកលើយើងតាំងពីពេលដែលយើងចាប់កំណើតមកម្ល៉េះ។ «ទេ អ្នកមិនអាចយករបស់នោះបានទេ។» «ទេ សូមដាក់វាចុះវិញ។» «ទេ អ្នកមិនអាចទៅដល់ទៅនោះបានទេ។» «ទេ អ្នកមិនអាចរកប្រាក់ល្មមទិញរបស់នោះទេ។» នៅទីបំផុត យើងក៏ស្រាប់តែឈប់និយាយពាក្យថា « បាទ/ចាស» ចំពោះរឿងណាមួយលើកលែងតែ ចំពោះការរត់គេចម្ដងម្កាលចំពោះសកម្មភាពណាមួយដែលធ្វើឱ្យចិត្តគំនិតយើងស្ពឹកស្រពន់ ចំពោះកាលៈទេសៈជាក់ស្ដែងជាច្រើនរបស់យើង ប្រៀបដូចជាការបរិភោគអាហារដែលយើងចូលចិត្តបំផុតច្រើនហួសកំណត់ដូច្នេះឯង។

មានការសិក្សាមួយបានប៉ាន់ប្រមាណថា ចំនួនកុមារជាមធ្យមដែលឮពាក្យថា *ទេ* ឬ *កុំ* មានច្រើនជាង ១៩៨,០០០ដង ក្នុងពេលដែលពួកគេចម្រើនវ័យឡើង ប្រៀបធៀបជាមួយនឹងពាក្យថា *បាទ/ចាស* ត្រឹមតែពីរបីពាន់ដងប៉ុណ្ណោះ។[4]

---

4 "ក្លាយជាម្ដាយដែលនិយាយថាបាន ចំពោះអ្វីដែលល្អបំផុតសម្រាប់កូន" http://www.babyzone.com

កាលពីពេលថ្មីៗនេះ ខ្ញុំបានធ្វើសន្និបាតប្រចាំឆ្នាំមួយអំពីការផ្គត់ផ្គង់ ហើយនៅក្នុងវេទិកានោះខ្ញុំបានដាក់រថយន្តម៉ាក Ferrari ស៊េរីឆ្នាំ២០១៧ ដើម្បីបង្ហួតមនុស្សគ្រប់គ្នាច្បាស់ៗតែម្ដង។ ម្ចាស់រថយន្តនោះជាអ្នកចូលរួមក្នុងក្រុមជំនុំរបស់ខ្ញុំ និងបានប្រើប្រាក់សុទ្ធទិញរថយន្តនោះ ដែលមានតម្លៃដល់ទៅជិត ៨០០,០០០ដុល្លារ។ ពេលអ្នកចូលរួមទាំងអស់បានចូលមក ពួកគេម្នាក់ៗបានស្ញប់ស្ញែង និងបានសម្លឹងមើលទៅរថយន្តនោះ គ្រប់គ្នាបានទៅមើលវា ចង់មើលវាឱ្យកាន់តែជិត។ ក៏ប៉ុន្តែទោះបីជាពួកគេទាំងអស់គ្នាស្ញប់ស្ញែងរថយន្តនោះ ចំណុចដែលខ្ញុំចង់បង្ហាញពួកគេតាមរយៈការដាក់បង្ហាញវានៅលើវេទិកា មិនមែនដើម្បីជំរុញឱ្យពួកគេមានគោលដៅមានជីវភាពសម្ភារៈនិយមទេ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺចង់បង្រៀនពួកគេពីមេរៀនមួយ។ មនុស្សទាំងអស់គ្នាមកផ្ដុំគ្នានៅជុំវិញឡាននោះ ទាំងអស់គ្នាបាននិយាយថាពួកគេចង់សាកល្បងបើកវា។

ខ្ញុំបានដឹងពីការបណ្ដុះបណ្ដាលឱ្យប្រើពាក្យថា «ទេ» ដែលពួកគេទទួលបានមកពីប្រព័ន្ធនៃបណ្ដាសាលោកិយ ពេញដោយកិច្ចការដ៏លំបាក និងការបង្ខូរញើសដែលធ្វើឱ្យពួកគេស្រែកឡើងដោយមិនដឹងខ្លួននូវពាក្យថា «ទេ អ្នកគ្មានផ្លូវបានធ្វើជាម្ចាស់រថយន្តនេះទេ! ទេ អ្នកគ្មានផ្លូវរកប្រាក់ទិញវាបាននោះទេ កុំចេះតែស្រមៃអី»។ ដោយសារតែការបណ្ដុះបណ្ដាលឱ្យប្រើពាក្យថា «ទេ» ដែលពួកគេទទួលបាន ហើយយើងទាំងអស់គ្នាក៏ទទួលបាន ពួកគេភាគច្រើននៅទីនោះមិនទាំងគិតថាចង់ធ្វើជាម្ចាស់រថយន្ត Ferrari ផងដោយសារតែផ្នត់គំនិតនេះមិនអាចមើលឃើញ ឬទទួលយកការធ្វើជាម្ចាស់បានទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើខ្ញុំនៅបន្តផ្លាស់ប្ដូររថយន្តមួយម៉ោងម្ដង ពីរថយន្តតម្លៃថ្លៃ ទៅដល់រថយន្តដែលមានតម្លៃធូរថ្លៃជាងគេ នោះជាការពិតណាស់ថាខ្ញុំនឹងដាក់តាំងរថយន្តមួយនៅលើវេទិកានោះមុខជាមានពួកគេខ្លះគិត និងនិយាយថា «ខ្ញុំចង់ចូលចិត្តឡាននោះ ខ្ញុំគួរតែទិញវាមួយ»។

តើខុសគ្នាត្រង់ណា? ទាំងអស់នេះគឺបង្ហាញអំពីរបៀបដែលពួកគេមើលមកខ្លួនឯង សក្ដានុពលរបស់គេ និងតម្លៃរបស់ឡាននោះ។ ពិតមែនហើយ គួរតែមានពួកគេពីរបីនាក់ដែលនិយាយទៅខ្លួនគេថា «ខ្ញុំនឹងធ្វើជាម្ចាស់ឡាននោះក្នុងថ្ងៃណាមួយមិនខាន» ឬអាចនឹងមានមនុស្សមួយចំនួននៅទីនោះដែលមានលុយ និងបានមើលទៅរថយន្តនោះក្នុងរបៀបផ្សេង។ ក៏ប៉ុន្តែខ្ញុំប្រាកដចិត្តណាស់ថាសម្រាប់ពួកគេភាគច្រើន ការធ្វើជាម្ចាស់លើរថយន្តប្រភេទនេះមិនទាំងស្ថិតនៅក្នុងគំនិតរបស់ពួកគេផង។ ចំពោះមហាសេដ្ឋីដែលបាន

ចំណាយលុយទិញរថយន្តនោះ ការពិតទៅគាត់មានរថយន្ត Ferraris ដល់ទៅ៦ គ្រឿងឯណោះ។ ចំពោះផ្នត់គំនិតរបស់គាត់ វាត្រឹមតែជារថយន្តដ៏អស្ចារ្យមួយគ្រឿង។ ពេលគាត់ឃើញរថយន្តនោះ គាត់មាននិមិត្តក្នុងការធ្វើជាម្ចាស់លើវា ហើយបានចាប់ផ្ដើមធ្វើការបញ្ជាទិញវាពីប្រទេសអ៊ីតាលីមក ហើយបន្ទាប់មកបានឱ្យគេដឹកជញ្ជូនវាតាមកប៉ាល់មកផ្ទះរបស់គាត់ក្នុងប្រទេសអាមេរិក។ វាគ្មានអ្វីពិបាកទេសម្រាប់គាត់ក្នុងការធ្វើសកម្មភាពតាមនិមិត្តរបស់គាត់ដោយសារតែគាត់មានការផ្គត់ផ្គង់។ នៅត្រង់នេះគឺជាកូនសោសំខាន់មួយទៅរកការសម្រាក - ការផ្គត់ផ្គង់គឺជាការគាំទ្រដល់និមិត្ត។

# កូនសោសំខាន់៖

## <u>ការផ្គត់ផ្គង់គឺជាការគាំទ្រដល់និមិត្ត</u>

ប្រសិនបើគ្មានការផ្គត់ផ្គង់ទេនោះ គឺគ្មាននិមិត្តទេ ហើយនឹងមានត្រឹមតែការតស៊ូរស់នៅប៉ុណ្ណោះ។ ប្រព័ន្ធនៃបណ្ដាសាលោកិយរបស់ភាពក្រីក្របានលួចសុបិននិមិត្តរបស់យើង និងអនាគតរបស់យើងទៅ។ ខ្ញុំដឹងថារថយន្ត Ferrari គឺជាឧទាហរណ៍ទូទៅមួយ ក៏ប៉ុន្តែវាបង្ហាញពីអ្វីដែលខ្ញុំចង់និយាយ។ មនុស្សនៅទីនោះមិនទាំងអនុញ្ញាតឱ្យខ្លួនគេសុបិនចង់ក្លាយជាម្ចាស់រថយន្តប្រភេទនោះផង ដោយសារតែពួកគេមើលទៅវាថាជាអ្វីដែលខ្លួនមិនអាចមាន។ ប្រសិនបើពួកគេសុបិនចង់បានបន្តិច ហើយអនុញ្ញាតឱ្យខ្លួនគេសុបិនចង់ក្លាយជាម្ចាស់របស់វានោះ ការបណ្ដុះបណ្ដាលដែលពួកគេទទួលបានពីប្រព័ន្ធនៃបណ្ដាសាលោកិយ នឹងស្រែកដាក់ពួកគេវិញថា «ពិតជាខ្ជះខ្ជាយលុយមែន!» ក៏ប៉ុន្តែចុះប្រសិនបើអ្នកមានលុយ ២៥ លានដុល្លារជាលុយសុទ្ធនៅក្នុងគណនីធនាគាររបស់អ្នក(ខ្ញុំគ្រាន់តែឧបមាប៉ុណ្ណោះ)? រថយន្តមួយគ្រឿងនោះនឹងមើលទៅដូចជាមានតម្លៃថោកដែលអ្នកអាចទិញវាមួយគ្រឿងមកដើម្បីតែប្រើវានៅថ្ងៃចុងសប្ដាហ៍ប៉ុណ្ណោះ។ ទាំងអស់នេះគឺជាបញ្ហារបស់ទស្សនៈ ហើយដោយសារតែព្រះបន្ទូលរបស់ព្រះជាម្ចាស់មានបន្ទូលថា រាល់ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់គឺពាក្យថា «បាទ/ចាស» ហើយនិង «អាម៉ែន (សូមឱ្យកើតឡើងចុះ)» នោះទស្សនៈរបស់អ្នកត្រូវតែមានការផ្លាស់ប្ដូរ ដើម្បីឱ្យមានការគិតដូចជាព្រះជាម្ចាស់ព្រះតម្រិះ។

*ព្រះគ្រិស្តបានធ្វើឱ្យព្រះបន្ទូលសន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់បានសម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយបានជាយើងពោលពាក្យ«អាម៉ែន»*

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

*ទៅកាន់ព្រះជាម្ចាស់ តាមរយៈព្រះគ្រិស្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។*

២ កូរិនថូស ១៖២០

យោងតាមវចនានុក្រម និយមន័យរបស់ទស្សនៈគឺ៖ ឥរិយាបថជាក់លាក់មួយចំពោះ ឬរបៀបមួយនៃទំនាក់ទំនងអ្វីមួយ គឺជាការយល់ឃើញ ឥរិយាបថ បរិបទ ឬការបកស្រាយមួយ។ ជាទូទៅទស្សនៈគឺជារបៀបដែលអ្នកគិតយ៉ាងពិតប្រាកដអំពីអ្វីមួយ។

ត្រង់នេះគឺជាគំនិតមួយដែលខ្ញុំចង់ឱ្យអ្នកគិត។ លោកអដាំគឺជាព្រះរាជបុត្រាមួយអង្គមុនពេលដែលគាត់បានចុះចូលជាមួយនឹងមារសាតាំង។ ហេតុដូច្នេះហើយប្រសិនបើអ្នកបានឃើញគាត់បន្ទាប់ពីការធ្លាក់ចុះមួយនោះ អ្នកមុខជាឃើញបុរសដ៏ក្រីក្រម្នាក់ រួមជាមួយនឹងក្រុមគ្រួសារដ៏រញ៉េរញ៉ៃមួយ (លោកកាអ៊ីនជាកូនប្រុសគាត់បានសម្លាប់លោកអេបិលជាប្អូនប្រុសគាត់) ហើយអ្នកមុខជាគិតថា គាត់មិនមែនជាមនុស្សសំខាន់ទេ។ ក៏ប៉ុន្តែអ្វីដែលអ្នកមើលមិនឃើញនោះគឺថាគាត់មានឈាមជ័រជាសៃរាជវង្ស។ ទោះបីជាអ្នកមិនអាចមើលឃើញគាត់នៅក្នុងសមាសភាពនោះក្តី គាត់ពិតជាបានកើតមកដើម្បីគ្រប់គ្រង និងកាន់អំណាចនៅក្នុងជីវិតរបស់គាត់។ ការពិតមួយនេះក៏ត្រូវយកមកអនុវត្តជាមួយអ្នកដូចគ្នាផងដែរ។ អ្នកមិនអាចមើលមកខ្លួនឯង ដោយផ្អែកលើទីកន្លែងដែលអ្នកនៅ អ្វីដែលអ្នកមាន និងកាលៈទេសៈបច្ចុប្បន្នរបស់អ្នក ហើយយកវាមកកាត់សេចក្តីលើសក្តានុពលរបស់អ្នកឡើយ។ អ្នកត្រូវតែមើលសម្លឹងមើលទៅដើមកំណើតដ៏មានសក្តានុពលរបស់អ្នក។

ខ្ញុំអាចចងចាំបានពេលដែលខ្ញុំកំពុងឆ្លងកាត់កាលៈទេសៈដ៏លំបាកជាច្រើន និងពេលដែលខ្ញុំកំពុងតែជួបប្រទះបញ្ហាមួយចំនួន ដែលមើលទៅធំជាងខ្លួនខ្ញុំ។ ខ្ញុំបានប្រឈមមុខនឹងការសម្រេចចិត្តមួយចំនួន ដែលនឹងទាមទារឱ្យខ្ញុំចំណាយលុយច្រើនជាងចំនួនដែលខ្ញុំមាននៅក្នុងដៃ។ ខ្ញុំមានអារម្មណ៍ដឹងពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលមកខ្ញុំពីអ្វីដែលខ្ញុំត្រូវធ្វើ ក៏ប៉ុន្តែកាលនោះខ្ញុំនៅតែមានភាពខ្មាសអៀនបន្តិចបន្តួចក្នុង ការធ្វើវា។ ព្រះអម្ចាស់បានប្រទានសុបិនមួយមកខ្ញុំក្នុងពេលនោះ។ ខ្ញុំបានជិះសេះមួយនៅលើកំពូលភ្នំមួយ។ ខ្ញុំមានដាវមួយនៅក្នុងដៃ។ នៅពីក្រោមខ្ញុំ ឯជើងភ្នំឯណោះមានកងទ័ព បើមិនមែនរាប់ពាន់នាក់ទេ គឺរាប់រយនាក់ជិះលើខ្នងសេះរបស់ពួកគេ ដោយលើកដាវនៅក្នុងដៃដើម្បី

**អ្នកត្រូវការប្តូរទស្សនៈ ដើម្បីផ្លាស់ប្តូរ ដើម្បីគិតបានដូចជាព្រះជាម្ចាស់មានព្រះតម្រិះ។**

ប្រយុទ្ធជាមួយខ្ញុំ។ ខ្ញុំមានគ្នាតែម្នាក់ឯងនៅលើចង្កេះភ្នំ ហើយខ្ញុំប្រាកដចិត្តណាស់ថា ពួកគេមានចំនួនច្រើនរាប់មិនអស់។ សំឡេងមួយនៅក្នុងការយល់សព្វរបស់ខ្ញុំបានបន្លឺពាក្យទាំងនេះថា «សូមកុំមើលស្រាលខ្លួនឯងអី ហ្គារី!» ដោយឮដូច្នេះ ខ្ញុំបានលើកដាវរបស់ខ្ញុំឡើង និងចាប់ផ្ដើមជិះសេះចុះពីលើភ្នំទៅរកសត្រូវរបស់ខ្ញុំ មកដល់ពេលឥឡូវនេះដោយមើលឃើញការវាយលុករបស់ខ្ញុំ សត្រូវក៏វាយលុកដោយរត់ឡើងមកលើភ្នំដែរ ទាំងលើកដាវរបស់ពួកគេឡើងផង។ ពេលខ្ញុំកំពុងតម្រង់ទៅរកពួកគេ ខ្ញុំបានស្រែកឮៗថា «THOR!»។

ពេលខ្ញុំភ្ញាក់ឡើង ខ្ញុំបានដឹងថានោះគឺជាអ្វីដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំ និងជាការលើកទឹកចិត្តដល់ខ្ញុំជាថ្មីម្ដងទៀត ក៏ប៉ុន្តែខ្ញុំមិនដឹងថាពាក្យ *Thor* មានអត្ថន័យដូចម្ដេចឡើយ។ មានបុរសម្នាក់នៅក្នុងក្រុមជំនុំខ្ញុំ ដែលបានធ្វើជាគ្រូគង្វាលអស់រយៈពេល ៣០ ឆ្នាំ និងបានសិក្សាភាសាជាច្រើន។ ខ្ញុំបានសួរគាត់ក្រែងលគាត់ដឹងពីអត្ថន័យពាក្យនេះ ហើយគាត់ប្រាប់ថាគាត់នឹងជួយរកមើលអត្ថន័យវា។ នៅថ្ងៃបន្ទាប់គាត់បានទូរស័ព្ទមកខ្ញុំ ហើយបានប្រាប់ខ្ញុំថាពាក្យថា Thor មានន័យថាព្រះនៃផ្គរលាន់។ ខ្ញុំបានអរគុណគាត់ និងពិតជាស្ញប់ស្ញែងចំពោះអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ខ្ញុំ។ ចំពោះមុខសត្រូវ ខ្ញុំបញ្ចេញសំឡេងដូចជាផ្គរលាន់! មិនថាខ្ញុំប្រាប់វិញ្ញាណអាក្រក់ថាខ្ញុំទន់ខ្សោយប៉ុណ្ណាក៏ដោយ នៅពេលដែលខ្ញុំនិយាយ សំឡេងខ្ញុំប្រៀបបាននឹងផ្គរលាន់ (អំណាច) ទៅកាន់វា។

កាលនោះខ្ញុំកំពុងអធិប្បាយនៅក្នុងសន្និបាតការផ្គត់ផ្គង់ដំបូងរបស់យើង ក្នុងឆ្នាំ ២០១០ និងនិយាយពីរឿងនេះ។ ពេលខ្ញុំប្រាប់ពីរឿងនេះ ខ្ញុំបានធ្វើការសន្និដ្ឋានជាមួយនឹងអ្វីដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំនៅក្នុងសុបិននោះថា «ពេលខ្មាំងសត្រូវមើលឃើញអ្នករត់ចូលទៅរកពួកគេ ហ្គារីអើយ សំឡេងអ្នកប្រៀបបាននឹងផ្គរលាន់» ខណៈពេលខ្ញុំនិយាយពាក្យថា «មានសំឡេងដូចជាផ្គរលាន់» មានសំឡេងទះដៃឮៗប្រៀបដូចផ្គរលាន់លាន់ក្នុងបរិយាកាសទាំងមូល។ គ្មានភ្លៀង គ្មានសំឡេងផ្គរលាន់ពីមុនមកទេ ហើយសំឡេងនោះគឺជាសំឡេងទះដៃលាន់ដូចផ្គរលាន់ ដែលលាន់ឮពេញមួយយប់នោះ។ មនុស្សដែលចូលរួមនៅក្នុងយប់នោះនៅទីនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក៏ប៉ុន្តែគ្មាននរណាម្នាក់មានអំណរហួសប្រមាណជាងខ្ញុំពេលនោះឡើយ ដោយខ្ញុំបានដឹងថាព្រះជាម្ចាស់បានដាក់ព្រះបន្ទូលថា «អាម៉ែន» របស់ទ្រង់នៅលើអ្វីដែលខ្ញុំបាននិយាយ ហើយវាក៏ត្រូវយកមកអនុវត្តជាមួយនឹងកូនៗទាំងអស់របស់ទ្រង់ដែរ។ ក្នុងពេលជាមួយគ្នានោះដែរ កាមេរ៉ាទូរទស្សន៍ជាច្រើន

កំពុងរំកិលទៅមកៗក្នុងយប់នោះដែរ ហើយប្រសិនបើអ្នកចង់មើលព្រឹត្តិការណ៍នោះ អ្នកអាចចូលទៅកាន់តំណភ្ជាប់នេះ៖ https://youtu.be/rtx1XYJGIAg។

ដូច្នេះត្រង់នេះគឺជាគំនិតដែលអ្នកត្រូវយល់។

## ទាសករគ្មានសុបិននិមិត្តធំដុំទេ!

តើទាសករសុបិនអំពីអ្វី? ការឈប់សិន! នោះហើយជាអ្វីដែលគេសុបិន។ ពួកគេសុបិនឃើញម៉ោង ៥៖០០ ដែលពួកគេចំណាយពេលមើលនាឡិការបស់ពួកគេពេញពេលពាក់កណ្ដាលថ្ងៃនីមួយៗរបស់ពួកគេក្នុងពេលរសៀល ដោយគ្រាន់តែចង់ឱ្យដល់ម៉ោងឈប់ និងបានចេញពីធ្វើការ។ ពួកគេសុបិនអំពីពេលវិស្សមកាល ពួកគេសុបិនពីការចូលនិវត្តន៍ ពួកគេសុបិនថាពួកគេនឹងមានលុយហើយអាចឈប់ធ្វើការបាន។ ទាសករសុបិនអំពីការឈប់ មិនមែនអំពីការបង្កើតការងារថែមទៀតទេ! ផ្នត់គំនិតរបស់ទាសករ ឬទស្សនៈរបស់ទាសករមិនបង្កើតអ្វីថ្មី ឬបង្កើតការងារទេ វាស្វែងរកវិធីណាមួយដើម្បីចេញឱ្យផុតពីការងារ។ ទាសករម្នាក់មានអារម្មណ៍ថាពេញហូរហៀររួចទៅហើយ ហើយមើលមិនឃើញពីសក្ដានុពលដែលធ្វើដំណើរឆ្លងកាត់គាត់ជារៀងរាល់ថ្ងៃទាល់តែសោះ។

ដើម្បីក្លាយជាក្បាល និងមិនក្លាយទៅជាកន្ទុយ ផ្នត់គំនិតរបស់អ្នកត្រូវតែផ្លាស់ប្ដូរពីភាពជាទាសករម្នាក់ ទៅជាម្ចាស់ និងជាអ្នកបង្កើតម្នាក់។ អ្នកត្រូវតែមានសុបិននិមិត្តជាថ្មីម្ដងទៀត។ អ្នកត្រូវការមើលឃើញលើសពីគំនិតដែលអ្នកគិតថាអ្នកជានរណា ទោះបីជាអ្នកអាចនឹងមើលទៅដូចជាទន់ខ្សោយនៅក្នុងខ្សែភ្នែករបស់ខ្លួនអ្នកក៏ដោយ ត្រូវធ្វើឱ្យវិញ្ញាណអាក្រក់ឃើញថាអ្នកមានសំឡេងប្រៀបដូចជាផ្គរលាន់។ អ្នកមានលោហិតរាជវង្ស នៅក្នុងសរសៃឈាមអ្នក ហើយអ្នកគ្រាន់តែត្រូវការគិត និងធ្វើសកម្មភាពបែបនោះប៉ុណ្ណោះ។

ខ្ញុំមានមិត្តភក្ដិម្នាក់ជាមហាសេដ្ឋីរាល់លាន។ គាត់មានផ្ទះដ៏ស្រស់ស្អាតជាច្រើនផ្ទះទាំងនោះស្ថិតនៅលើសមុទ្រ ឬនៅលើបឹង។ នៅថ្ងៃមួយខ្ញុំបានទៅសួរសុខទុក្ខគាត់ ពេលនោះយើងបានដើរនៅតាមផ្លូវនៅជាប់មាត់ទឹក កណ្ដាលចំណោមកប៉ាល់ជាច្រើន។ នៅពេលយើងដើរកាត់ទូកមួយៗ គាត់នឹងប្រាប់ពីឈ្មោះម្ចាស់កប៉ាល់នីមួយៗប្រាប់ដល់ខ្ញុំ។ ខ្ញុំនឹងផ្ដល់ឧទាហរណ៍មួយដល់អ្នកទាក់ទងនឹងរបៀបដែលយើងធ្វើការសន្ទនា ក៏ប៉ុន្តែខ្ញុំគ្រាន់តែប្រឌិតឈ្មោះឡើងទេ ដោយសារតែខ្ញុំភ្លេចឈ្មោះអស់ទៅហើយ។ នេះគឺជាអ្វីដែលមិត្តភក្ដិខ្ញុំសន្ទនាជាមួយខ្ញុំ៖ «កប៉ាល់នេះគឺជារបស់ ប៊ីល ស្មីត (Bill Smith) ជាម្ចាស់សេវាកម្មថែទាំ

សុខភាពអូហៃយ៉ូ។ កប៉ាល់នៅជាប់នោះគឺជារបស់លោក ចន រ៉ូចឺ (John Rogers) ជាម្ចាស់ការិយាល័យមេធាវី Rogers and Rogers។ កប៉ាល់នៅជាប់នោះទៀតគឺជារបស់លោក រ៉ាហ្វ ថៃវែល (Ralph Tidewell) ជាម្ចាស់ហាងលក់ស្បែកជើងដ៏ស្រស់ស្អាតមួយក្នុងតំបន់ហាយស្ទ្រីត (High Street)»។

ពេលយើងដើរឆ្លងកាត់កប៉ាល់មួយជួររួចមកហើយ ហើយបន្ទាប់ពីដើរកាត់កប៉ាល់ចំនួន២០រួចមក ខ្ញុំបានដឹងថាកប៉ាល់នីមួយៗជាកម្មសិទ្ធិរបស់មនុស្សម្នាក់ដែលមានអាជីវកម្មផ្ទាល់ខ្លួន។ គ្មានកប៉ាល់ណាមួយជាកម្មសិទ្ធិរបស់បុគ្គលសាមញ្ញឈ្មោះចូ (Jeo) ដែលធ្វើការពីម៉ោង ៩ដល់ម៉ោង ៥ ជានិយោជិតធ្វើការនៅតូបលក់ការ៉េមក្នុងតូមិទេ។ យ៉ាងណាមិញក្នុងពេលជាច្រើនខ្ញុំមិនជំទាស់នឹងការធ្វើការនៅឯតូបលក់ការ៉េមក្នុងតូមិទេ ហើយខ្ញុំក៏មិនជំទាស់នឹងការធ្វើជានិយោជិតម្នាក់ដែរ។ ខ្ញុំគ្រាន់តែផ្ដល់ឧទាហរណ៍មួយអំពីប្រភេទមនុស្សដែលមានទ្រព្យសម្បត្តិ។

សូមយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលខ្ញុំកំពុងតែនិយាយ។ វាមិនពាក់ព័ន្ធនឹងលុយដែលពួកគេមានទេ វាគឺពាក់ព័ន្ធនឹងផ្នត់គំនិតដែលពួកគេមាន។ សូមកុំទិញរទេះមុនពេលទិញសេះឱ្យសោះ។ មនុស្សភាគច្រើនអាចនឹងនិយាយថា «ខ្ញុំបន់ស្រន់សុំឱ្យខ្ញុំមានលុយច្រើនអីចឹង»។ អ្វីដែលពួកគេគួរតែនិយាយនោះគឺ «ខ្ញុំបន់ស្រន់ឱ្យខ្ញុំមានគំនិតដូចជាពួកគេ!» ពួកគេមានទស្សនៈផ្សេងអំពីជីវិត និងអំពីខ្លួនគេ។

មានក្រុមគ្រួសារភាគច្រើន ធ្លាប់បានឈានទៅដល់ការទទួលបានប្រាក់ចំណូលដែលអាចចាត់ទុកថាជាចំណូលដ៏ច្រើនហូរហៀរនោះទេ។ មានការសិក្សាមួយពីពេលថ្មីៗនេះថា មានអ្នកបំពេញការងារជាជនជាតិអាមេរិកប្រមាណ ៥១% រកប្រាក់ចំណូលបានតិចជាង ៣០,០០០ដុល្លារក្នុងមួយឆ្នាំ។[5] មានចំនួនប្រជាជនជាងពាក់កណ្ដាលក្នុងប្រទេសយើងទទួលបានប្រាក់ចំណូលតិចជាង ៣០,០០០ដុល្លារអីចឹងឬ?! ប្រសិនបើអ្នកស្ថិតក្នុងវ័យម្ភៃឆ្នាំ និងទើបតែចាប់ផ្ដើមចេញធ្វើការ ឬអ្នកកំពុងស្ថិតក្នុងមុខតំណែងដែលអ្នកចង់បាន

5 Michael Snyder, "លាហើយវណ្ណៈកណ្ដាល៖ មានអ្នកបំពេញការងារជាជនជាតិអាមេរិកប្រមាណ ៥១% រកប្រាក់ចំណូលបានតិចជាង ៣០,០០០ដុល្លារក្នុងមួយឆ្នាំ។" "ចុងបញ្ចប់នៃក្ដីស្រមៃរបស់ជនជាតិអាមេរិក" Washington's Blog, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥

http://www.washingtonsblog.com/2015/10/goodbyemiddle-class-51-percent-of-all-american-workers-make-less-than-30000-dollars-a-year.html

ហើយលុយមិនមែនជាអាទិភាពកំពូលរបស់អ្នកនោះអ្នកមុខជាមិនអីទេ ក៏ប៉ុន្តែខ្ញុំដឹងថាសម្រាប់ប្រជាជនក្នុងប្រទេសខ្ញុំជាងពាក់កណ្តាល មិនស្ថិតក្នុងស្ថានភាពដូចអ្នកទេ។ ខ្ញុំដឹងថាពួកគេត្រូវការលុយ។ សូមជឿខ្ញុំចុះ ខ្ញុំបានទៅដល់ផ្ទះរាប់ពាន់មកហើយក្នុងរយៈពេលជាង៣៦ឆ្នាំមកនេះ នៅក្នុងអាជីវកម្មខាងសេវាកម្មហិរញ្ញវត្ថុ ហើយខ្ញុំបានឃើញពីការត្រូវការលុយនេះមុនគេ។

ដូច្នេះហេតុអ្វីបានជាពួកគេគ្មានប្រាក់ចំណូលច្រើនជាងនេះ? មុនពេលដែលអ្នកស្រែកថាជីវិតអ្នកជួបរឿងអយុត្តិធម៌យ៉ាងណា ឬរឿងស្រែកថាអ្នកជាជនរងគ្រោះ ឬអំពីរឿងឥតប្រយោជន៍ផ្សេងទៀតនោះ ខ្ញុំនឹងប្រាប់អ្នកថា រឿងបែបនេះកើតមានដោយសារតែហេតុផលពីរ។ ទីមួយ ពួកគេជាប់អន្ទាក់របស់ប្រព័ន្ធនៃបណ្តាសាលោកិយពេញដោយភាពក្រីក្រ និងមិនស្គាល់ពីព្រះរាជ្យនៃព្រះ ក៏ដូចជាគោលការណ៍ផ្សេងៗនៃការផ្គត់ផ្គង់របស់ទ្រង់។ ទីពីរគឺពួកគេបានជិតជាមជាប់នូវគំនិតអវិជ្ជមាន ហើយក៏ដោយសារតែការបណ្តុះបណ្តាលនៃបណ្តាសាលោកិយ ដែលពួកគេបានទទួល និងដោយសារតែពួកគេរកមិនឃើញនូវផ្លូវចេញ ទោះបីជាមានផ្លូវចេញមួយអាចនឹងស្ថិតនៅចំពោះមុខពួកគេក៏ដោយចុះ។ ជាទូទៅទាសករមានចិត្តគំនិតមួយបែរទៅរកភាពជាទាសករ ដូចដែលខ្ញុំបានចែកចាយរួចមកហើយនេះ។ ពួកគេមិនបានឃើញពីឱកាសឡើយនៅពេលដែលពួកគេកំពុងស្វែងរកការសម្រាក។ សូមប្រឈមមុខជាមួយនឹងរឿងនេះចុះថាបើគ្មានចម្លើយពិតប្រាកដទេ មនុស្សនឹងបោះបង់អ្វីដែលមាននៅក្នុងដួងចិត្តរបស់គេ។

ខ្ញុំសូមលើកឧទាហរណ៍មួយ ដែលខ្ញុំបានប្រើនៅក្នុងវគ្គសិក្ខាសាលាជាច្រើនមកប្រាប់ដល់អ្នក។ ឧបមាថា ខ្ញុំប្រាប់អ្នកថាខ្ញុំអាចដោះស្រាយរាល់បញ្ហាលុយកាក់ទាំងអស់របស់អ្នកដោយប្រើតែប្រយោគដ៏ងាយស្រួលមួយ។ សូមត្រៀមក្រដាស និងខ្មៅដៃរបស់អ្នក ព្រោះខ្ញុំនឹងធានាជូនអ្នកថាអ្វីដែលខ្ញុំនិយាយជាចម្លើយរបស់អ្នក។ តើអ្នកត្រៀមរួចរាល់ហើយ ឬនៅ? សូមមើលនេះហើយជាចម្លើយ៖ សូមរកចំណូលសរុបប្រចាំឆ្នាំឱ្យបានប្រាំលានដុល្លារក្នុងឆ្នាំនេះ។ ពេលខ្ញុំនិយាយឃ្លានេះនៅលើវេទិកា គ្រប់គ្នាចាប់ផ្តើមអស់សំណើច។ ក៏ប៉ុន្តែហេតុអ្វីបានជាពួកគេសើច? ដោយសារតែពួកគេមិនអាចមើលឃើញថាខ្លួនគេអាចរកប្រាក់ចំនួនច្រើនបែបនោះបាន ហើយពួកគេក៏មិនគិតថាវាមិនអាចទៅរួចទេ ក្នុងការរកចំណូលសរុបឱ្យបាន៥លានដុល្លារក្នុងមួយឆ្នាំបែបនេះ។

បន្ទាប់មកខ្ញុំបានប្រាប់ពួកគេថា គ្មានផ្លូវណាដែលពួកគេអាចធ្វើជាម្ចាស់កម្មសិទ្ធិលើអ្វីដែលពួកគេមិនអាចមើលឃើញនោះទេ។ បន្ទាប់ពីនោះខ្ញុំបានធ្វើលំហាត់នោះម្តងទៀត ក៏ប៉ុន្តែលើកនេះខ្ញុំបន្ថយទម្លាក់ចំនួនលេខឱ្យនៅទាបជាងមុនៈ ២០០,០០០ដុល្លារ ១០០,០០០ដុល្លារ ៧០,០០០ដុល្លារឬ ៨០,០០០ដុល្លារក្នុងមួយឆ្នាំ។ នៅទីបំផុតខ្ញុំបានប្រាប់ពួកគេថា «ខ្ញុំនឹងនិយាយពីតួលេខដែលអ្នកនឹងនិយាយពាក្យថា "ចំនួននេះហើយ។ ងាយស្រួលណាស់។ ខ្ញុំអាចរកប្រាក់ប៉ុណ្ណេះបាន"»។

បន្ទាប់មកខ្ញុំបាននិយាយប្រាប់ពួកគេពីរឿងមួយផ្សេងទៀត។ ឧបមាថាខ្ញុំគឺជាអ្នកជំនួញដ៏មានទ្រព្យសម្បត្តិម្នាក់នៅក្នុងអាជីវកម្មនាំចេញ។ ខ្ញុំចង់នាំបាល់ចេញទៅប្រទេសចិន ហើយខ្ញុំត្រូវការជំនួយខ្លះដើម្បីជួយវេចខ្ចប់បាល់ទាំងនោះដើម្បីធ្វើការដឹកជញ្ជូន។ ខ្ញុំប្រាប់ពួកគេថាខ្ញុំនឹងបង់លុយឱ្យពួកគេ៥០០ដុល្លារសម្រាប់បាល់នីមួយៗដែលពួកគេបានដាក់ចូលទៅក្នុងប្រអប់។ ឧបមាថាពួកគេអាចវេចខ្ចប់បាល់បាន ២០០បាល់ក្នុងមួយថ្ងៃ ដែលពួកគេអាចរកលុយបានប្រមាណ ១០០,០០០ដុល្លារ ក្នុងមួយថ្ងៃ។ ខ្ញុំក៏នឹងផ្តល់កិច្ចសន្យារយៈពេលមួយឆ្នាំសម្រាប់ការវេចខ្ចប់បាល់ដល់ពួកគេក្នុងអាត្រាតម្លៃដដែលផងដែរ។ ឥឡូវនេះប្រសិនបើខ្ញុំប្រាប់ពួកគេថាចម្លើយរបស់ពួកគេនោះគឺ ការរកចំណូលសរុបបាន៥លានដុល្លារក្នុងរយៈពេល ១២ខែ តើពួកគេនឹងឆ្លើយតបបែបណាទៅ? «ងាយស្រួលណាស់ គ្មានបញ្ហាអ្វីទេ អ្នកអាចរកប្រាក់បាន៥លានដុល្លារយ៉ាងងាយស្រួលពីការងារនោះ។»

តើខុសប្លែកគ្នាត្រង់ណា? អ្វីដែលខុសគ្នានោះគឺផែនការមួយ។ ផែនការមួយធ្វើឱ្យអ្វីៗមើលទៅខុសប្លែកគ្នា។ ព្រះជាម្ចាស់ដែលបានបង្កើតអ្នកមកស្គាល់ពីផែនការនោះ និងអ្វីៗគ្រប់បែបយ៉ាងដែលអ្នកត្រូវធ្វើគឺស្តាប់ឮពីវា។ ដូច្នេះវានៅជាមួយនឹងព្រះរាជ្យនៃព្រះ។ ពេលព្រះជាម្ចាស់បានប្រទានសុបិននិមិត្តនោះដល់ខ្ញុំដើម្បីចាប់ផ្តើមធ្វើអាជីវកម្ម ហើយបន្ទាប់មកបានបង្ហាញខ្ញុំពីរបៀបធ្វើវា ប្រាក់ចំណូលរបស់ខ្ញុំនៅមិនទាន់បានផ្លាស់ប្តូរនៅឡើយទេ ក៏ប៉ុន្តែខ្ញុំកាលនោះខ្ញុំបានស្រែកនៅក្នុងចិត្តថា «កិច្ចការនេះងាយស្រួលទេតើ! បញ្ហារឿងលុយកាក់របស់ខ្ញុំចប់ហើយ ខ្ញុំមានផែនការរួចហើយ!»

*យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុកសម្រាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្តល់សេចក្តីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនាទេ។ យើងនឹងផ្តល់សេចក្តីសង្ឃឹម និងអនាគតល្អឱ្យអ្នករាល់គ្នា - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។*

យេរេមា ២៩ៈ១១

ព្រះជាម្ចាស់មានផែនការឱ្យអ្នកចម្រុងចម្រើនឡើង! ពេលអ្នករកឃើញថាព្រះជាម្ចាស់មានផែនការសម្រាប់ឱ្យអ្នកចម្រុងចម្រើន នោះអ្នកបានយកឈ្នះលើសមរភូមិពាក់កណ្ដាលទៅហើយ! សូមស្ដាប់ខ្ញុំ ការដោះស្រាយបញ្ហារឿងលុយកាក់វាមិនស្មុគស្មាញពេកទេ។ ការផ្គត់ផ្គង់គឺជាការគាំទ្រដល់និមិត្ត! វាពិតជាសាមញ្ញមែនទែន។ ចម្លើយឆ្លើយតបទៅនឹងការគ្មានគ្រឿងម្ហូបអាហារ គឺការមានគ្រឿងម្ហូបអាហារ។ ចម្លើយឆ្លើយតបទៅនឹងការត្រូវការផ្ទះធំជាងនេះមួយ គឺការមានផ្ទះមួយធំជាងនេះ។ ចម្លើយឆ្លើយតបទៅនឹងឡានដែលមានគុណភាពល្អ គឺជាធ្វើជាម្ចាស់របស់ឡានដែលមានគុណភាពល្អ។

**ក្នុងនាមជាប្រជាជននៅក្នុងព្រះរាជ្យនៃព្រះ អ្នកមានសិទ្ធស្របច្បាប់ ហើយរាល់ច្បាប់ និងគោលការណ៍ គឺមានសម្រាប់ឱ្យអ្នកអាចស្វែងរកបានក្នុងពេលឥឡូវនេះ។**

ខ្ញុំដឹងថាខ្ញុំកំពុងតែនិយាយដដែលៗនៅត្រង់នេះ ក៏ប៉ុន្តែខ្ញុំក៏ធ្លាប់បើកបរឡានចាស់ទ្រុឌទ្រោមអស់ពេលជាច្រើនឆ្នាំដែរ។ អ្នកអាចមើលឃើញខ្ញុំតាំងពីចម្ងាយនៅឆ្ងាយជាងមួយគីឡូដីមុនឯណោះ ដោយសារតែផ្សែងឡានរបស់ខ្ញុំហុយទ្រលោមពីក្រោយគ្រប់ទីកន្លែងដែលខ្ញុំទៅ។ ខ្ញុំស្គាល់អារម្មណ៍តានតឹងចិត្តដែលអាចកើតមានដោយសារតែបញ្ហាឡានខូច នៅពេលដែលអ្នកត្រូវការធ្វើដំណើរទៅទីណាមួយ។ ខ្ញុំក៏ស្គាល់អារម្មណ៍នៃការដើរចូលទៅក្នុងក្រុមហ៊ុនចែកចាយរថយន្តមួយកន្លែង និងបានទិញឡានថ្មីមួយគ្រឿងដោយប្រាក់សុទ្ធដែរ។ សូមទាយមើលថាមានអ្វីកើតឡើង? គឺគ្មានការតានតឹងចិត្ត គ្មានការព្រួយបារម្ភទៀតទេ។ ហេតុអ្វី? ដោយសារតែតម្រូវរបស់ខ្ញុំត្រូវបានបំពេញរួចទៅហើយ ម៉្យាងទៀតខ្ញុំក៏មានសេចក្ដីសុខសាន្តដែរ។ ខ្ញុំអាចផ្ដោតអារម្មណ៍លើអ្វីដែលខ្ញុំត្រូវធ្វើជាជាងត្រូវដោះស្រាយបញ្ហាផ្សេងៗជាមួយឡានខូចមួយគ្រឿង។

ការពិតនៅក្នុងបញ្ហានេះគឺថាមនុស្សភាគច្រើនត្រូវដោះស្រាយជាមួយនឹងបញ្ហាលុយកាក់រហូតដល់ធ្វើឱ្យខ្លួនឯងធ្លាក់ខ្លួនស្ថិតនៅក្រោមភាពតានតឹងស្ទើរតែពេញមួយជីវិតពួកគេ។ ពួកគេអាចនឹងកំពុងតែបំពេញការងារអស់ពេលជាច្រើនម៉ោងដើម្បីព្យាយាមសម្រេចបាននូវអ្វីដែលពួកគេគ្មាននៅក្នុងជីវិតរបស់ខ្លួន។ មិត្តទាំងអស់គ្នាអើយ ការធ្វើបែបនេះមិនស្របនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតអ្នកទេ។

ដូចជាអ្វីដែលខ្ញុំបានរៀបរាប់មុននេះមកថា មនុស្សបោះបង់ក្តីស្រមៃ និងចំណង់ចំណូលចិត្តរបស់ពួកគេដើម្បីតែប្រាក់ខែពីការងារជាច្រើនដែលពួកគេមិនចូលចិត្ត។ ជាទូទៅទាសករមិនមែនជាមនុស្សដែលសប្បាយចិត្តយ៉ាងខ្លាំងទេ។ តែគួរឱ្យសោកស្តាយណាស់មនុស្សជាច្រើនកំពុងរស់នៅក្នុងសភាពបែបនេះ ពួកគេមិនសប្បាយចិត្តនឹងកន្លែងដែលពួកគេរស់នៅ មិនសប្បាយចិត្តនឹងភាពគួរឱ្យស្អប់ខ្ពើម និងក្តីអស់សង្ឃឹមក្នុងជីវិតរបស់ពួកគេ។ ប៉ុន្តែជាក់ស្តែងកន្លែងទាំងនោះគ្រាន់តែជាទស្សនៈ ផ្លាស់ប្តូរមួយដែលឃ្លាតចេញពីសេរីភាព ឬដូចជាអ្វីដែលខ្ញុំទើបតែបានចែករំលែករួចមកហើយអំពីការមានផែនការប៉ុណ្ណោះ។

ខ្ញុំនឹងលើកពីឧទាហរណ៍ផ្ទាល់ខ្លួនមួយប្រាប់ដល់អ្នក។ មនុស្សជាច្រើនក្នុងចំណោមអ្នកទាំងអស់គ្នាដឹងថាខ្ញុំចូលចិត្តធ្វើការបរបាញ់សត្វ និងស្ទូចត្រី ជិះកង់ និងឡើងភ្នំជាដើមជាសកម្មភាពណាមួយដែលធ្វើនៅខាងក្រៅ។ ខ្ញុំធំធាត់ឡើងក្នុងរដ្ឋអូហៃយ៉ូ នៅក្នុងសហគមន៍ស្រែចម្ការតូចមួយដែលត្រូវបានគេស្គាល់ថាជាទីប្រជុំជនស្ថិតក្នុងវាលទំនាប។ គេបានហៅវាថាជាទីប្រជុំជនស្ថិតក្នុងវាលទំនាបគឺដោយសារតែ វាដូចជាអ្វីដែលអ្នកអាចស្រមៃមើលបានថា វាមានផ្ទៃដីរាបស្មើ។ ជាការពិតណាស់ដីបែបនោះមានលក្ខណៈល្អប្រសើរសម្រាប់កសិករ ក៏ប៉ុន្តែវាមិនមែនជាដីដែល មានទេសភាពទាក់ទាញបំផុតនោះទេ។ ខ្ញុំបានចុះឈ្មោះនៅលើប្រព័ន្ធអ៊ីនធើណិតដើម្បីមើលរាល់ទស្សនាវដ្តីអំពីការបរបាញ់ និងការនេសាទដែលខ្ញុំអាចរកបានមានដូចជាទស្សនាវដ្តី *Outdoor Life, Sports Afield, Field & Stream* និងទស្សនាវដ្តីផ្សេងទៀត។ ខ្ញុំនឹងអានរឿងដ៏អស្ចារ្យជាច្រើនអំពីការស្ទូចត្រី និងការបរបាញ់សត្វព្រៃ និងភ្នំដ៏ស្រស់ស្អាតជាច្រើននៅទិសខាងលិច និងភ្នំដែលមានពណ៌ខៀវស្រងាត់ជាច្រើន នៅជ្រលងភ្នំ Appalachian ដែលចំណាយពេលទៅដល់ត្រឹមតែមួយម៉ោងប៉ុណ្ណោះតាមទិសខាងកើត។ ខ្ញុំមិនធ្លាប់ទៅលេងនៅក្នុងតំបន់ទាំងនោះទេ។ ពេលដែលខ្ញុំបានឃើញភ្នំជាលើកដំបូងនោះ គឺនៅពេលខ្ញុំមានអាយុ ៤០ឆ្នាំ។

តើហេតុអ្វីទៅ? កាលនោះខ្ញុំមានប្រាក់សម្រាប់ធ្វើដំណើរ ខ្ញុំមានទាំងឡានផ្ទាល់ខ្លួនទាំងសិទ្ធិបើកបរឆ្លងកាត់រដ្ឋ ផ្លូវ I-៧០កាត់តាមស្រុកកំណើតខ្ញុំ និងធ្វើដំណើរទៅទិសខាងលិចឆ្លងកាត់ភ្នំរ៉ក់ឃី (Rocky) តែម្តង។ ក៏ប៉ុន្តែបញ្ហាដ៏ពិតប្រាកដនោះគឺថា ខ្ញុំមិនដែលគិតសូម្បីតែម្តងអំពីការទៅទីនោះ ឬសូម្បីតែអនុញ្ញាឱ្យខ្លួនឯងគិតពីវា «ខ្ញុំនឹងទៅទីនោះនៅថ្ងៃណាមួយ»។ ខ្ញុំបានស្ងើចសរសើរដល់ទីកន្លែងទាំងនោះតាមរយៈសន្លឹករូបថតរលោងៗនៅ

ក្នុងទស្សនាវដ្ដីមួយ ក៏ប៉ុន្តែខ្ញុំគិតថាចង់ទៅទីនោះសោះ។ ទីកន្លែងទាំងនោះមិនស្ថិតនៅឆ្ងាយដល់ឋានព្រះច័ន្ទដូចអ្វីដែលខ្ញុំគិតទេ វាគ្រាន់តែថា ខ្ញុំគិតថាការទៅទីនោះវាមិនអាចទៅរួចសោះ។ ទីបំផុតពេលខ្ញុំមានអាយុ៥០ឆ្នាំ ខ្ញុំបានបើកបរចេញទៅទិសខាងលិច ទៅដល់ខ្ញុំស្ទើរតែមិនជឿនូវអ្វីដែលអ្វីដែលខ្ញុំបានបាត់បង់នៅក្នុងជីវិតនេះសោះ។ ឥឡូវនេះខ្ញុំត្រូវតែចំណាយពេលយ៉ាងហោចណាស់ម្ដងក្នុងមួយឆ្នាំជាមួយនឹងតំបន់ភ្នំ។ មិត្តទាំងអស់គ្នាអើយ នៅខាងក្រៅមានអ្វីៗជាច្រើនទៀតដែលអ្នកមិនឃើញក្នុងពេលឥឡូវនេះ។ អ្នកអស្ចារ្យជាងអ្វីដែលអ្នកឃើញឥឡូវនេះ! មានទស្សនៈមួយផ្សេងទៀតចំពោះជីវិតដែលអ្នកត្រូវការមើលឃើញ និងទទួលបទពិសោធ។

**ពេលអ្នកចាប់ផ្ដើមយល់ និងរៀនពីរបៀបដែលព្រះរាជ្យនៃព្រះមានដំណើរការ និងអ្វីដែលព្រះរាជ្យនៃព្រះប្រាប់អ្នកពីអ្វីដែលមានរួចទៅហើយ នោះទស្សនៈរបស់អ្នកនឹងផ្លាស់ប្ដូរ!**

*ហេតុនេះ បងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។*

អេភេសូ ២៖១៩

ក្នុងនាមជាប្រជាជននៅក្នុងព្រះរាជ្យនៃព្រះ អ្នកមានសិទ្ធិស្របច្បាប់ ហើយរាល់ច្បាប់ និងគោលការណ៍ គឺមានសម្រាប់ឱ្យអ្នកអាចស្វែងរកបានក្នុងពេលឥឡូវនេះ។ រឿងនេះធ្លាប់ជាបញ្ហារបស់ឌ្រីនដា និងខ្ញុំ។ មិនថាយើងជាគ្រិស្តបរិស័ទ និងស្រលាញ់ព្រះជាម្ចាស់ក្ដី យើងធ្លាប់ជាប្រជាជននៅក្នុងព្រះរាជ្យនៃព្រះដែលគ្មានចំណេះដឹងពីច្បាប់ និងគោលការណ៍ផ្សេងៗនៃព្រះរាជ្យនៃព្រះទេ។ ដោយសារតែទស្សនៈនៅមានកម្រិតរបស់យើងដែលប្រព័ន្ធបណ្ដាសាលោកិយបានផ្ដល់មក ធ្វើឱ្យយើងគ្មានសុបិននិមិត្ត។ ក៏ប៉ុន្តែចំណេះទៅវិញទេដែលជាអំណាច។

ឧទាហរណ៍នៅក្នុងបន្ទប់សវនាការ កិច្ចសន្យាជួលដែលមានចុះហត្ថលេខាមួយច្បាប់បានបង្ហាញថាអ្នកមានសិទ្ធិស្របច្បាប់ដើម្បីរស់នៅក្នុងផ្ទះអ្នក។ ការយល់ដឹងថាមានឯកសារដែលមានចុះហត្ថលេខាមួយច្បាប់ និងសិទ្ធិទទួលបានយុត្តិធម៌ដើម្បីធានាដល់សិទ្ធិស្របច្បាប់របស់អ្នកដើម្បីរស់នៅក្នុងផ្ទះនោះ ដែលផ្ដល់ឱ្យអ្នកនូវសេចក្ដីសុខសាន្ត និងអំណរ។ ក្នុងរបៀបដូចគ្នានេះដែរ ការយល់ដឹងពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល និងអ្វី

ដែលព្រះរាជ្យនៃព្រះមានសម្រាប់អ្នក ផ្តល់ឱ្យអ្នកនូវទំនុកចិត្តដើម្បីកាន់កាប់អ្វីៗគ្រប់យ៉ាងដែលជាកម្មសិទ្ធិរបស់អ្នកដោយស្របច្បាប់។ ឧទាហរណ៍ តើតាពចម្រុងចម្រើនរបស់កសិករជាអ្វី? តើជាលុយមែនឬទេ? មិនមែនទេ។ តើជាគ្រាប់ពូជដែលគាត់ត្រូវសាបព្រោះមែនឬទេ? មិនមែនទេ។ វាគឺជាចំណេះដឹងដែលអ្នកមានអំពីច្បាប់ទាក់ទងនឹងការសាបព្រោះ និងការច្រូតកាត់។ មិនថាគាត់ក្រីក្រយ៉ាងណានោះទេ គាត់នឹងដឹងពីរបៀបក្លាយទៅជាអ្នកមានជាមិនខាន។ គាត់គ្រាន់តែធ្វើតាមច្បាប់នៅលើផែនដីដែលព្រះជាម្ចាស់បានបង្កើតមក។ ដំណើរការនៃពេលវេលាសាបព្រោះ និងច្រូតផលអាចកើតមានឡើងសម្រាប់កសិករម្តងហើយម្តងទៀត។

គាត់យល់ពីច្បាប់នៃការប្រមូលផល និងមានទំនុកចិត្តពេញលេញលើច្បាប់ទាំងនោះ។ គាត់សាបព្រោះគ្រាប់ពូជដែលមានតម្លៃរាប់ពាន់ដុល្លារទៅក្នុងដី តែទោះយ៉ាងណាគាត់មិនបានភ័យខ្លាចឡើយ។ អ្នកនឹងមិនឃើញមានកសិករណាម្នាក់អង្គុយនៅក្បែរត្រាក់ទ័ររបស់គាត់ពេលដែលគាត់បានសាបព្រោះគ្រាប់ពូជរួចរាល់ ហើយមកអង្គុយយំស្តាយលុយដែលគាត់បានចំណាយទាំងប៉ុន្មានដែលត្រូវព្រោះចោលទៅលើដីនោះទេ។ មិនដូច្នោះទេ គាត់នឹងមិនយំដោយសារតែតម្លៃគ្រាប់ពូជនោះទេ។ គាត់នឹងមានទំនុកចិត្តលើច្បាប់ដែលគ្រប់គ្រងលើផែនដីនេះតាមធម្មជាតិ។ តើគាត់អាចប្រាប់អ្នកបានដែរឬទេពីរបៀបដែលគ្រាប់ពូជលូតលាស់ឡើង? ខ្ញុំមិនប្រាកដទេថាគាត់អាចប្រាប់បាន ក៏ប៉ុន្តែគាត់អាចប្រាប់អ្នកបានថាគាត់កំពុងតែរកដីបន្ថែមទៀតដើម្បីដាំដុះ។ រឿងដូចគ្នានេះក៏ជាការពិតសម្រាប់អ្នក និងខ្ញុំដែរ។ លុះត្រាតែយើងស្គាល់ពីច្បាប់របស់ព្រះរាជ្យនៃព្រះ និងមានទំនុកចិត្តលើច្បាប់ទាំងនោះ មិនដូច្នេះទេយើងមិនអាចរីករាយនឹងជីវិតដែលព្រះជាម្ចាស់បានរៀបចំទុកឱ្យយើងរស់នៅទេ។

រឿងមួយដ៏គួរឱ្យរំភើបបំផុតក្នុងចំណោមរឿងជាច្រើននោះគឺ យើងបានធ្វើជាសាក្សីថានៅក្នុងពេលដំបូងៗទាំងនោះដែលបានកើតឡើងពេលខ្ញុំទទួលបានទូរស័ព្ទហៅចូលពីបុរសម្នាក់ ដែលខ្ញុំនឹងដាក់ឈ្មោះឱ្យគេថា «ដុន (Don)» ជាបុរសម្នាក់ដែលជួបប្រទះបញ្ហាធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ។ គាត់បានឮថាខ្ញុំបានជួយដល់មនុស្សជាច្រើនដែលមានបញ្ហាហិរញ្ញវត្ថុ។

ពេលដំបូងដែលខ្ញុំជួបដុន គាត់បានមកការិយាល័យរបស់ខ្ញុំក្នុងសភាពបាក់ទឹកចិត្តយ៉ាងខ្លាំង និងជាប់បំណុលផង។ គ្មានអ្វីម្យ៉ាងដែលរលូនទៅមុខឡើយនៅក្នុងជីវិតរបស់

គាត់កាលនោះ។ ពេលដែលខ្ញុំបានអង្គុយចុះ និងបាននិយាយជាមួយគាត់ ខ្ញុំបានដឹងថាគាត់មិនបានបង់ប្រាក់ឈ្នួលផ្ទះបីទៅបួនខែមកហើយ រួមជាមួយនឹងវិក្កយបត្រផ្សេងៗដែលគាត់មានដែរ។ កាលនោះក៏មានបញ្ហាទាក់ទងនឹងអាពាហ៍ពិពាហ៍ដែរ ប្រពន្ធរបស់គាត់ឆ្អែតឆ្អន់នឹងស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេ ហើយចាប់ផ្ដើមបាត់បង់ការគោរពចំពោះដុនដោយសារតែគាត់មិនអាចផ្គត់ផ្គង់ប្រពន្ធ និងកូនៗទាំងប្រាំរបស់ពួកគេបាន។ ជាក់ស្ដែងនោះគឺដុនបាត់បង់ការគោរពចំពោះខ្លួនគាត់ ហើយពេលនោះគាត់មានសុទ្ធតែចម្ងល់។

ការងារដែលគាត់ធ្វើក្នុងពេលនោះជាកិច្ចការពាក់ព័ន្ធនឹងការលក់ប័ណ្ណធានារ៉ាប់រងសុខភាពនៅជុំវិញរដ្ឋអូហៃយ៉ូ ក៏ប៉ុន្តែកង្វះខាតភាពជោគជ័យបាននាំគាត់ឱ្យធ្លាក់ចូលទៅក្នុងគ្រោះមហន្តរាយផ្នែកហរិញ្ញវត្ថុយ៉ាងឆាប់រហ័ស។ ទោះបីជាមានរឿងជាច្រើនកើតឡើងទាស់នឹងដុនក្ដី ខ្ញុំមើលឃើញពីសក្ដានុពលដែលគាត់មាន។ គាត់មានឆន្ទៈក្នុងការរៀន និង បំពេញការងារ។ ការរួមផ្សំគ្នាប្រកបដោយអំណាចនោះបានធ្វើឱ្យខ្ញុំមានការចាប់អារម្មណ៍នឹងគាត់ល្មមឱ្យខ្ញុំជ្រើសរើសគាត់មកបម្រើការងារ និងបានដាក់ខ្លួនខ្ញុំវិនិយោគនៅក្នុងសុខុមាលភាពនៃអនាគតរបស់គាត់។ ចុងក្រោយ វាបានក្លាយជាការវិនិយោគដែលផ្ដល់ឱ្យយើងទាំងពីរនាក់នូវភាគលាភដ៏សន្ធឹកសន្ធាប់។

ក្រុមហ៊ុនដែលប្រៀបបាននឹងបក្សីនៅមានស្លាបទន់នៅឡើយរបស់ខ្ញុំទើបតែបានទទួលរង្វាន់ជាដំណើរកម្សាន្តទៅរដ្ឋហាវ៉ៃពីឈ្មួញរបស់យើងម្នាក់ ហើយខ្ញុំមានអារម្មណ៍ថានេះអាចនឹងជាឱកាសដ៏ល្អសម្រាប់ខ្ញុំដើម្បីចែកចាយពីព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមួយនឹងដុន។ ទោះបីជាដុនគឺជាគ្រិស្តបរិស័ទក៏ដោយ តែគាត់គ្មានការយល់ឃើញដូចជាខ្ញុំមានទេ។ ហើយទោះបីជាខ្ញុំបានព្យាយាមយកឱកាសប៉ុន្មានដងមកហើយដើម្បីចែករំលែកពីគោលការណ៍របស់ព្រះជាម្ចាស់ជាមួយខ្ញុំទាក់ទងនឹងរឿងនេះ មើលទៅគាត់ដូចជាមិនជឿនូវអ្វីដែលខ្ញុំនិយាយឡើយ។

ខ្ញុំនៅតែរកវិធីដើម្បីចាប់យកចំណាប់អារម្មណ៍របស់ដុន ដែលនឹងជួយដល់គាត់ឱ្យដឹងថាគាត់ក៏ដូចគ្នាដែរ គឺគាត់អាចមានជោគជ័យតាមរយៈការរៀនសូត្រពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់បានធ្វើការ។ ទោះជាយ៉ាងណាក៏ដោយ ដុនពេលនោះហាក់ដូចជាបាក់ទឹកចិត្តខ្លាំង ដែលធ្វើឱ្យគាត់មានការលំបាកក្នុងការជឿលើខ្លួនគាត់ និងជឿថាការផ្លាស់ប្ដូរពិតជាអាចកើតឡើងបានពិតមែន។ ខ្ញុំបានដឹងរួចមកហើយថាដំណើរកម្សាន្តទៅហាវ៉ៃនេះជាឱកាសរបស់ខ្ញុំ។

នៅក្នុងពេលជាច្រើនសប្ដាហ៍មុនពេលដែលដុន និងខ្ញុំរៀបចេញដំណើរ យើងបាននិយាយគ្នាពីអ្វីដែលយើងអាចទៅមើល និងធ្វើនៅទីនោះ។ មានរឿងដ៏គួរឱ្យចាប់អារម្មណ៍ដ៏ពិសេសមួយ បានឆក់យកចំណាប់អារម្មណ៍របស់ដុន ដែលមិនធ្លាប់មានអ្វីធ្វើឱ្យគាត់ចាប់អារម្មណ៍ដូចរឿងនេះទេ។ កាលនោះគាត់ចង់ចាប់ត្រីម៉ារីនពណ៌ខៀវដែលរស់នៅក្នុងទឹកដ៏ស្រស់ស្អាតនៃមហាសមុទ្រប៉ាស៊ីហ្វិក។ «នៅហាវ៉ៃគឺជាទីប្រជុំដ៏ធំនៃត្រីម៉ារីនពណ៌ខៀវនៃពិភពលោកនេះ» ដុនបាននិយាយប្រាប់ខ្ញុំទាំងចិត្តរំភើប។ «ខ្ញុំតែងតែចង់ស្ទូចត្រីម៉ារីនពណ៌ខៀវនេះ វាគឺជាអ្វីដែលខ្ញុំសុបិនចង់ធ្វើ។» អស់រយៈពេលជាច្រើនសប្ដាហ៍មកហើយ នេះគឺជាលើកដំបូងដែលខ្ញុំបានឃើញពន្លឺមួយនៅក្នុងកែវភ្នែករបស់ដុន។ មានអ្វីម្យ៉ាងពិតជាធ្វើឱ្យគាត់មានអារម្មណ៍រំភើប ហើយខ្ញុំដឹងមុនថាក្ដីរំភើបរបស់គាត់នឹងបើទ្វារចំហសម្រាប់ទទួលមេរៀនដ៏មានអំណាចមួយ។

ខ្ញុំបាននិយាយថា «ដុន តើប្អូនដឹងទេថា ប្អូនអាចដឹងបាន មិនមែនគ្រាន់តែសង្ឃឹមទុកទេ ថាប្អូននឹងចាប់ត្រីម៉ារីនខៀវនៅហាវ៉ៃបាន ដោយការនៅជាប់ជាមួយនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់?» ដុនស្ដាប់ទៅដូចជាច្របូកច្របល់ តែហាក់ដូចជាចាប់អារម្មណ៍ខ្លាំងណាស់ ហើយគាត់ចង់ដឹងបន្ថែមទៀត ទើបខ្ញុំបានបន្តពន្យល់គាត់អំពីព្រះរាជ្យនៃព្រះ។ ខ្ញុំបានដកស្រង់ពាក្យចេញពីគម្ពីរម៉ាកុស ១១:២៤ ចែងថា *«ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថាអ្វីក៏ដោយឱ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។»* សម្រាប់ដុនរឿងស្ដាប់ទៅដូចជារឿងមិនគួរឱ្យជឿ។ ខ្ញុំបានចំណាយពេលខ្លះដើម្បីជួយឱ្យគាត់បានយល់ពីព្រះរាជ្យនៃព្រះ និងរបៀបដែលគាត់បង្ហាញចេញនូវជំនឿរបស់គាត់។ ហេតុដូច្នេះហើយ មុនពេលយើងចេញដំណើរ គាត់ និងប្រពន្ធរបស់គាត់បានអធិស្ឋានដោយមានការយល់ស្របគ្នា និងបានជឿថាពួកគេបានទទួលត្រីម៉ារីនពណ៌ខៀវរួចទៅហើយ។ ពួកគេក៏បានសាបព្រោះគ្រាប់ពូជហិរញ្ញវត្ថុចូលទៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់ឆ្ពោះទៅរកការប្រមូលផលរបស់ពួកគេដែរ។ នេះគឺជាអ្វីម្យ៉ាងដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបង្រៀនខ្ញុំឱ្យធ្វើពេលខ្ញុំបង្ហាញចេញនូវជំនឿរបស់ខ្ញុំ ចំពោះអ្វីៗដែលខ្ញុំត្រូវការ។

ក្នុងពេលជាមួយគ្នានោះ ដុនបានធ្វើអ្វីៗគ្រប់យ៉ាងដែលគាត់បានដឹងដើម្បីប្រតិបត្តិតាមផ្នែករបស់គាត់អំពីការច្រូតផល។ គាត់បានធ្វើការស្រាវជ្រាវអំពីកប៉ាល់ដែលអាចរកបាន និងតម្លៃ ហើយចុងក្រោយគាត់បានកក់កប៉ាល់ជាមួយនឹងកាពីទែនប៉ាល់ដែល

គាត់ពេញចិត្ត។ អ្វីៗគ្រប់យ៉ាងបានរៀបចំរៀបរយ ហើយយើងទាំងអស់គ្នារំភើបចិត្តយ៉ាងខ្លាំងអំពីការធ្វើដំណើរលើទឹកពណ៌ខៀវនៅហាវ៉ៃ។

ថ្ងៃចេញកប៉ាល់ក៏ចូលមកដល់ ហើយក្នុងពេលដែលយើងចេញកប៉ាល់យើងបានប្រាប់ទៅនាយកប៉ាល់ដោយក្ដីរីករាយថាថ្ងៃនេះជាថ្ងៃដែលយើងនឹងចាប់បានត្រីម៉ារីនពណ៌ខៀវ។ ខណៈពេលរំពឹងថាថ្ងៃនេះជាថ្ងៃជោគជ័យរបស់យើងក្នុងការស្ទូចត្រីផ្សេងទៀតដើម្បីកម្សាន្តនោះ គាត់ក៏បានអះអាងដែរថា យើងមានឱកាសតិចតួចណាស់ដែលអាចចាប់បានត្រីម៉ារីនខៀវនៅថ្ងៃនោះ។ ដោយមានកប៉ាល់សម្រាប់ជួលទេសចរណ៍ចំនួនពីរជារៀងរាល់ថ្ងៃ សម្រាប់រយៈពេលបួនខែចុងក្រោយនេះ អ្នកជិះលើកប៉ាល់របស់គាត់អាចស្ទូចត្រីម៉ារីនខៀវបានតែមួយប៉ុណ្ណោះ។ ហេតុផលដ៏ធំនោះគឺដោយសារតែការពិតទៅនេះមិនមែនជារដូវសម្បូរត្រីម៉ារីននៅឡើយទេ ដោយសារតែត្រីម៉ារីននេះជាត្រីដែលធ្វើបំលាស់ទីពីតំបន់ផ្សេង។ ដោយមិនទទួលការបំបាក់ទឹកចិត្ត យើងបានប្រាប់គាត់ដោយមានការគោរពថាយើងនឹងស្ទូចបានត្រីមួយ និងបាននៅតែបន្តត្រៀមចិត្តកាយរួចជាស្រេច។

បន្ទាប់ពីចំណាយពេលអស់៦ម៉ោងក្នុងការបោះនុយសន្ទូចរបស់យើង នោះយើងមិនឃើញសូម្បីតែសញ្ញាមួយថានឹងស្ទូចបានត្រី ហើយពេលនោះខ្ញុំចាប់ផ្ដើមបារម្ភបន្តិចថាបើសិនជាយើងមិនសូវមានសកម្មភាពអ្វីវា អាចនឹងធ្វើឱ្យជំនឿរបស់ដុនចុះខ្សោយបាន។ ដោយមានការបារម្ភបន្តិច ខ្ញុំបានស្រែកសួរទៅគាត់ ខ្ញុំបានស្រែកសួរគាត់ពីជាន់ខ្ពស់ជាងនៅលើស្ពានមួយពីលើគាត់ថា «ដុនអើយ សុំសួរមួយ។ ពេលណាទៅដែលប្អូនចាប់បានត្រីម៉ារីនខៀវនោះ? ពេលដែលវាបង្ហាញខ្លួន ឬពេលយើងអធិស្ឋាន?» ដុនបានតបដោយមាំទាំទាំងមានទំនុកចិត្តថា «ហ្គារីអើយ វាសាមញ្ញទេ។ ខ្ញុំចាប់វាបានពេលដែលខ្ញុំអធិស្ឋាន»។ កាលនោះខ្ញុំមានចិត្តរំភើប និងមានទំនុកចិត្តពេលខ្ញុំបានឮគាត់ឆ្លើយតបបែបនោះ។ ពេលនោះហើយដែលខ្ញុំបានដឹងថាដុនបានយកចិត្តទុកដាក់ទទួលយកការណែនាំរបស់ខ្ញុំណាស់ ហើយគាត់បានប្ដេជ្ញាចិត្តដើម្បីចាប់ត្រីម៉ារីនខៀវឱ្យបាន។

ប៉ុន្មាននាទីក្រោយមក ដុំរ៉ៃខ្សែសន្ទូចរបស់ដុនចាប់ផ្ដើមបន្លឺសំឡេងឡើង ក្នុងពេលដែលសន្ទូចចំកោងខ្លួនឆ្ពោះទៅសមុទ្រ ហើយមិត្តរួមដំណើរក៏ស្រែកឡើងថា «ត្រីស៊ីសន្ទូចហើយ!»

កាពីទែនកប៉ាល់និយាយដោយប្រុងប្រយ័ត្នថា «កុំអាលរំភើបចិត្តពេក។ វាជាត្រីធំពិតមែន ក៏ប៉ុន្តែវាមិនមែនជាត្រីម៉ារីនខៀវទេ។ ត្រីម៉ារីនខៀវច្រើនតែឡើងមកលើផ្ទៃទឹក និង

លោតឡើងយ៉ាងសម្បើមទៅលើ តែមើលត្រីនេះចុះវាដូចជានៅជ្រៅណាស់»។ ពេលវេលាចេះតែកន្លងផុតពេលដែលដុនបានបន្តប្រទាញប្រទុងជាមួយនឹងត្រីដែលមិនទាន់ឡើងមកជិតផ្ទៃទឹកខាងលើ ល្មមឱ្យគ្រប់គ្នាមើលឃើញត្រីនោះនៅឡើយ។ ដូចដែលដុនកំពុងតែអស់កម្លាំងបន្តិចម្តងៗទៅ ត្រីនោះក៏អស់កម្លាំងដូចគ្នា ហើយវាក៏ឈប់ប្រទាញប្រទង់នៅក្នុងដំណើរប្រឆាំងគ្នានេះទៅ។ ទាំងដុន និងខ្ញុំមិនបានភ្ញាក់ផ្អើលអ្វីសោះឡើយពេលគាត់បានរវៃខ្សែសន្ទូចដែលមានជាប់ត្រីម៉ារីនដ៏ធំ និងស្រស់ស្អាតមកជាមួយ តែអ្នកផ្សេងទៀតគ្រប់គ្នានៅលើកកប៉ាល់នោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

រូបថតរបស់ដុន និងត្រីរបស់គាត់នៅតែរក្សាទុកនៅក្នុងការិយាល័យរបស់ខ្ញុំដល់សព្វថ្ងៃនេះទុកជាទីបន្ទាល់ដល់អ្នកដទៃទៀត និងជាការរឭកដល់ខ្ញុំជានិច្ចអំពីការពិតនៃព្រះរាជ្យនៃព្រះ។ មើលពីខាងក្រៅវាគ្រាន់តែជាត្រីមួយក្បាល។ តែចំពោះដុនវិញ ត្រីម៉ារីនខៀវនេះមានអត្ថន័យជ្រាលជ្រៅជាងនេះទៅទៀត។ ប្រសិនបើព្រះរាជ្យនៃព្រះបានធ្វើការចំពោះត្រីម៉ារីន ព្រះរាជ្យក៏ច្បាស់ជាអាចធ្វើការផ្សេងទៀតគ្រប់បែបយ៉ាងដែលគាត់ត្រូវការក្នុងជីវិតគាត់ដែរ។ សម្រាប់ដុនវាគ្រាន់តែជាការចាប់ផ្តើមក្នុងការដឹងថា ការប៉ះពាល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់អាចកើតមានឡើងនៅក្នុងជីវិតរបស់គាត់។

ខ្ញុំស្រលាញ់សាច់រឿងនេះណាស់ ហើយខ្ញុំស្រលាញ់ការមើលឃើញបទពិសោធពិតជាមួយនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ណាស់។ នោះហើយជាអ្វីដែលខ្ញុំចង់បានសម្រាប់អ្នកទាំងអស់គ្នាដែរ!

# ជំពូក ៤
# ខ្ញុំរកឃើញកូនសោសំខាន់ នៃព្រះរាជ្យរបស់ព្រះជាម្ចាស់

ពួកយើងទាំងអស់គ្នាមានកូនសោតាមប្រភេទផ្ទះរបស់យើង ប្រភេទរថយន្ត និងអ្វីៗផ្សេងទៀតដែលយើងចង់ការពារ។ គន្លឹះសំខាន់បានជួយឱ្យយើងចូលទៅកាន់អ្វីដែលត្រូវបានការពារពីខាងក្នុង ឬសិទ្ធិអំណាចដើម្បីប្រើប្រាស់របស់អ្វីមួយ ដូចជារថយន្តជាដើម។ ការរស់នៅដូចជាគ្រិស្តបរិស័ទរយៈពេលប្រាំបួនឆ្នាំដ៏យូរអង្វែងនៅក្នុងស្ថានភាពរីករវផ្នែកហិរញ្ញវត្ថុ និងដោយភាពអស់សង្ឃឹម នោះខ្ញុំដឹងថាមានអ្វីមួយកំពុងតែបាត់បង់ មានអ្វីមួយដែលខុស។ មិនចាំបាច់មាននរណាម្នាក់មកប្រាប់ខ្ញុំពីចំណុចនេះឡើយ។ អ្វីដែលខ្ញុំចាំបាច់ត្រូវដឹងនោះគឺ តើមានខុសអ្វី ហើយតើត្រូវដោះស្រាយវាដោយរបៀបណា។

នៅពេលព្រះអម្ចាស់មានព្រះបន្ទូលមកកាន់ខ្ញុំ នៅពេលខ្ញុំស្រែកហៅសុំឱ្យទ្រង់ជួយដោយបានគេងសន្ទឹងលើគ្រែនៅក្នុងផ្ទះចម្ការបាក់បែក នោះទ្រង់មានបន្ទូលប្រាប់ខ្ញុំថា បញ្ហារបស់ខ្ញុំគឺថា ខ្ញុំមិនដែលរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការឡើយ។ នៅក្នុងពាក្យមួយឃ្លានេះ ខ្ញុំបានឮនូវពាក្យគន្លឹះ ឬខ្ញុំគួរនិយាយថា ចាំបាច់ត្រូវមានប្រភពនៃពាក្យគន្លឹះ ឬចាំបាច់ត្រូវមានគន្លឹះសំខាន់នោះគឺពាក្យ ព្រះរាជ្យ។ ព្រះជាម្ចាស់កំពុងមានបន្ទូលប្រាប់ខ្ញុំថាចម្លើយនោះគឺនៅក្នុងព្រះរាជ្យរបស់ទ្រង់។ ខ្ញុំមិនដែលចំណាយពេលរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការឡើយ ប៉ុន្តែប្រសិនបើខ្ញុំធ្វើវា នោះខ្ញុំប្រាកដជាបានចម្លើយមិនខាន។ នៅពេលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅថ្ងៃនោះដែលទាក់ទងនឹងកង្វះខាតរបស់ខ្ញុំក្នុងការយល់ដឹងពីព្រះរាជ្យនៃព្រះ ខ្ញុំពិតជាទាល់គំនិតតែម្តងពីអ្វីដែលទ្រង់ចង់មានន័យថាព្រះរាជ្យនោះ។ ប៉ុន្តែខ្ញុំបានស្តាប់ឮទ្រង់យ៉ាងខ្លាំង និងច្បាស់ថា ប្រសិនបើខ្ញុំរៀនពីរបៀបដែលព្រះ

រាជ្យទ្រង់ដំណើរការ នោះខ្ញុំប្រាកដជារកឃើញចម្លើយដែលខ្ញុំកំពុងស្វែងរកនោះ។ ដូចនេះ សម្រាប់ខ្ញុំ គន្លឹះដ៏ធំមួយគឺជាប្រយោគទូទៅមួយ «អ្នកមិនដែលចំណាយពេលរៀនពីរបៀបដែលព្រះរាជ្យយើងដំណើរការឡើយ!» ពិតណាស់ នៅក្នុងប្រយោគនេះនិយាយជាច្រើនណាស់ គឺបាននិយាយពីគន្លឹះសំខាន់ខ្លាំងទីមួយដែលធ្វើឱ្យជីវិតខ្ញុំផ្លាស់ប្រែ។

*ដ្បិតមានព្រះរាជបុត្រមួយអង្គប្រសូតមកសម្រាប់យើង ព្រះជាម្ចាស់បានប្រទានព្រះបុត្រាមួយព្រះអង្គមកយើងហើយ។ បុត្រនោះទទួលអំណាចគ្រប់គ្រងគេនឹងថ្វាយព្រះនាមថាៈ "ព្រះដ៏គួរស្ងើចសរសើរ ព្រះប្រកបដោយព្រះប្រាជ្ញាញាណ ព្រះដ៏មានឫទ្ធិចេស្ដា ព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គម្ចាស់នៃសេចក្ដីសុខសាន្ត។ ព្រះរាជបុត្រនោះនឹងលាតសន្ធឹងអំណាច ព្រះអង្គនឹងធ្វើឲ្យរាជបល្ល័ង្ករបស់ព្រះបាទដាវីឌ និងនគររបស់ព្រះអង្គមានសេចក្ដីសុខសាន្តរហូតតទៅ។ ព្រះអង្គយកសេចក្ដីសុចរិត និងយុត្តិធម៌ មកពង្រឹងនគររបស់ព្រះអង្គឲ្យគង់វង្ស ចាប់ពីពេលនេះ រហូតអស់កល្បជាអង្វែងតរៀងទៅ ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូលសម្រេចដូច្នេះ មកពីព្រះអង្គមានព្រះហឫទ័យស្រឡាញ់យ៉ាងខ្លាំងចំពោះយើង។*

*អេសាយ ៩៖៦-៧*

ការយល់ឃើញថាព្រះរាជ្យនៃព្រះ តាមពិតជារាជាណាចក្រដែលមានមុខងារលើមូលដ្ឋាននៃរដ្ឋាភិបាលគ្រប់គ្រង និងច្បាប់ បានបើកភ្នែកខ្ញុំឱ្យមើលឃើញការយល់ដឹងអំពីព្រះរាជ្យដែលខ្ញុំមិនដែលបានដឹងពីមុនមក។ ការដឹងថាព្រះរាជ្យនៃព្រះត្រូវបានបង្កើតឡើងហើយព្រះរាជ្យនេះកំពុងត្រូវបានគាំពារដោយភាពយុត្តិធម៌ (រដ្ឋបាលនីតិបញ្ញត្តិ) និងសេចក្ដីសុចរិតរបស់ព្រះ (ច្បាប់របស់ទ្រង់) ដែលបានបង្ហាញខ្ញុំថា អ្វីៗដែលបានកើតឡើងនៅក្នុងព្រះរាជ្យគឺជាលទ្ធផលនៃច្បាប់ និងគោលការណ៍នៃព្រះរាជ្យ។ ខ្ញុំអាចមិនមានភាពវៃឆ្លាតខ្លាំងនៅក្នុងគំនិតនេះ តែខ្ញុំមានប្រាជ្ញាគ្រប់គ្រាន់ក្នុងការស្វែងយល់ថា ប្រសិនបើព្រះរាជ្យត្រូវបានដំណើរការដោយឈរលើមុខងារនៃច្បាប់ នោះខ្ញុំអាចរៀនសូត្របានពីច្បាប់ទាំងនោះ និងយកវាទៅអនុវត្តនៅក្នុងជីវិតរបស់ខ្ញុំ។ នៅពេលព្រះជាម្ចាស់បានចាប់ផ្ដើមបើកបង្ហាញ និងបង្រៀនដល់គ្រិនដា និងខ្ញុំពីច្បាប់របស់ទ្រង់ នោះខ្ញុំបានចាប់ផ្ដើមដឹងថាគ្រប់សាច់រឿងនីមួយៗនៅក្នុងព្រះគម្ពីរមានផ្ទុកនូវគន្លឹះសំខាន់ដែលខ្ញុំចាំបាច់ត្រូវដឹង ទាក់ទិននឹងរបៀបដែលព្រះរាជ្យដំណើរការ។ ខ្ញុំបានចាប់ផ្ដើមអានរឿងនីមួយៗនៅក្នុងព្រះគម្ពីរដោយរបៀបផ្សេងៗគ្នា៖ «ហេតុ

អ្វីបានជាការនោះកើតឡើង? ហេតុអ្វីបានជាការនោះមិនកើតឡើង?» ខ្ញុំតែងអានសាច់រឿងនីមួយៗដោយឥរិយាបថបែប «តើនៅក្នុងសាច់រឿងនេះមានបង្ហាញនូវគោលការណ៍អ្វីខ្លះ? តើការនោះកើតឡើងបានយ៉ាងដូចម្ដេច?»

ខ្ញុំបានចាប់ផ្ដើមហៅខ្លួនឯងថាជាអ្នកវិទ្យាសាស្ត្រផ្នែកព្រលឹងវិញ្ញាណ ហើយខ្ញុំរំភើបណាស់ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបើកបង្ហាញឱ្យខ្ញុំបានដឹងពីច្បាប់មួយហើយមួយទៀត។ ខ្ញុំកាន់តែរំភើបជាងមុនទៅទៀតក្នុងការដឹងថាខ្ញុំបានរកឃើញថាច្បាប់ដែលខ្ញុំបានរកឃើញនោះអាចយកមកប្រតិបត្តិនៅក្នុងជីវិតរបស់ខ្ញុំផ្ទាល់ ដូចដែលវាបានធ្វើនៅក្នុងព្រះគម្ពីរដែរ។ មនុស្សម្នាបានសួរខ្ញុំថា «ហ្គារី តើច្បាប់នៃព្រះរាជ្យនោះមានន័យអ្វី?» ខ្ញុំតែងតែរំឭកពួកគេពីច្បាប់ទាំងអស់ដែលពួកគេប្រើប្រាស់នៅលើពិភពផែនដីនេះ និងច្បាប់ទាំងអស់ដែលគ្រប់គ្រងធម្មជាតិ។

កសិករម្នាក់ប្រើប្រាស់ច្បាប់ទាំងនេះនៅពេលគាត់ចង់ប្រើ គាត់មិនចាំបាច់អធិស្ឋានឱ្យការទាំងនោះដំណើរការទេ។ ច្បាប់ទាំងនេះអាចធ្វើទៅបាននៅពេលគាត់សម្រេចចិត្តប្រើវា។ ច្បាប់ទាំងនេះអាចប្រើបានសម្រាប់មនុស្សគ្រប់គ្នា និងសម្រាប់គ្រប់គ្នាដែលចង់ប្រើវា។ ក្នុងរបៀបដូចគ្នានេះដែរ ព្រះរាជ្យនៃព្រះដំណើរការទៅបានជាមួយនឹងច្បាប់ដែលអាចយកមករៀនសូត្របាន។ ដោយសារតែទាំងនេះជាច្បាប់ នោះពួកវាមិនដែលផ្លាស់ប្ដូរឡើយ ហើយពួកគេក៏អាចយកមករៀនសូត្របាន និងយកមកអនុវត្តចំពោះជីវិតនៅក្នុងព្រះរាជ្យនេះផងដែរ។

**នៅពេលព្រះជាម្ចាស់បានចាប់ផ្ដើមបើកបង្ហាញ និងបង្រៀនដល់ខ្ញុំ ដា និងខ្ញុំពីច្បាប់របស់ទ្រង់ នោះខ្ញុំបានចាប់ផ្ដើមដឹងថាគ្រប់សាច់រឿងនីមួយៗនៅក្នុងព្រះគម្ពីរមានផ្ទុកនូវគន្លឹះសំខាន់ដែលខ្ញុំចាំបាច់ត្រូវដឹងទាក់ទិននឹងរបៀបដែលព្រះរាជ្យមានដំណើរការ។**

ដូចនេះ នៅពេលអ្នកទទួលជឿព្រះគ្រិស្ត អ្នកជាពលរដ្ឋនៃព្រះរាជ្យរបស់ទ្រង់ ហើយព្រះរាជ្យទាំងអស់របស់ទ្រង់ គឺជារបស់អ្នក។ អ្នកក៏អាចយកច្បាប់នៃព្រះរាជ្យនៃព្រះមករៀនសូត្រ និងប្រើប្រាស់ផងដែរ។

«មិនអីទេ» នេះជាពាក្យដែលមនុស្សម្នានឹងប្រាប់ខ្ញុំ «ខ្ញុំយល់ពីចំណុចនោះ ប៉ុន្តែសូមលើកជាឧទាហរណ៍ពីច្បាប់មួយនៃព្រះរាជ្យទៅមើល។» គឺថាមានច្បាប់ច្រើនណាស់ ច្រើនមែនទែន។ តាមពិតទៅ ខ្ញុំបានសរសេរចំណុចនៃច្បាប់មួយចំនួនទៅហើយ ដូចជាច្បាប់យុត្តា

ធិការ ច្បាប់នៃជំនឿ និងច្បាប់នៃការឯកភាព ទោះបីជាខ្ញុំមិនបានលើកឡើងច្រើន និងកំណត់ឈ្មោះវាដូចនេះនៅក្នុងជំពូកមុនៗក៏ដោយ។ ជាថ្មីម្តងទៀត មានច្បាប់ច្រើនណាស់ ហើយច្បាប់ទាំងអស់នេះអាចនឹងបំបែកជាចំណែកតាមមុខងារ និងការអនុវត្ត ដែលជាផ្នែកនានាដែលយើងពិតជាចង់ផ្តោតលើវាយ៉ាងពិតប្រាកដ។ ខ្ញុំសូមលើកសាច់រឿងមួយប្រាប់ដល់លោកអ្នកដើម្បីជួយបើកបង្ហាញពីអ្វីដែលខ្ញុំកំពុងនិយាយ។

ខ្ញុំមានយន្តហោះមួយគ្រឿង ជាប្រភេទយន្តហោះតូចប្រភេទ Piper Mirage ដែលខ្ញុំប្រើប្រាស់វាដើម្បីហោះទៅចូលរួមប្រជុំ ដើម្បីជួបជាមួយអតិថិជនដៃគូ និងដើម្បីធ្វើដំណើរក្នុងវិស័យធុរកិច្ច។ ខ្ញុំមាននូវដំណើរការងារមួយដែលគ្រោងនឹងទៅរដ្ឋខូឡូរ៉ាដូដើម្បីចូលរួមសន្និបាត និងបានរៀបគម្រោងយ៉ាងយកចិត្តទុកដាក់ពីការថែទាំប្រចាំឆ្នាំលើការពិនិត្យពិច័យយាន្តដែលច្បាប់តម្រូវនៅក្នុងការធ្វើដំណើរទៅមកនោះ។ អ្នកគួរតែបានដឹងហើយថា គ្រប់យន្តហោះនីមួយៗដែលធ្វើដំណើរនៅក្នុងសហរដ្ឋ គឺតម្រូវឱ្យជាប់ការពិនិត្យមួយឆ្នាំម្តងចំពោះការថែទាំប្រចាំឆ្នាំ។ អ្នកបើកយន្តហោះរបស់ខ្ញុំរៀបនឹងទៅយកយន្តហោះMirage ហើយបម្រុងនឹងដឹកពួកយើងទៅប្រជុំទៅហើយ។ ប៉ុន្តែនៅថ្ងៃនោះ មុននឹងគាត់ទៅយកវា នោះខាងហាងក៏បានទូរស័ព្ទមក ហើយនិយាយថាពួកគេបានធ្វើឱ្យផ្លិតទឹកនៅកញ្ចក់ខាងមុខនោះបាក់ដោយចៃដន្យ។ ពួកគេនឹងដូរថ្មីឱ្យដោយឥតគិតថ្លៃ ប៉ុន្តែដំណើរការនៃការដាក់វាឡើងវិញនោះត្រូវប្រើពេលអស់បីថ្ងៃទៀតមុននឹងយន្តហោះនោះអាចហោះហើរបាន។ នោះមានន័យថាឌ្រិនដា និងខ្ញុំត្រូវតែជិះយន្តហោះតាមជើងក្រុមហ៊ុនហោះហើររកស៊ីទៅកាន់រដ្ឋខូឡូរ៉ាដូហើយ។ គ្មានអ្វីត្រូវត្អូញត្អែរទេ ប៉ុន្តែប្រសិនបើអាច ពួកយើងតែងតែចង់ជិះយន្តហោះផ្ទាល់ខ្លួនទៅគ្រប់ទីកន្លែងដែលពួកយើងទៅ។ ពួកយើងក៏មានការខកចិត្តបន្តិចបន្តួចដែរ ប៉ុន្តែពួកយើងក៏បានរកមធ្យោបាយទៅចូលរួមសន្និបាតនោះ។ ចំណែកយន្តហោះនោះ គឺអ្នកបើកយន្តហោះរបស់ពួកយើងនឹងត្រូវបើកទៅយកពួកយើងសម្រាប់ការវិលត្រលប់មករដ្ឋអូហៃយ៉ូវិញ។

រយៈពេលពីរថ្ងៃនៃសន្និបាតនោះ ក៏ស្រាប់តែមានព្យុះព្រិលបោកបក់ក្នុងតំបន់នោះភ្លាមៗ។ គ្រាប់ព្យុះព្រិលនោះធំៗណាស់ ដែលវាបានបំផ្លាញតំបន់នោះទាំងស្រុង។ នៅក្នុងតំបន់ខ្លះទៀត មានដុំទឹកកកធំមួយបានធ្លាក់មកទម្លុះដំបូល។ រថយន្តរាប់រយគ្រឿងត្រូវបានបំផ្លាញដោយជួសជុលលែងកើត។ អាគារ និងដំបូលត្រូវបានបំផ្លាញ។ នៅពេលអ្នកបើកយន្តហោះរបស់ខ្ញុំមកយកពួកយើង នោះគាត់បានចតនៅកន្លែង FBO ដែលយើងអាចនឹងបានចតយន្តហោះនោះនៅទីនោះប្រសិនបើពួកយើងបានជិះមកពីថ្ងៃដំបូងនៃសន្និបាត។ ខ្ញុំក៏បានឃើញនូវ

ទិដ្ឋភាពដ៏គួរឱ្យភ្ញាក់ផ្អើលមួយ។ យន្តហោះនីមួយៗដែលបានចតនៅកន្លែងដែលយន្តហោះខ្ញុំគួរតែបានចតនោះ សុទ្ធតែបានខូចខ្ទេចខ្ទីអស់។ ដោយសារតែព្រះគុណរបស់ព្រះ យន្តហោះរបស់ខ្ញុំមិននៅទីនោះ ហើយក៏មិនត្រូវបានបំផ្លាញដែរ។ រឿងនេះប្រាកដណាស់ថាជារឿងអស្ចារ្យ ប៉ុន្តែតើវាបានកើតឡើងយ៉ាងដូចម្តេចទៅ? ខ្ញុំចង់មានន័យថា តើវាគ្រាន់តែជារឿងចៃដន្យ ឬការដែលយន្តហោះនោះមិននៅទីនោះក៏ព្រះតែជាលទ្ធផលនៃច្បាប់ខាងវិញ្ញាណដែលខ្ញុំទទួលបានផលចំណេញពីច្បាប់នេះ?

ខ្ញុំដឹងច្បាស់ដែលថាវាជាលទ្ធផលនៃច្បាប់ខាងវិញ្ញាណដែលខ្ញុំបានធ្វើវាឡើង ដែលខ្ញុំនឹងចែករំលែកជាមួយលោកអ្នកពេលខាងមុខនេះ។ ការយល់ពីច្បាប់អនុញ្ញាតឱ្យអ្នកចម្លងនូវលទ្ធផលនៅពេលដែលអ្នកចង់ចម្លងវាចេញមក។ នៅក្នុងករណីនេះ ខ្ញុំបានអនុវត្តច្បាប់មួយដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំកាលពីចំណុចចាប់ផ្តើម នៅពេលដែលព្រះជាម្ចាស់បានចាប់ផ្តើមបណ្តុះបណ្តាលខ្ញុំពីដំបូងនៅក្នុងច្បាប់នៃព្រះរាជ្យរបស់ទ្រង់ និងការដំណើរការនៃព្រះរាជ្យ។

ខ្ញុំសូមបង្ហាញអ្នកពីច្បាប់ដែលព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំ បន្ទាប់មកខ្ញុំនឹងបង្ហាញអ្នកពីរបៀបដែលខ្ញុំអនុវត្តច្បាប់ទាំងនេះ។ សូមចងចាំថា គ្រប់សាច់រឿងនីមួយៗនៅក្នុងព្រះគម្ពីរគឺកំពុងបង្ហាញលោកអ្នកអំពីអ្វីមួយដែលអំពីព្រះរាជ្យ និងរបៀបដែលវាដំណើរការ។ ខ្ញុំហៅខ្លួនឯងថាជាអ្នកវិទ្យាសាស្ត្រផ្នែកព្រលឹងវិញ្ញាណ។ នៅពេលខ្ញុំអានព្រះគម្ពីរ ខ្ញុំតែងតែសម្លឹងរកមើលច្បាប់ដែលបណ្តាលឱ្យមានអ្វីមួយកើតឡើង ឬច្បាប់ដែលមិនអនុញ្ញាតឱ្យអ្វីមួយកើតឡើង។ យើងរកឃើញនូវសាច់រឿងដែលទាក់ទងនឹងមេរៀននេះដែលខ្ញុំចង់បង្ហាញលោកអ្នកនៅក្នុងគម្ពីរម៉ាកុស ជំពូក៦។

*ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សិស្សនាំគ្នាចូលមកគាល់ព្រះយេស៊ូ ទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ ថ្ងៃក៏ជិតលិចផង សូមប្រាប់អ្នកទាំងនេះឲ្យត្រឡប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះ តាមភូមិជិតៗនេះ»។*

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ!»។*

*គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីររយដួង ទៅទិញម្ហូបអាហារឲ្យគេបរិភោគឬ?»។*

*ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។*

*កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំបុ័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*

*ព្រះយេស៊ូបង្គាប់ពួកសិស្សឲ្យប្រាប់បណ្ដាជន អង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំបុ័ងប្រទានឲ្យពួកសិស្ស ដើម្បីឲ្យគេចែកបណ្ដាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឲ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំបុ័ង និងត្រីដែលនៅសល់ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំបុ័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

*ម៉ាកុស ៦៖៣៥-៤៤*

នេះជាសាច់រឿងដ៏អស្ចារ្យមួយ និងជាការបើកបង្ហាញពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងដំណើរការ។ នំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយបានផ្ដល់អាហារដល់មនុស្ស ២០,០០០នាក់! ប៉ុន្តែអ្នកថា «លោកហ្គារី ព្រះគម្ពីរចែងថា មានតែបុរស ៥,០០០នាក់ទេ។» បាទ គឺពិតមែនហើយ ប៉ុន្តែខ្ញុំអាចសន្និដ្ឋានថា នៅទីនោះក៏មានស្ត្រី និងកុមារផងដែរ។ ដូចនេះខ្ញុំទស្សន៍ទាយថាអាចមានមនុស្សប្រហែល ២០,០០០នាក់នៅទីនោះ។

នៅពេលពួកសាវ័កមករកព្រះយេស៊ូនិយាយអំពីបញ្ហាអាហារ នោះព្រះយេស៊ូចង់បង្រៀនពួកគេអំពីព្រះរាជ្យនៃព្រះ ដូចនេះព្រះអង្គមានព្រះបន្ទូលថា «ចូរអ្នកឱ្យអាហារដល់ពួកគេចុះ។» បន្ទូលនេះពិតជាធ្វើឱ្យពួកគេរន្ធត់ណាស់។ តើពួកគេទៅរកអាហារនៅឯណាទៅ? ពួកគេបានឆ្លើយតាមការយល់ដឹងតែពីប្រភពតែមួយដែលពួកគេបានដឹង គឺកម្លាំងពលកម្ម! ពួកគេនិយាយថា «តែនេះគឺស្មើនឹងការចំណាយខិតខំធ្វើការរបស់មនុស្សម្នាក់ក្នុងរយៈពេលប្រាំខែឯណោះ!» ពួកគេគិតតាំងពីចំនួនប្រាក់រកបានគិតជាម៉ោងក្នុងការខិតខំយ៉ាងលំបាក និងប្រឹងប្រែងកាប់គាស់ដីដោយបែកញើសផង នោះក៏នឹងមិនអាចរកអាហារឱ្យពួកគេគ្រប់ឡើយ។

ប៉ុន្តែនៅក្នុងព្រះរាជ្យនៃព្រះ ច្បាប់ផ្សេងៗនៃការដំណើរការធ្វើឱ្យគ្រប់យ៉ាងអាចទៅរួចបាន។ ព្រះយេស៊ូចង់ជួយពួកគេឱ្យមើលហួសពីប្រព័ន្ធនៃបណ្ដាសានៃផែនដី និងរៀនពីរបៀបថ្មីដែលអាចទៅរួចដែលមាននៅក្នុងព្រះរាជ្យនៃព្រះ។ បន្ទាប់មក ព្រះយេស៊ូឱ្យពួកគេសម្លឹងរកមើលអ្វីដែលពួកគេមានដើម្បីផ្ដល់អាហារដល់បណ្ដាហ្វូងមនុស្ស។ ពួកគេចេញដើររកមើល ហើយក៏បានចម្លើយមកថា ពួកគេមានបានរកឃើញនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ ប៉ុន្តែចំនួននោះយកធ្វើអ្វីមិនបាននោះទេ។ បន្ទាប់មក ទើបព្រះយេស៊ូឱ្យយកនំប៉័ង និងត្រីនោះមក។ ព្រះអង្គកាន់នំប៉័ង និងត្រីនៅនឹងព្រះហស្តទ្រង់ ទ្រង់ក៏អធិស្ឋាន និងប្រទានពរដល់ចំណីនេះ។ បន្ទាប់មកទៀត ទ្រង់ក៏ប្រទានឱ្យពួកទៅពួកសាវ័ករបស់ទ្រង់វិញដើម្បីចែកដល់បណ្ដាហ្វូងមនុស្ស។ ខ្ញុំជឿថាលោកអ្នកបានដឹងថារឿងនេះមានអ្វីកើតឡើងជាបន្តទៀតហើយ គឺមនុស្សប្រមាណ ២០,០០០នាក់ ដែលនៅទីនោះបានបរិភោគរហូតដល់ពួកគេបានឆ្អែត ហើយក៏នៅសល់១២ល្អីទៀតផង។

សំណួររបស់ខ្ញុំគឺ «ហេតុអ្វីព្រះយេស៊ូចាំបាច់ឱ្យយកនំប៉័ង និងត្រីមកឯទ្រង់ មុននឹងទ្រង់បានប្រាប់ពួកគេឱ្យចែករបស់ទាំងនោះ? ហេតុអ្វីបានជាព្រះយេស៊ូមិនគ្រាន់តែប្រាប់ឱ្យពួកសាវ័កចែកចំណីនេះដល់ពួកគេភ្លាមៗនៅពេលដែលពួកសាវ័កបានវាទៅ? តើរបស់ទាំងនេះចាំបាច់ត្រូវមានការប្រទានពរពីព្រះយេស៊ូជាមុនសិនឬ?» ចម្លើយដែលត្រឹមត្រូវនោះគឺថា ព្រះយេស៊ូត្រូវតែឱ្យពរលើនំប៉័ង និងត្រីនោះជាមុនសិន។ លោកអ្នកឃើញទេ នំប៉័ង និងត្រីស្ថិតនៅក្នុងពិភពផែនដីដែលនៅក្រោមសិទ្ធិអំណាច និងយុត្តាធិការរបស់មនុស្ស នៅពេលដែលសាវ័ករបស់ព្រះអង្គបានរកឃើញជាលើកដំបូង។ នៅក្នុងសភាពនោះ ព្រះយេស៊ូមិនមានយុត្តាធិការលើរបស់ទាំងនោះទេ។ ប៉ុន្តែនៅពេលដែលមានគេយកនំប៉័ង និងត្រីមកឯព្រះយេស៊ូដោយស្ម័គ្រចិត្ត នោះទ្រង់ក៏អាចឱ្យពរដល់របស់ទាំងនោះបាន។ ពាក្យថា ប្រទានពរមានន័យថា ដើម្បីញែកចេញ ឬទុកដោយឡែក។ ដូចនេះ នេះជាច្បាប់នៃព្រះរាជ្យដែលត្រូវបានបើកបង្ហាញឡើង។

**នៅពេលព្រះយេស៊ូឱ្យពរលើនំប៉័ងនិងត្រី នោះត្រីនិងនំប៉័ងបានផ្លាស់ប្ដូរព្រះរាជ្យ។**

ជាពិសេស យុត្តាធិការលើនំប៉័ងនិងត្រីបានផ្លាស់ប្ដូរ។ ពេលនេះ ព្រះជាម្ចាស់មាននូវសិទ្ធិស្របច្បាប់ដើម្បីពហុគុណនំប៉័ង និងត្រីសម្រាប់ប្រជារាស្ត្រទ្រង់។

**ប្រសិនបើព្រះយេស៊ូមិនបានយកនំប៉័ងនិងត្រី ហើយឱ្យពរលើរបស់ទាំងនេះទេ នោះរបស់ទាំងនេះមិនមានការពហុគុណឡើយ។**

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

យើងក៏ប្រើប្រាស់នូវច្បាប់ដូចគ្នានេះដែរនៅពេលឱ្យពរលើម្ហូបអាហាររបស់យើង ទោះបីជាយើងគិតថាមនុស្សភាគច្រើនមិនដឹងពីអ្វីដែលពួកគេកំពុងធ្វើឡើយនៅពេលដែលពួកគេអធិស្ឋានដាក់ម្ហូបអាហាររបស់ពួកគេ។ ប៉ុន្តែនិយាយរួមទៅ នៅពេលយើងអធិស្ឋានលើម្ហូបអាហារ វាបានផ្លាស់ប្ដូរព្រះរាជ្យ ដោយអនុញ្ញាតឱ្យព្រះជាម្ចាស់ការពារពួកយើងពីអ្វីដែលគ្រោះថ្នាក់ដែលមាននៅក្នុងអ្វីដែលយើងបរិភោគ។ ខ្ញុំត្រូវបន្ថែមត្រង់ចំណុចនេះបន្តិចទៀតហើយមើលទៅ។ ប្រសិនបើយើងចង់បន្តរស់នៅដោយហូបអាហារឥតគុណភាព និងបរិភោគអ្វីៗដែល<u>យើងដឹង</u>ថាអាក្រក់ដល់ខ្លួនយើង នោះយើងនឹងច្រូតផលដែលយើងបានសាបព្រោះនោះ។ ប៉ុន្តែ ប្រសិនបើយើងបានបរិភោគអ្វីដែលគ្រោះថ្នាក់ ជាអ្វីដែលយើងមិនបានដឹងថានឹងផ្ដល់ទុក្ខទោសដល់យើង នោះព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចបានការពារយើងដូចការដែលបានការពារយន្តហោះរបស់ខ្ញុំដែរ។ ខ្ញុំមិនមែនកំពុងនិយាយអំពើប្រភេទនៃការអធិស្ឋានធ្វើតាមទម្លាប់តគ្នាដែលអ្នកបានឮពីមនុស្សភាគច្រើនអធិស្ឋានសម្រាប់អាហាររបស់ពួកគេនោះទេ។ ប៉ុន្តែការអធិស្ឋានដោយជំនឿ ការអរព្រះគុណព្រះដែលទ្រង់បានដកចេញនូវជំងឺចេញពីកណ្ដាលចំណោមយើងរាល់គ្នា ដែលក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ ដើម្បីរីករាយនឹងសេចក្ដីសន្យារបស់ទ្រង់។

*ប្រសិនបើគេកាន់ពស់ ឬផឹកអ្វីដែលមានជាតិពុល ក៏គេពុំមានគ្រោះថ្នាក់អ្វីដែរ។*

ម៉ាកុស ១៦៖១៨

ក្នុងលោកិយនាពេលបច្ចុប្បន្ននេះ យើងត្រូវការនូវទំនុកចិត្តនៃការថែរក្សារបស់ព្រះជាម្ចាស់ដើម្បីឱ្យយើងអាចសម្រាកបាន។ គឺថាមាននូវអ្វីៗជាច្រើនដែលអាចលួចយកនូវសេចក្ដីសុខសាន្តរបស់យើងដែលនៅចំពោះមុខយើង ដោយរួមមានទាំងអាហារដែលយើងបរិភោគផងដែរ។ ទុកចិត្តខ្ញុំចុះ អ្នកអាចប្រាកដថា សាតាំងមាននូវផែនការលួចសុខភាព និងសមត្ថភាពរបស់អ្នកក្នុងការប្រឆាំងនឹងវាយ៉ាងមានប្រសិទ្ធភាពនៅក្នុងពិភពផែនដីនេះតាមរយៈអាហារ!

យើងអាចមើលឃើញឧទាហរណ៍ផ្សេងទៀតនៃការនាំយកនូវបញ្ហា រឿងរ៉ាវ សន្តិភាពក្នុងចិត្ត ដោយតាមពិតទៅគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើងស្ថិតក្រោមយុត្តាធិការនៃព្រះរាជ្យព្រះ ដែលមានចែងក្នុងគម្ពីរភីលីព ៤៖៦-៧។

*សូមកុំខ្វល់ខ្វាយនឹងអ្វីឡើយ ផ្ទុយទៅវិញ ក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវទូលព្រះជាម្ចាស់ឲ្យជ្រាបពីសំណូមពររបស់បងប្អូន ដោយអធិស្ឋាន និងទូលអង្វរ ទាំងអរព្រះគុណព្រះអង្គផង។ ធ្វើដូច្នេះ សេចក្ដីសុខសាន្ដរបស់ព្រះជាម្ចាស់ដែលហួសពីការស្មានរបស់មនុស្ស នឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូន ដែលរួមក្នុងអង្គព្រះគ្រិស្តយេស៊ូមិនខាន។*

*ភីលីព ៤៖៦-៧*

នៅពេលយើងអធិស្ឋានអំពីអ្វីមួយ វានាំមកនូវបញ្ហានោះ ឬរឿងរ៉ាវនោះឱ្យស្ថិតក្រោមយុត្តាធិការនៃព្រះរាជ្យរបស់ព្រះ។ ប្រសិនបើយើងមិនអធិស្ឋានអំពីបញ្ហានេះទេ នោះព្រះហស្តរបស់ព្រះត្រូវបានចងជាប់នៅឡើយទេ។ ដូចនេះហើយទើបព្រះគម្ពីរចែងថា ចូរអធិស្ឋានឥតឈប់ឈរ (១ថែស្សាឡូនិក ៥៖១៧) ហើយអ្នកមិនបានទទួលវាក៏ព្រោះតែអ្នកមិនបានទូលសុំព្រះជាម្ចាស់ (យ៉ាកុប ៤៖២)។

នៅពេលខ្ញុំទិញយន្តហោះ ហើយពេលខ្ញុំទិញអ្វីៗផ្សេងទៀត ខ្ញុំអធិស្ឋានឱ្យរបស់នោះ ដោយដាក់ដៃលើវា និងនាំវាមកស្ថិតក្រោមយុត្តាធិការនៃព្រះរាជ្យនៃព្រះ ដើម្បីសម្រេចបាននូវអ្វីដែលចង់បាន ដើម្បីយកវាមកបម្រើដល់ព្រះរាជ្យនៃព្រះ និងកិច្ចការរបស់ខ្ញុំដែលត្រូវបានចាត់តាំង។ ដោយសារការនេះ យន្តហោះរបស់ខ្ញុំក៏គេចផុតពីដែនរបស់សាតាំង និងពួកបរិវាររបស់វា។ នៅក្នុងយន្តហោះនោះគ្មានគ្រោះថ្នាក់អ្វីនឹងកើតឡើងចំពោះខ្ញុំនោះឡើយ!

ប្រមាណជាមួយខែមុន ក្រោយបញ្ចប់សន្និបាត ខ្ញុំបានជិះយន្តហោះខ្នាតតូចម៉ាក Mirage នេះពីទីក្រុងអូស្ទីនទៅកាន់រដ្ឋអូហៃយ៉ូ។ ពេលនោះក៏វាងយប់បន្តិចហើយ នោះយើងក៏ជិះកាត់តំបន់ជនបទក្រោមមេឃងងឹត។ នៅខាងស្តាំយើងឯណោះក៏មានផ្លេកបន្ទោរចុះឡើង ហើយចំហៀងខាងឆ្វេងដៃវិញក៏ឃើញមានខ្យល់ព្យុះកំពុងបោកបក់កាត់តំបន់នោះដែរ។ ខ្យល់ព្យុះដែលកំពុងបោកបក់កាត់ពីមុខក៏ធ្វើឱ្យពួកយើងផ្លាស់ប្តូរខ្សែហោះហើរដើម្បីគេចចេញពីខ្យល់ព្យុះនោះ ហើយដោយសារការហោះវាងបែបនេះហើយ ទើបពួកយើងត្រូវចំណាយប្រេងសាំងអស់ច្រើនជាងអ្វីដែលពួកយើងបានគ្រោងទុក។ ដូចនេះ ដើម្បីប្រាកដថាពួកយើងអាចហោះទៅផ្ទះវិញដោយសុវត្ថិភាព និងដើម្បីធ្វើតាមច្បាប់របស់សហព័ន្ធអាកាសចរណ៍ (FFA) ទាក់ទិននឹងតារាងនៃប្រេងសាំងត្រៀមបម្រុង នោះពួកយើងក៏បានសម្រេចចិត្តចុះចតនៅតំបន់ល្វីសវ៉ាល់ រដ្ឋខេនធឹកគី ដើម្បីឈប់ចាក់សាំងបន្ថែម។ ពេលចុះចត នៅលើអេក្រង់ទិន្នន័យឃើញនៅសល់សាំងប្រមាណ១១០លីត្រដែរ ប៉ុន្តែពួកយើងត្រូវបន្តដំណើរហោះ

ហើយមួយម៉ោងទៀត ហើយក៏មិនចង់ឱ្យខ្វះសាំងដែរ។ យើងក៏បានចូលទៅហ្គារាសចាក់ប្រេងសាំង និងបានប្រាប់ឱ្យពួកគេចាក់ប្រេងសាំង៧៥លីត្រក្នុងធុងសាំងម្ខាងៗនៃយន្តហោះ។ បើសរុបទៅគឺមានសាំងប្រហែល២៦០លីត្រ ដែលចំណុះនេះគឺលើសពីគ្រប់គ្រាន់សម្រាប់ធ្វើការហោះហើរពីទីនោះទៅអូហៃយ៉ូទៅទៀត ព្រោះថាយន្តហោះខ្នាតតូចរបស់យើងស៊ីប្រេងប្រមាណ៨៣លីត្រក្នុងមួយម៉ោង។

នៅពេលពួកយើងរង់ចាំនៅហ្គារាសចាក់ប្រេងសាំងយន្តហោះ ក៏មានមនុស្សស្រីម្នាក់នៅតុបេឡាក៏បានប្រាប់ពួកយើងថានាងនឹងរៀបចំចាក់ប្រេង១៥០លីត្រឱ្យ។ ពេលនោះកម្មករនៅទៅនោះបានចូលមកដោយកាន់ក្រដាសមួយចំនួនពាក់ព័ន្ធនឹងក្រដាសស្នាមអំពីការចាក់សាំងនោះ។ ស្ត្រីម្នាក់នេះក៏យកវាពីដៃគាត់ហើយសម្លឹងមើលវាបន្តិច រួចក៏ពោលថា «ដូចជាមិនត្រូវទេ។ លេខលើក្រដាសនេះមិនស៊ីគ្នាទេ។» កម្មករនោះក៏បាននិយាយថា គាត់បានចាក់ប្រេងរួចហើយ ហើយគាត់អាចសារ៉េលេខកុងទ័រចំណុះនោះពេលក្រោយ។ នាងក៏ពោលថា «មិនអីទេ» ប៉ុន្តែក៏បាននិយាយថា នាងមិនអាចចេញវិក្ក័យបត្របានទេរហូតលេខកុងទ័រចំណុះនោះត្រូវបានជួសជុលរួច តែនាងនឹងផ្ញើអ៊ីម៉ែលមកកាន់ពួកយើង។ ពួកយើងក៏ពោលថា «មិនថ្វីទេ» ហើយក៏បានដើរចេញទៅរកយន្តហោះជាមួយកម្មករនោះទៅ។ អ្នកបើកយន្តហោះរបស់ខ្ញុំក៏បានសួរដើម្បីបញ្ជាក់ទៅកម្មករចាក់ប្រេងនោះថាគាត់ពិតជាបានចាក់ប្រេងសាំង៧៥លីត្រសម្រាប់ស្លាបម្ខាងៗមែន ហើយគាត់ក៏ថា «ពិតមែនហើយ ខ្ញុំបានចាក់សាំងចំនួន៧៥លីត្រសម្រាប់ស្លាបម្ខាងៗ។»

ដូចនេះពួកយើងក៏បានចេញដំណើរទៅរដ្ឋអូហៃយ៉ូទៅ ហើយក្រោយពេលហោះហើរបានប្រហែលជា៥០នាទី ស្រាប់តែអស់សាំងបាត់ទៅហើយ។ ពួកយើងតក់ស្លុតខ្លាំងណាស់ តើវាអាចកើតឡើងបានដោយរបៀបណា? មួយនីទីក្រោយមក ធុងសាំងនៃស្លាបខាងស្តាំក៏អស់សាំង។ ពេលនេះគឺពាក់កណ្តាលយប់ក្នុងផ្ទៃមេឃដ៏ងងឹត ហើយពួកយើងកំពុងហោះក្នុងរយៈកម្ពស់៤,៥០០ម៉ែត្រដោយរលត់ម៉ាស៊ីន។ តើមានរឿងអ្វីហ្នឹង? ពួកយើងទើបតែបានចាក់ប្រេងរួចទេតើ។ គេប្រាកដជានិយាយដាក់ខ្ញុំថា «តើយន្តហោះរបស់អ្នកមិនមានកុងទ័របង្ហាញចំណុះទេឬ?» ប្រាកដណាស់ ប៉ុន្តែកុងទ័រចំណុះនៃយន្តហោះយើងលោតទ្រនិចឡើងយឺតណាស់នៅពេលចាក់សាំង។ ប្រសិនបើអ្នកបើប្រភេទសេរីចាស់ៗ អ្នកអាចនឹងយល់អ្វីដែលខ្ញុំកំពុងនិយាយហើយ។ គឺកុងទ័រចំណុះរបស់វាលោតទ្រនិចឆ្លើយតបយឺតណាស់ទៅនឹងប្រេងសាំងដែលបានចាក់ចូលនោះ។

ដូចនេះនៅក្នុងករណីនេះ អ្នកបើកយន្តហោះរបស់ខ្ញុំបានសួរបញ្ជាក់កម្មករចាក់ប្រេងសាំងនោះថាគាត់បានចាក់ប្រេសាំងចូលយន្តហោះ និងត្រូវតាមចំនួនដែលបានចាក់ចូល។

**មានច្បាប់នៅក្នុងព្រះរាជ្យ ដែលអ្នកត្រូវរៀនឱ្យមាន ប្រសិទ្ធភាព សុវត្ថិភាព និង ដើម្បីទទួលបានការផ្គត់ផ្គង់ នៅក្នុងលោកិយនេះ។**

ពួកយើងខ្លួនឯងក៏បានឃើញថាគាត់បើកឡានប្រេងដោយចាក់ប្រេងចូលក្នុងយន្តហោះដែរ ហើយនិយាយបញ្ជាក់ថាចំនួនសរុបនៃប្រេងនោះប្រមាណ១៥០លីត្រត្រូវបានចាក់ចូលក្នុងយន្តហោះនោះ។ នៅពេលពួកយើងបញ្ជាក់ពីចំណុះប្រេងសាំង នោះយើងបានកំណត់កុងទ័រវាស់ចំណុះបែបឌីជីថលដែលតាមដានពីចំណុះប្រេងសាំងពិតជាក់ស្តែងដែលនៅសល់បន្តិច។ ពួកយើងគិតថាពួកយើនបានធ្វើគ្រប់យ៉ាងរួចរាល់ដើម្បីមានសុវត្ថិភាពរួចរាល់ហើយ។

ពួកយើងបានប្រកាសអាសន្ន និងរកមើលដើម្បីចុះចតនៅព្រលានយន្តហោះហ្វ្រេតធ័រស៊ីនស៊ូណាទី ដោយសារពួកយើងកំពុងធ្វើដំណើរសំដៅមកកន្លែងនោះនៅពេលប្រេងសាំងអស់ នោះវាមិនមានបញ្ហាអ្វីនោះទេ ប៉ុន្តែវាជារឿងដ៏គួរឱ្យភ្ញាក់ផ្អើលជាប្រាកដណាស់។ ពេលក្រោយមកទៀត ពួកយើងក៏បានដឹងថា យន្តហោះនេះជាយានទីមួយដែលបុរសកម្មករចាក់ប្រេងសាំងនោះបានចាក់ប្រេងសាំង។ គាត់បានចាក់ប្រេងសាំងតែ៧.៥លីត្រប៉ុណ្ណោះសម្រាប់ស្លាបម្ខាងៗ គឺមិនមែនចាក់៧៥លីត្រនោះទេ។ គាត់មិនដឹងពីរបៀបមើលកុងទ័រនៅឡើយទេ។ ស្លាប់ហើយ! ក្រុមហ៊ុនក្នុងប្រទេសផ្នែកចាក់ប្រេងសាំងយន្តហោះមួយទាំងមូលធ្វើបែបហ្នឹងហ្ន៎! ពិតជាប្លែកមែន!

អ្វីដែលសត្រូវចង់បង្កគ្រោះថ្នាក់មិនមែនជាបញ្ហាទេ ប៉ុន្តែវាគួរតែអាចក្លាយជាបញ្ហាធំបានប្រសិនបើយើងអស់ប្រេងសាំងក្នុងរយៈកម្ពស់ផ្សេងក្រៅពីកម្ពស់៤,៥០០ម៉ែត្រពីដី។ ប៉ុន្តែដូចនិយាយពីមុនអីចឹង សត្រូវមិនអាចបង្កគ្រោះថ្នាក់ដល់ខ្ញុំ ឬយន្តហោះនោះទេ។ ដើម្បីបញ្ចៀសការប៉ុនប៉ងផ្សេងទៀតពីមារសត្រូវរបស់ពួកយើង នោះពួកយើងក៏បានផ្លាស់ប្តូរនីតិវិធីរបស់ពួកយើងក្នុងពេលចាក់ប្រេងសាំង។ ពេលនេះពួកយើងមិនទុកឱ្យកម្មករធ្វើការចាក់ប្រេងសាំងយន្តហោះពួកយើងដោយមិនមានវត្តមានរបស់ពួកយើងនៅចាំពិនិត្យមើលភ្លើងសញ្ញាចាក់ប្រេងនោះឡើយ។ ឧប្បត្តិហេតុមួយនេះអាចក្លាយមហន្តរាយបាន ប្រសិនបើយើងហោះទាប ឬមានការយឺតយ៉ាវក្នុងការរកកន្លែងចុះចត ឬបើសិនមានអាកាសធាតុមិនល្អ។

ប៉ុន្តែប្រាកដណាស់ វាមិនបានកើតឡើងទ្បើយដោយសារតែមាននូវសេចក្ដីសន្យានៃការការពារពីព្រះ។

ឧប្បត្តិហេតុទាំងពីរលើកដែលបានកើតឡើងចំពោះយន្តហោះរបស់ខ្ញុំពាក់ព័ន្ធនឹងសុវត្ថិភាពនៃយន្តហោះ និងខ្លួនខ្ញុំផងដែរនោះ គឺជាលទ្ធផលនៃសេចក្ដីសន្យារបស់ខ្ញុំ សិទ្ធិស្របច្បាប់របស់ខ្ញុំនៅក្នុងព្រះរាជ្យ។ ពិតណាស់ ខ្ញុំអាចប្រាប់លោកអ្នកពីរឿងរ៉ាវដែលខ្ញុំបានយន្តហោះនេះមកជាលើកដំបូង ប៉ុន្តែខ្ញុំសូមមិនប្រាប់នៅពេលនេះទេ។ ខ្ញុំគិតថាលោកអ្នកយល់ចំណុចសំខាន់នៃសាច់រឿងនេះហើយ-គឺព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់!

មានច្បាប់នៅក្នុងព្រះរាជ្យដែលអ្នកត្រូវរៀនឱ្យមានប្រសិទ្ធភាព សុវត្ថិភាព និងដើម្បីទទួលបានការផ្គត់ផ្គង់នៅក្នុងលោកិយនេះ។ សាតាំងស្អប់ពួកយើងណាស់ ប៉ុន្តែវាមិនអាចបញ្ឈប់យើងបានឡើយ! សូមសរសើរតម្កើងព្រះជាម្ចាស់។ ការការពារក៏ជាការសម្រាកផងដែរ គឺគ្មានការបារម្ភ និងគ្មានការភ័យខ្លាច! វាជាសិទ្ធិស្របច្បាប់របស់អ្នក។

និយាយអីចឹង ក្រែងលោលោកអ្នកនៅមានចម្ងល់ ច្បាប់ដែលខ្ញុំបានពណ៌នា និងប្រើប្រាស់នេះ គឺជាអ្វីដែលខ្ញុំបានហៅថាជាច្បាប់យុត្តាធិការ។

អត្ថបទមួយផ្សេងទៀតដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំកាលពីដំបូងដែលមានទាក់ទងនឹងព្រះរាជ្យរបស់ទ្រង់នោះគឺ គម្ពីរលូកា ៦៖២០។

> *«អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ! អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់។*
>
> លូកា ៦៖២០

ឌ្រិនដា និងខ្ញុំបានចាប់ផ្ដើមសិក្សាស្វែងយល់ពីអ្វីដែលព្រះជាម្ចាស់ចង់មានបន្ទូលចំពោះពាក្យថា «ព្រះរាជ្យនៃព្រះ» ដែលមាននៅក្នុងអត្ថបទគម្ពីរនេះ នៅពេលព្រះអម្ចាស់បានបង្ហាញមកកាន់ពួកយើងជាលើកដំបូង។ ជាថ្មីម្ដងទៀត ទ្រង់បានបង្ហាញពួកយើងថា ទ្រង់ជាស្ដេចនៃព្រះរាជ្យមួយ ដែលបានគ្រប់គ្រង និងដំណើរការដោយច្បាប់នានា។ ជាឧទាហរណ៍ ចូរយើងក្រឡេកមើលព្រំដែនភាគខាងត្បូងរបស់យើង។ ជារៀងរាល់ឆ្នាំ មនុស្សរាប់ពាន់នាក់ព្យាយាមចូលមកក្នុងសហរដ្ឋអាមេរិក។ តើហេតុអ្វីទៅ? គឺដោយសារតែនៅកន្លែងដែលពួកគេរស់នៅពួកគេមិនមានទេសភាពស្អាតមែនទេ? ទេ គឺមិនមែនបែបនេះទេ។ ពួកគេព្យាយាមចូល

មកសហរដ្ឋអាមេរិកដោយសារតែរដ្ឋាភិបាលនៅទីនេះ។ រដ្ឋាភិបាលរបស់ពួកយើងមាននូវច្បាប់ដែលការពារសិទ្ធិប្រជាពលរដ្ឋ និងមានកិច្ចប្រឹងប្រែងផ្តល់នូវសេរីភាពជាច្រើនដែលនៅបណ្តាប្រទេសផ្សេងៗទៀតមិនមាន៖ ម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិ សិទ្ធិលើម្ចាស់អាជីវកម្មរបស់អ្នក សិទ្ធិក្នុងការថ្វាយបង្គំតាមការពេញចិត្តរបស់អ្នក និងសិទ្ធិបញ្ចេញមតិ។ នៅក្នុងបណ្តាប្រទេសជាច្រើនផ្សេងទៀត មិនមាននូវចំណុចទាំងអស់នេះទេ។

ពួកយើងបានរៀបរាប់ខ្លះៗរួចមកហើយអំពីព្រះរាជ្យរបស់ព្រះ ដែលជាគ្រឹះនៃគ្រប់ទាំងគន្លឹះ (កូនសោ) ទាំងអស់ ជាគោលការណ៍ និងជាច្បាប់បញ្ញត្តិដែលព្រះជាម្ចាស់បានប្រទានដល់យើងដែលជាប្រជារាស្ត្រ។ ចំណេះដឹងរបស់អ្នក ឬកង្វះខាតនៃចំណេះដឹងអំពីច្បាប់បញ្ញត្តិទាំងនេះអាចមានភាពខុសប្លែកគ្នារវាងជីវិតឬសេចក្តីស្លាប់ ជ័យជម្នះឬបរាជ័យ។ ក្រោយពីបានរងទុក្ខវេទនាអស់រយៈពេលប្រាំបួនឆ្នាំនៃការភ័យខ្លាចក្នុងការចុះខ្សោយផ្នែកហិរញ្ញវត្ថុ ហើយពេលនេះខ្ញុំមានសេរីភាពហើយនោះ ខ្ញុំមិនអាចបញ្ជាក់បានគ្រប់គ្រាន់ឡើយថា តើវាសំខាន់ខ្លាំងប៉ុនណាទៅក្នុងការដឹងពីអត្ថន័យដែលបានក្លាយជាពលរដ្ឋនៃព្រះរាជ្យរបស់ព្រះ និងអត្ថន័យនៃការស្គាល់ច្បាប់ ព្រមទាំងគោលការណ៍ដែលបង្កើតនូវព្រះរាជ្យនោះឡើង។

ផែនដីមានវត្តមានអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ប៉ុន្តែអ្វីៗជាច្រើនដែលពួកយើងកំពុងមាននៅពេលសព្វថ្ងៃនេះ មិនត្រូវបានយល់ដឹងពីពួកវានោះទេ។ ជាឧទាហរណ៍ ខ្ញុំចង់ឱ្យអ្នកសម្លឹងមើលពីលក្ខណៈនៃរូបភាពដែលកើតមាននៅក្នុងរដូវកាលយប់មុនបុណ្យណូអែលនាឆ្នាំ១៩០៦ នៅក្នុងតំបន់អូសៀន ប្លាហ្វ ប្រ៊ែនរ៉ក់ នៅរដ្ឋម៉ាហ្សាឈូសេត។ នៅថ្ងៃនោះមានអ្វីមួយបានកើតឡើងដែលបានផ្លាស់ប្តូរពិភពលោក។ រីជីណាល ហ្វេស៊ែនដេន (Reginald Fessenden) បានចាក់បទចម្រៀង Oh Holy Night ដើម្បីបញ្ជូនសំឡេងដល់ឯនាយសមុទ្រតាមរយៈរលកវិទ្យុ ព្រមទាំងបានអានព្រះគម្ពីរលូកាជំពូក២ផងដែរ។ រលកធាតុអាកាសនេះគឺជាការបញ្ជូនសំឡេងតាមវិទ្យុដំបូងបំផុតនៅក្នុងពិភពលោក។ ពេលនេះ យើងគ្រាន់តែលើកទូរស័ព្ទ ហើយអាចនិយាយជាមួយនរណាក៏បាននៅលើភពនេះដោយមិនបាច់គិតពីវិធីរៀបចំបញ្ជូនសំឡេងនេះឡើយ។

ចុះព្រឹត្តិការណ៍នៅខែមករាឆ្នាំ១៨៧៩ឯណោះវិញ? លោកថូម៉ាស អ៊ែដឌីសុន (Thomas Edison) បានបង្កើតអំពូលភ្លើងឡើង ហើយពេលនេះជាតិសាសន៍នីមួយៗនៅលើ

ផែនដីនេះប្រើប្រាស់នូវច្បាប់អគ្គិសនីនេះ និងច្បាប់ដែលគ្រប់គ្រងផ្នែករូបវិទ្យាដើម្បីអាចមើលឃើញនៅពេលរាត្រី។

ចុះចំណែកឯព្រឹត្តិការណ៍នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩០៣ ឯណោះវិញ? បងប្អូនត្រកូលរ៉ៃហ្វយ៍ (Wright) បានបើកយន្តហោះជាលើកដំបូងបង្អស់ ហើយពេលនេះ យើងអាចឡើងជិះយន្តហោះ និងហោះទៅពាសពេញពិភពលោកបានដោយចំណាយពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ។

យន្តហោះប្រភេទ A380 ជាប្រភេទយន្តហោះពាណិជ្ជកម្មធំបំផុត ដែលមានទម្ងន់ជាង៦០០តោន ដែលអាចដឹកជញ្ជូនមនុស្សបានជាង៨០០នាក់ដោយហោះហើរបានរយៈពេល៩ម៉ោងដោយមិនបាច់ឈប់ចាក់ប្រេងសាំង និងអាចហោះហើរលើផែនដីបានក្នុងល្បឿនប្រមាណជិត១,០០០គីឡូម៉ែត្រក្នុងមួយម៉ោង។ ប្រសិនបើមនុស្សអាចមើលឃើញការទាំងនេះកាលពីទសវត្សរ៍ឆ្នាំ១៨០០វិញ នោះពួកគេប្រាកដជាសន្លប់ជាមិនខានទេ ពេលបានឃើញទិដ្ឋភាពបែបនេះ។ ប៉ុន្តែពេលនេះ ចំពោះពួកយើងវិញ វាជារឿងធម្មតាទេ គឺដូចជារឿងងាយៗដូចបិទ-បើកភ្លើងអំពូល។

អ្វីដែលខ្ញុំចង់និយាយនោះគឺថា ច្បាប់ទាំងនេះមានរួចស្រេចទៅហើយ គឺតែងតែមាននៅទីនេះជានិច្ច មាននៅក្នុងពិភពផែនដីតាំងពីមនុស្សត្រូវបានបង្កើតមកម្ល៉េះ។ ច្បាប់បញ្ញត្តិទាំងនេះតែងតែមានជាស្រេចសម្រាប់ឱ្យមនុស្សបានប្រើប្រាស់ គ្រាន់តែមនុស្សមើលមិនឃើញច្បាប់ទាំងនេះតែប៉ុណ្ណោះ។ គេមើលឃើញបក្សីហោះហើរ គេមើលឃើញផ្លេកបន្ទោរ ប៉ុន្តែគេនៅតែមិនយល់។ រឿងដូចគ្នានេះក៏ពិតជាក់ស្តែងដូចក្នុងបទគម្ពីរផងដែរ។ សាសនាបានកំណត់នូវព្រំដែនពាក់ព័ន្ធនឹងអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ចង់បង្ហាញ។ ជាច្រើនឆ្នាំមកហើយ អ្នកនិងខ្ញុំបានឮថា រឿងទាំងអស់នោះបានកន្លងផុតទៅហើយ ព្រះជាម្ចាស់មិនធ្វើការអស្ចារ្យទៀតទេ។ អំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធមានសម្រាប់តែពួកសាវ័ក ឬបន្លានៅក្នុងសាច់លោកប៉ូលគឺជាជំងឺមួយ។ នៅក្នុងសភាពជាក់ស្តែង ព្រះបន្ទូលពិតជាសាមញ្ញណាស់។ វាមានន័យជាក់ស្តែងដូចអ្វីដែលបានចែងមក។ ប៉ុន្តែគ្រឹះនៃព្រះរាជ្យគឺជាកូនសោរដ៏សំខាន់ដែលអ្នកត្រូវតែមានដើម្បីបើកទ្វារផ្សេងៗទៀត។

## ទីនេះមានកូនសោសំខាន់មួយទៀតគឺ៖

## <u>ច្បាប់មិនដែលផ្លាស់ប្តូរឡើយ</u>!

ចូរទម្លាក់ថ្ម នោះវានឹងធ្លាក់ចុះ។ តើវានឹងធ្លាក់ប៉ុន្មានដង? គឺធ្លាក់រាល់ពេលដែលយើងទម្លាក់វា! ច្បាប់ទំនាញបញ្ជាក់ថា អ្នកនឹងទទួលបាននូវចម្លើយដូចគ្នាគ្រប់ពេលទាំងអស់។ ហើយព្រះរាជ្យនៃព្រះក៏ដូចគ្នាដែរ។

# ជំពូក ៩
# ការហោះប្រសើរជាងការដើរ

ការហោះប្រសើរជាងការដើរ! ពេលខ្ញុំសរសេរជំពូកនេះ ខ្ញុំកំពុងជិះយន្តហោះផ្ទាល់ខ្លួនរបស់ខ្ញុំចេញពីផ្ទះលំហែកាយក្នុងរដូវក្ដៅនៅប្រទេសកាណាដាទៅកាន់ផ្ទះរស់នៅរបស់ពួកយើង ដោយបានហោះហើរក្នុងល្បឿន៥០០គីឡូម៉ែត្រក្នុងមួយម៉ោង ក្នុងកម្ពស់ ៧,០០០ម៉ែត្រពីដី។ ពួកយើងតែងតែបើកបររថយន្តពីផ្ទះរបស់ពួកយើងនៅរដ្ឋអូហៃយ៉ូទៅប្រទេសកាណាដាអស់រយៈពេលជាច្រើនឆ្នាំ។ វាគឺជាដំណើរដ៏វែងឆ្ងាយ និងគួរឱ្យធុញទ្រាន់ដែលត្រូវចំណាយពេលដល់ទៅ៣១ម៉ោងដើម្បីទៅដល់ទីនោះ។ ខ្ញុំចាំបាច់ត្រូវបើកឡានពេញមួយយប់ដើម្បីទៅដល់ទីនោះនៅថ្ងៃបន្ទាប់។ មែនហើយ មានពីរបីលើកដែរដែលពួកយើងធ្លាប់ត្រូវចំណាយពេលដល់ទៅពីរថ្ងៃដើម្បីដល់ទីនោះ តែពេលអ្នកមានពេលសម្រាកលំហែកាយពីរសប្ដាហ៍ ហើយត្រូវចំណាយពេលសម្រាប់ការបើកបរអស់រយៈពេលដល់ទៅបួនថ្ងៃ នោះប្រាកដជាខាតបង់ពេលវេលាសម្រាកនៅទីនោះអស់ច្រើនពេកហើយ។ តែហ្នឹងហើយ ទម្រាំដល់ទីនោះគឺអស់កម្លាំងខ្លាំងណាស់ ហើយមិនបានប៉ុន្មានផងក៏ត្រូវប្រឈមនឹងការធ្វើដំណើរត្រលប់មកវិញដែលត្រូវចំណាយពេល៣១ម៉ោងមករដ្ឋអូហៃយ៉ូវិញដដែល។

ជានិច្ចកាល ខ្ញុំចូលចិត្តយន្តហោះ ហើយខ្ញុំក៏ទទួលបណ្ណបើកបរយន្តហោះតាំងតែពីអាយុ១៨ឆ្នាំម្ល៉េះ ប៉ុន្តែគ្រាន់តែមិនដែលគិតស្រមៃថានឹងមានយន្តហោះផ្ទាល់ខ្លួន។ ខ្ញុំចង់មានន័យថា អ្នកបានដឹងពីតម្លៃយន្តហោះស្រាប់ហើយ មែនទេ? តែនៅពេលខ្ញុំសិក្សាពីព្រះរាជ្យកាន់តែច្រើន ខ្ញុំក៏បានដឹងថាខ្ញុំជាម្នាក់ដែលរារាំងនូវការមានយន្តហោះនោះដោយគំនិតថា « ទេ» និងគំនិតបែបអន់ថយរបស់ខ្ញុំ។ តាមពិតពេលនេះខ្ញុំមានយន្តហោះពីរគ្រឿងឯណោះ មួយគ្រឿងដែលជាយន្តហោះដំបូងរបស់ខ្ញុំនោះគឺទុកសម្រាប់ជិះលេង ហើយមួយគ្រឿងទៀតខ្ញុំទុកប្រើប្រាស់សម្រាប់ការធ្វើដំណើរនានា។ ដូចខ្ញុំបានរៀបរាប់នៅក្នុងជំពូកមុនថា ការដែល

យើង «គ្មានការបណ្ដុះបណ្ដាល» គឺមិនអនុញ្ញាតឱ្យមានក្ដីស្រមៃ ឬលទ្ធភាពកើតមានឡើយ។ យើងទេដែលបានបិទវាចោលមុនពេលវាចាប់ផ្ដើមទៅទៀត។

ពីមុនមក ខ្ញុំមិនដែលគិតថាមានយន្តហោះផ្ទាល់ខ្លួនទេ។ ខ្ញុំមើលមិនឃើញថាតើការនោះអាចទៅរួចបានយ៉ាងដូចម្ដេចនោះទេ។ ខ្ញុំបានជួលយន្តហោះជិះអស់រយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែនៅពេលខ្ញុំចាប់ផ្ដើមសិក្សាពីច្បាប់នៃព្រះរាជ្យ និងបានឃើញពីសាច់រឿងផ្សេងៗជាច្រើននៅក្នុងជីវិតរបស់ខ្ញុំដែលបានបើកបង្ហាញពីព្រះរាជ្យ នោះខ្ញុំក៏សម្រេចថាខ្ញុំនឹងជឿទុកចិត្តលើទ្រង់ចំពោះការមានយន្តហោះផ្ទាល់ខ្លួន។ ពេលនោះខ្ញុំមិនមានប្រាក់ទិញវានៅឡើយទេ ប៉ុន្តែខ្ញុំបានដកក្រដាសសែកចេញមក រួចសរសេរត្រង់ចំណុចកំណត់សម្គាល់ក្នុងក្រដាសនោះថា «សម្រាប់យន្តហោះរបស់ខ្ញុំ»។ ខ្ញុំបានសរសេរពីប្រភេទយន្តហោះជាក់លាក់ដែលខ្ញុំនឹងទទួលបានវា។ ភរិយារបស់ខ្ញុំ និងខ្ញុំបានសាបព្រោះសែកនោះចូលទៅក្នុងព្រះរាជ្យស្របតាមគម្ពីរម៉ាកុស ១១៖២៤ ដោយជឿថាខ្ញុំទទួលបានវានៅពេលដែលខ្ញុំអធិស្ឋាន។ នេះជាអ្វីដែលព្រះអម្ចាស់បានបង្ហាញខ្ញុំឱ្យធ្វើនៅពេលចាប់ផ្ដើមដំបូងដែលទាក់ទិននឹងព្រះរាជ្យ។ ខ្ញុំបានឃើញរឿងនេះបានកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំជាច្រើនដងណាស់។

រយៈពេលប៉ុន្មានសប្ដាហ៍ក្រោយមក ខ្ញុំបានមកធ្វើលំហាត់ប្រាណជាទម្លាប់ ហើយគ្រូពេទ្យម្នាក់ក៏បានពោលមកខ្ញុំថា «និយាយអ៊ីចឹង តើលោកដឹងថាមាននរណាគេចាប់អារម្មណ៍ទិញយន្តហោះដែរឬទេ?» ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ ព្រោះថាមិនដែលមាននរណាសួរខ្ញុំពីរឿងនេះទេពីមុនមក។ «តើនោះជាយន្តហោះប្រភេទអ្វីដែរ?» ខ្ញុំក៏សួរទៅវិញ។ គាត់ក៏បានបន្តពន្យល់ពីលក្ខណៈយន្តហោះនោះ និងបានប្រាប់ខ្ញុំថាវានៅឯព្រលានយន្តហោះក្នុងស្រុក ហើយក៏បបួលខ្ញុំទៅមើល។ ពិតជាអស្ចារ្យណាស់ វាគឺជាប្រភេទយន្តហោះដែលខ្ញុំបានសាបព្រោះនោះ! ខ្ញុំក៏បានទៅដល់ទីលានយន្តហោះ និងបានពិនិត្យមើលវា ហើយឃើញថាវានៅស្អាតណាស់។ ខ្ញុំដឹងថានេះជាយន្តហោះរបស់ខ្ញុំ។ ប៉ុន្តែនៅមានបញ្ហាមួយទៀត គឺខ្ញុំមិនមានលុយទិញយន្តហោះទេ។ ខ្ញុំបានប្រាប់គ្រូពេទ្យនោះថាខ្ញុំចាប់អារម្មណ៍ចំពោះយន្តហោះនោះ ហើយប្រាប់ថានឹងទាក់ទងគាត់តាមក្រោយ។

ពីរសប្ដាហ៍កន្លងផុតទៅ បងប្រុសរបស់ខ្ញុំដែលបានធ្វើការនៅឯភោជនីយដ្ឋានរបស់ឪពុកខ្ញុំដែលនៅជាប់អគាររបស់ខ្ញុំនោះ បានទូរសព្ទមកខ្ញុំ។ ខ្ញុំទើបតែក្លាយជាម្ចាស់អគារនោះកាលពីប៉ុន្មានខែមុនប៉ុណ្ណោះ គឺប្រហែលកាលពីប៉ុន្មានខែមុនរដូវស្លឹកឈើជ្រុះនោះឯង។ ខ្ញុំមានគម្រោងចង់កែប្រែអគារនោះជាទីស្នាក់ការការិយាល័យសម្រាប់ក្រុមហ៊ុនសេវាកម្មហិរញ្ញ

វត្ថុរបស់ខ្ញុំ។ អគារនោះមិនជាប់ចំណាត់ថ្នាក់សម្រាប់ការធ្វើជាអគារពាណិជ្ជកម្មតាមការចង់បានរបស់ខ្ញុំទេ ដូចនេះខ្ញុំដឹងថាខ្ញុំត្រូវសង់វាឡើងវិញ។ ខ្ញុំបានទាក់ទងទៅកាន់ជាងដែលបានគូសវាសគម្រោងសង់នោះ ហើយពួកយើងក៏បានចុះកុងត្រា។ យ៉ាងណាក្តី ដោយសារតែការព្រួយបារម្ភនឹងលក្ខខណ្ឌអាកាសធាតុ ពួកយើងសម្រេចថា ពួកយើងគួររង់ចាំរហូតដល់រដូវផ្ការីកទើបចាប់ផ្តើមគម្រោងនោះ។ ការជួសជុលនេះអាចតម្រូវឱ្យសង់ឡើងវិញទាំងស្រុងលើអគារនោះ។

អតីតម្ចាស់អគារបានប្រាប់ខ្ញុំថាបណ្តាញទឹកត្រូវបានបិទដោយសាររដូវរងា ដូចនេះខ្ញុំមិនដែលពិនិត្យមើលទេ។ នៅចុងខែកុម្ភៈ គឺក្រោយពីអាកាសធាតុប្រែក្តៅបន្តិចដែលបានធ្វើឱ្យព្រិលក្នុងរដូវរងារលាយអស់ នោះបងប្រុសរបស់ខ្ញុំក៏បានទូរសព្ទមកខ្ញុំ។ គាត់ប្រាប់ខ្ញុំថាអគាររបស់ខ្ញុំត្រូវរងការខូចខាតដោយសារតែមានទឹកហូរពីអគារនោះចេញមកដល់ផ្លូវ។ គាត់និងខ្ញុំដឹងពីសភាពការណ៍នោះ គឺមកពីមិនបានបិទរ៉ានទឹកដូចអ្វីដែលអតីតម្ចាស់អគារបានបង្ហាញប្រាប់។ ពេលខ្ញុំបានពិនិត្យពិច័យពីការខូចខាត ប្រាកដណាស់ថាវាចេញមកពីទុយោបន្ទប់ទឹកនៅជាន់លើ ក៏ដូចជាទុយោបន្ទប់ទឹកជាន់ក្រោមផងដែរ គឺបានបែកហៀរទឹកជោកពេញអគារ។ របាំងជញ្ជាំង ពិដាន និងជញ្ជាំងបានរបេះចេញមក។

ដំបូងឡើយ មើលទៅដូចជាប៉ះពាល់ធ្ងន់ធ្ងរណាស់ ប៉ុន្តែតាមផែនការជួសជុលរបស់ខ្ញុំវិញ ខ្ញុំបានគ្រោងដករបាំងជញ្ជាំងចេញ និងរចនាបន្ទប់ឡើងវិញ។ ចំណែកឯផ្ទៃអគារខាងក្រៅវិញ ក៏ត្រូវផ្លាស់ប្តូរដែរ។ ដូចនេះ ជាក់ស្តែង ទឹកមិនបានប៉ះពាល់ដល់តួអគារទេ។ កន្លែងដែលបានខូចខាតនោះគឺបានខូចត្រង់កន្លែងដែលបម្រុងនឹងត្រូវជួសជុលឡើងវិញ។ យ៉ាងណាក្តី នៅពេលខ្ញុំបានទិញអគារនេះ ខ្ញុំក៏បានដាក់ចូលក្នុងសេវាធានារ៉ាប់រងដែរ។ ការខូចខាតនោះក៏ត្រូវបានធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងក៏បានសរសេរចំនួនទឹកប្រាក់ក្នុងសែកលុយមួយសន្លឹក។ អ្នកដឹងទេ គឺតម្លៃនោះអាចបង់ថ្លៃទិញយន្តហោះរបស់ខ្ញុំបាន។ យន្តហោះខ្នាតតូចប្រភេទ Piper Warrior នោះងាយស្រួលហោះហើរ ហើយខ្ញុំតែងតែជិះវាលេងកម្សាន្ត។ គ្រប់ពេលដែលខ្ញុំជិះវា ខ្ញុំស្ញប់ស្ញែងពីភាពអស្ចារ្យដែលខ្លួនបានជិះយន្តហោះដែលខ្ញុំបានទិញវា។ គិតទៅគឺខ្ញុំទិញវាអស់រយៈពេល២០ឆ្នាំមកហើយ ហើយពេលនេះខ្ញុំនៅតែជាម្ចាស់វាដដែល។

ទោះបីជាក្នុងរឿងនេះ ព្រឹត្តិការណ៍នានាបានកើតឡើងពិតជាអស្ចារ្យ តែខ្ញុំមិនចង់ឱ្យអ្នកមានការយល់ខុសពីរបៀបដែលអ្វីៗដំណើរការទេ។ មិនមែនគ្រប់អ្វីៗទាំងអស់តែងតែកើត

មានឡើងភ្លាមៗដូចក្នុងសាច់រឿងនេះទេ។ ព្រះជាម្ចាស់អាចនាំអ្នកឱ្យកាន់ឱកាសមួយដើម្បីឱ្យអ្នករកលុយ ដើម្បីទិញយន្តហោះខ្លួនឯង ឬអ្នកអាចមានដំណោះស្រាយល្អខ្លាំងណាមួយក៏ថាបាន។ ផ្ទត់គំនិតដែលអ្នកចង់មាននៅពេលអ្នកសាបព្រោះនៅក្នុងព្រះរាជ្យនោះគឺ ព្រះជាម្ចាស់នឹងបង្ហាញឱ្យអ្នកឃើញនូវការច្រូតផល និងផែនការមួយដើម្បីចាប់យកវាឱ្យបាន។ រឿងទីពីរនោះគឺ ត្រូវស្ថិតនៅក្នុងជំនឿ និងសមត្ថភាពដែលបានអភិវឌ្ឍអ្នកឡើង។ ខ្ញុំធ្លាប់ធ្វើឱ្យគេគិតថាដោយសារព្រះជាម្ចាស់នឹងបង្ហាញពួកគេពីរបៀបរកលុយបង់ថ្លៃទិញរថយន្តរបស់ពួកគេដែលពួកគេអាចចាប់ផ្តើមចេញទៅសាបព្រោះលុយមួយពាន់លានដុល្លារ។ អ្នកមិនមានជំនឿថាមានលុយមួយពាន់លានដុល្លារទេ! ចូរចាប់ផ្តើមពីកន្លែងដែលអ្នកស្ថិតនៅ និងចាប់ផ្តើមអនុវត្តច្បាប់នៃព្រះរាជ្យ និងកសាងទំនុកចិត្តរបស់អ្នកនៅក្នុងច្បាប់នៃព្រះរាជ្យ និងសមត្ថភាពក្នុងការចាប់យកអ្វីដែលព្រះជាម្ចាស់បានបង្ហាញអ្នក។

ប៉ុន្តែត្រង់ចំណុចនេះខ្ញុំចង់បង្ហាញអ្នកនូវមួយចំណុច។ មុននឹងបានទិញយន្តហោះនោះ ខ្ញុំជាអ្នកបើកយន្តហោះអស់ជាង២០ឆ្នាំហើយ។ តើអ្នកគិតថាច្បាប់នៃព្រះរាជ្យព្រះធ្វើការ ២០ឆ្នាំមុននេះឬ? ប្រាកដណាស់ វាបានដំណើរការតាំងពីនោះមកមែន។ ការយល់ដឹងរបស់ខ្ញុំ ឬអាចថាការខ្វះខាតនូវការយល់ដឹងរបស់ខ្ញុំ មិនបានអនុញ្ញាតឱ្យខ្ញុំមានក្តីស្រមៃធ្វើជាម្ចាស់នៃយន្តហោះឡើយ។

មនុស្សបានមើលសត្វបក្សីហើរអស់រាប់ពាន់ឆ្នាំ ច្បាប់នៃការហោះឡើងលើបានដំណើរការក្នុងពន្លឺថ្ងៃដ៏ទូលំទូលាយសម្រាប់ឱ្យគ្រប់គ្នាអាចមើលឃើញបាន ប៉ុន្តែគ្មាននរណាម្នាក់បានឃើញវាឡើយ។ តើអ្នកមានឃើញអ្វីខ្លះដែរ? ចូរសាកគិតបន្តិចទៅមើល។

អត្ថបទគម្ពីរមួយក្នុងចំណោមបទគម្ពីរដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំកាលពីដំបូងៗដែលពាក់ព័ន្ធនឹងសម្រាកនៅក្នុងការផ្គត់ផ្គង់នៃព្រះរាជ្យនោះគឺ គម្ពីរសុភាសិត ១០៖២២។

> *មានតែព្រះពរមកពីព្រះអម្ចាស់ទេ ដែលធ្វើឱ្យមនុស្សចម្រុងចម្រើន ការខ្វល់ខ្វាយរបស់មនុស្សមិនអាចបន្ថែមអ្វីបានឡើយ។*

សុភាសិត ១០៖២២

អត្ថបទគម្ពីរនេះសំដៅលើបទគម្ពីរ និងគោលការណ៍ដែលមានចែងក្នុងគម្ពីរលោកុប្បត្តិ ៣៖១៧

*ដីនឹងត្រូវបណ្ដាសា ព្រោះតែអ្នក។ ដូច្នេះ អ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិត យ៉ាងវេទនាជារៀងរាល់ថ្ងៃ អស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញ ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើសរហូតដល់ថ្ងៃដែលអ្នកត្រឡប់ទៅជាដីវិញ ដ្បិតអ្នកមានកំណើតមកពីដី។*

លោកុប្បត្តិ ៣៖១៧

ពេលអដាំបានបាត់បង់ព្រះរាជ្យ នោះគាត់បានបាត់បង់នូវការផ្គត់ផ្គង់នៃព្រះរាជ្យ និងនៅសល់តែការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីរស់រាន។ តែពេលអ្នកនិងខ្ញុំបានរកឃើញ នោះយើងមិនអាចរត់លឿនល្មមជាមួយនឹងការប្រឹងប្រែងដោយឈឺចាប់និងបែកញើសដើម្បីឈោងចាប់សេរីភាពដែលយើងចង់បានយ៉ាងខ្លាំងនោះទេ។ ប៉ុន្តែពេលនេះមាននូវដំណឹងល្អមួយ! គឺព្រះយេស៊ូបានយាងមកបង្រៀនអំពីដំណឹងល្អដល់អ្នកក្រីក្រហើយ!

*ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់សណ្ឋិតលើខ្ញុំ ដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ ជួយថែទាំអ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថា ពួកគេនឹងរួចខ្លួនហើយ ប្រាប់អ្នកជាប់ឃុំឃាំងថា ពួកគេនឹងមានសេរីភាព។*

អេសាយ៦១៖១

ព្រះយេស៊ូត្រូវបានបញ្ជូនមកដើម្បីបង្រៀនអំពីដំណឹងល្អទៅកាន់អ្នកក្រ។ តើអ្វីជាដំណឹងល្អទៅកាន់អ្នកក្រ? សាមញ្ញណាស់ គឺពួកគេមិនត្រូវជាប់ចំណងនៃភាពខ្វះខាត និងភាពក្រីក្រក្នុងប្រព័ន្ធបណ្ដាសានៃការផ្គត់ផ្គង់នៅលើផែនដីនេះ។ ទុកចិត្តខ្ញុំចុះ ក្រោយពីបានរស់នៅ ឬអាចនិយាយបានថា ក្រោយផុតពីការត្រដររស់នៅអស់រយៈពេលប្រាំបួនឆ្នាំដោយគ្មានសល់អ្វីក្រៅពីបំណុល និងភាពតានតឹង នោះបទគម្ពីរនេះគឺជាដំណឹងល្អមួយ តែវានៅមានភាពតាន់ច្រទ្បំនៅឡើយ។ តើវាពិតជាមានន័យដូចអ្វីដែលបានចែងមកទេ? តើមិនល្អទេ ឬដែលវាមានន័យត្រង់ដូចដែលបានចែងមក ដែលថាព្រះពររបស់ព្រះអម្ចាស់ពិតជាបានធ្វើអ្វីមួយដែលនាំនូវទ្រព្យសម្បត្តិចូលមកក្នុងជីវិតរបស់យើង? ខ្ញុំពិតជាចាំបាច់ចង់ដឹងណាស់បើនេះជាការពិតមែន និងចងដឹងពីរបៀបអនុវត្តតាមនេះ។ យ៉ាងណាក្ដី អ្វីម្យ៉ាងដែលខ្ញុំពិតជាបានយល់នោះគឺ បណ្ដាសានៃការប្រឹងប្រែងទាំងឈឺចាប់ និងបែកញើសនោះ គឺត្រូវបានផ្ដល់

ឱ្យបានត្រឹមតែក្នុងកម្រិតសម្រាប់តែមួយរស់ប៉ុណ្ណោះ ហើយការបានត្រឹមតែមួយរស់នោះគឺមិនទាន់ល្អគ្រប់គ្រាន់ទេ។ គ្មាននរណាម្នាក់ចង់បានសេរីភាពរួចពីបណ្តាសានេះខ្លាំងជាងខ្ញុំទេ ប៉ុន្តែខ្ញុំមិនបានដឹងសោះថាតើត្រូវនាំវាចូលមកក្នុងជីវិតខ្ញុំបានដោយរបៀបណា។ ខ្ញុំថា នេះជារបៀបដែលគ្រិស្តបរិស័ទជាច្រើនរស់នៅ ដោយគ្រាន់តែការពីសេចក្តីសន្យារបស់ព្រះ តែមិនដឹងពីរបៀបរស់នៅឱ្យសមរម្យ និងត្រូវស្តែងចេញមកនៅក្នុងជីវិតរបស់ពួកគេផ្ទាល់។

នៅពេលខ្ញុំបានចាប់ផ្តើមសិក្សាពីវា ហើយនៅពេលព្រះអម្ចាស់បានដឹកនាំខ្ញុំក្នុងការស្វែងយល់ពីគោលកាណ៍នៃព្រះរាជ្យទ្រង់ នោះខ្ញុំបានអានពីរបៀបដែលលោកអប្រាហាំមានទ្រព្យសម្បត្តិយ៉ាងច្រើន។ ឈប់សិន! ចុះរឿងប្រព័ន្ធបណ្តាសាផែនដីនោះ តើគាត់បានយកឈ្នះវាដោយរបៀបណា?

*លោកអាប់រ៉ាមមានហ្វូងសត្វ និងមានមាសប្រាក់ជាច្រើន។*

លោកុប្បត្តិ ១៣៖២

លោកបានក្លាយជាអ្នកមាន ទេ ព្រះគម្ពីរបានថែងថាជាអ្នកមានខ្លាំង (ច្រើន) ប៉ុន្តែតើលោកមានបានដោយរបៀបណា? អ្នកប្រហែលនិយាយថា «ហ្នឹងហើយ គឺដោយសារតែគាត់ជាអប្រាហាំ។ ទេ គឺមិនមែនអ៊ីចឹងទេ។ ត្រង់ចំណុចនេះជាកន្លែងដែលអ្នកត្រូវចាប់យកនូវការយល់ដឹងពីច្បាប់នៃព្រះរាជ្យ។ ច្បាប់មិនបានកំណត់ថាអ្នកជានរណានោះទេ។ ច្បាប់ទាំងនេះមិនបានផ្តល់តម្លៃបុគ្គលណាទេ។ ប្រសិនបើនរណាម្នាក់ ឬនរណាមួយលោតពីលើអគារកប់ពពក Empire State ដោយគ្មានឆ័ត្រយោងទេ នោះមិនថាអ្នកជាអ្នកធំ ឬអ្នកតូចតាចទេ គ្រប់គ្នាប្រាកដជាដឹងពីលទ្ធផលហើយ។ ច្បាប់ទំនាញផែនដីនឹងនៅតែដំណើរការគ្រប់ពេល។ ដូចនេះ តើអប្រាហាំអាចចម្រុងចម្រើនដូចម្តេចបានបើមាននូវប្រព័ន្ធបណ្តាសានោះ? តើយើងអាចរកឃើញតម្រុយខ្លះៗនៅក្នុងសាច់រឿងរបស់លោកទេ? យើងអាចរកឃើញផ្នែកខ្លះនៃចម្លើយនេះនៅក្នុងគម្ពីរលោកុប្បត្តិជំពូក១២។ ក្នុងជំពូកនេះ ព្រះជាម្ចាស់បានប្រទាននូវនូវការសន្យាមួយមកលោកអាប់រ៉ាម (ដែលក្រោយមកលោកក្លាយជាអប្រាហាំ) ដែលពាក់ព័ន្ធនឹងជីវិត ព្រមទាំងកូនចៅរបស់លោក។

*ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖ «ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីញាតិសន្តាន និងចាកចេញពីក្រុមគ្រួសារឪពុករបស់អ្នក តម្រង់ឆ្ពោះទៅស្រុកដែលយើងនឹងបង្ហាញអ្នក ។ យើងនឹងឱ្យប្រជាជាតិមួយ*

*ដ៏ធំកើតចេញពីអ្នក ហើយយើងនឹងឱ្យពរអ្នក។ យើងនឹងធ្វើឱ្យអ្នកមានឈ្មោះល្បី។ ដូច្នេះ ចូរធ្វើជាអ្នកផ្តល់ពរដល់អ្នកដទៃចុះ! យើងនឹងឱ្យពរដល់ជនទាំងឡាយណាដែលឱ្យពរអ្នក យើងក៏នឹងដាក់បណ្តាសាដល់ជនទាំងឡាយណាដែលដាក់បណ្តាសាអ្នកដែរ ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក» ។*

លោកុប្បត្តិ ១២៖១-៣

សេចក្តីសន្យានោះ គឺស្រេចតែលើលោកអប្រាហាំជឿព្រះជាម្ចាស់ និងស្តាប់បង្គាប់ទ្រង់ប៉ុណ្ណោះ ហើយវាទាមទារនូវជំនឿដ៏ធំធេងដើម្បីចាកចេញពីកន្លែងដែលខ្លួនធ្លាប់ស្គាល់ និងមិនដឹងថាលោកនឹងទៅណា។

*ដោយសារជំនឿ លោកអប្រាហាំស្តាប់បង្គាប់ព្រះជាម្ចាស់ដែលបានត្រាស់ហៅលោក ហើយចេញដំណើរទៅកាន់ស្រុកមួយ ដែលលោកនឹងទទួលទុកជាមត៌ក។ លោកចេញដំណើរទៅ ទាំងពុំដឹងថាត្រូវទៅណាផង។*

ហេប្រឺ ១១៖៨

ដូចនេះ យើងដឹងថា ព្រះជាម្ចាស់បានរកឃើញនូវច្បាប់ដែលចូលមកក្នុងពិភពផែនដីតាមរយៈមនុស្សដែលបានជឿលើទ្រង់ ទោះបីជារឿងខ្លះស្តាប់ទៅមិនសមហេតុផលក៏ដោយ។ ជំនឿរបស់អប្រាហាំបានធ្វើឱ្យព្រះជាម្ចាស់ប្រទានពរដល់លោកដោយផ្ទាល់។ ប៉ុន្តែក្រោយមក ដោយសារជំនឿរបស់អប្រាហាំ នោះព្រះជាម្ចាស់ក៏បានចងសម្ពន្ធមេត្រីនឹងលោកទាក់ទិននឹងអ្នកស្នងមត៌ករបស់លោក។ សូមកុំគិតថានេះជារឿងចម្លែកឱ្យសោះ។ អ្នកនៅចាំទេ នេះជារបៀបដែលសាតាំងខ្លួនឯងបានទទួលសិទ្ធិចូលមកក្នុងពិភពផែនដីក្នុងគ្រាដំបូងបង្អស់។ អដាំដែលជាបុគ្គលដែលមាននូវយុត្តាធិការស្របច្បាប់លើផែនដី (ដូចបានកត់ត្រាទុកក្នុងគម្ពីរហេប្រឺ ២៖៧-៨) ក៏បានជ្រើសរើសជឿលើសាតាំងជាជាងជឿលើព្រះជាម្ចាស់។

ជំនឿរបស់អប្រាហាំដែលបានបើកទ្វារផ្នែកច្បាប់សម្រាប់ឥទ្ធិពលស្ថានសួគ៌មកលើជីវិតរបស់លោក បានអនុញ្ញាតឱ្យលោកចម្រុងចម្រើនយ៉ាងខ្លាំង។ ភាពចម្រុងចម្រើននេះបានបន្តរហូតដល់អ្នកស្នងមត៌កទាំងអស់របស់លោកអប្រាហាំទៀតផង។ នៅពេលខ្ញុំធ្វើការសិក្សាបន្ថែម ខ្ញុំក៏បានបន្តអានអំពីរឿងយ៉ូសែប ដែលជាចៅទួតរបស់លោកអប្រាហាំ។ ក្នុងនេះ ខ្ញុំ

បានរកឃើញនៅការបើកបង្ហាញ និងការយល់ដឹងដ៏អស្ចារ្យមួយអំពីព្រះរាជ្យ និងរបៀបដែលព្រះរាជ្យដំណើរការ ហើយជាពិសេសគឺបង្ហាញពីអត្ថន័យនៃគម្ពីរសុភាសិត១០៖២២។

នៅក្នុងរឿងនោះ បងៗរបស់យ៉ូសែបបានស្អប់លោក ហើយក៏បានលក់លោកឱ្យក្លាជាទាសករ ដោយលក់ឱ្យទៅឈ្មួញរកស៊ីទិញពួកទាសករដែលតែងតែធ្វើដំណើរតាមតំបន់នោះជាញឹកញាប់។ ពួកគេបាននាំយ៉ូសែបទៅដល់ស្រុកអេហ្ស៊ីប ដែលក្រោយមកគេក៏លក់យ៉ូសែបទៅឱ្យលោកប៉ូទីផារ ដែលជាមេបញ្ជាការកងទ័ពអេហ្ស៊ីបម្នាក់។ នៅក្នុងអត្ថបទក្រោយមកទៀត ខ្ញុំរកឃើញនូវចំណែកនៃចម្លល់មួយទៀតដែលទាក់ទិននឹងសមត្ថភាពរបស់អប្រាហាំដើម្បីមានភាពចម្រុងចម្រើនមកដល់កម្រិតដែលលោកបានធ្វើ។

*ជនជាតិអ៊ីស្មាអែលបាននាំយ៉ូសែបចុះទៅស្រុកអេស៊ីប ហើយលក់លោកឱ្យជនជាតិអេស៊ីបម្នាក់ ឈ្មោះប៉ូទីផារ ជាមន្ត្រីរបស់ព្រះចៅផារ៉ោន និងជាមេបញ្ជាការកងរក្សាស្ដេច។ ព្រះអម្ចាស់គង់នៅជាមួយលោកយ៉ូសែប ការអ្វីដែលលោកធ្វើ សុទ្ធតែបានលទ្ធផលល្អទាំងអស់។ លោករស់នៅក្នុងផ្ទះម្ចាស់របស់លោក ដែលជាជនជាតិអេស៊ីបនោះ។ ម្ចាស់របស់លោកឃើញថា ព្រះអម្ចាស់គង់នៅជាមួយលោក ហើយការអ្វីដែលលោកធ្វើ ព្រះអង្គប្រោសប្រទានឱ្យបានលទ្ធផលល្អទាំងអស់។*

*លោកប៉ូទីផារពេញចិត្តនឹងលោកយ៉ូសែបណាស់ គាត់ក៏ឱ្យលោកធ្វើជាអ្នកបម្រើជំនិតរបស់គាត់ ហើយតែងតាំងលោកឱ្យមើលខុសត្រូវលើផ្ទះសំបែង និងគ្រប់គ្រងលើទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់គាត់។ ចាប់ពីពេលលោកប៉ូទីផារតែងតាំងលោកយ៉ូសែបឱ្យមើលខុសត្រូវលើផ្ទះសំបែង និងលើទ្រព្យសម្បត្តិរបស់គាត់មក ព្រះអម្ចាស់ប្រទានពរដល់ជនជាតិអេស៊ីបនេះ ព្រោះតែលោកយ៉ូសែប **ហើយព្រះអង្គក៏ប្រទានពរដល់អ្វីៗទាំងអស់ ដែលជាកម្មសិទ្ធិរបស់គាត់ គឺទាំងផ្ទះសំបែង ទាំងស្រែចម្ការ។** គាត់ប្រគល់ឱ្យលោកយ៉ូសែបគ្រប់គ្រងលើអ្វីៗទាំងអស់ដែលគាត់មាន ហើយក្រៅតែពីបរិភោគ គាត់មិនខ្វល់ខ្វាយនឹងកិច្ចការអ្វីទៀតឡើយ។*

លោកុប្បត្តិ ៣៩៖១-៦

អត្ថបទគម្ពីរចែងយ៉ាងច្បាស់ថា វាជាព្រះពររបស់ព្រះអម្ចាស់ដែលបណ្ដាលឱ្យមានការចម្រុងចម្រើនមកកាន់យ៉ូសែប។ ប៉ុន្តែតើព្រះពររបស់ព្រះអម្ចាស់នោះជាអ្វីទៅ? ខ្ញុំកត់

សម្គាល់ឃើញថា វាជា ព្រះពរ «ជាក់លាក់» របស់ព្រះអម្ចាស់ មិនមែនជាព្រះពរ «តែមួយ» របស់ព្រះអម្ចាស់ទេ។ យើងគ្រប់គ្នានឹងពោលថាអ្វីមួយដ៏អស្ចារ្យដែលនោះជា «ព្រះពរមួយ»។ ប៉ុន្តែអត្ថបទនេះមិនបាននិយាយសំដៅលើអ្វីទូទៅ ជាអ្វីដែលកំពុងកើតឡើងទេ។ បទគម្ពីរបានចែងពី «ព្រះពរ (ជាក់លាក់)»។

ខ្ញុំដឹងច្បាស់ថា តាមពិត ព្រះពររបស់ព្រះអម្ចាស់នោះគឺជាសម្ពន្ធមេត្រីដែលបានធ្វើឡើងរវាងព្រះជាម្ចាស់ និងលោកអប្រាហាំ និងអ្នកស្នងមតិករបស់លោក។ ជាពិសេស ព្រះពរជាក់លាក់នេះ គឺជាសេចក្តីសន្យាដែលបានប្រទានឱ្យអប្រាហាំនៅក្នុងសម្ពន្ធមេត្រីនោះ។ កិច្ចព្រមព្រៀងស្របច្បាប់មាននូវភារកិច្ច និងកាតព្វកិច្ចចូលរួមពីភាគីទាំងពីរ ប៉ុន្តែកិច្ចព្រមព្រៀងនេះបង្កើតជាផលប្រយោជន៍ចំពោះភាគីនីមួយៗ។ ក្នុងករណីនេះ សេចក្តីសន្យាដែលបានផ្តល់ឱ្យអប្រាហាំនោះមាននូវអត្ថប្រយោជន៍ចំពោះកិច្ចព្រមព្រៀងនោះ។ ដើម្បីរីករាយនឹងអត្ថប្រយោជន៍ទាំងនេះ កាតព្វកិច្ចដែលត្រូវធ្វើគឺត្រូវដើរតាមបញ្ញត្តិ និងច្បាប់របស់ព្រះអម្ចាស់។ ខ្ញុំក៏បានឃើញយ៉ាងច្បាស់ដែរថា អ្វីៗដែលយ៉ូសែបបានយកមកនៅក្រោមយុត្តាធិការស្របច្បាប់របស់លោក ក៏បានស្ថិតនៅក្រោមសេចក្តីសន្យា ឬរីករាយនឹងសេចក្តីសន្យា ឬអត្ថប្រយោជន៍ទាំងនោះដូចគ្នា។

ដូចនេះ ខ្ញុំក៏ចាប់ផ្តើមយល់ពីន័យនៃគម្ពីរសុភាសិត ១០៖២២។ សេចក្តីសន្យារបស់ព្រះដែលបានប្រទានឱ្យអប្រាហាំ គឺជាកិច្ចព្រមព្រៀងស្របច្បាប់ដែលបានយកឈ្នះលើប្រព័ន្ធបណ្តាសានៃភាពក្រីក្រនៅលើផែនដី។ ព្រះពរដែលបានប្រទានឱ្យអប្រាហាំបានធ្វើឱ្យមានភាពស្របច្បាប់ដើម្បីឱ្យព្រះជាម្ចាស់អាចប្រទានពរដល់អប្រាហាំ និងកូនចៅសែស្រឡាយរបស់លោកឱ្យមានភាពចម្រុងចម្រើននិងមានឥទ្ធិពល ដូចការដែលព្រះជាម្ចាស់ចង់ឱ្យពួកគេមាន។ ពេលនេះ ចូរយើងអានគម្ពីរសុភាសិត ១០៖២២ ដោយមានការបកស្រាយតាមការយល់ឃើញដូចមានសរសេរក្នុងសញ្ញាវង់ក្រចក។

## កូនសោសំខាន់៖

## ព្រះពររបស់ព្រះយេហូវ៉ា [សេចក្តីសន្យាដែលត្រូវបានប្រទានឱ្យអប្រាហាំ] ធ្វើឱ្យទៅជាមាន ហើយព្រះអង្គមិនបន្ថែមទុក្ខព្រួយឡើយ។ (ពគប)

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

ឃ្លាដែលចែងថា *«ព្រះអង្គមិនបន្ថែមទុក្ខព្រួយឡើយ»* គឺសំដៅលើប្រព័ន្ធបណ្តាសាផែនដីដែលមានចែងក្នុងគម្ពីរលោកុប្បត្តិ ៣៖១៧ ដោយធ្វើឡើងតាមរយៈការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា។ ពាក្យជាភាសាហេប្រឺដែលប្រើសម្រាប់ពាក្យ ទុក្ខព្រួយ ក៏មានន័យថា ការងារពលកម្មយ៉ាប់យ៉ឺន! ឃើញទេ? មនុស្សអាចគេចផុតពីដែនកំណត់នៃបណ្តាសាផែនដី ដោយគេចផុតពីការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា តាមរយៈសេចក្តីសន្យាដែលបានប្រទានឱ្យអប្រាហាំ។ អូហ៎ ខ្ញុំដឹងថាអ្នកកំពុងគិតអ្វី «សេចក្តីសន្យាទាំងនោះត្រូវបានប្រទានឱ្យអប្រាហាំ និងពូជពង្សរបស់លោក។» មែនហើយ តែខ្ញុំត្រូវបង្ហាញខគម្ពីរមួយទៀតដល់អ្នកគឺ កាឡាទី ៣៖១៣-១៤។

> *ដោយព្រះគ្រិស្តបានទទួលបណ្តាសាសម្រាប់យើង ព្រះអង្គលោះយើងឱ្យរួចផុតពីបណ្តាសាដែលមកពីក្រឹត្យវិន័យ ដ្បិតមានចែងទុកមកថា «អ្នកណាដែលត្រូវគេព្យួរជាប់នឹងឈើ អ្នកនោះត្រូវបណ្តាសាហើយ» ហេតុការណ៍នេះកើតមានដូច្នេះ ដើម្បីឱ្យព្រះពរដែលលោកអប្រាហាំទទួល បានហូរទៅដល់សាសន៍ដទៃ តាមរយៈព្រះគ្រិស្តយេស៊ូដែរ ហើយឱ្យយើងទទួលព្រះវិញ្ញាណដែលព្រះជាម្ចាស់បានសន្យាប្រទានមក ដោយយើងមានជំនឿ។*
>
> កាឡាទី ៣៖១៣-១៤

ឥឡូវនេះ តាមរយៈជំនឿ យើងគឺជាអ្នកជឿលើព្រះយេស៊ូគ្រិស្តដែលបានចូលរួមក្នុងព្រះពរដែលត្រូវបានប្រទានឱ្យអប្រាហាំ។ ដូចនេះ តើអ្វីខ្លះជាព្រះពរដែលត្រូវបានប្រទានឱ្យអប្រាហាំនោះ? យើងអាចរកមើលបញ្ជីនៃសេចក្តីសន្យានានាដែលបានកត់ត្រាទុកនៅក្នុងគម្ពីរទុតិយកថា ជំពូក២៨។

> *«ប្រសិនបើអ្នកយកចិត្តទុកដាក់ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ដោយកាន់ និងប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ ដូចខ្ញុំបង្គាប់នៅថ្ងៃនេះ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានឱ្យអ្នកបានទៅជាប្រជាជាតិមួយ ប្រសើរជាងប្រជាជាតិទាំងអស់នៅលើផែនដី។ ប្រសិនបើអ្នកស្តាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក ព្រះអង្គនឹងប្រទានពរគ្រប់យ៉ាងដល់អ្នក៖*

*គឺព្រះអង្គប្រទានពរដល់អ្នក នៅតាមទីក្រុង ព្រះអង្គប្រទានពរដល់អ្នកនៅតាមស្រែចម្ការ។ ព្រះអង្គប្រទានពរឱ្យអ្នកមានកូនចៅច្រើន ឱ្យដីរបស់អ្នកកើនភោគផលបរិបូណ៌ ហើយហ្វូងសត្វរបស់អ្នក គឺគោ និងចៀមក៏នឹងកើនចំនួនឡើងជាច្រើនដែរ។ ព្រះអង្គប្រទានពរឱ្យអ្នកមានផ្លែឈើពេញល្អី ព្រមទាំងមានស្រូវពេញជង្រុក។ ព្រះអង្គនឹងប្រទានពរដល់អ្នក ក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ។*

*ព្រះអម្ចាស់នឹងធ្វើឱ្យបច្ចាមិត្តបាក់ទ័ព រត់នៅពីមុខអ្នក។ ពួកគេចេញមកវាយអ្នក ដោយដើរតាមផ្លូវតែមួយ តែពួកគេនឹងរត់នៅមុខអ្នក ទៅតាមផ្លូវប្រាំពីរ។*

*ព្រះអម្ចាស់ប្រទានពរឱ្យអ្នកមានស្រូវពេញជង្រុក ហើយអ្វីៗដែលអ្នកធ្វើ ព្រះអង្គប្រទានពរជានិច្ច។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានពរអ្នក ក្នុងស្រុកដែលព្រះអង្គប្រទានឱ្យអ្នក។*

*ពេលណាអ្នកប្រតិបត្តិតាមបទបញ្ជារបស់ព្រះអម្ចាស់ ជាព្រះនៃអ្នក ហើយដើរតាមមាគ៌ារបស់ព្រះអង្គ នោះព្រះអម្ចាស់នឹងធ្វើឱ្យអ្នកទៅជាប្រជារាស្ត្រដ៏វិសុទ្ធ ដូចព្រះអង្គបានសន្យាជាមួយអ្នក។ ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងឃើញថា ព្រះអម្ចាស់បានជ្រើសរើសអ្នកជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ ហើយពួកគេនឹងកោតខ្លាចអ្នក។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានឱ្យអ្នកបានចម្រុងចម្រើន ដោយធ្វើឱ្យពូជពង្សរបស់អ្នក និងហ្វូងសត្វរបស់អ្នកកើនចំនួនច្រើនឡើង ហើយក៏ធ្វើឱ្យអ្នកទទួលភោគផលជាច្រើន នៅលើទឹកដីដែលព្រះអង្គបានសន្យាដល់បុព្វបុរស ថាប្រទានឱ្យអ្នកដែរ។*

*ព្រះអម្ចាស់នឹងបើកផ្ទៃមេឃ បង្អុរភ្លៀងចុះមកស្រោចស្រពទឹកដីរបស់អ្នកតាមរដូវកាល ដើម្បីប្រទានពរដល់កិច្ចការទាំងប៉ុន្មានដែលអ្នកធ្វើ។ អ្នកនឹងឱ្យទ្រព្យដល់ប្រជាជាតិជាច្រើនខ្ចី តែអ្នកមិនខ្ចីពីគេឡើយ។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងធ្វើឱ្យអ្នកបានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ អ្នកនឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច គឺមិនចុះខិនថយឡើយ។ ប៉ុន្តែ អ្នកត្រូវស្តាប់បង្គាប់ ហើយកាន់ និងប្រតិបត្តិតាមបទបញ្ជារបស់ព្រះអង្គ ដែលខ្ញុំប្រគល់ឱ្យអ្នកនៅថ្ងៃនេះ។ មិនត្រូវងាកទៅឆ្វេង ទៅស្តាំ ឆ្ងាយពីបទបញ្ជាទាំងប៉ុន្មាន ដែលខ្ញុំប្រគល់ឱ្យអ្នកនៅថ្ងៃនេះ ហើយបែរទៅជំពាក់ចិត្ត និងគោរពថ្វាយបង្គំព្រះឯទៀតៗឡើយ។»*

ទុតិយកថា ២៨៖១-១៤

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

ទោះនោះជាអ្វីដែលកើតមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ក្តី ក៏ពេលនេះសេចក្តីសន្យាទាំងនេះជារបស់អ្នកដើម្បីរីករាយនឹងវាផងដែរ។ អ្វីដែលខុសគ្នានោះគឺថា នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មនុស្សបានចូលទៅរកសេចក្តីសន្យាទាំងនោះតាមរយៈអ្វីដែលពួកគេបានធ្វើ ប៉ុន្តែយើងបានចូលទៅរកសេចក្តីទាំងនោះតាមរយៈជំនឿនៅក្នុងព្រះយេស៊ូគ្រិស្តដែលស្ថិតក្រោមសម្ព័ន្ធមេត្រីថ្មី។ ក្នុងនាមជាសាសន៍ដទៃ អ្នកនឹងខ្ញុំត្រូវបានផ្សាំ ហើយពេលនេះតាមរយៈព្រះយេស៊ូគ្រិស្ត យើងមានចំណែកក្នុងព្រះពររបស់អប្រាហាំ។ ប៉ុន្តែ យើងមានច្រើនជាងព្រះពរខាងរូបកាយរបស់អប្រាហាំទៅទៀត គឺយើងមាននូវព្រះពរខាងព្រលឹងវិញ្ញាណនៃអ្នកដែលបានកើតជាថ្មី។ ពេលនេះ យើងមាននូវព្រះពរលើផែនដីរបស់អប្រាហាំ ប៉ុន្តែយើងក៏មាននូវព្រះពរនៃស្ថានសួគ៌ដ៏អស់កល្បជានិច្ច ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានសណ្ឋិតនៅក្នុងយើងដែលជាបុត្រាបុត្រីរបស់ព្រះ។ ចូរចាំថា មានតែបុត្រា និងបុត្រីប៉ុណ្ណោះដែលទទួលបាននូវមត៌ក ចំណែកទាសករវិញ គឺមិនអាចទទួលបានឡើយ។ ទោះបីជាអប្រាហាំស្រលាញ់ព្រះជាម្ចាស់ខ្លាំងប៉ុនណាក្តី បើគ្មានការកើតជាថ្មីទេ នោះព្រះវិញ្ញាណដ៏វិសុទ្ធមិនបានសណ្ឋិតនៅក្នុងលោកទេ ហើយលោកក៏មិនអាចចូលទៅស្ថានសួគ៌ដែរ។ ប្រាកដណាស់ លោកបានចូលទៅស្ថានសួគ៌ក្រោយពេលព្រះយេស៊ូបានបង់ថ្លៃបំណុលនៃអំពើបាប។

ពេលខ្ញុំយល់ពីអត្ថន័យដែលគម្ពីរសុភាសិត ១០៖២២ ចង់បង្ហាញ ដែលគម្ពីរនេះចែងថា ព្រះជាម្ចាស់ធ្វើឱ្យគេទៅជាមាន ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយឡើយ។ ពាក្យទុក្ខព្រួយ ជាភាសាហេប្រឺ មានន័យថា កាងារពលកម្មយ៉ាប់យ៉ឺន ដែលពេលនេះខ្ញុំបានយល់ពីអត្ថន័យរបស់វានោះ គឺមានសំដៅលើប្រព័ន្ធបណ្តាសាផែដីដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា។ ខ្ញុំយល់ថា សម្ពន្ធមេត្រីនេះហើយដែលជាព្រះពរនៃសេចក្តីសន្យានៃជំនួយព្រះ និងអត្ថប្រយោជន៍របស់ទ្រង់ ដោយបានលើកអប្រាហាំឡើងផុតពីបណ្តាសានៃផែនដី និងបានធ្វើឱ្យលោកបានចម្រុងចម្រើន។ ខ្ញុំបានដឹងថា អត្ថប្រយោជន៍នៃព្រះពរដែលដូចមានចែងក្នុងគម្ពីរទុតិយកថាជំពូក២៨នោះ បានបង្ហាញដល់ខ្ញុំយ៉ាងច្បាស់ថា ខ្ញុំត្រូវតែចម្រុងចម្រើន។ ឥទ្ធិពលនៃសេចក្តីសន្យាទាំងនេះគឺថា ខ្ញុំត្រូវបានកំណត់មកឱ្យធ្វើជាក្បាល មិនមែនជាកន្ទុយទេ ជាអ្នកផ្តល់កម្ចី មិនមែនជាអ្នកខ្ចីគេទេ។ នេះគឺជាសិទ្ធិស្របច្បាប់នៃបុត្រម្នាក់ៗរបស់ព្រះជាម្ចាស់។ ខ្ញុំមាននូវព្រះពររបស់ព្រះ គឺដូចលោកយ៉ូសែបដែរ ហើយខ្ញុំគួរតែបានចម្រុងចម្រើន។ ហើយខ្ញុំក៏មាននូវមត៌កនៃព្រះរាជ្យរបស់ព្រះទាំងមូលដែរ។ ក្នុងនាមជាកូន អ្វីទាំងអស់គឺជារបស់ខ្ញុំដោយស្របច្បាប់រួចស្រេចទៅហើយ។

នៅពេលខ្ញុំក្រលេកមើលពីសាច់រឿងរបស់លោកយ៉ូសែបក្នុងគម្ពីរលោកុប្បត្តិ ជំពូក ៣៩ ម្តងទៀត នោះខ្ញុំបានឃើញយ៉ាងច្បាស់ថា វាជាជោគជ័យរបស់យ៉ូសែបដែលបានធ្វើឱ្យលោកប៉ូទីផារមានចំណាប់អារម្មណ៍លើលោក ហើយវាក៏ជាជោគជ័យយ៉ាងច្បាស់ដែរដែលបានធ្វើឱ្យមានការចាប់អារម្មណ៍ពីជាតិសាសន៍នានាលើពិភពលោក និងឱ្យពួកគេបានឃើញពីភាពខុសគ្នាក្នុងប្រជារាស្ត្ររបស់ព្រះ។

> *ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងឃើញថា ព្រះអម្ចាស់បានជ្រើសរើសអ្នកជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ ហើយពួកគេនឹងកោតខ្លាចអ្នក។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានឱ្យអ្នកបានចម្រុងចម្រើន ដោយធ្វើឱ្យពូជពង្សរបស់អ្នក និងហ្វូងសត្វរបស់អ្នកកើនចំនួនច្រើនឡើង ហើយក៏ធ្វើឱ្យអ្នកទទួលភោគផលជាច្រើន នៅលើទឹកដីដែលព្រះអង្គបានសន្យាដល់បុព្វបុរសថាប្រទានឱ្យអ្នកដែរ។*
>
> ទុតិយកថា ២៨៖១០-១១

នៅក្នុងគម្ពីរលោកុប្បត្តិ ៣៩៖៦ ក៏មាននូវតម្រុយដ៏ច្រើនដែលខ្ញុំបានកត់សម្គាល់ទុក និងចង់ឱ្យអ្នកបានឃើញ។ និយាយពីលោកប៉ូទីផារ គម្ពីរបានចែងថា «*គាត់ប្រគល់ឱ្យលោកយ៉ូសែបគ្រប់គ្រងលើអ្វីៗទាំងអស់ដែលគាត់មាន ហើយក្រៅតែពីបរិភោគ គាត់មិនខ្វល់ខ្វាយនឹងកិច្ចការអ្វីទៀតឡើយ។*» ខ្ញុំបានមើលឃើញពីចំណុចនេះ! នេះគឺជាឧទាហរណ៍នៃការសម្រាកដែលយើងកំពុងនិយាយ។ លោកប៉ូទីផារមិនចាំបាច់ខ្វល់ខ្វាយអំពីអ្វីឡើយ ក្រៅតែពីការបរិភោគ។ ចំណុចនេះបង្ហាញថា ជោគជ័យដែលលោកយ៉ូសែបបាននាំមកកាន់គ្រួសាររបស់លោក ដែលជាព្រះពររបស់ព្រះជាម្ចាស់បានបង្កើតនូវលទ្ធផលដែលអនុញ្ញាតឱ្យលោកប៉ូទីផារអាចផ្តោតលើកិច្ចការរបស់លោក ហើយមិនចាំបាច់ផ្តោតលើការប្រឹងប្រែងដើម្បីរស់ទេ!

ឌ្រិនដា និងខ្ញុំមានពាក្យមួយឃ្លាដែលពួកយើងតែងតែប្រើវាជាច្រើនឆ្នាំមកហើយគឺពាក្យ «បើ អ្នកមិនដោះស្រាយរឿងលុយទេ អ្នកនឹងរកមិនឃើញជោគវាសនាខ្លួនឡើយ!» ហើយនឹងមិនអាចរកឃើញថាអ្នកជានរណាឡើយ។ អ្នកនឹងរកមិនឃើញនូវភាពពិសេសរបស់ខ្លួន បំណងចិត្តរបស់ខ្លួន និងមិនអាចរកឃើញនូវការពេញចិត្តដ៏ពិតប្រាកដឡើយ។ អ្នកនឹងមានតែការសម្រេចចិត្តគ្រប់យ៉ាងសម្រាប់តែការប្រឹងរស់រាន ដោយប្រឹងរក ឬសន្សំលុយ ដោយធ្វើជាមនុស្សម្នាក់ដែលមិនមែនជាខ្លួនឯង ដើម្បីបង់ការចំណាយផ្សេងៗប៉ុណ្ណោះ។ ត្រង់នេះ យើងឃើញមាននូវឥទ្ធិពលនៃព្រះពររបស់ព្រះអម្ចាស់មកលើលោកប៉ូទីផារ ដែលលោក

មិនបានដឹងអ្វីបន្តិចឡើយអំពីព្រះរាជ្យនៃព្រះ។ ទ្រព្យសម្បត្តិ និងសេចក្ដីព្រួយបារម្ភរបស់លោកប៉ូទីផារត្រូវបានផ្ទេរឱ្យស្ថិតក្រោមសម្ពន្ធមេត្រីដែលលោកយ៉ូសែបមាន ដោយលោកគ្រាន់តែទម្លាក់អ្វីៗរបស់លោកឱ្យស្ថិតក្រោមការថែរក្សារបស់លោកយ៉ូសែបប៉ុណ្ណោះ។ នៅក្នុងខ៥នៃជំពូកទី៣៩ អ្នកអាចឃើញយ៉ាងច្បាស់ពីសភាពលក្ខណៈនៅពេលដែលមានការផ្ទេរបន្ទុកនេះ។

> *<u>ចាប់ពីពេល</u>លោកប៉ូទីផារតែងតាំងលោកយ៉ូសែបឱ្យមើលខុសត្រូវលើផ្ទះសំបែង និងលើទ្រព្យសម្បត្តិរបស់គាត់មក ព្រះអម្ចាស់ប្រទានពរដល់ជនជាតិអេស៊ីបនេះ ព្រោះតែលោកយ៉ូសែប ហើយព្រះអង្គក៏ប្រទានពរដល់អ្វីៗទាំងអស់ដែលជាកម្មសិទ្ធិរបស់គាត់ គឺទាំងផ្ទះសំបែង ទាំងស្រែចម្ការ។*

លោកុប្បត្តិ ៣៩៖៥

ត្រង់ចំណុចនេះ យើងមើលឃើញនូវការផ្ទេរអ្វីមួយនៅក្នុងពិភពផែនដីនេះជាថ្មីម្ដងទៀតហើយ ដែលការនេះមានគោលបំណងសំដៅលើប្រព័ន្ធបណ្ដាសាផែនដី ដោយស្ថិតនៅក្រោមយុត្តាធិការនៃព្រះរាជ្យរបស់ព្រះ ហើយការផ្លាស់ប្ដូរដ៏ធំសម្បើមបានកើតឡើង។ ចូរគិតពីចំណុចនេះ៖ ប្រសិនបើព្រះជាម្ចាស់កំពុងជួយអ្នកដោយព្រះប្រាជ្ញាញាណរបស់ទ្រង់ ដោយដឹកនាំអ្នកទៅរកការសម្រេចចិត្តត្រឹមត្រូវ ព្រមទាំងព្រមានអ្នកឱ្យផុតពីគ្រោះថ្នាក់ដែលអាចកើតមានឡើង នោះនរណាក៏អាចចម្រុងចម្រើនបានដែរ! អ្នកឃើញទេ? ព្រះពររបស់ព្រះអម្ចាស់គឺជារបស់អ្នក!

ពេលខ្ញុំសិក្សាពីចំណុចនេះដូចដែលព្រះអម្ចាស់បានកំពុងបង្រៀនខ្ញុំអំពីព្រះរាជ្យ នោះខ្ញុំមានការភាន់ច្រឡំថា ហេតុអ្វីបានជាលោកយ៉ូសែបមានជោគជ័យដ៏ច្រើនដោយសារតែព្រះពរ ប៉ុន្តែគ្រិស្តបរិស័ទភាគច្រើនដែលខ្ញុំបានស្គាល់នៅពេលសព្វថ្ងៃនេះបែរជាកំពុងជាប់គាំងក្នុងការរកប្រាក់កាក់សម្រាប់ការចំណាយទៅវិញ។ ការមានសេរីភាពទាំងស្រុងពីផ្នែកហិរញ្ញវត្ថុគឺជាអ្វីដែលមនុស្សភាគច្រើនតែងគិតថាមិនអាចទៅរួច។ ប៉ុន្តែ យើងមាននូវសម្ពន្ធមេត្រីដែលប្រសើរជាង ដែលឈរលើមូលដ្ឋាននៃកិច្ចសន្យាដែលប្រសើរជាងអ្វីដែលនៅក្នុងសម្ពន្ធមេត្រីចាស់។ ទោះជាខ្ញុំយល់យ៉ាងច្បាស់ពីព្រះពររបស់ព្រះអម្ចាស់ ក៏ខ្ញុំនៅតែមិនដឹងពិតប្រាកដអំពីរបៀបដែលព្រះពរនោះបានបង្កើតនូវចម្លើយដែលខ្ញុំត្រូវការទេ ប៉ុន្តែខ្ញុំក៏រៀនបានកាន់តែច្រើន និងរីករាយនឹងវាកាន់តែខ្លាំង ព្រមទាំងមានសេរីភាពជាងមុន នៅពេលដែលខ្ញុំចាប់ផ្ដើមអនុវត្ត និងដកពិសោធជាមួយអ្វីដែលព្រះជាម្ចាស់កំពុងបង្រៀនខ្ញុំ។

នោះខ្ញុំក៏ងាកការចាប់អារម្មណ៍មកមើលសម្ពន្ធមេត្រីថ្មីវិញ និងបានក្រឡេកមើលព្រះយេស៊ូ និងព័ន្ធកិច្ចរបស់ទ្រង់ ដើម្បីសិក្សាបន្ថែមអំពីរបៀបដែលព្រះរាជ្យនៃព្រះកំពុងផ្លាស់ប្តូរស្ថានភាព និងកាលៈទេសៈនៅទីនោះ។

*ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្ដាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចព្រះអង្គសុំឱ្យគាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដាជនពីក្នុងទូកនោះ។*

*លុះព្រះអង្គបង្រៀនគេចប់ហើយ ព្រះអង្គមានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។ លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែបើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។*

*គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

*ពេលលោកស៊ីម៉ូន-ពេត្រុសឃើញដូច្នោះ គាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងឱ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប»។ លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅជាមួយ ភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ រីឯលោកយ៉ាកុប និងលោកយ៉ូហាន ជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។*

*ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។ ពេលទូកទៅដល់មាត់ច្រាំងវិញ គេបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។*

លូកា ៥៖១-១១

នេះជាសាច់រឿងស្ដីពីរបៀបដែលព្រះរាជ្យរបស់ព្រះដើរបញ្ច្រាសពីប្រព័ន្ធបណ្ដាសាផែនដីនៅក្នុងជីវិតរបស់អ្នកនេសាទទាំងបីនាក់នាព្រឹកមួយ។ ប្រសិនបើអ្នកអានអត្ថបទ នោះអ្នកនឹងឃើញថា ពេត្រុស យ៉ាកុប និងយ៉ូហានបាននេសាទអស់ពេញមួយយប់ដោយចាប់ត្រីមិនបានសោះ គឺទទេតែម្ដង។ តាមលក្ខណៈនៃប្រព័ន្ធបណ្ដាសាផែនដីដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា នោះពួកគេប្រឹងរកពេញមួយយប់ដោយមិនបានអ្វីពីការខិតខំធ្វើការរបស់ពួកគេសោះ។ ប៉ុន្តែនៅពេលព្រះយេស៊ូចូលទៅក្នុងព្រះរាជ្យនៃព្រះ និងមុខងាររបស់វា នោះអ្នកនេសាទដដែលនេះក៏ចាប់ត្រីបានយ៉ាងច្រើនដែលស្ទើរតែធ្វើឱ្យទូករបស់ពួកគេលិចទៀតផង!

ឈប់សិន!!! ចាំខ្ញុំគិតពីអ្វីដែលយើងទើបនឹងបានអាននេះសិន។ ភាពគ្មានបានអ្វីទាំងអស់ គ្មានត្រីមួយក្បាលទេ ភាពដាច់យ៉ៃនោះក៏ប្រាកប្រែទៅជាការប្រមូលផលដែលស្ទើតែនឹងលិចទូកពីរគ្រឿង? ប៉ុន្តែមនុស្សបានអានសាច់រឿងនេះ ហើយបានអានពីវាអស់រយៈពេលរាប់រយឆ្នាំមកហើយ តែនៅតែមើលមិនឃើញ ឬមិនគិតដល់ថាការនេះអាចកើតឡើងចំពោះពួកគេបាន។ តើហេតុអ្វីទៅ? ការឆ្លើយតបភាគច្រើននោះប្រាកដជាថា ព្រះយេស៊ូគង់នៅទីនោះ ហើយទ្រង់បានធ្វើវាឱ្យកើតឡើង។ នៅចាំសាច់រឿងដែលខ្ញុំបានបង្ហាញអ្នកនៅក្នុងគម្ពីរម៉ាកុស ជំពូក៦ ដែលព្រះយេស៊ូមិនអាចព្យាបាលមនុស្សដោយសារតែមនុស្សទាំងនោះមិនមានជំនឿទេ ដូចនេះ ព្រះរាជ្យនៃព្រះមិនមាននូវយុត្តាធិការឬ? ត្រូវតែមានអ្នកផ្ដល់នូវយុត្តាធិការស្ថានសួគ៌មុននឹងស្ថានសួគ៌អាចធ្វើបានក្នុងស្ថានភាពនេះ។

*លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ <u>ប៉ុន្តែបើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ</u>»។*

ពេត្រុសបានឯកភាពនឹងស្ថានសួគ៌ ហើយស្ថានសួគ៌ក៏បានចូលបំពេញកិច្ចការនៅក្នុងសាច់រឿងនេះ។ យើងក៏បានឃើញម្ដងទៀតថាភពផែនដីត្រូវបានផ្លាស់ប្រែដោយព្រះរាជ្យនៃព្រះ។ ស្ដាប់ទៅដូចជាវង្វេងអស់ហើយមែនទេ គឺដូចជាមនុស្សមើលឃើញបក្សីហោះហើររាប់ពាន់ឆ្នាំ ប៉ុន្តែមិនដឹងថាការហោះហើរក៏មានសម្រាប់ពួកគេ ហើយដូចនេះគេក៏មិនដែលតាមយកវា។ គ្រិស្តបរិស័ទនាពេលសព្វថ្ងៃនេះក៏ដូចគ្នាដែរ ពួកគេមិនដឹងថាខ្លួនមិនចាំបាច់នៅទ្រាំទ្រនឹងសំណាញ់តតត្រី មិនដឹងថាខ្លួនអាចមាននូវអំណាចស្ថានសួគ៌ដើម្បីជួយឱ្យពួកគេចម្រុងចម្រើននៅក្នុងជីវិតបាន។ អ្វីដែលខ្ញុំចង់ឱ្យអ្នកបានឃើញនៅត្រង់ចំណុចនេះគឺថា

មនុស្សដដែលដែលមិនទទួលបានលទ្ធផលសោះ គឺជាមនុសស្សតែមួយដែលទូកទាំងពីរពេញអស់ស្ទើរតែនឹងលិចទៀតផង!

បងប្អូនអើយ ភាពខុសគ្នាគឺស្ថិតលើព្រះរាជ្យព្រះ មិនមែនស្ថិតលើមនុស្សទេ។ អ្នកអាចគិតឃើញថាអ្នកមិនមានអនាគត ដោយការខ្វះខាត ដោយគ្មានអ្វីទៅរួចឡើយ។ ប៉ុន្តែតាមពិត អ្វីដែលអ្នកត្រូវការនោះគឺ ព្រះរាជ្យព្រះដើម្បីផ្លាស់ប្រែជីវិតរបស់អ្នកឱ្យក្លាយជាសាច់រឿងដ៏ជោគជ័យមួយ។ មែនហើយ អ្នកត្រូវតែចូលរួមធ្វើវា។ ពួកគេត្រូវតែចេញទៅនេសាទត្រីពួកគេត្រូវតែថែទាំសំណាញ់របស់ខ្លួន ហើយត្រូវរៀបចំចាប់ត្រី ប៉ុន្តែនរណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើព្រះជាម្ចាស់បង្ហាញថាត្រូវចាប់នៅឯណា។ សូមស្តាប់ ប្រព័ន្ធបណ្តាសាផែនដីនៃការប្រឹងរត់ប្រណាំង និងខិតខំទាំងលំបាកមិនអាចធ្វើបានសម្រេចទេ។ អ្នកមិនអាចរត់លឿនគ្រប់គ្រាន់ ឬរត់បានឆ្ងាយគ្រប់គ្រាន់ដើម្បីចាប់យកក្តីសុបិនរបស់អ្នកទេ។ ព្រះជាម្ចាស់មិនដែលមានចេតនាឱ្យអ្នកប្រឹងសង្កៀតធ្មេញ និងព្យាយាមអស់ពីកម្លាំងខ្លួនឯងដើម្បីធ្វើអ្វីមួយឱ្យបានសម្រេចនោះទេ។

ដោយការចូលទៅក្នុងច្បាប់ និងសេចក្តីសន្យានៃព្រះរាជ្យនៃព្រះ យើងអាចហោះហើរជំនួសឱ្យការដើរបាន។ ខ្ញុំសូមពន្យល់ក្នុងរបៀបផ្សេងគ្នាមួយទៀត។ ទោះបីជាច្បាប់ទំនាញផែនដីនៅតែមានឥទ្ធិពល ក៏យើងអាចហោះហើរដោយការចូលទៅក្នុងច្បាប់មួយទៀត នោះគឺច្បាប់នៃការលើកឡើង ព្រមទាំងរីករាយនឹងរបៀបនៃការរស់នៅថ្មី។

សូមចាំថា នៅពេលអ្នកចូលមកឯព្រះគ្រិស្ត អ្នកគឺជាសមាជិកម្នាក់នៃព្រះរាជ្យរបស់ព្រះ។ ក្នុងនាមជាពលរដ្ឋម្នាក់ អ្នកកំពុងតែសម្រេចយកសិទ្ធិស្របច្បាប់ ហើយក្នុងនាមជាកូនប្រុសស្រី អ្នកសម្រេចថាអ្នកមាននូវសិទ្ធិក្នុងការទទួលបាននូវមតិក។ សិទ្ធិស្របច្បាប់ និងអត្ថប្រយោជន៍របស់អ្នកបានកំណត់ឱ្យអ្នកបានខ្ពង់ខ្ពស់ផុតពីប្រព័ន្ធបណ្តាសាផែនដីអំពីភាពក្រីក្រ ជំងឺ និងការបរាជ័យ។

សាកស្រមៃមើលថាតើខគម្ពីរនេះស្តាប់ទៅយ៉ាងណាដែរចំពោះជនជាតិអ៊ីស្រាអែលដែលបានធ្វើជាទាសករពេញមួយជីវិត។ តាមការពិត អ្វីដែលពួកគេបានដឹងនោះមានតែការចងចាំពីភាពជាទាសករប៉ុណ្ណោះ។ ទាំងនេះជាពាក្យដែលលោកម៉ូសេបាននិយាយទៅកាន់សាសន៍អ៊ីស្រាអែល នៅពេលដែលពួកគេកំពុងធ្វើដំណើរឆ្ពោះទៅមុខដើម្បីចូលទៅឯទឹកដីសន្យា។

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

*«ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងនាំអ្នកចូលទៅក្នុងស្រុកដែលព្រះអង្គបានសន្យាជាមួយលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប ជាបុព្វបុរសរបស់អ្នកថានឹងប្រគល់ឱ្យអ្នក។ ស្រុកនោះមានក្រុងដ៏ធំៗ ហើយស្អាតៗ **<u>ជាក្រុងដែលអ្នកមិនបានសង់</u>** ព្រមទាំងមានផ្ទះពេញទៅដោយទ្រព្យសម្បត្តិគ្រប់យ៉ាង ជាទ្រព្យដែល<u>អ្នកពុំបានស្វះស្វែងរក</u> មានអណ្តូងស្រាប់ គឺអណ្តូងដែល<u>អ្នកពុំបានជីក</u> ហើយមានចម្ការទំពាំងបាយជូរ និងចម្ការអូលីវដែល<u>អ្នកពុំបានដាំ</u>។ ពេលណាអ្នកមានភោគផលបរិភោគឆ្អែតហើយ ចូរប្រយ័ត្នក្រែងលោអ្នកភ្លេចព្រះអម្ចាស់ ជាព្រះដែលបាននាំអ្នកចេញពីស្រុកអេស៊ីប ជាស្រុកដែលអ្នកធ្វើជាទាសករ។*

ទុតិយកថា ៦៖១០-១២

ក្នុងនាមជាអតីតទាសករ របៀបតែមួយដែលពួកគេបានដឹងក្នុងការសម្រេចបានអ្វីមួយនោះគឺមានតែការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាតែប៉ុណ្ណោះ។ ប៉ុន្តែដល់ចំណុចនេះព្រះជាម្ចាស់កំពុងប្រាប់ពួកគេថា ការខិតខំធ្វើការរបស់គេនឹងមិនបំពេញនូវអ្វីដែលពួកគេត្រូវការទេ។ ព្រះអង្គមិនមែនកំពុងប្រាប់ពួកគេថាពួកគេមិនចាំបាច់ធ្វើការប្រឹងប្រែងទៀតនោះទេ តែទ្រង់ប្រាប់ពួកគេថាពួកគេនឹងមិននៅជាប់នឹងប្រព័ន្ធដែលតម្រូវឱ្យខិតខំធ្វើការដើម្បីបានតែមួយរស់ទៀតហើយ។ ព្រះជាម្ចាស់មានបន្ទូលថា ពួកគេនឹងចម្រុងចម្រើននៅលើទឹកដីដែលទ្រង់កំពុងដឹកនាំពួកគេទៅ។

ខ្ញុំសូមបិទបញ្ចប់ជំពូកនេះជាមួយនឹងសាច់រឿងមួយទៀតដែលជួយបង្ហាញបន្ថែមទៀតពីអ្វីដែលខ្ញុំកំពុងនិយាយ។ ឌ្រិនដា និងខ្ញុំមិនសូវចូលចិត្តរថយន្តទេ។ មនុស្សមួយចំនួនចូលចិត្ត ហើយពួកគេអាចប្រាប់អ្នកពីរថយន្តនានាដែលពួកគេស្គាល់ស្ទើរតែទាំងអស់។ ដោយសារហេតុផលមួយចំនួន ពួកយើងមិនក៏មិនចូលចិត្តរថយន្ត។ តែពេលនេះសូមកុំគិតអាក្រក់ណា។ ពួកយើងចូលចិត្តរបស់ល្អៗ ប៉ុន្តែគ្រាន់តែពួកយើងមិនដែលនិយាយថា ពួកយើងចាំបាច់ត្រូវតែមានរថយន្តជាក់លាក់មួយទេ។ ជាធម្មតា ពួកយើងទិញរថយន្ត រួចក៏បើកបរវាអស់ប្រហែល១០ឆ្នាំប៉ុណ្ណោះ។ហើយប្រាកដណាស់ថា ពួកយើងក៏យកចិត្តទុកដាក់មើលថែរថយន្ត ហើយរថយន្តទាំងនោះក៏មិនដែលមើលទៅចាស់ទេ ប៉ុន្តែឱ្យតែវាមើលទៅល្អ និងអាចដំណើរការបានល្អ នោះពួកយើងសប្បាយចិត្តពេកហើយ។

**អ្វីដែលអ្នកត្រូវការនោះគឺ ព្រះរាជ្យដើម្បីផ្លាស់ប្រែជីវិតរបស់អ្នកឱ្យចូលទៅក្នុងសាច់រឿងជោគជ័យមួយ។ មែនហើយ គឺអ្នកត្រូវធ្វើអ្វីដែលជាចំណែកដែលអ្នកត្រូវធ្វើ។**

ប៉ុន្តែកាលពីប៉ុន្មានឆ្នាំមុន ក្រុមជំនុំយើងក៏បានជួលរថយន្តម៉ាកអេស្កាឡៃតប៉ុន្មានគ្រឿងសម្រាប់កម្មវិធីសន្និបាតដែលពួកយើងរៀបចំ។ ពួកយើងជួយរថយន្តទាំងនោះដើម្បីដឹកភ្ញៀវរបស់ពួកយើង ហើយពួកយើងក៏ចង់យករថយន្តល្អមួយមកបម្រើសេវាកម្មនេះ។ ហើយនេះមិនក៏មិនមែនជាលើកទីមួយដែលពួកយើងបានរៀបចំរឿងនេះដែរ។ ពួកយើងតែងតែរៀបចំបែបនេះមក។ ប៉ុន្តែវាជាលើកទីមួយដែលយើងបានបើកបររថយន្តមួយគ្រឿងក្នុងចំណោមរថយន្តផ្សេងទៀត ក្នុងពេលដែលយើងយកវាមកសម្រាប់ជារបស់ចាំបាច់នៅក្នុងព្រឹត្តិការណ៍មួយ។ ខ្ញុំមិនប្រាកដពីមូលហេតុដែលយើងត្រូវបើកបរក្នុងអំឡុងពេលនៃព្រឹត្តិការណ៍មួយនេះទេ តែយើងក៏បានបើកវាទៅផ្ទះនៅយប់នោះ។ អ្នកដឹងទេ! ពួកយើងចូលចិត្តរថយន្តនោះណាស់។ ឌ្រិនដា និងខ្ញុំពេញចិត្តពីដំណើរការបើកបរ និងរូបរាងរបស់វាណាស់។ ដែលនៅពេលនោះពួកយើងមានរថយន្តម៉ាកហុងដាពីឡុត តែរថយន្តម៉ាកអេស្កាឡៃតនេះគឺល្អជាងម៉ាក ពីឡុតមួយកម្រិតទៅទៀត។

វាជាប្រភេទអុបសិនផ្លាទីនៀមពណ៌សបែបគុជ ហើយជាប្រភេទរថយន្តខ្នាតខ្លី។ អ្នកប្រហែលបានដឹងពីរថយន្តអេស្កាឡៃតទាំងពីរស៊េរីនេះហើយ គឺវាផលិតមកនូវខ្នាតពីរផ្សេងគ្នា មួយស៊េរីវែង និងមួយស៊េរីទៀតជាប្រភេទខ្លីជាង។ ពួកយើងចូលចិត្តប្រភេទខ្លីច្រើនជាង ដោយសារវាងាយស្រួលប្រើប្រាស់ជាង ដោយងាយស្រួលផ្លាស់ទីរហ័សជាងបន្តិច។ នៅពេលដែលខ្ញុំកំពុងបើកបររថយន្តម៉ាកអេស្កាឡៃតនេះជាមួយឌ្រិនដា នោះនាងក៏ពោលថា « បងដឹងឬអត់ អូនចូលចិត្តរថយន្តនេះ។ អូនគិតថា ពួកយើងគួរតែទិញរថយន្តម៉ាកនេះប្រើមួយគ្រឿងទៅ។» ខ្ញុំក៏យល់ស្រប។ «យើងគួរតែទិញប្រភេទស៊េរីដូចមួយនេះទៅ គឺស៊េរីខ្លីដែលមានពណ៌សបែបគុជនេះតែម្តងទៅ។» ពួកយើងទាំងពីរក៏ស្របគំនិតគ្នា។

ទោះបីជាពួកយើងមិនបានប្រាប់នរណាម្នាក់អំពីការសន្ទនារបស់ពួកយើង តែប្រហែលជាមួយខែក្រោយមក គឺនៅពេលដែលខ្ញុំកំពុងដើរចេញក្រៅដើម្បីយកឯកសារ នោះស្រាប់តែទូរសព្ទខ្ញុំក៏បានរោទិ៍ឡើង។ ចុងក្រោយ ខ្ញុំចំណាំសំឡេងក្នុងទូរសព្ទនោះបានថាជាម្នាក់ដែលបានមកចូលរួមកម្មវិធីនៅក្រុមជំនុំរបស់យើង។ គាត់បាននិយាយថា «ជម្រាបសួរលោកគ្រូ» រួចលោកក៏បានប្រាប់ថាគាត់ចង់ទិញរថយន្តម៉ាកអេស្កាឡៃតឱ្យខ្ញុំមួយគ្រឿង។ ខ្ញុំ

ហាក់តាំងបន្តិច រួចក៏ពោលថា «អស្ចារ្យម្ល៉េះទេ!» រួចលោកក៏បានសួរខ្ញុំថាតើខ្ញុំចូលចិត្តពណ៌អ្វី ហើយខ្ញុំក៏ប្រាប់ថាពួកយើងចូលចិត្តពណ៌សបៃបគុជ។ គាត់ក៏ពោលថា «ខ្ញុំនឹងទូរសព្ទមកលោកគ្រូវិញ នៅពេលខ្ញុំទិញបាន។» តែយ៉ាងណា គាត់ក៏មិនបានសួរខ្ញុំថាតើខ្ញុំចង់បានប្រភេទខ្លី ឬប្រភេទវែងឡើយ។ ពេលវេលាក៏កន្លងផុតទៅអស់មួយខែ ហើយខ្ញុំគិតថាប្រហែលជាគាត់ភ្លេចអំពីរឿងរថយន្តនោះហើយ តែគាត់ក៏បានទូរសព្ទមកខ្ញុំ រួចសុំឱ្យខ្ញុំមកជាមួយគាត់ គឺគាត់បានត្រៀមរថយន្តម៉ាកអេស្កាឡៃត្សួចរាល់សម្រាប់ខ្ញុំទៅយក។

នៅពេលពួកយើងបានជួបគាត់ យើងបានឃើញរថយន្តអេស្កាឡៃតសេរីខ្លីពណ៌សបៃបគុជនៅសម្ងៃងខ្លួនយ៉ាងស្អាតរង់ចាំពួកយើង។ មើលទៅវាស្អាតឥតទាស់តែម្ដង ដោយគ្មានស្នានឆ្កូតអ្វីទេ គឺសមឥតទាស់។ ពួកយើងប្រាប់គាត់ថាពួកយើងស្រលាញ់រថយន្តនេះណាស់។ បន្ទាប់មកគាត់ក៏បានសុំទោសដែលគាត់ចំណាយពេលយូរទម្រាំនឹងទិញបានវា តែទោះជាគាត់ខំព្យាយាមស្វែងរកប្រភេទវែង គាត់ក៏រកមិនបាន គឺបានតែប្រភេទខ្លីតែប៉ុណ្ណោះ។ ពួកយើងក៏សើច រួចនិយាយថា «តាមពិតពួកយើងចង់បានប្រភេទខ្លីនេះហើយតើស៎។» ពួកយើងក៏បានបើករថយន្តនេះមកផ្ទះ ហើយគិតថាខ្លួនជាអ្នកមានហំហានជាងគេនៅលើផែនដីនេះ ដែលបានបើករថយន្តនោះ។ ប៉ុន្តែអ្នកដឹងដែរឬទេ? រថយន្តអេស្កាឡៃតទាំងនោះមានវត្តមានជាយូរមកហើយ។ ខ្ញុំគ្រាន់តែមិនដែលគិតថានឹងប្រើប្រាស់វាតែប៉ុណ្ណោះ! ដើម្បីយល់អំពីសាច់រឿងនេះទាំងស្រុង អ្នកត្រូវដឹងថា កាលពីមុនខ្ញុំធ្លាប់ផ្ដល់រថយន្តដល់គេចំនួនប្រាំបីគ្រឿង ដូចនេះខ្ញុំបានសាបព្រោះលើថ្នាលពង្រោះទាក់ទងនឹងរថយន្ត។ ខ្ញុំគ្រាន់តែមិនដែលនិយាយថា ខ្ញុំចង់បានវាប៉ុណ្ណោះ។

សេចក្ដីបន្ថែម៖ ខ្ញុំដឹងថាអ្នកកំពុងគិតអ្វី ដោយយល់ថារឿងទាំងនេះកើតឡើងតែសម្រាប់គ្រូអធិប្បាយប៉ុណ្ណោះ។ ខ្ញុំបានចូលប្រឡូកនៅក្នុងផ្នែកហិរញ្ញវត្ថុអស់រយៈពេល៣៦ឆ្នាំ និងបានជជែកជាមួយគ្រូអធិប្បាយច្រើន។ និយាយការពិតទៅចុះ ពួកគេភាគច្រើនរស់នៅដោយរកមួយថ្ងៃបានតែមួយចម្អែតប៉ុណ្ណោះ។ ទេ រឿងទាំងនេះមិនទាន់បានកើតឡើង និងមិនកើតឡើងចំពោះពួកយើងទេ ព្រោះពួកយើងអធិប្បាយអំពីព្រះរាជ្យ ប៉ុន្តែដោយសារយើងរស់នៅក្នុងព្រះរាជ្យ និងអនុវត្តនូវច្បាប់នៃព្រះរាជ្យនៅក្នុងជីវិតរបស់យើង។ តាមការពិត ខ្ញុំបានរួចបំណុលអស់មុនពេលដែលខ្ញុំបានចាប់ផ្ដើមក្រុមជំនុំរបស់ខ្ញុំទៅទៀត។ និយាយទៅ ខ្ញុំមិនចាំបាច់ចាប់ផ្ដើមក្រុមជំនុំដើម្បីឱ្យមានការងាររកប្រាក់បានបង់ថ្លៃចំណាយទេ។ ខ្ញុំបានចាប់ផ្ដើមក្រុមជំនុំនេះដើម្បីប្រាប់មនុស្សម្នាពីអ្វីដែលគ្រិនដា និងខ្ញុំបានរកឃើញ នោះគឺដំណឹងល្អនៃព្រះរាជ្យ!

# ជំពូក ៦
# មានរឿងល្អជាច្រើនចំពោះជីវិត ជាងការបង់ថ្លៃចំណាយផ្សេងៗទៅទៀត!

នៅក្នុងព្យុះនៃជីវិតដែលខ្ញុំកំពុងប្រឈមមុខ មានពេលមួយដែលវាហាក់ដូចជាពេលវេលាដ៏ធូរស្បើយ និងល្អប្រសើរ។ ពួកយើងបានអញ្ជើញមនុស្ស៥០នាក់មកលេងផ្ទះចម្ការចាស់នោះ មកជុំគ្នានៅជុំវិញភ្នក់ភ្លើង ហូបសាច់ហត់ដក និងរួមប្រកបគ្នា។ ពេលនោះបានកើតឡើងនៅឆ្នាំមួយដែលពេញដោយភាពតានតឹងខ្លាំង និងគ្មានប្រាក់ចាយ គឺកំពុងតែខិតខំប្រឹងដើម្បីរស់បានមួយសប្ដាហ៍ទៀត។ ដោយសារខ្ញុំហត់នឿយក្នុងចិត្តជាខ្លាំង ខ្ញុំកំពុងរង់ចាំព្រឹត្តិការណ៍មួយ និងត្រូវការអ្វីមួយដែលវិជ្ជមានដើម្បីផ្ដោតអារម្មណ៍បានខ្លះ។ ពេលវេលានាពេលល្ងាចនោះគឺជាពេលដ៏ជោគជ័យធំធេងមួយ៖ អាហារក៏ឆ្ងាញ់ ហើយមិត្តភក្ដិរបស់យើងជាច្រើនក៏យកកូនតូចៗមកជាមួយ ហើយគ្រប់គ្នាក៏មានពេលវេលាដ៏សប្បាយមួយ។ ផ្ទះយើងក៏មានមនុស្សពេញ ហើយពេលនោះក៏ស្រាប់តែមានសំឡេងគោះទ្វារ។ ខ្ញុំគិតថាប្រហែលជាមានអ្នកមកជួបជុំយឺតហើយ តែពេលខ្ញុំបើកទ្វារមើល ក៏ឃើញមានបុគ្គលិកខាងក្រុមហ៊ុនអគ្គិសនីម្នាក់នៅឈរចាំ។ គាត់ក៏ពោលពាក្យយ៉ាងទន់ភ្លន់ថាគាត់មកនេះដើម្បីផ្ដាច់ចរន្តអគ្គិសនីដោយសារការមិនបង់ថ្លៃភ្លើង។ ខ្ញុំហាក់តក់ស្លុតជាខ្លាំង។ ផ្ទះខ្ញុំមានភ្ញៀវពេញផ្ទះ ហើយខ្ញុំត្រូវការបើកភ្លើង ហើយវាជាភាពគួរឱ្យអៀនខ្មាសផងដែរដែលវាកើតឡើងបែបនេះ។

ភ្លាមៗនោះខ្ញុំក៏បានសុំឱ្យបុគ្គលិកនោះចេញពីក្នុងផ្ទះមកនៅទីធ្លាខាងក្រៅផ្ទះមួយសន្ទុះ។ ខ្ញុំបានសួរថ្លៃចំណាយសម្រាប់ការសុំគាត់ពន្យារពេលទុកភ្លើងប្រើសិន ហើយគាត់ក៏បង្ហាញចំនួនតម្លៃនោះ។ «យី ថ្លៃម្ល៉េះ» ខ្ញុំក៏គិតក្នុងចិត្ត។ «តើលោកអាចចុះថ្លៃជាងនេះបន្តិច

ទៀតបានទេ?» គាត់គិតមួយសន្ទុះ ហើយទីបំផុតក៏ទម្លាក់តម្លៃបន្តិច។ «សូមលោកទុកសែកនេះរហូតដល់ថ្ងៃអង្គារចាំលោកទៅដកលុយពីសែកនេះបានទេ?» ខ្ញុំក៏សុំគាត់។ គាត់ពោលថា «មិនថ្វីទេ»រួចខ្ញុំក៏ចេញសែកមួយសន្លឹកជូនគាត់។ នៅថ្ងៃសុក្រនោះគឺមិនមានទឹកប្រាក់ក្នុងគណនីធនាគារខ្ញុំទេ ហើយខ្ញុំមិនដឹងថាមុនថ្ងៃអង្គារចូលមកដល់នឹងមានប៉ុន្មានចូលក្នុងកុងនោះទេ តែយ៉ាងហោចណាស់ក៏យើងមានភ្លើងប្រើនៅថ្ងៃចុងសប្តាហ៍នោះដែរ។ ខ្ញុំមិនចាំថា ថ្ងៃអង្គារនោះខ្ញុំបានធ្វើអ្វីខ្លះទេ ប៉ុន្តែប្រហែលជាខ្ញុំបានយកអ្វីមួយទៅដាក់បញ្ចាំហើយ។

នោះជាពេលមួយក្នុងជីវិតរបស់ពួកយើងដែលរស់នៅក្នុងភាពជាប់គាំងយ៉ាងខ្លាំងក្នុងផ្នែកហិរញ្ញវត្ថុ។ ពេលនេះ សាកស្រមៃពីការរស់នៅក្នុងរបៀបនេះសម្រាប់រយៈពេលប្រាំបួនឆ្នាំទៅមើល! ការរស់នៅក្រោមភាពតានតឹងប្រភេទនោះបញ្ឈប់រាល់ទាំងនិមិត្ត និងបិទខ្ទប់នូវរាល់ទាំងអំណារនីមួយៗជាប្រចាំថ្ងៃដែលអាចកើតមាន។ រាល់ទាំងគំនិតនីមួយ គឺមានតែផ្តោតលើការប្រឹងរស់ គិតរកកន្លែងរកលុយសម្រាប់ការចំណាយសម្រាប់ថ្ងៃបន្ទាប់ប៉ុណ្ណោះ។ តើកាលពីសប្តាហ៍មុនខ្ញុំបានចំណាយប្រាក់ច្រើនពេកមែនទេ? តើខ្ញុំគួរយកម៉ាស៊ីនគិតលេខសម្រាប់ការបូកចំណាយថ្លៃទិញគ្រឿងហូបចុកតាមខ្លួនដើម្បីឱ្យប្រាកដថាខ្ញុំមិនចំណាយលើសខ្ទង់ដែរឬទេ? ខ្ញុំតែងតែគិតពីរបៀបធ្វើអ្វីមួយឱ្យចំណាយអស់តិចបំផុតតាមតែអាចធ្វើបាន។ បងប្អូនមិត្តសម្លាញ់អើយ នោះមិនមែនជារបៀបរស់នៅទេ! ចូរក្រឡេកមើលអ្វីដែលគម្ពីរម៉ាថាយ ៦:២៥ចែង។

> *«ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នា កុំឱ្យខ្វល់ខ្វាយអំពីម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត ឬសម្លៀកបំពាក់សម្រាប់បិទបាំងកាយឡើយ។ ជីវិតមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយក៏មានតម្លៃលើសសម្លៀកបំពាក់ទៅទៀត។*

ម៉ាថាយ ៦:២៥

ព្រះយេស៊ូកំពុងមានបន្ទូលថា រឿងរ៉ាវនៃជីវិតមិនមែនជាជីវិតទេ! អ្វីគ្រប់យ៉ាងនៅក្នុងជីវិត គឺដើម្បីទ្រទ្រង់ជីវិត ដែលជាគោលបំណងរបស់យើង។ ប៉ុន្តែដោយសារអដាំបានបាត់បង់ការផ្គត់ផ្គង់នៃព្រះរាជ្យ នោះជីវិតក៏បានក្រឡាប់ចាក់ ហើយពេលនេះអ្វីគ្រប់យ៉ាងដែលទ្រទ្រង់ជីវិតមានសារៈសំខាន់ជាងជីវិតទៅទៀត។ មនុស្សមិនដឹងទាល់តែសោះថាតើជីវិតពិតជាអ្វីផង ហើយពួកគេប្រាកដជាមិនដឹងថាថាខ្លួនឯងជានរណា។ ចូរសាកសួរនរណាម្នាក់ថាពួកគេជានរណា ហើយពួកគេនឹងប្រាប់អ្នកពីអ្វីដែលពួកគេធ្វើ។ «ខ្ញុំជាគ្រូ

ពេទ្យ ខ្ញុំជាត្មាក់ងារអចលនទ្រព្យ» ។ល។ ទេ នេះមិនមែនជាអ្វីដែលបង្ហាញថាអ្នកជានរណាទេ។ វាជាអ្វីដែលអ្នកធ្វើប៉ុណ្ណោះ។ មនុស្សបានបាត់បង់សុបិននិមិត្តរបស់ខ្លួន។ អ្វីដែលខ្ញុំចង់ប្រាប់នោះគឺថា ពេលនេះមនុស្សមានសុបិននិមិត្តពីរបៀបរកប្រាក់ឱ្យបានច្រើន ប៉ុន្តែបានបាត់បង់នូវក្តីសុបិននៃគោលបំណង។ ម្យ៉ាងទៀត អ្វីៗដែលកំពុងតែត្រូវចំណាយប្រាក់ច្រើនបំផុតនោះបានក្លាយជាក្តីសុបិននិមិត្តរបស់គេ។ យ៉ាងណាក្តី ដោយសារតែបុគ្គលម្នាក់ៗត្រូវបានបង្កើតមកដោយលក្ខណៈពិសេសរៀងៗខ្លួនដោយមាននូវទេពកោសល្យ និងសមត្ថភាពផ្សេងៗគ្នា នោះពួកគេរកឃើញថាខ្លួនឯងកំពុងប្រកបរបរ ឬការងារដែលមិនមែនជាការចេញពីចិត្តស្រលាញ់របស់ខ្លួន។ ជីវិតក៏ហាក់អូសវែងអន្លាយ ដោយមានតែរង់ចាំរាប់អាទិត្យដើម្បីឱ្យបានមានសេរីភាពនៅថ្ងៃចុងសប្តាហ៍ ឬរង់ចាំយ៉ាងយូរសម្រាប់ជីវិតចូលនិវត្តន៍។

ដូចនេះ ខ្ញុំសូមសួរលោកអ្នកមួយសំណួរ។ ប្រសិនបើអ្នកមិនត្រូវការប្រាក់ទៀតទេ គឺមានប្រាក់លើសពីអ្វីដែលអ្នកត្រូវចំណាយសម្រាប់ពេញមួយជីវិតទៅទៀត តើអ្នកនឹងធ្វើអ្វី? អ្នកប្រហែលជានឹងនឹកឃើញនូវគំនិតអ្វីមួយដែលខុសផ្សេងពីអ្វីដែលអ្នកកំពុងធ្វើនៅពេលនេះណាស់។ ដូចខ្ញុំបានលើកឡើងមកហើយអីចឹង ខ្ញុំបានដឹងតាមចំនួនស្ថិតិថា យ៉ាងហោចណាស់មានប្រជាជនអាមេរិកប្រមាណ ៧០% ដែលពេលសួរពួកគេថាតើពួកគេចូលចិត្តការងាររបស់ពួកគេឬទេ នោះពួកគេឆ្លើយថាពួកគេមិនមែនកំពុងធ្វើអ្វីដែលពួកគេស្រលាញ់ទេ។ ខ្ញុំចង់ឱ្យលោកអ្នកយល់ថា ការរត់ដេញតាមទ្រព្យសម្បត្តិនេះ ដែលជារឿងសម្ពាធដែលត្រូវបំពេញ និងជាការបារម្ភតតឈប់ឈរចំពោះថ្ងៃស្អែក មិនមែនជាផែនការរបស់ព្រះជាម្ចាស់នៅគ្រាដំបូងបង្អស់ឡើយ។

> *ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គព្រះអង្គបានបង្កើតគេឱ្យមានលក្ខណៈដូចព្រះជាម្ចាស់ ព្រះអង្គបានបង្កើតគេជាបុរសជាស្ត្រី។ ព្រះជាម្ចាស់បានប្រទានពរឱ្យគេ គឺព្រះអង្គមានព្រះបន្ទូលថា៖ «ចូរបង្កើតកូនចៅឱ្យបានកើនច្រើនឡើងពាសពេញលើផែនដី ហើយត្រួតត្រាផែនដីទៅ។ ចូរមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ និងលើសត្វទាំងប៉ុន្មានដែលលូនវារនៅលើដី»។*
>
> *ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «មើល៍ យើងប្រគល់ធញ្ញជាតិទាំងប៉ុន្មានដែលមានគ្រាប់ពូជដុះនៅពាសពេញលើផែនដី និងដើមឈើដែលមានផ្លែមាន*

*គ្រាប់បន្តពូជឱ្យអ្នករាល់គ្នាធ្វើជាអាហារ យើងក៏ឱ្យស្មៅខៀវខ្ចីទាំងប៉ុន្មានដល់សត្វព្រៃទាំងអស់ ដល់បក្សាបក្សីទាំងអស់នៅលើមេឃ ដល់សត្វទាំងអស់ដែលលូនវារនៅលើដី គឺដល់សត្វទាំងប៉ុន្មានដែលមានដង្ហើមជីវិត ធ្វើជាអាហារដែរ» នោះក៏កើតមានដូច្នោះមែន។*

*ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ ដែលព្រះអង្គបានបង្កើតមក ព្រះអង្គឈ្វេងយល់ថាល្អប្រសើរបំផុតហើយ។ ពេលនោះ មានល្ងាច មានព្រឹក គឺជាថ្ងៃទីប្រាំមួយ។*

លោកុប្បត្តិ ១:២៧-៣១

មនុស្សត្រូវបានបង្កើតមកនៅថ្ងៃទី៦នៃការបង្កើតផែនដី -នេះនិយាយឱ្យជាក់លាក់ គឺនៅចុងថ្ងៃទីប្រាំមួយ។ មនុស្សត្រូវបានបង្កើតមកនៅចុងថ្ងៃទីប្រាំមួយ ដោយព្រោះគេត្រូវបានបង្កើតមកដើម្បីរស់នៅជាមួយព្រះជាម្ចាស់នៅថ្ងៃទីប្រាំពីរ ដែលជាថ្ងៃដែលយើងគ្រប់គ្នាដឹងថាជាថ្ងៃសម្រាក។

*ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី ព្រមទាំងអ្វីៗទាំងអស់នៅលើមេឃ និងផែនដី ចប់សព្វគ្រប់ហើយ។ នៅថ្ងៃទីប្រាំពីរ ព្រះជាម្ចាស់បង្ហើយកិច្ចការដែលព្រះអង្គបានធ្វើ គឺក្រោយពីបានបញ្ចប់កិច្ចការទាំងនោះមក ព្រះអង្គក៏ឈប់សម្រាកនៅថ្ងៃទីប្រាំពីរ។ ព្រះជាម្ចាស់ប្រទានពរឱ្យថ្ងៃទីប្រាំពីរ និងញែកថ្ងៃនោះឱ្យបានវិសុទ្ធ ដ្បិតថ្ងៃនោះ ព្រះអង្គបញ្ចប់កិច្ចការទាំងប៉ុន្មាន ដែលព្រះអង្គបានបង្កើត។*

លោកុប្បត្តិ ២៖១-៣

ព្រះគម្ពីរចែងថា ព្រះជាម្ចាស់សម្រាកនៅថ្ងៃទីប្រាំពីរ។ ទ្រង់មិនបានហត់នឿយទេ! ទ្រង់បានបង្ហើយរួចរាល់។ គ្រប់យ៉ាងបានចប់សព្វគ្រប់។ គ្រប់យ៉ាងដែលមនុស្សអាចមានតម្រូវការនៅលើផែនដីនេះមានស្រាប់រួចរាល់នៅលើផែនដីនៅពេលដែលមនុស្សបានមានវត្តមានឡើង។ ពិតជាមានសន្តិភាពណាស់! មនុស្សមាននូវការផ្គត់ផ្គង់ទាំងអស់ដែលគេត្រូវការ។ គឺមិនមានការព្រួយបារម្ភរឿងបង់ថ្លៃចំណាយផ្សេងៗឡើយ គ្មានការបារម្ភចំពោះការឈឺថ្កាត់ឡើយ។ គេមានកាយសម្បទាល្អឥតខ្ចោះ និងមានភរិយាល្អឯក។

រឿងតែម្យ៉ាងដែលពួកគេត្រូវផ្តោតលើនោះគឺមានតែផ្តោតលើគ្នាទៅវិញទៅមក ផ្តោតលើព្រះជាម្ចាស់ និងភារកិច្ចដែលត្រូវបានចាត់តាំង ឬគោលបំណងរបស់ពួកគេ។ អដាំត្រូវមើលការខុសត្រូវលើផែនដី។ គាត់ត្រួតត្រាលើវាទាំងស្រុងដោយសិទ្ធិអំណាច និងអំណាចនៃព្រះរាជ្យរបស់ព្រះ។ ប៉ុន្តែយើងបានដឹងរួចហើយថាតើរឿងនោះបញ្ចប់ទៅដោយរបៀបណា។ អដាំ និងអេវ៉ាបានក្បត់នឹងព្រះរាជ្យនៃព្រះ ព្រមទាំងបានបាត់បង់នូវឋានៈរបស់ខ្លួន បាត់បង់ការផ្គត់ផ្គង់ និងបាត់បង់នូវគោលបំណងរបស់ពួកគេ។ គោលបំណងរបស់ពួកគេបានក្លាយទៅជាការធ្វើយ៉ាងណាឱ្យតែបានរស់។

**ទ្រព្យសម្បត្តិទាក់ចិត្តយើងដោយប្រាប់ថាយើងអាចរត់គេចទៅកន្លែងសម្រាកបាន រត់ទៅកន្លែងដែលយើងអាចផ្តោតលើអ្វីដែលយើងចង់ធ្វើពិតប្រាកដ និងរស់នៅពេញដោយគោលបំណងមិនមែនគ្រាន់តែប្រឹងដើម្បីតែបានរស់។**

ពេលនេះ ការព្រួយបារម្ភ និងការភ័យខ្លាចបានស៊ីគំនិត និងការស៊ូទ្រាំដើម្បីរស់។ ដូចមានចែងក្នុងគម្ពីរលោកុប្បត្តិ ៣:១៧ អ៊ីចឹង គឺវាទាមទារនូវការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនា។

## អដាំបានបាត់បង់ថ្ងៃទីប្រាំពីរ!

សម្រាប់អដាំក្នុងពេលនេះគ្មានការសម្រាក ហើយគ្មានសន្តិភាពទៀតទេ។ ភាពមិនពេញលេញនៃភាពខ្មោងងឹងហ៊ុំជិតជីវិតរបស់គាត់ ហើយអដាំត្រូវខិតខំកុំឱ្យខ្លួនគាត់គ្មានអ្វីសោះ។ តាំងពីពេលនោះមក មនុស្សបានរស់នៅក្នុងលក្ខណៈបែបនេះជារៀងរហូតមក។ យ៉ាងណាមិញ មានសេចក្តីសង្ឃឹម។ នៅពេលមនុស្សបានធ្លាក់ចុះ ព្រះជាម្ចាស់បានប្រទាននូវការរំលឹកដល់គេ ជារូបភាពមួយដែលបង្ហាញថាថ្ងៃណាមួយទ្រង់នឹងស្តារការបង្កើតរបស់ទ្រង់ឡើងវិញ។ វាត្រូវបានហៅថា «សប្ប័ទ»។ ពាក្យថា *សប្ប័ទ* មានន័យយ៉ាងសាមញ្ញថា សម្រាក។ ថ្ងៃទីប្រាំពីរត្រូវបានប្រទានដល់មនុស្សទុកជាថ្ងៃសប្ប័ទ។ ដូចដែលអ្នកអាចស្រមៃឃើញស្រាប់ គឺមិនអនុញ្ញាតិឱ្យធ្វើកិច្ចការងារអ្វីនោះឡើយ គ្មានការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនាកើតឡើងនោះទេ។ ជាថ្ងៃដែលមនុស្សត្រូវឈប់ សប្បាយជាមួយក្រុមគ្រួសារ និងថ្វាយបង្គំព្រះជាម្ចាស់។ សម្រាប់ការផ្គត់ផ្គង់ផ្សេងៗសម្រាប់ថ្ងៃសប្ប័ទត្រូវបានរៀបចំទុកជាមុនស្រាច់បាច់មុនពេលថ្ងៃសប្ប័ទមកដល់។ សូម្បីតែម្ហូបអាហារ

សម្រាប់ថ្ងៃសប្ប័ទ ក៏ត្រូវតែរៀបចំមួយយប់ជាមុនដែរ។ វាជាថ្ងៃនៃការសម្រាកដែលពោរពេញដោយការផ្គត់ផ្គង់ ហើយគ្រប់អ្វីដែលអាចជាតម្រូវការត្រូវបានត្រៀមលក្ខណៈទុកមុន។ មនុស្សអាចឈប់ ហើយគិត ជាជាងដែលដែលខិតខំប្រឹងប្រែងឱ្យតែបានរស់រាន។

ថ្ងៃសប្ប័ទនោះគឺមានតែមួយថ្ងៃ។ ប៉ុន្តែមនុស្សបាននឹងកំពុងតែយល់សុបិនថា ជាជីវិតនៃសេចក្ដីសម្រាកអស់មួយជីវិត។ មនុស្សស្វែងរកទ្រព្យសម្បត្តិជាសញ្ញាមួយនៃបំណងចិត្តរបស់គេ ដែលចង់មានសេរីភាពចេញពីការធ្វើការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនា ដែលចងគេជាប់ពេញមួយជីវិត។ ទ្រព្យសម្បត្តិទាក់ទាញយើងដោយការអាចរត់គេចចេញទៅកន្លែងដែលត្រូវសម្រាក ជាកន្លែងដែលយើងអាចផ្ដោតលើអ្វីដែលយើងចង់ធ្វើឱ្យពិតប្រាកដ រស់នៅដោយពេញដោយគោលបំណងជាជាងការបានតែប្រឹងដើម្បីរស់។

សព្វថ្ងៃនេះ ថ្ងៃសប្ប័ទដែលជាថ្ងៃទីប្រាំពីរ មិនថាអ្នករៀបចំប្រារព្ធ នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យទេ វាមិនមានការផ្ដល់តម្លៃខ្ពង់ខ្ពស់នៅក្នុងវប្បធម៌យើងឡើយ។ ហ្នឹងហើយ មនុស្សភាគច្រើនដែលចូលរួមក្រុមជំនុំ ទៅក្រុមជំនុំនៅព្រឹកថ្ងៃអាទិត្យ។ យ៉ាងណាមិញ មើលទៅកាន់វប្បធម៌ជាលក្ខណៈទាំងមូល អ្នកមុខជាមើលទៅមិនឃើញមានអ្វីខុសប្លែកពីថ្ងៃធ្វើការធម្មតានោះទេ។ កាលពីខ្ញុំនៅក្មេង អ្វីៗទាំងអស់បិទនៅថ្ងៃអាទិត្យ។ អ្នកមិនអាចទៅផ្សារទិញឥវ៉ាន់នៅថ្ងៃអាទិត្យ មិនទាំងអាចទិញហ្គាសនៅអាទិត្យ។ ឪពុករបស់ខ្ញុំត្រូវប្រាកដថាបានទិញហ្គាស និងអ្វីៗដែលយើងត្រូវការសម្រាប់ថ្ងៃអាទិត្យទាំងអស់នៅយប់ថ្ងៃសៅរ៍។ បើអ្នកស្គាល់ខ្ញុំកាន់តែច្រើន អ្នកនឹងដឹងថាខ្ញុំចូលចិត្តបរបាញ់ ប៉ុន្តែទោះបីជាខ្ញុំជាអ្នកប្រមាញ់ក្ដីក៏ខ្ញុំមិនអាចចេញទៅប្រមាញ់នៅថ្ងៃអាទិត្យផងដែរ។ វាជារឿងខុសច្បាប់ក្នុងការបរបាញ់នៅថ្ងៃអាទិត្យ។ មនុស្សធ្លាប់តែពាក់សម្លៀកបំពាក់ល្អបំផុតរបស់គេដើម្បីអាហារពេលល្ងាច ហើយមានការជួបជុំក្រុមគ្រួសារធំនៅយប់ថ្ងៃអាទិត្យ។ ប៉ុន្តែជាការពិតណាស់អ្វីៗទាំងអស់នេះបានផ្លាស់ប្ដូរអស់ទៅហើយសព្វថ្ងៃនេះ។ តែរូបភាពដ៏ពិតនៃថ្ងៃសប្ប័ទមិនទាន់ផ្លាស់ប្ដូរនៅឡើយ។

ប៉ុន្តែមិនថាបានរៀបចំល្អប្រសើរយ៉ាងណាសម្រាប់ថ្ងៃសប្ប័ទនោះទេ មិនថាមានពេលវេលាបរិភោគអាហារជុំគ្រួសារយ៉ាងអស្ចារ្យយ៉ាងណាក្ដី ក៏ថ្ងៃច័ន្ទនឹងមកដល់។ ឃ្លាដែលថា «ថ្ងៃច័ន្ទពណ៌ខៀវ» ជាវេវចនៈនៃពាក្យ ភ័យខ្លាចខ្លាំង បើតាមអ្វីដែលខ្ញុំចាំបាន។ « ខ្ញុំត្រូវទៅធ្វើការ ហើយត្រឡប់មកឡើងជ្រុញចាស់របស់ខ្ញុំវិញហើយ» ជាឃ្លាដែលគេ

ពិពណ៌នាពីព្រឹកថ្ងៃច័ន្ទ។ ហើយបើអ្នកឈប់ ហើយគិតពីវាបន្តិចនោះ ស្តាប់មើលទៅហាក់បីដូចជាទាសករអីចឹង។ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ណាស់ ថ្ងៃនេះជាថ្ងៃសុក្រ! ថ្ងៃនេះ ជាថ្ងៃចុងសប្តាហ៍ ហើយថ្ងៃសប្ប័ទផ្តល់ដល់មនុស្សជាច្រើននូវការសម្រាកខ្លីមួយ។ ប៉ុន្តែដូចជាទើបតែរស់នៅបានខ្លីណាស់ ហើយថ្ងៃកកស្ទះចរាចណ៍នៅព្រឹកថ្ងៃច័ន្ទក៏នឹងចូលមកដល់ដែរ។

ប៉ុន្តែចុះនឹងមានអ្វីកើតឡើង ប្រសិនបើមានផ្លូវចូលទៅកាន់ការរស់នៅក្នុងជីវិតនៃថ្ងៃសប្ប័ទជារៀងរហូត។ តើវានឹងល្អអស្ចារ្យយ៉ាងណាទៅ ប្រសិនបើមានផ្លូវរស់នៅក្នុងជីវិតដែលមានសេរីភាព រួចពីភាពភ័យខ្លាច ពេញពោរដោយការផ្គត់ផ្គង់ ហើយរស់នៅក្នុងទីកន្លែងមួយដែលសម្រាក! ឌ្រិនដា និងខ្ញុំរស់នៅក្នុងជីវិតដែលរងទុក្ខសោក ភ័យខ្លាច មានជំងឺ និងអសុវត្ថិភាពអស់រយៈពេល ៩ឆ្នាំដ៏សែនយូរ រហូតដល់យើងបានរកឃើញការសម្រាកថ្ងៃសប្ប័ទ តាមពិតទៅជាជម្រើសនៅក្នុងជីវិតយើង។ ខ្ញុំនិយាយមែនណា!

> *ដូច្នេះ ព្រះជាម្ចាស់បានតម្រូវទុកឱ្យមានថ្ងៃសម្រាកមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរដែរ ដ្បិតអ្នកណាចូលទៅសម្រាកជាមួយព្រះជាម្ចាស់ អ្នកនោះបានបង្ហើយកិច្ចការរបស់ខ្លួន ដូចព្រះជាម្ចាស់បង្ហើយកិច្ចការរបស់ព្រះអង្គដែរ។ ហេតុនេះ យើងត្រូវតែខ្នះខ្នែងចូលទៅរកសម្រាកជាមួយព្រះអង្គនោះវិញ កុំឱ្យមាននរណាម្នាក់ធ្លាក់ខ្លួនទៅយកតម្រាប់តាមពួកអ្នកដែលមិនស្តាប់បង្គាប់នោះឡើយ។*
>
> *ហេប្រឺ ៤:៩-១១*

មិត្តសម្លាញ់អើយ នេះជាសម្ពន្ធមេត្រីថ្មី។ សព្វថ្ងៃនេះមានថ្ងៃ

សប្ប័ទជាការសម្រាកសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ បទគម្ពីរបញ្ជាក់ប្រាប់ច្បាស់ថា យើងអាចចូលក្នុងការសម្រាករបស់ព្រះជាម្ចាស់ ហើយសម្រាកពីកិច្ចការងាររបស់យើង។ សូមចងចាំនូវអ្វីដែលយើងទើបតែបានសិក្សា៖ ការឈប់សម្រាករបស់ព្រះជាម្ចាស់ ជាអ្វីៗដែលមានទាំងស្រុង ពេញលេញ និងមានការផ្គត់ផ្គង់ត្រៀមជាស្រេច។ មាននូវសេរីភាពចេញពីសតិអារម្មណ៍នៃការដែលគ្រាន់តែដើម្បីឱ្យគ្រាន់តែបានរស់ និងមាន បាសេរី

ភាពពីជីវិតដែលជាប់ឃុំឃាំងដោយភាពក្រីក្រ និងសេរីភាពពីការឈឺចុកចាប់ និងជំងឺ។ មានជម្រើសថ្មី! ថ្ងៃសប្ប័ទមិនមែនគ្រាន់តែជាព័ត៌មាននៅគម្ពីរសញ្ញាចាស់ប៉ុណ្ណោះទេ វាក៏មានសម្រាប់យើងសព្វថ្ងៃនេះដែរ។ ប៉ុន្តែមុនពេលដែលអ្នកគិតថាខ្ញុំកំពុងនិយាយអំពីការរស់នៅក្រោមច្បាប់និងការធ្វើពិធីសាសនាតាមគម្ពីរសម្ពន្ធមេត្រីចាស់ ជាថ្មីម្តងទៀតខ្ញុំមិនដូច្នោះទេ។ ផ្ទុយទៅវិញខ្ញុំចង់ពិនិត្យមើលការឈប់សម្រាកនៅថ្ងៃឈប់សម្រាកនេះដែលគម្ពីរហេប្រឺនិយាយអំពី។ ព្រោះដូចដែលឌ្រីនដា និងខ្ញុំបានរកឃើញហើយថា នេះគឺជាកូនសោសំខាន់ណាស់សម្រាប់ព្រះរាជ្យនៃព្រះជាម្ចាស់ដែលកំពុងបំពេញមុខងារ និងជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់សម្រាប់ជីវិតរបស់យើង។

**តើនឹងល្អប្រពៃយ៉ាងទៅ ប្រសិនបើមានផ្លូវដែលឱ្យយើងរស់នៅក្នុងជីវិតមានសេរីភាពពីភាពភ័យខ្លាច ពេញដោយការផ្គត់ផ្គង់ ពោពេញដោយគោលបំណង ហើយរស់នៅក្នុងកន្លែងនៃការសម្រាក។**

## រឿងដ៏កាន់តែគួរឱ្យភ្ញាក់ផ្អើល៖ គឺថ្ងៃសប្ប័ទមិនមែនជាថ្ងៃតែមួយទៀតនោះទេ!

ខ្ញុំសង្ឃឹមថាប្រយោគនេះធ្វើឱ្យអ្នកចាប់អារម្មណ៍។ មានការពិភាក្សាគ្នាជាច្រើននៅក្នុងរូបកាយរបស់ព្រះគ្រិស្តអំពីរបៀបនៃការឈប់សម្រាកថ្ងៃសប្ប័ទ៖ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬចាប់ពីពេលល្ងាចថ្ងៃលិចនៃថ្ងៃសុក្ររហូតដល់ពេលល្ងាចថ្ងៃលិចនាថ្ងៃសៅរ៍។ និកាយទាំងអស់បានបង្កើតថ្ងៃសប្ប័ទឡើងទៅតាមការបកស្រាយរបស់ពួកគេអំ ពីថ្ងៃសប្ប័ទ។ មុនពេលដែលអ្នកបោះសៀវភៅនេះចោលទៅកន្លៀតបន្ទប់ ដោយគិតថាខ្ញុំជាមនុស្សពួកឆ្កួតគួរឱ្យខ្ពើមរអើម សូមនៅជាមួយខ្ញុំមួយភ្លែត ហើយសូមមើលទៅកាន់ គម្ពីរកូឡូស ២:១៦-១៧។

> *ហេតុនេះ មិនត្រូវឱ្យនរណាម្នាក់ថ្កោលទោសបងប្អូនអំពីរឿងចំណីអាហារភេសជ្ជៈ ឬអំពីរឿងបុណ្យទាន បុណ្យចូលខែ និងថ្ងៃសប្ប័ទនោះឡើយ។ ការទាំងអស់នេះគ្រាន់តែជាស្រមោលនៃអ្វីៗដែលនឹងកើតមាននៅអនាគតកាលប៉ុណ្ណោះ រីឯអ្វីៗដែលពិតវិញ គឺព្រះគ្រិស្ត។*
>
> កូឡូស ២:១៦-១៧

ចូរយកចិត្តទុកដាក់លើអ្វីដែលលោកប៉ូលនិយាយនៅត្រង់នេះ ថ្ងៃសប្ប័ទជាស្រមោលនៃអ្វីៗដែលនឹងមកដល់។ យ៉ាងណាមិញ អ្វីៗដែលពិតនឹងនឹងមកដល់នៅពេលព្រះគ្រិស្តយាងមកដល់។ ថ្ងៃសប្ប័ទគឺជាស្រមោល មិនមែនជាអ្វីមួយដែលពិតជាក់ស្តែងនោះទេ។ បើមានព្រះគ្រិស្តពិតប្រាកដមែន នោះថ្ងៃសប្ប័ទជាស្រមោលនៃលក្ខណៈរបស់ទ្រង់ និងអ្វីដែលព្រះអង្គបានធ្វើ។ ខ្ញុំសូមនិយាយបែបនេះវិញៈ គ្មានអំណាចអ្វីនៅថ្ងៃសប្ប័ទដើម្បីនឹងដកចេញ ឬផ្លាស់ប្តូរប្រព័ន្ធផែនដីពីការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនាដែលលោកអដាំបានពាំនាំមកលើផែនដីនេះទេ។ ប្រសិនបើអ្នកជាអ្នកគោរពខាងសាសនា សាសនានោះផ្ទាល់ក៏គ្មានអំណាចអ្វីក្នុងការរំដោះអ្នកឱ្យមានសេរីភាពនោះដែរ។ តែវាគ្រាន់តែជារូបភាព ជាស្រមោលនៃអ្វីដែលអ្នកនឹងរកឃើញនៅក្នុងព្រះគ្រិស្ត។

កាលពីខ្ញុំរៀននៅថ្នាក់ទី១ គ្រូរបស់ខ្ញុំឱ្យយើងទាំងអស់គ្នាគូសគំនូរស្រមោលក្បាលរបស់យើងពីចំហៀង។ គេយកម៉ាស៊ីនបញ្ចាំងកុន ហើយឱ្យយើងអង្គុយនៅពីមុខវា ហើយវាជះស្រមោលក្បាលរបស់យើងទៅលើក្រដាសស។ បន្ទាប់មកគេគូសពគ្រាងរូបស្រមោលក្បាលរបស់យើង ហើយបន្ទាប់មក ក៏បង្កើតបានជាគំនូរស្រមោល ដែលយើងកាត់ចេញមក ហើយបានយកវាទៅផ្ទះជូនអ្នកម្តាយរបស់យើងសម្រាប់ទិវាអ្នកម្តាយ។ ស្រមោលបានចាប់យកទ្រង់ទ្រាយដែលដូចនឹងខ្ញុំខ្លះៗ ប៉ុន្តែមិនបានចាប់យកបាននូវ ភាពលម្អិត ចរិតលក្ខណៈ និងបុគ្គលិកលក្ខណៈរបស់ខ្ញុំនោះឡើយ។ ប៉ុន្តែវាផ្តល់ឱ្យនូវព័ត៌មានខ្លះៗអំពីខ្ញុំ។

ថ្ងៃសប្ប័ទក៏ដូចគ្នាដែរ ស្រមោលរបស់វានិយាយថា កុំឱ្យធ្វើការ មិនចាំបាច់មានការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនាទេ។ យ៉ាងណាមិញ វាគ្រាន់តែជាស្រមោល មិនមែនជារឿងពិតជាក់ស្តែងទេ។ ជាការពិតណាស់ វាចង្អុលបង្ហាញទៅកាន់ព្រះយេស៊ូគ្រិស្ត ដែលទ្រង់មានអំណាចប្រោសយើងឱ្យរួចពីបណ្តាសានៃក្រឹត្យវិន័យ និងប្រព័ន្ធបណ្តាសានៃផែនដីនេះ ហើយកសាងយើងឱ្យក្លាយជាបុត្រា បុត្រីរបស់របស់ព្រះជាម្ចាស់សាជាថ្មី និងជាប្រជារាស្ត្រនៃព្រះរាជ្យរបស់ព្រះជាម្ចាស់! ជាថ្មីម្តងទៀត វាគឺជារូបភាពនៃអ្វីដែលព្រះយេស៊ូនឹងនាំមកដល់យើងនៅពេលដែលព្រះអង្គយាងត្រឡប់មកវិញនៅថ្ងៃណាមួយ។ វាជាកិច្ចដែលបានបញ្ចប់ ដែលគ្រប់ៗអ្វីៗដែលយើងត្រូវការនៅក្នុងជីវិតត្រូវបានស្តារឡើងវិញដល់យើង។ យ៉ាងណាមិញ ដូចដែលគម្ពីរហេប្រឺថែងថា យើងចូលមកកាន់ទីសម្រាកនេះតាមរយៈជំនឿ។ ចូរចងចាំថាជំនឿទាមទារធ្វើឱ្យវាបានត្រឹមត្រូវស្របតាមច្បាប់នៃស្ថានសួគ៌

ដើម្បីឱ្យវាមានយុត្តាធិការនៅលើផែនដីនេះ។ នៅលើឈើឆ្កាង ព្រះយេស៊ូបានស្រែកឡើងថា «វាបានបញ្ចប់សព្វគ្រប់ហើយ!» ដូចដែលព្រះជាម្ចាស់មានបន្ទូលនៅថ្ងៃទីប្រាំមួយថា វាបានបញ្ចប់សព្វគ្រប់ហើយ។

ថ្ងៃសប្ប័ទសម្រាប់មនុស្សភាគច្រើននាពេលបច្ចុប្បន្ននេះ គឺជាថ្ងៃនៃសាសនា។ មនុស្សមើលទៅកាន់ថ្ងៃសប្ប័ទថា ជាថ្ងៃរបស់ព្រះជាម្ចាស់ ជាថ្ងៃមួយដែលយើងជំពាក់ព្រះជាម្ចាស់ក្នុងការទៅក្រុមជំនុំ ធ្វើកិច្ចការសម្រាប់ព្រះជាម្ចាស់ និងធ្វើកិច្ចការងារសាសនាផ្សេងៗទៀត។ ព្រះយេស៊ូបានកែតម្រូវសារីកដែលមានផ្នត់គំនិតបែបនេះ។

> *ថ្ងៃសប្ប័ទត្រូវបានបង្កើតឡើងសម្រាប់មនុស្ស មិនមែនបង្កើតមនុស្សមកសម្រាប់ថ្ងៃសប្ប័ទទេ។*
>
> *ម៉ាកុស ២:២៧*

ថ្ងៃសប្ប័ទត្រូវបានធ្វើឡើងសម្រាប់មនុស្ស មិនមែនបង្កើតមកមនុស្សសម្រាប់ថ្ងៃសប្ប័ទនោះទេ។ តើអ្នកដឹងទេថា មានមនុស្សជាច្រើនមានអារម្មណ៍ថាមានកំហុសប្រសិនបើពួកគេមិនបានទៅក្រុមជំនុំ? ហេតុអ្វីបានជាពួកគេមានអារម្មណ៍ថាខ្លួនមានកំហុសចំពោះក្រុមជំនុំ ដែលតាមពិតទៅពួកគេជាក្រុមជំនុំ? ខ្ញុំមិននិយាយថាយើងមិនគួរជួបជុំគ្នាក្នុងការថ្វាយបង្គំនោះទេ ប៉ុន្តែផ្នត់គំនិតនេះបានបង្ហាញថា ពួកគេមានទស្សនៈខុសឆ្គងអំពីថ្ងៃសប្ប័ទ។

ខ្ញុំដឹងថាអ្នកអាចនឹងនៅតែច្រឡំ ដូច្នេះខ្ញុំសូមពន្យល់កាន់តែស៊ីជម្រៅដោយមើលការអត្ថាធិប្បាយដែលព្រះយេស៊ូមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ជំពូក ១១ ។

> *កាលព្រះយេស៊ូយាងទៅដល់ ព្រះអង្គក៏ជ្រាបថា គេបានដាក់សពលោកឡាសារក្នុងផ្នូរបួនថ្ងៃហើយ។ ភូមិបេតថានីមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីក្រុងយេរូសាឡឹម។ មានជនជាតិយូដាជាច្រើននាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថា និងនាងម៉ារីក្នុងពេលប្អូនស្លាប់។*
>
> *កាលនាងម៉ាថាបានដឹងថាព្រះយេស៊ូយាងមកដល់ នាងក៏ចេញទៅទទួលព្រះអង្គ រីឯនាងម៉ារីវិញ នាងអង្គុយនៅក្នុងផ្ទះ។ នាងម៉ាថាទូលព្រះយេស៊ូថា ៖ «លោកម្ចាស់ ប្រសិនបើលោកបាននៅទីនេះ ប្អូននាងខ្ញុំមិនស្លាប់ទេ។ ប៉ុន្តែ ឥឡូវ*

*នេះ នាងខ្ញុំដឹងថា បើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ក៏ព្រះអង្គមុខជាប្រទានឱ្យមិនខាន»។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ប្អូននាងនឹងរស់ឡើងវិញ»។*

*នាងទូលទៅព្រះអង្គវិញថា៖ «នាងខ្ញុំដឹងហើយ នៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹងរស់ឡើងវិញ ប្អូននាងខ្ញុំក៏នឹងរស់ឡើងវិញដែរ»។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សឱ្យរស់ឡើងវិញ ខ្ញុំនឹងផ្តល់ឱ្យគេមានជីវិត ។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្តីនេះឬទេ?»។*

*នាងម៉ាថាទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! ខ្ញុំម្ចាស់ជឿថា ព្រះអង្គពិតជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!»។*

យ៉ូហាន ១១:១៧-២៧

ព្រះយេស៊ូមានបន្ទូលថា ទ្រង់គឺជាការរស់ឡើងវិញ។ វាមិនមែនគ្រាន់តែជាថ្ងៃមួយនោះទេ។ ថ្ងៃសប្ប័ទ គឺជាស្រមោលនៃអ្វីដែលព្រះយេស៊ូបានធ្វើនៅលើឈើឆ្កាងសម្រាប់យើង។ ព្រះយេស៊ូជាថ្ងៃសប្ប័ទពិតប្រាកដ ហើយនៅក្នុងទ្រង់យើងអាចចូលទៅកាន់ព្រះរាជាណាចក្ររបស់ព្រះជាម្ចាស់ និងអ្វីៗទាំងអស់ដែលមាន។ ដូច្នេះយើងអាចសម្រាកបាន!

ដូចនេះ ចូរយើងងាកទៅមើលបទគម្ពីរក្នុងសម្ពន្ធមេត្រីថ្មីដែលមានចែងក្នុងគម្ពីរហេប្រឺវិញ។

*ដូច្នេះ ព្រះជាម្ចាស់បានតម្រូវទុកឱ្យមានថ្ងៃសម្រាកមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរដែរ ដ្បិតអ្នកណាចូលទៅសម្រាកជាមួយព្រះជាម្ចាស់ អ្នកនោះបានបង្អើយកិច្ចការរបស់ខ្លួន ដូចព្រះជាម្ចាស់បង្អើយកិច្ចការរបស់ព្រះអង្គដែរ។ ហេតុនេះ យើងត្រូវតែខ្នះខ្នែងចូលទៅរកសម្រាកជាមួយព្រះអង្គនោះវិញ កុំឱ្យមាននរណាម្នាក់ធ្លាក់ខ្លួនទៅយកតម្រាប់តាមពួកអ្នកដែលមិនស្តាប់បង្គាប់នោះឡើយ។*

ហេប្រឺ ៤:៩-១១

ស្រមោលនៃថ្ងៃសប្ប័ទបង្ហាញថា អ្នកត្រូវបានហាមឃាត់មិនឱ្យធ្វើការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនា សម្រាប់អ្វីដែលអ្នកត្រូវការនៅលើថ្ងៃសប្ប័ទនោះទេ ប៉ុន្តែវាផ្តល់ឱ្យយើងមើលឃើញអ្វីមួយដែលព្រះយេស៊ូបានធ្វើសម្រាប់យើង ដែលត្រូវបានដោះលែងយើងពីប្រព័ន្ធនៃបណ្តាសាផែនដីនេះ ឱ្យត្រូវតែធ្វើការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនាដើម្បីរស់។ អាចនិយាយម្យ៉ាងទៀតថា អ្វីដែលជារូបភាពនេះ បានក្លាយជាការពិតនៅក្នុងព្រះគ្រិស្ត។ តាមពិត សារដំបូងដែលព្រះយេស៊ូបានប្រកាស គឺសំដៅទៅលើថ្ងៃសប្ប័ទ។ នៅក្នុងគម្ពីរអេសាយ ៦១ យើងរកឃើញពាក្យនៃសេចក្តីអធិប្បាយដំបូងបំផុតរបស់ព្រះអង្គ ដែលទ្រង់បានអធិប្បាយនៅក្នុងគម្ពីរលូកា ជំពូក៤ ។

*ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់សណ្ឋិតលើខ្ញុំ ដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់។*

*អេសាយ ៦១:១ (គខប)*

ការនិយាយថា មានផ្លូវចេញពីភាពក្រីក្រ ទ្រង់កំពុងតែមានបន្ទូលថា មានផ្លូវចេញពីប្រព័ន្ធបណ្តាសានៅលើផែនដីនៃការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនា។ វាគឺជាទាសភាពស្វែងរកការផ្គត់ផ្គង់ ដែលទាក់ទាមមនុស្សជាប់ជាអ្នកទោស ហើយមិនអាចសម្រាកបាន។ ប៉ុន្តែថ្ងៃសប្ប័ទ គឺមិនមែនគ្រាន់តែជារូបភាពតែមួយគត់ ដែលព្រះជាម្ចាស់បានប្រទានឱ្យប្រជារាស្ត្ររបស់ទ្រង់នូវអ្វីនឹងត្រូវបានស្តារឡើងវិញនៅថ្ងៃណាមួយនោះទេ។ វាក៏មានឆ្នាំសប្ប័ទផងដែរ!

*«ប្រាំពីរឆ្នាំម្តង អ្នកត្រូវតែលុបបំណុល។ ការលុបបំណុលនេះត្រូវអនុវត្តដូចតទៅៈ ម្ចាស់បំណុលទាំងឡាយដែលបានឱ្យប្រាក់អ្នកដទៃខ្ចី ត្រូវលុបបំណុលនោះ។ កាលណាគេប្រកាសការលុបបំណុល ដើម្បីលើកតម្កើងព្រះអម្ចាស់ ម្ចាស់បំណុលមិនត្រូវទាមទារឱ្យអ្នកដទៃ ដែលជាបងប្អូនរួមជាតិរបស់ខ្លួន សងប្រាក់វិញឡើយ។ អ្នកអាចទាមទារឱ្យជនបរទេសសងប្រាក់ តែត្រូវលុបបំណុលឱ្យបងប្អូន ដែលជាជនរួមជាតិរបស់អ្នក។*

*ក្នុងចំណោមអ្នករាល់គ្នា មិនត្រូវឱ្យមានជនក្រីក្រឡើយ ដ្បិតព្រះអម្ចាស់នឹងប្រទានពរអ្នកយ៉ាងបរិបូណ៌ នៅក្នុងស្រុកដែលព្រះអម្ចាស់ ជាព្រះរបស់អ្នកប្រគល់ឱ្យអ្នកកាន់កាប់ទុកជាចំណែកមត៌ក។ ប៉ុន្តែ អ្នកត្រូវស្តាប់បង្គាប់ព្រះអម្ចាស់*

*ជាព្រះរបស់អ្នក ដោយកាន់ និងប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មាន ដែលខ្ញុំប្រគល់ឱ្យនៅថ្ងៃនេះ។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានពរដល់អ្នក ដូចព្រះអង្គបានសន្យាជាមួយអ្នក។ អ្នកអាចចងការប្រាក់ឱ្យប្រជាជាតិជាច្រើន តែអ្នកមិនត្រូវខ្ចីប្រាក់ពីពួកគេទេ អ្នកនឹងត្រួតត្រាលើប្រជាជាតិជាច្រើន តែពួកគេនឹងមិនត្រួតត្រាលើអ្នកឡើយ។*

ចោទិយកថា ១៥:១-៦

សូមកត់សម្គាល់ថា ពួកគេត្រូវលុបចោលបំណុលទាំងអស់រៀងរាល់ប្រាំពីរឆ្នាំម្ដង។ ជាថ្មីម្ដងទៀត យើងឃើញព្រះជាម្ចាស់កំពុងប្រើលេខ ៧ ដើម្បីបង្ហាញថាអ្វីៗទាំងអស់ពេញលេញ។ មិនមានការខ្វះខាតទេ។ ទ្រង់បានផ្តល់អ្វីៗគ្រប់យ៉ាងដែលចាំបាច់សម្រាប់មនុស្ស។ ប៉ុន្តែ ប្រសិនបើមានអ្នកខ្លះសួរសណ្ដួរអំពីប្រាជ្ញារបស់ទ្រង់ក្នុងការប្រាប់ពួកគេឱ្យលើកលែងបំណុលនោះ ទ្រង់បានបន្ថែមថា «**ទោះយ៉ាងណា មិនត្រូវមានអ្នកក្រីក្រនៅក្នុងទឹកដីដែលព្រះអម្ចាស់ជាព្រះរបស់អ្នកប្រទានឱ្យអ្នកទុកជាកេរមតិករបស់អ្នកឡើយ ព្រះអង្គនឹងប្រទានពរអ្នកយ៉ាងបរិបូណ៌។**» ទ្រង់បានបន្តទៀតថា ពួកគេត្រូវតែមានព្រះពរ ដើម្បីពួកគេនឹងក្លាយជាអ្នកឱ្យគេខ្ចី ហើយមិនមែនជាអ្នកខ្ចីប្រាក់គេនោះទេ។ ជាថ្មីម្ដងទៀតយើងឃើញនៅទីនេះថា ប្រព័ន្ធបណ្ដាសានៃការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនា ត្រូវបានទុកជាមោឃៈ ដោយច្បាប់ថ្មីនៃជីវិតដែលបានជួយយើងឱ្យរួចផុតពីបណ្ដាសាក្រឹត្យវិន័យនៃអំពើបាប និងសេចក្ដីស្លាប់។

នៅថ្ងៃសប្ប័ទ ពួកគេមិនធ្វើការប្រឹងប្រែងកាប់គាស់ចិញ្ចឹមជីវិតយ៉ាងវេទនាសម្រាប់ពេញមួយឆ្នាំឡើយ ដូច្នេះពួកគេមិនត្រូវបានអនុញ្ញាតឱ្យសាបព្រោះដំណាំរបស់ពួកគេទេ។ ប៉ុន្តែបន្ទាប់មកអ្វីៗបានចាប់ផ្ដើមតានតឹងបន្តិច។ ពួកគេមិនត្រឹមតែត្រូវលើកលែងបំណុលដល់ដែលអ្នកដែលជំពាក់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏មិនត្រូវបានអនុញ្ញាតិឱ្យសាបព្រោះដំណាំរបស់ពួកគេដែរ។ នៅពេលនេះ អ្នកខ្លះអាចនិយាយថា «នែ៎! ខ្ញុំអាចរស់បានមួយថ្ងៃជាមួយនឹងអ្វីដែលមាននៅក្នុងទូរទឹកកក ប៉ុន្តែការរស់នៅពេញមួយឆ្នាំដោយមិនធ្វើការ គឺពិបាកជាងនេះណាស់។»

ដូច្នេះ នៅត្រង់នេះ ស្រមោលនៃថ្ងៃសប្ប័ទបានប្រាប់យើងឱ្យលើកលែងដល់អ្នកជំពាក់បំណុលរបស់យើង។ ព្រះអង្គបានប្រាប់ពួកគេថា ពួកគេនឹងមិនចាំបាច់ប្រើបំណុលទេពីព្រោះពួកគេនឹងមានច្រើន ដូច្នេះពួកគេនឹងក្លាយជាអ្នកឱ្យខ្ចីហើយមិនមែនជាអ្នកខ្ចីគេ

នោះទេ។ បំណុលគឺជាប្រព័ន្ធមួយដែលផ្អែកលើភាពមិនគ្រប់គ្រាន់ ប៉ុន្តែព្រះជាម្ចាស់នឹងផ្គត់ផ្គង់ឱ្យពួកគេទាំងស្រុង ដូច្នេះលែងត្រូវការបំណុលទៀតហើយ។ ស្រមោលនិយាយថា «អ្នកមិនត្រូវដាំដំណាំរបស់អ្នកទេ» ដោយសំដៅទៅលើរបៀបថ្មីនៃការរស់នៅក្រៅប្រព័ន្ធបណ្ដាសានៅលើផែនដី។ ឥឡូវនេះ ទាំងអស់នេះត្រូវបានរកឃើញនៅក្នុងព្រះយេស៊ូគ្រិស្ត។

ប៉ុន្តែសូមចងចាំថា នៅមានអ្វីៗជាច្រើនទៀត - រូបភាពធំបំផុតដែលនឹងត្រូវមកដល់ មិនទាន់បានបង្ហាញដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់នៅឡើយ ។ វាត្រូវបានគេហៅថាឆ្នាំមេត្តាករុណា។

# ជំពូក ៧

# មិនអាចទៅរួចទេ!

អ្វីដែលអ្នកនឹងអានបន្តិចទៀតនេះគឺជាអ្វីដែលអស្ចារ្យ។ មិនមែនទេ ទុកឱ្យខ្ញុំកែសម្រួលឃ្លានេះបន្តិចសិន។ អ្នកមុខជាគិតថាមិនអាចទៅរួចទាល់តែសោះ។ ខ្ញុំកំពុងតែនិយាយអំពីឆ្នាំមេត្តាករុណា អំពីរូបភាពដ៏ល្អបំផុតនៃអ្វីដែលព្រះយេស៊ូចង់ធ្វើនៅក្នុងផ្នែកហិរញ្ញវត្ថុរបស់អ្នកដែលបានសរសេរនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ក៏មានមនុស្សតែមួយចំនួនតូចប៉ុណ្ណោះដែលដឹង ឬយល់ពីអត្ថន័យរបស់វា។ យើងបាននិយាយរួចមកហើយអំពីថ្ងៃសប្ប័ទ ឆ្នាំសប្ប័ទ ដែលអ្វីទាំងពីនេះគឺជារូបភាពនៃអ្វីដែលយើងមាននៅក្នុងព្រះគ្រិស្ត ក៏ប៉ុន្តែឥលូវនេះយើងមកចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏ធំ គឺជាឆ្នាំមេត្តាករុណា។

គ្រាន់តែស្ដាប់ឈ្មោះក៏មានអារម្មណ៍ថាវាជាការប្រារព្ធពិធីមួយដែរ មែនដែរទេ? ទោះជាយ៉ាងណាក៏ដោយនៅក្នុងពិតពផ្នែកហិរញ្ញវត្ថុ មានមនុស្សភាគច្រើនមិនសូវមានអ្វីច្រើនដើម្បីអបអរទេ ហើយពេលដែលខ្ញុំនិយាយពីមនុស្សភាគច្រើនគួរឱ្យសោកស្ដាយណាស់ គឺខ្ញុំសំដៅលើគ្រិស្តបរិស័ទភាគច្រើនដែរ។ ពេលខ្ញុំបានចែកចាយនោះ ខ្ញុំជាមនុស្សសកម្មនៅក្នុងនៅក្នុងវិស័យហិរញ្ញវត្ថុអស់រយៈពេល ៣៦ឆ្នាំមកហើយ។ ខ្ញុំបានធ្វើជាម្ចាស់ក្រុមហ៊ុនជាច្រើនក្នុងពេលនោះ និងបានធ្វើការជាមួយមនុស្សបើមិនមែន១០ ទេក៏ ១០០ ពាន់នាក់ដែរនៅលើផ្នែកហិរញ្ញវត្ថុរបស់ពួកគេ នៅក្នុងពេលជាមួយគ្នានោះ។ ដូច្នេះហើយខ្ញុំបានដឹងថាមានអ្វីកើតឡើងនៅទីនោះ។ ហើយខ្ញុំក៏ដឹងថាមានអ្វីនៅពីក្រោយរថយន្តថ្មីដ៏ភ្លឺចែងចាំង ឬផ្ទះដ៏ធំស្កឹមស្កៃនោះ។ ជាទូទៅតែងមានបំណុល និងភាពតានតឹងចិត្តជាច្រើននៅពីក្រោយ។ ការរស់នៅក្នុងពេលសព្វថ្ងៃនេះគឺត្រូវចំណាយប្រាក់ច្រើនណាស់។

ចំណែកឯប្រព័ន្ធនៃបណ្ដាសាលោកិយ គឺជាប្រព័ន្ធនៃការរស់រានមានជីវិតមួយដែលតែងតែនឹងបរាជ័យក្នុងការធ្វើឱ្យមនុស្សមានសេរីភាព។ សូមជឿខ្ញុំចុះ ក្នុងចំណោមមនុស្សរាប់ពាន់អ្នកដែលខ្ញុំបានជួប ភាគច្រើនពួកគេមិនមែនជាមនុស្សអាក្រក់ទេ។ ពួកគេ

បានព្យាយាមធ្វើកិច្ចការឱ្យល្អបំផុតតាមដែលពួកគេអាចធ្វើបានដោយខ្លួនឯង ហើយពួកគេមិនបានស្គាល់ព្រះរាជ្យនៃព្រះ ឬអ្វីដែលខ្ញុំកំពុងតែចែករំលែកនៅក្នុងសៀវភៅនេះឡើយ។ ជាការពិតណាស់ អ្នកដឹងថាឌ្រិនដា និងខ្ញុំបានរស់នៅក្នុងជីវភាពដែលតានតឹងផ្នែកហិរញ្ញវត្ថុអស់រយៈពេល៩ឆ្នាំដ៏សែនយូរ និងលំបាកដោយផ្ទាល់រហូតដល់យើងបានរៀនអំពីការសម្រាកក្នុងថ្ងៃសប្ប័ទ។ បន្ទាប់ពីការរស់នៅក្នុងសភាពបែបនោះអស់រយៈពេលដ៏យូរ អ្នកមិនដឹងថាភាពច្របូកច្របល់ច្រើនប៉ុណ្ណាដែលអ្នកនៅតែបន្តទទួលយក ហើយគិតថាវាគឺជារឿងធម្មតា។

កាលពីប៉ុន្មានឆ្នាំមុន ព្រះជាម្ចាស់បានមានបន្ទូលមកខ្ញុំអំពីការគិតតូចរបស់ខ្ញុំ និងធ្វើឱ្យខ្ញុំដឹងថាខ្ញុំគួរតែរីករាយនឹងឆ្នាំមេត្តាករុណា ចាត់ទុកថាជាពិធីជប់លៀងក៏ប៉ុន្តែខ្ញុំមិនបានរីករាយនោះទេ។ មែនហើយ ខ្ញុំបានរួចពីបំណុលហើយ ហើយក៏បានឃើញការអស្ចារ្យជាច្រើនកើតឡើងដែរ ជាការពិតមែនដែរដែលខ្ញុំមានចិត្តអរសប្បាយ និងស្កប់ចិត្ត។ ក៏ប៉ុន្តែខ្ញុំឈប់មានការស្រមៃទៅហើយ ហើយព្រះជាម្ចាស់ក៏បានជ្រាបរឿងនោះដែរ ហើយទ្រង់ចង់ឱ្យខ្ញុំពត់ខ្លួនម្តងទៀត ដើម្បីរក្សាខ្ញុំឱ្យនៅតែមានភាពច្នៃប្រឌិត និងមានក្តីស្រមៃ។ ខ្ញុំមានអារម្មណ៍ដូចជាស្ពឹកស្រពន់បន្តិច អារម្មណ៍ដូចជាសប្បាយតែនៅស្ពឹកស្រពន់។

ដូចខ្ញុំបាននិយាយអីចឹង ខ្ញុំជាម្ចាស់ក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុ ហើយមានអ្នកលក់របស់ខ្ញុំម្នាក់បានអញ្ជើញខ្ញុំឱ្យចូលរួមព្រឹត្តិការណ៍អបអរភាពជោគជ័យនៃឆ្នាំកន្លងទៅរបស់គេជារៀងរាល់ឆ្នាំ។ ជាទូទៅមានអ្នកចូលរួមប្រមាណ ២៥០នាក់ជាសហការី និងជានាយកប្រតិបត្តិកំពូល។ វាគឺជាការធ្វើដំណើរដែលទទួលបានការចំណាយទាំងស្រុងឱ្យរួចទៅហើយ ទៅកាន់ទីកន្លែងដ៏អស្ចារ្យជាច្រើន ក៏ប៉ុន្តែសម្រាប់បុគ្គលកំពូលៗមួយចំនួនតូច ពួកគាត់មានការទទួលស្គាល់ជាពិសេស និងទទួលបានប្រាក់រង្វាន់ផ្សេងៗផងដែរ។ ដោយសារតែពេលនោះខ្ញុំជាប់រវល់ធ្វើជាគ្រូគង្វាលនៅក្នុងក្រុមជំនុំមួយដ៏ធំមួយ ធ្វើកម្មវិធីទូរទស្សន៍ និងគ្រប់គ្រងកិច្ចការក្រុមហ៊ុនរបស់ខ្ញុំ ទើបខ្ញុំតែងតែមានអារម្មណ៍ខ្ញុំគ្មានពេលវេលាដើម្បីបង្កើតផលិតកម្មណាមួយដែលចាំបាច់ដើម្បីឈានទៅដល់កម្រិតដែលមានការទទួលស្គាល់នោះទេ។

ក៏ប៉ុន្តែនៅមានឆ្នាំមួយ ពេលខ្ញុំអង្គុយនៅក្នុងអង្គប្រជុំ និងមើលទៅសហការីកំពូលទាំង១០នាក់មានការទទួលស្គាល់ និងទទួលបានប្រាក់រង្វាន់ដល់ទៅ ១០០,០០០ ដុល្លារឯណោះ នោះហើយជាអ្វីដែលទាក់ចិត្តខ្ញុំ។ ខ្ញុំបានគិតថា «អេឈប់សិន! ខ្ញុំគួរតែបាន

ទៅឈរនៅត្រង់នោះ នៅលើឆាក ហើយត្រូវគេទទួលស្គាល់ដូចនោះដែរ។ ខ្ញុំគឺជាបុត្ររបស់ព្រះជាម្ចាស់ ហើយព្រះវិញ្ញាណដ៏វិសុទ្ធគឺជាទីប្រឹក្សារបស់ខ្ញុំ។ ខ្ញុំគួរតែនៅទីនោះចែកចាយ និងបង្ហាញពីសេចក្ដីល្អរបស់ព្រះជាម្ចាស់!» ហេតុដូច្នេះហើយឌ្រិនដា និងខ្ញុំបានប្ដូរចិត្តតាំងពីពេលនោះមក និងសម្រេចចិត្តថាយើងនឹងឡើងទៅលើឆាកនោះនៅឆ្នាំក្រោយ។ តើនឹងធ្វើដូច្នេះដោយរបៀបណាទៅ? យើងមិនដឹងទាល់តែសោះ។

កាលពី ១០ឆ្នាំមុនខ្ញុំរកប្រាក់បានប្រមាណ ៣ ទៅ ៤លានដុល្លារក្នុងមួយឆ្នាំនៅក្រុមហ៊ុនមួយនេះ ក៏ប៉ុន្តែផលិតកម្មនេះត្រូវតម្រូវឱ្យមានប្រាក់ចំណូលប្រមាណ ១១លានដុល្លារអាមេរិក ដើម្បីសម្រេចបានជាក្រុមហ៊ុនលំដាប់កំពូលទី១០។ ខ្ញុំមិនដឹងទេថាត្រូវធ្វើបែបណាដើម្បីសម្រេចទៅដល់កម្រិតនោះ និងខ្ញុំមិនទាំងច្បាស់ផងថាកាលវិភាគខ្ញុំអាចអនុញ្ញាឱ្យខ្ញុំធ្វើដូច្នោះបានឬទេ។ មេរៀនមួយដែលខ្ញុំរៀនបាននោះគឺថា ខ្ញុំមិនអាចសម្រេចវាបានដោយប្រើកម្លាំងផ្ទាល់ខ្លួនរបស់ខ្ញុំទេ។ ដូច្នេះឌ្រិនដា និងខ្ញុំបានអធិស្ឋាន និងបានដាក់គោលដៅក្នុងការសាបព្រោះគ្រាប់ពូជផ្នែកហិរញ្ញវត្ថុ បង្ហាញជំនឿរបស់យើង និងប្រកាសឱ្យវាបានសម្រេច។

និយាយឱ្យខ្លីទៅ ក្នុងខែមករានៃឆ្នាំបន្ទាប់ ពេលឆ្នាំថ្មីរៀបនឹងចូលមកដល់ ព្រះជាម្ចាស់បានបង្ហាញខ្ញុំពីរបៀបសម្រេចគោលដៅរបស់ខ្ញុំនៅក្នុងសុបិននិមិត្តមួយ។ ទ្រង់បានបង្ហាញខ្ញុំយ៉ាងច្បាស់នូវអ្វីដែលខ្ញុំត្រូវការធ្វើ ហើយដរាបណាខ្ញុំធ្វើតាមអ្វីដែលទ្រង់បង្ហាញមកខ្ញុំ នោះខ្ញុំនឹងអាចសម្រេចវាបាន។ តើអ្នកដឹងទេថាយើងរកប្រាក់បានដល់ទៅ១១លានដុល្លារសម្រេចតាមគោលដៅរបស់យើងក្នុងឆ្នាំនោះជាមួយនឹងចំនួននៃការលក់តែមួយប៉ុណ្ណោះ! ពិតជាគួរឱ្យរំភើបមែនចំពោះការឈរនៅលើឆាកនោះក្នុងសន្និបាតបន្ទាប់ក្នុងចំណោមក្រុមហ៊ុនកំពូលទាំង១០ និងទទួលបានប្រាក់រង្វាន់ ១០០,០០០ដុល្លារនោះ។ តើអ្នកចង់ដឹងទេថាតើអារម្មណ៍មួយនោះវាវិសេសវិសាលយ៉ាងណា? វាពិតជាពិធីជប់លៀងមួយដ៏ធំសម្បើម។ យើងមិនត្រឹមតែបានសម្រេចគោលដៅដោយទទួលបានប្រាក់រង្វាន់ប៉ុណ្ណោះទេ ក៏ប៉ុន្តែវារួមទាំងប្រាក់ចំណូលរបស់យើងដែលបានកើនឡើងក្នុងចំនួនរាប់ពាន់ដុល្លារនៅក្នុងឆ្នាំនោះ។ វាស្ដាប់ទៅហាក់ដូចជាពិធីជប់លៀងមួយសម្រាប់ខ្ញុំ!

**អ្នកមិនដឹងថាភាពច្របូកច្របល់ច្រើនប៉ុណ្ណាដែលអ្នកនៅតែបន្តទទួលយក ហើយគិតថាវាគឺជារឿងធម្មតា។**

ដូច្នេះពេលខ្ញុំចាប់ផ្ដើមនិយាយអំពីព្រឹត្តិការណ៍មួយចំនួននៅក្នុងសម្ពន្ធមេត្រីថ្មី ដូចជាពិធីបុណ្យទី៥០ សូមកុំគ្រវិក្បាលដើរចេញ និងគិតថានេះជាអ្វីដ៏គួរឱ្យធុញទ្រាន់អី ព្រោះវាមិនគួរឱ្យធុញទ្រាន់ទេ។ សូមចាំថាជីវិតយើងមានអ្វីល្អប្រសើរដោយមានពិធីជប់លៀង ដូច្នេះសូមមើលទៅកាន់ព្រឹត្តិការណ៍ / ពិធីជប់លៀងដ៏ធំជាងគេដែលជនជាតិអ៊ីស្រាអែលបានប្រារព្ធឡើង និងរៀនពីរបៀបមានពិធីជប់លៀងដោយខ្លួនអ្នក។

# ឆ្នាំមេត្តាករុណា

*ចូររាប់ឆ្នាំសប្ប័ទប្រាំពីរដង គឺប្រាំពីរឆ្នាំប្រាំពីរដង សរុបទាំងអស់សែសិបប្រាំបួនឆ្នាំ។ នៅខែទីប្រាំពីរ ថ្ងៃទីដប់ ត្រូវផ្លុំស្នែង និងស្រែកយ៉ាងរំពងពាសពេញស្រុកទាំងមូល ព្រោះជាថ្ងៃរំដោះបាប។ អ្នករាល់គ្នាត្រូវចាត់ទុកឆ្នាំទីហាសិបនោះជាឆ្នាំដ៏វិសុទ្ធ ត្រូវប្រកាសសេរីភាពនៅក្នុងស្រុកទាំងមូល។ ឆ្នាំនោះត្រូវមានឈ្មោះថា «ឆ្នាំមេត្តាករុណា»។ ពេលនោះ ម្នាក់ៗវិលត្រឡប់ទៅកាន់ស្រុកភូមិ ទៅជួបជុំនឹងអំបូររបស់អ្នករាល់គ្នាវិញ។*

*ឆ្នាំទីហាសិប ជាឆ្នាំមេត្តាករុណានោះ អ្នករាល់គ្នាមិនត្រូវសាបព្រោះ ឬច្រូតកាត់ភោគផលដុះពីគ្រាប់ដែលធ្លាក់ទៅលើដី កាលពីរដូវចម្រូតមុនឡើយ ហើយក៏មិនត្រូវបេះផ្លែទំពាំងបាយជូរ ដែលអ្នករាល់គ្នាទុកចោលនោះដែរ។ អ្នករាល់គ្នាត្រូវចាត់ទុកឆ្នាំមេត្តាករុណាជាឆ្នាំសក្ការៈ។ អ្នករាល់គ្នានឹងបរិភោគអ្វីៗដែលដុះនៅក្នុងចម្ការ។នៅឆ្នាំមេត្តាករុណា អ្នករាល់គ្នាអាចវិលទៅកាន់កាប់កម្មសិទ្ធិរបស់ខ្លួនវិញ។*

លេវីវិន័យ ២៥៖៨-១៣

ពេលខ្ញុំចាប់ផ្ដើមពិភាក្សាពីឆ្នាំមេត្តាករុណា សូមធ្វើការដាក់មូលដ្ឋានគ្រឹះមួយចំនួនដែលអ្នកគួរតែបានកត់សម្គាល់រួចមកហើយ។ ឆ្នាំមេត្តាករុណា កើតឡើងជារៀងរាល់ ៥០ឆ្នាំម្ដង ហើយវាកើតឡើងបន្ទាប់ពីឆ្នាំសប្ប័ទមួយគឺឆ្នាំទី៤៩។ ខ្ញុំគិតថាអ្នកដូចជាបានឃើញបញ្ហាធំមួយលេចឡើងមក តើអ្នកអាចមើលឃើញទេ? ក្នុងអំឡុងឆ្នាំសប្ប័ទ ជនជាតិអ៊ីស្រាអែលត្រូវហាមឃាត់មិនឱ្យមានការដាំដំណាំឡើយ។ ឆ្នាំមេត្តាករុណា ដែលចូលមកតាមក្រោយឆ្នាំមួយនោះក៏មានលក្ខខណ្ឌតម្រូវដូចគ្នាគឺហាមឃាត់មិនឱ្យមានការដាំដំណាំដូចគ្នាដែរ។ ដូច្នេះអ្វីដែលសំខាន់គឺថា ជនជាតិអ៊ីស្រាអែលមិនដាំដុះដំណាំដល់ទៅពីរឆ្នាំជាប់ៗគ្នា

ហើយត្រូវរង់ចាំក្នុងឆ្នាំទីបីទៀតទម្រាំដំណាំដល់កាលកំណត់ត្រូវប្រមូលផលបាន និង ប្រមូលផលមុនពេលពួកវាអាចបំពេញការផ្គត់ផ្គង់ស្បៀងអាហាររបស់ពួកគេបាន។ នេះអាចក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរចំពោះមនុស្សដែលចូលចិត្តទទួលទានអាហារឆ្ងាញ់ៗ ឬជាអ្នកប្រកបរបរលក់គ្រាប់ពូជជាដើម។ ពេលលោកម៉ូសេពឹងផ្អែកលើការណែនាំទាក់ទងនឹងឆ្នាំមេត្តាករុណា អ្នកអាចស្រមៃមើលឃើញពីភាពច្របូកច្របល់ដែលមុខជាបានកើតឡើងនៅពេលនោះមិនខាន។ ជាការពិតណាស់ ការគិតអំពីការសម្រាករយៈបីឆ្នាំគឺជាគំនិតមួយដ៏ល្អ ក៏ប៉ុន្តែត្រូវមាននរណាម្នាក់ដែលត្រូវលះបង់ដើម្បីវា។ រឿងទីមួយដែលពួកគេបានសួរលោកម៉ូសេ ពេលពួកគេបានឮអំពីការណែនាំនោះ «តើវាអាចទៅរួចបានយ៉ាងដូចម្ដេចទៅ?»

> *ប្រសិនបើអ្នករាល់គ្នាពោលថា "នៅឆ្នាំទីប្រាំពីរ តើពួកយើងនឹងបានអ្វីបរិភោគ បើពួកយើងមិនសាបព្រោះ មិនច្រូតកាត់ដូច្នេះ!"។ នៅឆ្នាំទីប្រាំមួយ យើងនឹងឲ្យពរអ្នករាល់គ្នា គឺក្នុងឆ្នាំនោះ អ្នករាល់គ្នានឹងទទួលភោគផលគ្រប់គ្រាន់សម្រាប់បីឆ្នាំ។ អ្នករាល់គ្នាសាបព្រោះសាជាថ្មី នៅឆ្នាំទីប្រាំបី តែអ្នករាល់គ្នាបរិភោគផលដែលប្រមូលបានពីមុន រហូតដល់ឆ្នាំទីប្រាំបួន។ អ្នករាល់គ្នាត្រូវបរិភោគផលចាស់ រហូតទាល់តែបានទទួលភោគផលថ្មី។*

លេវីវិន័យ ២៥៖២០-២២

ព្រះជាម្ចាស់បានឆ្លើយតបទៅពួកគេដោយចម្លើយដ៏អស្ចារ្យមួយដែលយើងនឹងចំណាយពេលជាច្រើនក្នុងការរុករក នៅក្នុងខ្លឹមសារដែលនៅសេសសល់ក្នុងសៀវភៅនេះ។ ទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងបញ្ជូនព្រះពរមួយមកនៅក្នុងឆ្នាំទី៦ ដែលព្រះពរនោះនឹងធ្វើជាទិន្នផលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់បានរយៈពេលបីឆ្នាំរហូតដល់មានរដូវកាលប្រមូលផលថ្មីចូលមកដល់បន្ទាប់ពីឆ្នាំមេត្តាករុណា។ មានបន្ទាត់ស្របគ្នាមួយនៅទីនេះ យោងតាមថ្ងៃនៃកំណើតពិភពលោក។ ព្រះគម្ពីរចែងថាព្រះជាម្ចាស់បានបញ្ចប់ការងារនៅថ្ងៃទី៦ នៃថ្ងៃកំណើតពិភពលោក និងបានសម្រាក។ ទោះបីជាទ្រង់សម្រាក មិនមែនមានន័យថាទ្រង់នឿយហត់ឡើយ។ ផ្ទុយទៅវិញគឺទ្រង់បាបបញ្ចប់កិច្ចការ។ អ្វីៗដែលមនុស្សត្រូវការ ត្រូវបានបង្កើតរួចជាស្រេច ហើយមនុស្សមានអ្វីៗទាំងអស់នោះ។

កាលនោះព្រះជាម្ចាស់កំពុងបង្ហាញជនជាតិអ៊ីស្រាអែលនូវរូបភាពមួយពីអ្វីដែលលើសពីគ្រប់គ្រាន់ ដែលផ្ទុយស្រឡះពីប្រព័ន្ធនៃបណ្ដាសាលោកិយឈើ អំពីក្ដីឈឺចាប់នឿយហត់ និងការបង្ហូរញើស។ ទ្រង់ចង់ឱ្យពួកគេមើលឃើញទ្រង់ថាជាអ្នកផ្គត់ផ្គង់របស់ពួកគេ

និងឱ្យពួកគេយល់ថាទ្រង់ផ្តល់ឱ្យពួកគេនូវការផ្គត់ផ្គង់ដ៏មានអំណាច។ ជាថ្មីម្តងទៀត ទោះបីជានេះគឺជារូបភាពមួយសម្រាប់ពួកគេដែលប្រាប់ពីការផ្គត់ផ្គង់របស់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ពួកគេមើលមិនឃើញដូច្នោះទេ លុះត្រាតែរហូតដល់ព្រះយេស៊ូបានយាងមក ទើបយើងមើលឃើញអ្វីដែលបង្ហាញមកកាន់យើងតាមរយៈរូបភាពនោះ។ បើនិយាយតាមធម្មជាតិ ហាក់ដូចជាគ្មានផ្លូវដើម្បីរស់រានមានជីវិតក្នុងអំឡុងពេលបីឆ្នាំដោយគ្មានការដាំដំណាំអ្វីសោះនោះឡើយ។ ដូចគ្នានេះដែរតាមធម្មជាតិ ការរស់នៅក្រោមប្រព័ន្ធបណ្តាសាលោកិយនឹងគ្មានផ្លូវក្នុងការមានជ័យជម្នះផ្នែកហិរញ្ញវត្ថុដោយគ្មានការចំណាយពេលវេលាទាំងថ្ងៃ ទាំងយប់របស់អ្នកធ្វើការដោយបង្ខូរញើសនោះឡើយ។ អ្នកមិនអាចរត់បានលឿនល្មមដើម្បីសម្រេចកិច្ចការនេះបានឡើយ។ សូមសាកល្បងឈប់សម្រាករយៈពេលបីឆ្នាំពីការងារដែលអ្នកកំពុងតែបំពេញ ពេលដែលអ្នកមានកាតព្វកិច្ចសំខាន់ៗលេចធ្លោផ្សេងៗ នោះអ្នកដូចជាកំពុងតែផ្សំរូបមន្តដ៏ប្រាកដជាក់លាក់មួយសម្រាប់ការក្ស័យធនដូច្នេះដែរ។ ក៏ប៉ុន្តែព្រះជាម្ចាស់ព្យាយាមបង្ហាញពួកគេនូវរូបភាពមួយនៃរបៀបថ្មីមួយ ជារបៀបមួយដែលទ្រង់ផ្គត់ផ្គង់ប្រជាជនរបស់ទ្រង់ ប្រៀបដូចជាលោកអប្រាហាំ ទទួលបានការផ្គត់ផ្គង់ តាមរយៈអ្វីដែលព្រះជាម្ចាស់បានត្រៀមទុកសម្រាប់គាត់អំឡុងពេលកំណើតពិភពលោកដូច្នោះដែរ។

មានរឿងពីរផ្សេងទៀតដែលឆ្នាំមេត្តាករុណា បង្ហាញយើងថាយើងត្រូវតែពិនិត្យមើល។ ជាថ្មីម្តងទៀតយើងបានឃើញដីកំពុងតែសម្រាក គ្មានកិច្ចការនឿយហត់ និងការបង្ហូរញើសនៅក្នុងឆ្នាំទី៥០ឆ្នាំនេះទេ។ អ្នកនឹងកត់សម្គាល់ផងដែរថាដីទាំងអស់នឹងនៅតែត្រលប់ទៅជាកម្មសិទ្ធិរបស់ម្ចាស់ដើមវិញ។ ពេលជនជាតិអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ កុលសម្ព័ន្ធ និងគ្រួសារនីមួយៗ ទទួលបានដីជាកម្មសិទ្ធិរបស់ពួកគេ និងដាំស្បៀង រួមទាំងប្រាក់ចំណូលដែលពួកគេត្រូវការដើម្បីរស់នៅ។ និយាយរួមទៅដីគឺជាទ្រព្យសម្បត្តិរបស់ពួកគេ។ នៅលើដីពួកគេដាំដំណាំ និងបានចិញ្ចឹមសត្វ។ ដូច្នេះការប្រគល់ដីត្រលប់ទៅរកម្ចាស់ដើមវិញ គឺជាការប្រគល់លទ្ធភាពក្នុងការមានភាពចម្រុងចម្រើនទៅឱ្យម្ចាស់ដើមវិញ។

ជាថ្មីម្តងទៀត នេះគឺជារូបភាពនៃអ្វីដេលព្រះយេស៊ូបានធ្វើសម្រាប់យើង។ ប្រមោលនោះប្រាប់យើងថា ភាពចម្រុងចម្រើននឹងត្រូវនឹងត្រូវត្រលប់ទៅរកពលរដ្ឋដែលជាប្រជាជននៃប្រទេសអ៊ីស្រាអែលវិញ។ ការពិតបានប្រាប់យើងនូវអ្វីដែលដូចគ្នានេះដែរថាភាព

ចម្រុងចម្រើនរបស់យើងបានត្រលប់មករកយើងវិញដូច្នោះដែរ និងប្រាប់យើងថា មរតកនៃព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាកម្មសិទ្ធិរបស់យើងជាថ្មីម្តងទៀត។

**ពេលអ្នកដឹងពីអ្វីដែលថ្ងៃសប្ប័ទពិតជាចង់បង្ហាញដល់យើង នោះការផ្លាស់ប្រែដ៏ធំអាចកើតមានឡើងនៅក្នុងផ្នែកហិរញ្ញវត្ថុក្នុងជីវិតអ្នក។**

មានរឿងទីបីមួយដែលឆ្នាំមេត្តាករុណាបង្ហាញឱ្យយើងឃើញ និងបង្ហាញថាអ្នកជាទាសករទាំងអស់នឹងត្រូវមានសេរីភាព នឹងបានត្រលប់ទៅរកក្រុមគ្រួសាររបស់ពួកគេវិញបាន។ នេះគឺជារឿងមួយដ៏ធំ។ ជាថ្មីម្តងទៀត រូបភាពនោះបានប្រាប់ថាអ្នកមិនមែនជាទាសករទៀតទេ តែជាបុត្រធីតានៅក្នុងដំណាក់របស់ព្រះជាម្ចាស់ដោយមានសិទ្ធិពេញលេញក្នុងទទួលមរតក និងភាពចម្រុងចម្រើននៅក្នុងដំណាក់នោះ។

ដូច្នេះសូមគិតអំពីអ្វីដែលអ្នកទើបតែបានរៀននេះ។ ព្រះយេស៊ូបានប្រទានឱ្យយើងវិញនូវអ្វីដែលលោកអដាំបានបាត់បង់។ ព្រះយេស៊ូបានប្រទានឱ្យយើងមានសេរីភាពចេញពីភាពជាទាសករ ធ្វើឱ្យយើងក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់។ ទ្រង់ផ្តល់ឱ្យយើងមានសេរីភាពចេញពីប្រព័ន្ធបណ្តាសាលោកិយនៃសេចក្តីហត់នឿយ ឈឺចាប់ និងការបង្ខូរញើស និងអនុញ្ញាតឱ្យព្រះជាម្ចាស់ប្រទានពរដល់កិច្ចការដែលនៅក្នុងដៃយើង ក្នុងរបៀបមួយប្រកបដោយអំណាច។ ទោះបីជាព្រះយេស៊ូបានបង់ថ្លៃសម្រាប់រឿងទាំងនេះហើយក្តី យើងនៅតែត្រូវដឹងពីរបៀបដើម្បីអរព្រះគុណចំពោះផលប្រយោជន៍ដែលបានចូលកាន់ជីវិតពិតរបស់យើង នៅទីនេះក្នុងផែនដីនេះ។ ត្រង់នេះគឺជាចំណុចដែលគ្រិស្តបរិស័ទជាច្រើនបានមើលរំលង។ ការមិនដឹងពីដំណើរការរបស់ព្រះរាជ្យនៃព្រះស្របតាមច្បាប់ ការមិនដឹងពីសិទ្ធិស្របច្បាប់ក្នុងនាមជាបុត្រធីតា និងជាពលរដ្ឋ ធ្វើឱ្យពួកគេជឿថាព្រះជាម្ចាស់បានជ្រើសរើសប្រទានពរនរណាដែលទ្រង់ចង់ប្រទានពរតាមតែព្រះទ័យទ្រង់ប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាពួកគេមិនសិក្សាពីច្បាប់ផ្សេងៗរបស់ព្រះរាជ្យនៃព្រះ ដែលជាច្បាប់គន្លឹះទៅរកភាពរីករាយពិតប្រាកដ និងអនុវត្តនូវអ្វីដែលព្រះគម្ពីរចែងថាជាកម្មសិទ្ធិរបស់ពួកគេ។ ខ្ញុំកំពុងតែប្រាប់អ្នកម្តងទៀតថា ពេលអ្នកដឹងពីអ្វីដែលថ្ងៃសប្ប័ទពិតជាចង់បង្ហាញដល់យើង នោះការផ្លាស់ប្រែដ៏ធំអាចកើតមានឡើងនៅក្នុងផ្នែកហិរញ្ញវត្ថុក្នុងជីវិតអ្នក។

**បង្កើនផលហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃការសម្រាក

មានសុភាពបុរសម្នាក់នៅក្នុងក្រុមជំនុំរបស់ខ្ញុំ បានចាប់ផ្តើមលើពីអ្វីដែលខ្ញុំបង្រៀនដូចគ្នាទៅនឹងជំនឿ និងរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ។ គ្រួសារគាត់ និងកូនៗរបស់គាត់បានសិក្សាពីច្បាប់ទាំងនេះជាមួយគ្នាជាលក្ខណៈគ្រួសារ។ ពេលឆ្នាំថ្មីជិតចូលមកដល់ ពួកគេបានសម្រេចចិត្តពួកគេនឹងអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេ និងជឿថាពួកគេមុខជាអាចទិញផ្ទះដួលពីរកន្លែង ដែលពួកគេទើបតែទទួលបាននៅក្នុងឆ្នាំនោះ។ ប្រសិនបើខ្ញុំចាំមិនខុសទេ ខ្ញុំគិតថាចំនួនប្រាក់សរុបដែលពួកគេត្រូវការដើម្បីទិញផ្ទះទាំងពីរនោះគឺប្រមាណជា ៩០០,០០០ ដុល្លារ។ ដូច្នេះហើយពួកគេបានអធិស្ឋាន និងសាបព្រោះគ្រាប់ពូជហិរញ្ញវត្ថុដ៏សំខាន់មួយឆ្ពោះទៅរកគោលដៅក្នុងការទិញផ្ទះទាំងពីរនេះនៅក្នុងឆ្នាំនោះ។ នោះគឺជាការផ្លាស់ប្តូរដ៏ធំមួយសម្រាប់ពួកគេ ក៏ប៉ុន្តែសុភាពបុរសម្នាក់នោះបានធ្វើការនៅក្នុងវិស័យមួយដែលអាចទៅរួចស្រាប់ក្នុងការស្វែងរកអតិថិជនបានគ្រប់ និង/ឬទទួលបានកិច្ចសន្យាធំៗពីអតិថិជន ដែលអាចរកឱកាសសម្រាប់គាំទ្រដល់លទ្ធភាពរបស់គាត់បាន។ ក្រុមគ្រួសារទាំងមូលបានអធិស្ឋានជាមួយគ្នា និងបានយល់ស្របគ្នាថាអ្វីដែលពួកគេធ្វើនឹងបានសម្រេច។ ជារៀងរាល់សប្តាហ៍ គ្រួសារនេះនឹងរំលឹកពីគោលដៅរបស់ពួកគេឡើងវិញ និងរំលឹកពីខគម្ពីរផ្សេងៗដែលផ្តល់ឱ្យពួកគេមានមូលដ្ឋានស្របច្បាប់ដើម្បីឈរមាំបន្តទៀត និងដើម្បីរង់ចាំការប្រមូលផលនោះចូលមក។ ជាការពិតណាស់ សុភាពបុរសម្នាក់នេះបានដឹងថាគាត់ត្រូវតែបំពេញកិច្ចការក្នុងផ្នែករបស់គាត់។

មែនហើយពេលឆ្នាំថ្មីចូលមកដល់ ប្រាកដណាស់គឺមានកិច្ចសន្យាធំៗពីរបីអាចនឹងត្រូវធ្វើឡើងបាន ក៏ប៉ុន្តែដោយសារតែវាជាកិច្ចសន្យាជាមួយក្រុមហ៊ុនធំៗ ក្នុងការព្រមព្រៀងដែលមានចំនួនទឹកប្រាក់រាប់លានដុល្លារ មិនងាយនឹងចេញជាផ្លែផ្កាឆាប់រហ័សបាននោះទេ។ បានប្រហែលជាពាក់កណ្តាលឆ្នាំ បុរសម្នាក់នេះបានដាក់ទីតាំង និងចាប់យកបានការលក់ដ៏ធំមួយសម្រាប់ក្រុមហ៊ុនរបស់គាត់ ជាការលក់ដ៏ធំសម្បើមដែលវាជាចំនួនដែលទទួលបានស្មើនឹង ៩០% នៃផលិតកម្មរបស់ក្រុមហ៊ុនគាត់នៅក្នុងឆ្នាំនោះ។ ដោយទទួលបានកម្រៃជើងសារនោះ ទើបគាត់អាចចំណាយលុយទិញផ្ទះដួលមួយក្នុងចំណោមផ្ទះទាំងពីរបាន។ រហូតដល់ចុងឆ្នាំនោះមានក្រុមហ៊ុនមួយផ្សេងទៀត បានបង្ហាញថាពួកគេពិតជាចង់ចុះហត្ថលេខាកិច្ចសន្យា នៅក្នុងកិច្ចព្រមព្រៀងរាប់លានដុល្លារ ដែលមិត្តរបស់ខ្ញុំម្នាក់នេះបានផ្តល់ដល់ពួកគេផងដែរ។ ក៏ប៉ុន្តែកាលបរិច្ឆេទយល់ព្រមលើការព្រមព្រៀងនោះចេះតែលើកទៅមុខរហូត។ ឯកសារពាក់ព័ន្ធបានរៀបចំរួចជាស្រេចហើយ តែក្រោយមកកាលបរិច្ឆេទក៏ចេះតែលើកទៅមុខទៀត។ រហូតមកដល់ចុងរដូវស្លឹកឈើជ្រុះទៅហើយទើបមិត្ត

របស់ខ្ញុំទទួលដំណឹងថាក្រុមការងារផ្នែកគ្រប់គ្រងដែលគាត់បានធ្វើការជាមួយពីមុនមក នោះ បានប្តូរទៅហើយ ហើយមានក្រុមការងារថ្មីបានចូលមកធ្វើការងារនេះជំនួសវិញ។

មិត្តរបស់ខ្ញុំបាក់ទឹកចិត្តនៅពេលនោះឯង ដោយគាត់ដឹងថារឿងនេះនឹងក្លាយទៅជាយ៉ាងណា។ ក្រុមការងារផ្នែកគ្រប់គ្រងដែលនឹងចូលមកថ្មីនោះមិនបានដឹងពីកិច្ចសន្យាដែលមិនទាន់បានព្រមព្រៀងនោះទេ ដែលជាការពិតណាស់កិច្ចសន្យានោះបានក្លាយជាមោឃៈ និងគ្មានប្រសិទ្ធភាពទៅហើយ។ គាត់មុខជាត្រូវធ្វើការនោះឡើងវិញតាំងពីដើម ជាមួយនឹងក្រុមការងារថ្មី។ ពេលគាត់ជួបក្រុមអ្នកគ្រប់គ្រងថ្មី ពួកគេមើលទៅដូចជាចូលចិត្តមើលការសំណូមពរផ្សេងរបស់ក្រុមហ៊ុនគាត់។ បន្ទាប់ពីពិនិត្យមើលវានៅចុងខែវិច្ឆិកា ពួកគេនិយាយថា ពួកគេចង់បន្តធ្វើការការជាមួយគ្នា។ តែជាថ្មីម្តងទៀត គេពន្យារពេលធ្វើឯកសារ និងសរសេរវាជាថ្មីរហូតដល់វានៅសល់តែពីរថ្ងៃទៀតនឹងចូលដល់ឆ្នាំថ្មីទៅហើយ។ មានគេទូរស័ព្ទមកមិត្តខ្ញុំ ហើយប្រាប់ថាគេចង់ជួប និងចុះហត្ថលេខាលើឯកសារ ព្រមទាំងប្រាប់ថាគេនឹងបង់ជាលុយសុទ្ធ ប្រសិនបើគាត់អាចជួបគេ និងចុះហត្ថលេខាក្នុងថ្ងៃនោះបាន។ ក្នុងកិច្ចព្រមព្រៀងនោះមិត្តខ្ញុំបានទទួលកម្រៃជើងសារគ្រប់ល្មម ដើម្បីសម្រេចគោលដៅដ៏ខ្ពស់របស់គាត់ដើម្បីទិញផ្ទះទាំងពីដាច់តែម្តងក្នុងឆ្នាំនោះ ជាឆ្នាំដែលគាត់ និងគ្រួសារគាត់បានដាក់ជំនឿរបស់គេទៅមុខ។

វាត្រឹមតែតាមរយៈការសិក្សាពីគោលការណ៍នៃព្រះរាជ្យ ដែលថែមទាំងអនុញ្ញាត ឬបានលើកគាត់ឡើងដើម្បីស្រមៃពីគោលដៅដ៏ខ្ពស់មួយនោះ ដោយគាត់មិនធ្លាប់មានគេស្គាល់ក្នុងកិច្ចការធំបែបនេះពីមុនមក ឬរកលុយបានច្រើនដូចនេះក្នុងពេលច្រើនឆ្នាំមុនមក ដែលអាចបង្ហាញថាគោលដៅរបស់គាត់ប្រហែលជាអាចសម្រេចបាននោះទេ។ គាត់បានប្រាប់ខ្ញុំថា ពួកគេបានជប់លៀងធំបន្តិចដើម្បីអបអរភាពជោគជ័យមួយនោះ!

រឿងមួយទៀតដែលនិយាយអំពី «រឿងនោះពិតជាបានកើតឡើងមែន» បានកើតឡើងចំពោះកូនរបស់ខ្ញុំម្នាក់។ ជាការពិតណាស់ កូនៗទាំងអស់របស់ខ្ញុំមើលឃើញដំណើរការរបស់ព្រះរាជ្យពេញមួយជីវិតគេទៅហើយ។ ពួកគេទាំងអស់គ្នាបានអនុវត្តគោលការណ៍ផ្សេងៗដែលខ្ញុំកំពុងរៀបរាប់នេះ និងបានឃើញព្រះជាម្ចាស់ធ្វើកិច្ចការដ៏អស្ចារ្យជាច្រើន។ ទោះបីជាពួកគេស្ថិតក្នុងវ័យខ្ទង់ ២០នៅឡើយ តែពួកគេទាំងអស់គ្នាមានលុយទិញឡាន ហើយពួកគេស្ទើរតែគ្រប់គ្នាមានលុយទិញផ្ទះ ឬមានលុយជិតគ្រប់ទិញផ្ទះ។ កូនប្រុសច្បងរបស់ខ្ញុំឈ្មោះ ធីម (Tim) ចង់ទិញផ្ទះមួយដោយប្រើលុយសុទ្ធ។ ដូច្នេះហើយគាត់បានព្រោះ

គ្រាប់ពូជ ទាំងជឿលើព្រះជាម្ចាស់សម្រាប់ជម្រើសដ៏ល្អបំផុតចំពោះផ្ទះស្ថិតក្នុងតម្លៃដែលគាត់អាចទិញបាន។ គាត់ក៏ប៉ិនប្រសប់ណាស់ដែរក្នុងកិច្ចការសាងសង់ ដូច្នេះគាត់មិនខ្លាចឡើយចំពោះការទិញផ្ទះចាស់ទ្រុឌទ្រោម។

គាត់បានចំណាយពេលមើលផ្ទះជាច្រើន ក៏ប៉ុន្តែរកមិនបានផ្ទះដែលត្រូវចិត្តសោះ។ នៅថ្ងៃមួយ គាត់បានបើកឡានទៅមក ហើយទាក់ចិត្តនឹងផ្ទះមួយនេះដែលគេបានដាក់លក់ ហើយគាត់មិនបានឃើញវាពីមុនមកទេ។ វាគឺជាទ្រព្យបញ្ចាំដែលត្រូវគេរឹបអូស ហើយពេលគាត់មើលទៅផ្ទះនោះ គាត់ដឹងភ្លាមថាផ្ទះនោះត្រូវការជួសជុលខ្លះៗ តែមើលទៅវាហាក់ដូចជាល្អឥតខ្ចោះ។ គាត់បានទូរស័ព្ទទៅភ្នាក់ងារអចលនទ្រព្យ និងប្រាប់គេឱ្យសួរពីតម្លៃផ្ទះនោះ។ គាត់សឹងតែមិនជឿនឹងត្រចៀកពេលឮថាវាមានតម្លៃ ៣៧,០០០ដុល្លារ។ «ប៉ុន្តែដូចជាមិនអាចទេ មែនទេ?» គាត់គិត។

ភ្នាក់ងារនោះបានស្រាវជ្រាវពីផ្ទះនោះ និងបានប្រាប់ពីរឿងមួយដ៏អស្ចារ្យ។ តាមពិតទៅផ្ទះនោះជាផ្ទះដែលគេរឹបអូស ហើយវាត្រូវគេដាក់លក់ក្នុងតម្លៃ ១១០,០០០ដុល្លារ ប្រមាណជា៦ខែមុននេះ។ នោះគឺជាតម្លៃរឹបអូស តែតាមពិតទៅផ្ទះនោះត្រូវលក់ក្នុងតម្លៃដល់ទៅ ១៦០,០០០ដុល្លារឯណោះកាលពីប៉ុន្មានឆ្នាំមុននេះ។ មកទល់ពេលនេះគ្មាននរណាចាប់អារម្មណ៍ផ្ទះនេះទេ គិតទៅគឺតាំងពី៦ខែមុនឯណោះដែលផ្ទះនេះត្រូវប្រកាសលក់។ ដូច្នេះហើយធនាគារនៅតែបន្តទម្លាក់តម្លៃ ដោយសារតែមិនថាមូលហេតុអ្វីគ្មានអ្នកចាប់អារម្មណ៍ផ្ទះនេះសោះ។ ក៏ប៉ុន្តែក្រោយពេលធីម និងភ្នាក់ងារអចលនទ្រព្យរបស់គាត់ស៊ើបមើលកាន់តែស៊ីជម្រៅទៅ ពួកគេក៏រកឃើញមូលហេតុដែលគ្មានអ្នកចាប់អារម្មណ៍ផ្ទះនោះ។ ផ្ទះនោះត្រូវគេដាក់លក់នៅក្នុងទីក្រុងផ្សេង ដោយដាក់អាសយដ្ឋានផ្សេង ហើយបើមើលទៅលេខទូរស័ព្ទវិញនោះក៏ដាក់ខុសដែរ។ ដូច្នេះហើយបានជាគ្មានអ្នកដឹងថាផ្ទះនោះស្ថិតនៅទីនោះ! ផ្ទះនោះស្ថិតនៅតាមដងផ្លូវតូចមួយនៅក្នុងទីប្រជុំជន ស្ថិតនៅត្រង់ផ្លូវទាល់ដែលគ្មានចរាចរណ៍ទៅមក។ តម្លៃផ្ទះចេះតែធ្លាក់ចុះទាបរហូតដល់ថ្ងៃដែល ធីម បានមើលឃើញវា។ ពិតជាអស្ចារ្យមែន។ ខ្ញុំបានប្រាប់ធីមថា ផ្ទះនោះគឺមានគេលាក់ទុកសម្រាប់គាត់! គាត់បានលាបថ្នាំផ្ទះថ្មី ហើយបានជួសជុលកន្លែងមួយចំនួនក្នុងផ្ទះ ហើយក៏បានលក់វាក្នុងតម្លៃ ១៦០,០០០ដុល្លារ។

អេមី (Amy) កូនស្រីខ្ញុំដឹកនាំការថ្វាយបង្គំនៅឯក្រុមជំនុំ Life Church។ គាត់និង ជេសិន (Jason) ត្រូវការមានផ្ទះធំជាងមុនមួយ ដោយសារតែគ្រួសារពួកគេបានរីកធំ

ឡើង ពីសមាជិក៤ ឡើងដល់ទៅ ៥នាក់។ នៅក្នុងរដូវក្តៅឆ្នាំ ២០១៧ តម្លៃផ្ទះគឺមិនអាចប៉ាន់ស្មានបានទេនៅក្នុងរដ្ឋអូហៃយ៉ូ ហើយផ្ទះដែលគេដាក់លក់ច្រើនតែលក់ដាច់ក្នុងអំឡុងពេលមួយសប្តាហ៍។ ក្តីសង្ឃឹមចង់ស្វែងរកផ្ទះធំល្មមមួយក្នុងតម្លៃប្រមាណ ២៥០,០០០ដុល្លារ ឬក្រោម ៣០០,០០០ដុល្លារ ជាមួយដីប្រមាណ ២ ទៅ ៤ ហិចតា និងលទ្ធភាពដែលអាចមានទឹកនៅក្នុងបរិវេណផ្ទះតាមដែលពួកគេចង់បាន ហាក់ដូចជាមិនទាន់រកឃើញនៅឡើយទេ។ សម្រាប់ដីកសិដ្ឋាននៅក្នុងតំបន់នោះ ០.៤ហិចតាគឺមានតម្លៃដល់ទៅប្រមាណ ២០០,០០០ដុល្លារកាលពីរដូវក្តៅឆ្នាំនោះ។ បន្ទាប់ពីបានរត់ទៅរត់មករកមើលផ្ទះជាច្រើនពួកគេបានឈប់រក ហើយបានអធិស្ឋាន។ ពួកគេសាបព្រោះគ្រាប់ពូជសម្រាប់ការណែនាំ ពួកគេបានប្រាប់ព្រះអម្ចាស់ថា «យើងរវល់ពេកទើបមិនអាចនៅតែរកមើលផ្ទះដូច្នេះទេ។ ទ្រង់ដឹងថាមួយណានឹងក្លាយជាផ្ទះយើង ហើយយើងសូមឱ្យទ្រង់ជួយបង្ហាញវាមកយើងក្នុងពេលមួយដ៏ត្រឹមត្រូវ។ យើងនឹងមិនស្វែងរកតាមអនឡាញទេ ហើយក៏មិននិយាយជាមួយនឹងភ្នាក់ងារអចលនទ្រព្យអំពីរឿងផ្ទះទៀតដែរ!»

ក៏ប៉ុន្តែនៅយប់មួយ មានរឿងគួរឱ្យចាប់អារម្មណ៍មួយបានកើតឡើង។ កូនស្រីរបស់ពួកគេដែលមានអាយុបួនឆ្នាំនៅពេលនោះ បាននិយាយទៅពួកគេពេលពួកគេដើរចូលផ្ទះថា «ម៉ាក់ យើងដល់ពេលរើផ្ទះហើយ។» អេមីក៏សួរកូនថា «កូនចង់និយាយពីអ្វីកូន?» កូនស្រីអាយុបួនឆ្នាំរបស់គាត់និយាយឡើង «ដល់ពេលត្រូវរើទៅផ្ទះដែលមានជណ្តើរឡើងទៅបន្ទប់កូនដែលធំជាងនេះហើយ» អេមីក៏សួរកូនទៀតថា «ផ្ទះណាទៅកូន? តើកូនបានយល់សប្តិឃើញមែនទេ?»។ កូនស្រីរបស់គាត់ក៏និយាយថានាងបានយល់សប្តិឃើញមែន។ មែនហើយ នៅយប់នោះឯងបន្ទាប់ពីពួកគេបានដាក់កូនៗឱ្យចូលគេងហើយ អេមីហាក់នៅតែនឹកឃើញពីការសន្ទនានោះ ហើយគាត់បានប្រាប់ទៅ ជេសិន ថាប្រហែលជាពួកគេគួរតែរកមើលផ្ទះតាមអនឡាញ។

មែនហើយ ជាក់ស្តែងមានផ្ទះដែលត្រូវគេរឹបអូសមួយ ដែលគេទើបតែដាក់លក់ជាផ្ទះពីជាន់នៅលើដី ៤ហិចតា ដែលមានបឹងមួយនៅពីមុខផ្ទះនោះ។ ទោះជាយ៉ាងនេះក្តីផ្ទះនោះគឺមានតម្លៃ ២៦,០០០ដុល្លារលើសពីតម្លៃជាមធ្យមទូទៅ ៣០០,០០០ដុល្លារដែលពួកគេបានធ្វើការសាបព្រោះដើម្បីវា។ ពួកគេយល់ឃើញថាគេគង់តែអាចសុំការបញ្ចុះតម្លៃបានដូច្នេះហើយពួកគេបានទាក់ទងទៅភ្នាក់ងារអចលនទ្រព្យ។ ភ្នាក់ងាររបស់ពួកគេបានចេញទៅរដ្ឋផ្លរីដា (Florida) នៅថ្ងៃបន្ទាប់ ក៏ប៉ុន្តែគេអាចត្រឹមតែបង្ហាញឱ្យពួកគេចូលមើលផ្ទះ

នោះមុនគេនៅពេលព្រឹកម៉ោងប្រមាណ ៩ព្រឹកប៉ុណ្ណោះ។ ជេសិន និងអេមី បានប្រាប់ថាពួកគេអាចជួបភ្នាក់ងារបាននៅទីនោះ។

ភ្នាក់ងារនោះបានចេញទៅដល់ផ្ទះនោះឃើត ក៏ប៉ុន្តែមើលទៅផ្ទះនោះដូចជាល្អឥតទាស់។ ដោយរួមមានកាមេរ៉ាសុវត្ថិភាពនៅគ្រប់ជ្រុងក្នុងផ្ទះ ទំហំដី ៤ហិចតា និងមានបឹងនៅខាងមុខផ្ទះ អ្វីៗគ្រប់យ៉ាងហាក់ដូចជាល្អឥតទាស់ទេ។ រង្វាន់បន្ថែមដែលទទួលបានពីលើនេះគឺថាមានដើម្បីព័ទ្ធជុំវិញផ្ទះទាំងមូលនោះ វាពិតជាគួរឱ្យរំភើបចិត្តមែនទែន។ ពេលពួកគេដើរចូលក្នុងផ្ទះកូនស្រីរបស់ពួកគេបានបន្លឺសំឡេងឡើង ហើយនាងបានរត់ឡើងទៅលើជណ្តើររាងគួចខ្យងដ៏ធំតម្រង់ទៅបន្ទប់របស់នាង។ និយាយឱ្យខ្លីទៅ ជេសិន និងអេមីបាននិយាយថាពួកគេចង់សុំសំណូមពរមួយ។ នៅព្រឹកនោះក្រោយពេលភ្នាក់បានពិនិត្យមើលព័ត៌មានលម្អិតពីផ្ទះរួចហើយ នាងបានដឹងថារាល់សំណូមពរទាំងអស់នឹងត្រូវផ្តល់ជូននៅពេលថ្ងៃ។ ពេលថ្ងៃនោះគឺនៅមិនដល់មួយម៉ោងផង! ប្រសិនបើកូនស្រីអាយុបួនឆ្នាំរបស់ពួកគេមិនបានប្រាប់ពីសុបិនរបស់នាងទេនោះ ហើយប្រសិនបើពួកគេមិនមើលព័ត៌មានតាមអនឡាញនៅយប់នោះទេ ផ្ទះនោះមុខជាត្រូវគេទិញបាត់ទៅហើយ។

ពួកគេបានស្នើសុំការដេញថ្លៃក្នុងតម្លៃ ៣២៦,០០០ដុល្លារ ហើយក៏ឈ្នះការដេញថ្លៃនោះ។ ពួកគេពិតជារំភើបណាស់។ ក្នុងអំឡុងពេលត្រួតពិនិត្យ ទោះបីជាដំបូលមើលទៅដូចជាមានរូបរាងសមរម្យមែន អ្នកត្រួតពិនិត្យបានប្រាប់វានឹងត្រូវការផ្លាស់ប្តូរនៅក្នុងពេល ៥ឆ្នាំខាងមុខ ឬអំឡុងពេលស្របាលនេះ។ ជេសិន មានគំនិតមួយ។ គាត់សម្រេចចិត្តថាសុំឱ្យធនាគារបញ្ចុះតម្លៃបន្តិចទៀតដោយសារតែគាត់ត្រូវការជួសជុលដំបូលនៅពេលក្រោយនោះ។ ភ្នាក់របស់ពួកគេបានប្រាប់ថាកុំព្យាយាមស្នើសុំឡើយ ផ្ទះនោះនឹងត្រូវគេប្រគល់ជូនដូច «បានកំណត់រួចហើយ» ហើយនាងក៏មិនធ្លាប់ឃើញធនាគារមួយណាបញ្ចុះតម្លៃចំពោះផ្ទះដែលគេរឹបអូសដោយសារតែការខូចខាតនៅក្នុងផ្ទះនោះឡើយ។ ក៏ប៉ុន្តែជេសិន និងអេមីបានទទួលអារម្មណ៍នៅក្នុងវិញ្ញាណរបស់ពួកគេឱ្យសរសេរសំបុត្រមួយច្បាប់ និងសុំឱ្យធនាគារធ្វើការបញ្ចុះតម្លៃសម្រាប់ពួកគេ។ អ្នកមុខជាភ្ញាក់ផ្អើលមិនខានទេ គឺថាធនាគារបានបញ្ចុះតម្លៃផ្ទះឱ្យពួកគេនៅសល់ត្រឹមតែ ២៩៦,០០០ដុល្លារ គឺទាបជាង ៣០០,០០០ដុល្លារដែលជាទឹកប្រាក់ដែលពួកគេជឿថាគឺព្រះជាម្ចាស់បានឱ្យពួកគេចំណាយ។ ព្រះជាម្ចាស់បាននាំផ្ទះនេះមក ដូចអ្វីដែលពួកគេបានសុំឱ្យទ្រង់ធ្វើ។ ពេលពួកគេសួរអ្នកវាយតម្លៃផ្ទះថាគេ

គិតថាផ្ទះនោះមានតម្លៃប៉ុន្មាន គាត់បាននិយាយថា «៥០០,០០០ដុល្លារ»។ មិត្តអ្នកអាន អើយ តម្លៃនោះគឺជាតម្លៃមួយទ្វេរជាពីរឯណោះ!

ដូចអ្នកអាចមើលឃើញនេះ កូនៗរបស់ខ្ញុំទាំងអស់គ្នារីករាយជាមួយនឹងរបៀបនៃព្រះរាជ្យក្នុងការរស់នៅ។ ជាក់ស្តែង កូនពៅរបស់ខ្ញុំឈ្មោះ ខឺស្ទិន (Kirsten) ទើបតែទិញផ្ទះមួយដោយប្រើលុយសុទ្ធសម្រាប់ផ្ទះទីមួយរបស់នាងក្នុងឆ្នាំនេះក្នុងដែលនាងមានអាយុខ្ទង់ ២០នៅឡើយ។ តើវាកើតឡើងយ៉ាងដូចម្តេចទៅ? ពួកគេទាំងអស់គ្នាដឹងពីរបៀបធ្វើវាតាមរបៀបរបស់ព្រះរាជ្យ!

# ជំពូក ៨

# ចំណែកទ្វេដង

ពេលនេះ ខ្ញុំចង់ដឹកកកាយឱ្យជ្រៅបន្តិចអំពីរបៀបដែលការសម្រាកនៅថ្ងៃសប្ប័ទដំណើរការយ៉ាងពិតប្រាកដ និងនិយាយអំពីរបៀបដែលអាចយកវាមកប្រើនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នក។ ខ្ញុំចង់និយាយត្រឡប់ទៅដល់សាច់រឿងរបស់យើងនៅក្នុងឆ្នាំមេត្តាករុណា និងក្រឡេកមើលអត្ថបទរបស់យើង។ នៅត្រង់នោះហើយដែលយើងបានរកឃើញនូវចម្លើយរបស់ព្រះជាម្ចាស់ចំពោះមនុស្សនៅពេលដែលពួកគេចោទសួរពីរបៀបដែលពួកគេត្រូវរស់នៅដោយគ្មានការប្រមូលផលអស់រយៈពេលបីឆ្នាំ។ ជាសំណួរល្អមែន!

*ប្រសិនបើអ្នករាល់គ្នាពោលថា “នៅឆ្នាំទីប្រាំពីរ តើពួកយើងនឹងបានអ្វីបរិភោគ បើពួកយើងមិនសាបព្រោះ មិនច្រូតកាត់ដូច្នេះ!”។ នៅឆ្នាំទីប្រាំមួយ យើងនឹងឱ្យពរអ្នករាល់គ្នា គឺក្នុងឆ្នាំនោះ អ្នករាល់គ្នានឹងទទួលភោគផលគ្រប់គ្រាន់សម្រាប់បីឆ្នាំ។ អ្នករាល់គ្នាសាបព្រោះសាជាថ្មី នៅឆ្នាំទីប្រាំបី តែអ្នករាល់គ្នាបរិភោគផលដែលប្រមូលបានពីមុន រហូតដល់ឆ្នាំទីប្រាំបួន។ អ្នករាល់គ្នាត្រូវបរិភោគផលចាស់ រហូតទាល់តែបានទទួលភោគផលថ្មី។*

*លេវីវិន័យ ២៥:២០-២២*

យើងមើលឃើញក្នុងអត្ថបទនេះថា ឆ្នាំមេត្តករុណា ក៏ដូចជាឆ្នាំសប្ប័ទមុនឆ្នាំនោះគឺសុទ្ធតែអាចទៅរួចទាំងពីរ ដោយសារតែមានការប្រមូលផលយ៉ាងច្រើននៅក្នុងឆ្នាំទីប្រាំមួយ ករណីនេះគឺជាឆ្នាំទីសែសិបប្រាំបី (រាប់ចាប់តាំងពីឆ្នាំសោមនស្សចុងក្រោយ)។ បើគ្មានការប្រមូលផលដ៏ច្រើនបែបនោះទេ នោះការសម្រាកនៅថ្ងៃសប្ប័ទក៏មិនអាចធ្វើទៅបានដែរ។ ចូរយើងងាកមកមើលអត្ថបទគម្ពីរមួយទៀត ដែលខ្ញុំជឿថាខគម្ពីរនេះនឹងជួយបញ្ជាក់ចំណុចនេះបានកាន់តែស៊ីជម្រៅថែមទៀត។

*ចាប់ពីពេលនោះមក រៀងរាល់ព្រឹក ពួកគេរើសអាហារល្មមដែលខ្លួនអាចបរិភោគឆ្អែត។ ពេលថ្ងៃរះពេញកម្ដៅ អាហារដែលនៅសល់ក៏រលាយបាត់អស់។ នៅថ្ងៃទីប្រាំមួយ ពួកគេរើសអាហារពីរដងច្រើនជាង គឺពីរកូនល្អីក្នុងម្នាក់ៗ។ មេដឹកនាំទាំងអស់របស់សហគមន៍មករាយការណ៍ជម្រាបលោកម៉ូសេ។ លោកប្រាប់ពួកគេវិញថា៖ «ព្រះអម្ចាស់បានបញ្ជាមកដូច្នេះមែន។ ស្អែកជាថ្ងៃសប្ប័ទ ជាថ្ងៃដ៏វិសុទ្ធដែលត្រូវញែកថ្វាយព្រះអម្ចាស់ ចូរចម្អិនអ្វីដែលអ្នករាល់គ្នាត្រូវចម្អិន ចូរស្ងោរអ្វីដែលអ្នករាល់គ្នាត្រូវស្ងោរ ហើយទុកអាហារដែលលើសរហូតព្រឹកស្អែក»។*

*ដូច្នេះ ពួកគេទុកអាហាររហូតដល់ព្រឹកស្អែក តាមបង្គាប់របស់លោកម៉ូសេ។ អាហារទាំងនោះពុំមានស្អុយរលួយ ឬមានដង្កូវចោះឡើយ។ លោកម៉ូសេមានប្រសាសន៍ថា៖ «ថ្ងៃនេះ ចូរបរិភោគអាហារទាំងនេះចុះ ដ្បិតថ្ងៃនេះជាថ្ងៃសប្ប័ទ សម្រាប់គោរពព្រះអម្ចាស់។ ថ្ងៃនេះ អ្នករាល់គ្នានឹងពុំឃើញមានអ្វីនៅខាងក្រៅទេ។ អ្នករាល់គ្នាអាចរើសអាហារនេះក្នុងរយៈពេលប្រាំមួយថ្ងៃ ប៉ុន្តែនៅថ្ងៃទីប្រាំពីរ ដែលជាថ្ងៃសប្ប័ទនឹងគ្មានអ្វីរើសទេ»។*

*ទោះជាយ៉ាងនេះក្ដី នៅថ្ងៃទីប្រាំពីរ ក៏មានប្រជាជនខ្លះចេញពីជំរំ ដើម្បីទៅរើសអាហារ តែពួកគេរកពុំបានសោះ។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «តើអ្នករាល់គ្នានៅតែពុំព្រមស្ដាប់បទបញ្ជា និងវិន័យរបស់យើងដល់កាលណាទៀត? ត្រូវចងចាំថា យើងជាព្រះអម្ចាស់ បានប្រគល់ថ្ងៃសប្ប័ទឱ្យអ្នករាល់គ្នា ហេតុនេះហើយបានជានៅថ្ងៃទីប្រាំមួយ យើងឱ្យអ្នករាល់គ្នាមានអាហារមួយជាពីរ។ នៅថ្ងៃទីប្រាំពីរ ម្នាក់ៗនៅក្នុងជំរំរបស់ខ្លួន គឺមិនត្រូវចេញទៅក្រៅឡើយ»។ ហេតុនេះ ប្រជាជននាំគ្នាឈប់សម្រាក នៅថ្ងៃទីប្រាំពីរ។*

និក្ខមនំ ១៦:២១-៣០ (នំម៉ាណា)

ជាការពិតណាស់ អត្ថបទនេះកំពុងនិយាយអំពីនំម៉ាណាដែលបានធ្លាក់ពីស្ថានលើជារៀងរាល់ថ្ងៃថ្ងៃដើម្បីចិញ្ចឹមមនុស្ស ហើយក៏មានការពណ៌នាថា នៅថ្ងៃទីប្រាំពីរដែលជាថ្ងៃសប្ប័ទនឹងមិនមាននំនេះធ្លាក់មកទេ។ ដោយសារនំនោះទុកបានតែមួយគ្លែត នោះពួកគេមិនអាចរក្សាទុកវាពីមួយថ្ងៃទៅមួយថ្ងៃទៀតទេ។ គឺមានតែនៅថ្ងៃទីប្រាំមួយប៉ុណ្ណោះដែលពួកគេអាចប្រមូលវា និងរក្សាទុកលើសមួយយប់ដោយគ្មានខូចគុណភាព។ យើងឃើញ

មានចំណុចគួរឱ្យកត់សម្គាល់មួយដែលបានចែងក្នុងគម្ពីរ**ទុតិយកថា ៨:៦** ដែលសរសេរទាក់ទងនឹងមូលហេតុដែលនំម៉ាណាឆាប់ខូចគុណភាពយ៉ាងឆាប់។

*ព្រះអង្គប្រទាននំម៉ាណាឱ្យអ្នកបរិភោគ ជាអាហារដែលដូនតារបស់អ្នកពុំធ្លាប់ស្គាល់។ ព្រះអង្គធ្វើឱ្យអ្នកជួបទុក្ខលំបាក និងល្បងលអ្នកដូច្នេះ ដើម្បីប្រទានពរអ្នកនៅពេលក្រោយ។*

ជាការពិតណាស់ថា ព្រះជាម្ចាស់កំពុងតែបណ្តុះបណ្តាលជាតិសាសន៍នោះឱ្យសម្លឹងមើលទៅរកព្រះអង្គជារៀងរាល់ថ្ងៃដើម្បីបានម្ហូបអាហាររបស់ពួកគេ ប៉ុន្តែមិនមែនតែអាហារតែមួយមុខទេ ពោលគឺគ្រប់អ្វីៗទាំងអស់នៅក្នុងជីវិតរបស់ពួកគេផងដែរ។ ព្រះជាម្ចាស់ជ្រាបថា ពួកគេកំពុងតែតម្រង់ឆ្ពោះទៅមុខ ច្រើនជាងការដែលត្រឹមតែត្រូវការអាហារ។ ក្នុងពេលដ៏ខ្លី ពួកគេនឹងបានពើបប្រទះនឹងក្រុងដែលមានជញ្ជាំងមាំ និងមនុស្សមាឌធំ។ ដោយការស្ថិតក្នុងស្ថានភាពនោះ ការពឹងផ្អែករបស់ពួកគេលើព្រះអង្គ ប្រាកដជាមានភាពខុសគ្នាដូចមេឃនិងដីហើយ។

ចូរយើងត្រឡប់ទៅមើលគម្ពីរ**និក្ខមនំ ១៦:២៩** វិញ។ ត្រង់ចំណុចនេះ អ្នកអាចមើលឃើញយ៉ាងច្បាស់ថា ការសម្រាកនៅថ្ងៃសប្ប័ទ គឺអាចធ្វើទៅបានតែក្នុងការមានចំណែកទ្វេដងដែលត្រូវបានប្រទានឱ្យពួកគេនៅថ្ងៃទីប្រាំមួយប៉ុណ្ណោះ។

*ត្រូវចងចាំថា យើងជាព្រះអម្ចាស់ បានប្រគល់ថ្ងៃសប្ប័ទឱ្យអ្នករាល់គ្នា ហេតុនេះហើយបានជានៅថ្ងៃទីប្រាំមួយ យើងឱ្យអ្នករាល់គ្នាមានអាហារមួយជាពីរ។ នៅថ្ងៃទីប្រាំពីរ ម្នាក់ៗនៅក្នុងជំរំរបស់ខ្លួន គឺមិនត្រូវចេញទៅក្រៅឡើយ»។*

អ្នកឃើញទេ? ការសម្រាកនៅថ្ងៃសប្ប័ទគឺអាចធ្វើទៅបានដោយការមានចំណែកទ្វេដងប៉ុណ្ណោះ។ ការនេះសំខាន់ខ្លាំងណាស់ ហើយខ្ញុំចង់ឱ្យអ្នកកត់ចំណាំនូវចំណុចនេះទុក។

ការសម្រាកនៅថ្ងៃសប្ប័ទមិនអាចធ្វើទៅបានដោយគ្មានចំណែកទ្វេដងឡើយ!

ខ្ញុំសូមនិយាយពីចំណុចនេះក្នុងបរិបទមួយផ្សេងទៀត។ បើអ្នកអ្នកមិនមានវាលើសពីគ្រប់គ្រាន់ទេ នោះអ្នកនឹងមិនអាចមានការសម្រាកពីការប្រឹងរត់ប្រណាំងទាំងបែកញើសតាមប្រព័ន្ធនៃបណ្តាសាលោកិយនេះឡើយ។ ដូចគ្រ្ទិនដា និងខ្ញុំប្រាប់មនុស្សនៅគ្រប់ទីកន្លែងដែលពួកយើងទៅអឺចឹង «បើអ្នកមិនដោះស្រាយរឿងប្រាក់កាក់ទេ នោះអ្នកនឹងមិន

អាចរកឃើញជោគវាសនារបស់ខ្លួនឡើយ!» តើហេតុអ្វីទៅ? ពីព្រោះបើមិនមានគ្រប់គ្រាន់ទេ អ្នកនឹងមិនមានជម្រើស ហើយអ្នកនឹងធ្វើជាទាសករពេញមួយជីវិត ដើម្បីបានត្រឹមតែមួយរស់។

អ្នកនៅចាំបានទេ នៅពេលដែលយើងបានអានអំពីសារៈសំខាន់នៃព្រះពររបស់អប្រាហាំដែលមានចែងក្នុងគម្ពីរទុតិយកថា ២៨:១១-១៣ ដែលបានសរសេរនៅក្នុងផ្នែកដំបូងនៃមេរៀន។

*ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានឱ្យអ្នកបានចម្រុងចម្រើន ដោយធ្វើឱ្យពូជពង្សរបស់អ្នក និងហ្វូងសត្វរបស់អ្នកកើនចំនួនច្រើនឡើង ហើយក៏ធ្វើឱ្យអ្នកទទួលភោគផលជាច្រើន នៅលើទឹកដីដែលព្រះអង្គបានសន្យាដល់បុព្វបុរសថាប្រទានឱ្យអ្នកដែរ។ ព្រះអម្ចាស់នឹងបើកផ្ទៃមេឃ បង្អុរភ្លៀងចុះមកស្រោចស្រពទឹកដីរបស់អ្នក តាមរដូវកាល ដើម្បីប្រទានពរដល់កិច្ចការទាំងប៉ុន្មានដែលអ្នកធ្វើ។ អ្នកនឹងឱ្យទ្រព្យដល់ប្រជាជាតិជាច្រើនខ្ចី តែអ្នកមិនខ្ចីពីគេឡើយ។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងធ្វើឱ្យអ្នកបានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ អ្នកនឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច គឺមិនចុះឱនថយឡើយ។ ប៉ុន្តែ អ្នកត្រូវស្ដាប់បង្គាប់ ហើយកាន់ និងប្រតិបត្តិតាមបទបញ្ជារបស់ព្រះអង្គ ដែលខ្ញុំប្រគល់ឱ្យអ្នកនៅថ្ងៃនេះ។*

ទុតិយកថា ២៨:១១-១៣

ភាពក្រីក្រ ការប្រឹងរស់ និងការខ្ស័យទុន មិនមែនជាជោគវាសនារបស់អ្នកទេ។ អ្នកត្រូវតែជាអ្នកផ្ដល់កម្ចី មិនមែនជាអ្នកសុំខ្ចីពីគេ ជាក្បាល មិនមែនជាកន្ទុយឡើយ! លក្ខណៈសម្បូរហូរហៀរគឺជាលក្ខណៈនៃព្រះរាជ្យព្រះ។ នេះជាការសម្រាកនៅថ្ងៃសប្ប័ទ ជាការមានលើសពីគ្រប់គ្រាន់ ជាចំណែកទ្វេដង!

ខ្ញុំដឹងថាអ្នកកំពុងគិតអ្វី «បើអ៊ីចឹងប្រាកដជាល្អហើយហ្គារីអើយ ប៉ុន្តែជីវិតខ្ញុំពេលនេះមិនដូច្នេះឡើយ។» វាមិនអីទេ យើងមិនសម្លឹងមើលទៅក្រោយឡើយ តែយើងកំពុងសម្លឹងមើលទៅអ្វីដែលព្រះជាម្ចាស់មានបន្ទូល និងកំពុងរំពឹងពីអ្វីដែលព្រះរាជ្យនៃព្រះបានចែងអំពីយើង។ បើគ្មានរូបភាពជាក់លាក់ ដែលជាការស្គាល់នូវអ្វីដែលជាលក្ខណៈនៃជីវិតយើងគួរតែមានទេ នោះយើងនឹងធ្លាក់ចូលក្នុងកលល្បិច និងអន្ទាក់ ព្រមទាំងធ្លាក់ចូលក្នុង

ការគិតបែបផ្លូវអាក្រក់របស់ប្រព័ន្ធនៃបណ្ដាសាលោកិយជាមិនខាន។ ជំនឿកំពុងតែមានភាពស្របទៅនឹងអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលហើយ គឺមិនមែនស្របនឹងកាលៈទេសៈរបស់យើងទេ។

មុននឹងឈានដល់ការចែករំលែកអំពីរបៀបដែលព្រះជាម្ចាស់បានបង្រៀនឌ្រិនដា និងខ្ញុំអំពីចំណែកទ្វេដង នោះខ្ញុំចង់ចែករំលែកប្រាប់ដល់អ្នកនូវសាច់រឿងមួយក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ដែលខ្ញុំជឿថា វាជារឿងដ៏អស្ចារ្យបំផុតអំពីចំណែកទ្វេដង។

សាច់រឿងដែលខ្ញុំចង់ប្រាប់អ្នកនៅពេលនេះគឺជារឿងមួយដែលអ្នកធ្លាប់បានឮជាច្រើនលើកច្រើនសាមកហើយ តែប្រហែលជាអ្នកមិនបានឮពីវាក្នុងបរិបទនៃចំណែកទ្វេដង ឬការយល់ដឹងពីព្រះរាជ្យនៃព្រះដែលអ្នកមាននៅពេលនេះ។ សាច់រឿងនេះមានចែងក្នុងគម្ពីរលូកា ជំពូក ១៥ ជាសាច់រឿងស្ដីពីកូនពៅដែលចាយខ្ជះខ្ជាយ។ សូមនៅបន្តអានសាច់រឿងនេះជាមួយខ្ញុំណា។ ខ្ញុំដឹងថាអ្នកធ្លាប់បានអានវាពីមុនមក តែយើងត្រូវអានវាជាមួយគ្នាដោយការយល់ដឹងថ្មីមួយ។

**ជំនឿកំពុងតែមានភាពស្របនឹងអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលហើយ គឺមិនមែនស្របនឹងកាលៈទេសៈរបស់យើងទេ។**

*ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «មានបុរសមួយរូបមានកូនប្រុសពីរនាក់។ កូនពៅនិយាយទៅឪពុកថា “លោកឪពុក! សូមចែកកេរមរតកឱ្យកូនមក” ។ ឪពុកក៏ចែកមរតកឱ្យកូន។ ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិរួចចាកចេញទៅស្រុកឆ្ងាយ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយបង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ។ ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្ដើមខ្វះខាត។ គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ គេប្រើគាត់ឱ្យមើលជ្រូកតាមស្រែចម្ការ។ គាត់ចង់ចម្អែតក្រពះនឹងចំណីដែលគេដាក់ឱ្យជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឱ្យបរិភោគឡើយ។*

*ពេលនោះ កូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា “អ្នកបម្រើរបស់ឪពុកអញសុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជម្រាប*

*គាត់ថា លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ សូមលោកឪពុកចាត់ទុកកូនជាអ្នកបម្រើចុះ”។ លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។*

*កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។ កូនពៅជម្រាបឪពុកថា “លោកឪពុកកូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ”។*

*ឪពុកប្រាប់ពួកអ្នកបម្រើថា “ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុត មកពាក់ឱ្យកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើង មកពាក់ឱ្យផង។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឱ្យសប្បាយចុះ ដ្បិតកូនខ្ញុំនេះបានស្លាប់ទៅហើយ តែឥឡូវរស់ឡើងវិញ វាវង្វេងបាត់ តែឥឡូវនេះ ខ្ញុំរកឃើញវិញហើយ”។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ។*

*ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រឡប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចម្រៀងរបាំ គាត់ហៅអ្នកបម្រើម្នាក់មកសួរថា មានការអ្វីកើតឡើង។ អ្នកបម្រើឆ្លើយថា “ប្អូនលោកត្រឡប់មកវិញហើយ។ ឪពុករបស់លោកឱ្យគេកាប់កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រឡប់មកវិញដោយសុខសាន្ត”។*

*កូនច្បងខឹងណាស់មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរឱ្យចូល។ កូនច្បងនិយាយទៅឪពុកថា “ខ្ញុំបាននៅបម្រើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបទបញ្ជារបស់លោកត្រង់ណាឡើយ តែលោកមិនដែលឱ្យកូនពពែ ដើម្បីឱ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង។*

*ពេលកូនលោកត្រឡប់មកវិញ លោកបានកាប់កូនគោបំប៉នទទួលវា មើល៍ វានេះបានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី”។*

*ឪពុកនិយាយទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះ រស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះ យើងរកឃើញវិញហើយ»។*

លូកា ១៥:១១-៣២

នៅក្នុងសាច់រឿងនេះ យើងមើលឃើញថា កូនប្អូនបានចាកចេញពីផ្ទះដោយយកជាមួយនូវចំណែកនៃទ្រព្យសម្បត្តិរបស់ខ្លួន។ នេះជាសេចក្ដីលម្អិតដ៏សំខាន់អំពីសាច់រឿងនេះ ដ្បិតវានិយាយសំដៅលើចំណែកនៃមរតករបស់គាត់។ ចូរសម្គាល់ថា កូនប្រុសពៅនេះបានទទួលចំណែកនៃមរតករបស់ខ្លួនរួចទៅហើយ គាត់មិនបានទាមទារនូវចំណែកនៃទ្រព្យសម្បត្តិបន្ថែមទៀតទេ។

*កូនពៅនិយាយទៅឪពុកថា "លោកឪពុក! សូមចែកកេរមរតកឱ្យកូនមក"។ ឪពុកក៏ចែកមរតកឱ្យកូន។*

ចំណុចបន្ទាប់មកទៀត សាច់រឿងនេះក៏បានប្រាប់យើងពីកន្លែងដែលកូនប្រុសពៅនេះបានទៅ៖ ទៅស្រុកឆ្ងាយ។ វាជាការសំខាន់ដែលអ្នកយល់ថា កូនពៅនេះបានចេកចេញពីផ្ទះឪពុក ដោយបញ្ជាក់ថាគាត់បានបោះបង់ចោលនូវការផ្គត់ផ្គង់ ការការពាររបស់ខ្លួន និងច្បាប់របស់ប្រទេសដែលមាននៅលើទឹកដីស្រុកឪពុកខ្លួន។ គាត់បានចាចចេញទៅស្រុកឆ្ងាយ ដែលជាទីដែលមានច្បាប់ផ្សេងគ្នា និងមានបែបផែនជីវិតផ្សេងគ្នា។ ខ្ញុំមិនប្រាកដទេថាតើកូនពៅនេះពិតជាមិនដឹងថាខ្លួនកំពុងធ្វើអ្វីឬយ៉ាងណា។ ខណៈពេលដែលខ្លួនកំពុងរស់នៅក្នុងផ្ទះរបស់ឪពុក គាត់រីករាយនឹងអត្ថប្រយោជន៍នៃភាពជាកូនប្រុស។ ពេលគាត់កំពុងរស់នៅទីនោះ អ្វីៗទាំងអស់ដែលឪពុកមាន គឺសុទ្ធតែអាចយកបានទាំងអស់។ ប៉ុន្តែដោយមូលហេតុមួយចំនួន គាត់ក៏មានអារម្មណ៍ថា ខ្លួនហាក់ដូចជាខ្វះអ្វីម៉្យាង ដែលគាត់ត្រូវបានបោកបញ្ឆោតដោយឱកាសដែលមាននៅកន្លែងផ្សេងទៀត។

នៅក្នុងភាពពិតជាក់ស្ដែង ប្រសិនបើអ្នកមិនបានរកឃើញ នោះព្រះយេស៊ូកំពុងប្រាប់យើងពីសាច់រឿងនៃមនុស្សលោក ជាសាច់រឿងរបស់អដាំ។ នៅក្នុងសាច់រឿងនេះ អដាំជាកូនប្រុសពៅដែលបានចាកចេញពីផ្ទះឪពុក។ អដាំជាម្នាក់ដែលយល់ថា គាត់នឹងមានអនាគតប្រសើរជាងនេះបើទៅកន្លែងណាមួយក្រៅពីការត្រឹមនៅបន្តបម្រើព្រះជាម្ចាស់ ដែល

ជាឪពុករបស់ខ្លួន។ ខ្ញុំដឹងថាអ្នកកំពុងគិតថា «អ៊ីចឹង ប្រសិនបើអដាំជាកូនពៅ តើក្នុងសាច់រឿងនោះ នរណាជាកូនច្បងដែលនៅបន្តស្នាក់នៅក្នុងផ្ទះ?» ខ្ញុំនឹងបង្ហាញចម្លើយនៃសំណួរនេះនៅផ្នែកខាងចុងនៃការពិភាក្សានេះ តែសម្រាប់ពេលនេះ យើងគ្រាន់តែចាំថា អដាំជាកូនពៅដែលបានចាកចេញពីផ្ទះ។

ទោះជាអដាំ និងអេវ៉ាមានអ្វីគ្រប់យ៉ាង ក៏ពួកគេត្រូវបានបញ្ឆោតឱ្យជឿថា នៅកន្លែងផ្សេងទៀតមាននូវអ្វីច្រើនជាងការដែលត្រឹមស្នាក់នៅផ្ទះឪពុក ហើយក៏សម្រេចចិត្តចាកចេញទៅ ដោយគាត់បានងាកមកស្ថិតក្រោមរដ្ឋាភិបាលថ្មី ដែលជាលោកិយថ្មី ដោយមាននូវច្បាប់ប្រតិបត្តិការថ្មី។ ព្រះគម្ពីរហៅវាថា លោកិយនៃភាពងងឹត ដែលត្រូវបានសាតាំងត្រួតត្រា។ ខ្ញុំមិនប្រាកដថាតើអដាំមានអារម្មណ៍ភ័យរន្ធត់ដោយភាពក្រីក្រ និងភាពអស់សង្ឃឹមនៃលោកិយថ្មីនេះឬអត់ទេ។ ជាដំបូង គ្រប់យ៉ាងមើលទៅហាក់ដូចជាអស្ចារ្យណាស់។ ដរាបណាគាត់មានប្រាក់នៅក្នុងដៃ នោះវាការជប់លៀងដ៏ធំមួយ! ប៉ុន្តែដល់ពេលដែលគាត់ដឹងថាខ្លួនបានប្រព្រឹត្តខុស នោះគឺយឺតពេលទៅហើយ។ បន្ទាប់មក ដោយគាត់បានខ្ជះខ្ជាយមរតករបស់ខ្លួនអស់ ទើបគាត់ដឹងថាខ្លួនកំពុងវង្វេង។ ចិត្តរបស់គាត់ដែលធ្លាប់តែពោរពេញដោយនិមិត្ត ពេលនេះបានក៏បានត្រឹមតែផ្ដោតលើកិច្ចការប្រចាំថ្ងៃដើម្បីបានត្រឹមតែធ្វើរស់។ ពោលគឺគ្មានសម្រាប់ថ្ងៃស្អែកឡើយ។ វាបានតែសម្រាប់ថ្ងៃនេះ ហើយថ្ងៃក៏គ្មានអ្វីអាចសន្យាបានឡើយ។

*ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុកឆ្ងាយ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយបង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ។*

ពេលនេះ កូនពៅបានដឹងថាខ្លួនកំពុងនៅក្នុងលោកិយមួយដែលមានភាពខ្វះខាតទាំងស្រុង ជាលោកិយដែលមានតែភាពអត់ឃ្លានយ៉ាងធ្ងន់ធ្ងរ។ កូនប្រុសនេះក៏ព្យាយាមនឹកគិតពីអ្វីដែលខ្លួនកំពុងមើលឃើញ គឺថាមនុស្សម្នាកំពុងតែស្លាប់ដោយភាពអត់ឃ្លាន។ ដោយខ្លួនជាមនុស្សដែលចាកចេញពីផ្ទះដែលមាពភាពសម្បូរសប្បាយ នោះគេពិបាកចិត្តក្នុងការត្រិះរិះពិចារណាពីអ្វីដែលខ្លួនបានឃើញ។ ប៉ុន្តែសេចក្ដីស្រេកឃ្លានដែលកំពុងធ្វើទុក្ខដល់ក្រពះរបស់គាត់ រំឭកគាត់ថា អ្វីដែលគាត់បានឃើញនោះគឺពិតប្រាកដណាស់។ ដើម្បីមានជីវិតរស់នៅ ពេលនេះគាត់ត្រូវបង្ខំចិត្តដើរសុំទាននៅតាមផ្លូវ។ នៅក្នុងលោកិយដ៏ខ្មៅងងឹតនេះ ផែនដីផ្ដល់គោគផលតែបន្លា និងអញ្ចាញប៉ុណ្ណោះ ហើយដើម្បីឱ្យទទួលបានគោគផល គឺមានតែការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា។ ដោយកំពុងត្រូវការជំនួយជាខ្លាំង

ទើបបុរសនោះបានសុំឱ្យគេជួយខ្លួន។ ប៉ុន្តែគ្រប់គ្នាក៏កំពុងស្ថិតក្នុងស្ថានភាពដូចគ្នា។ គ្មាននរណាម្នាក់នឹងដាក់ទានជាច្រើនដល់គាត់នោះទេ ដ្បិតពួកគេក៏សុទ្ធតែកំពុងឆ្លងកាត់នូវគ្រោះទុរ្ភិក្សយ៉ាងធ្ងន់ធ្ងរដូចតែគាត់ដែរ។

ពេលវេលាកំណត់មួយបានកើតឡើងបែបនេះសម្រាប់បុរសវ័យក្មេងនេះ ដែលជារបត់មួយដែលបានជះឥទ្ធិពលមកលើអ្នក និងខ្ញុំ ព្រមទាំងមនុស្សជាតិគ្រប់គ្នាផង។ ជាលើកដំបូងនៅក្នុងជីវិតរបស់ខ្លួន កូនប្រុសពៅក៏បានសុំគេធ្វើជាឈ្នួលបម្រើ ដោយធ្វើការស៊ីឈ្នួល ការធ្វើការពលកម្មដោយកម្លាំងបាយ។ នេះគឺជាការបើកកកាយបង្ហាញពីអត្តសញ្ញាណពិត និងបញ្ជាក់ថាគាត់ជានរណាឱ្យពិតប្រាកដ។ គាត់មិនមែនជាកូនប្រុសរបស់បុរសដ៏មានកិត្យានុភាព ដែលមានកិត្តយស និងទ្រព្យសម្បត្តិទេ គាត់ជាអ្នកយាមគុក ជាអ្នកកាប់សាច់ ឬជាភ្នាក់ងារអចលនវត្ថុ ឬជាអ្នករត់សំបុត្រ និងមានច្រើនទៀត។ ពេលនេះគេស្គាល់តាមរយៈអ្វីដែលគាត់ធ្វើ មិនមែនស្គាល់ពីលក្ខណៈថាគាត់ជានរណានោះទេ! គាត់បានបាត់បង់អត្តសញ្ញាណរបស់ខ្លួនហើយ! ជាការបញ្ជាក់បន្ថែមពីការបាត់បង់អត្តសញ្ញាណរបស់គាត់បន្ថែមទៀត ព្រះយេស៊ូក៏មានបន្ទូលថា គាត់មានការអស់សង្ឃឹមយ៉ាងខ្លាំងរហូតដល់គាត់ទទួលយកការងារជាអ្នកដាក់ចំណីឱ្យសត្វជ្រូកចិញ្ចឹម។ សត្វជ្រូកត្រូវបានសាសន៍យូដាចាត់ទុកថាជាសត្វមិនស្អាត ហើយព្រះយេស៊ូក៏មានបន្ទូលប្រាប់បណ្ដាហ្វូងមនុស្សថា ពេលនេះកូនពៅម្នាក់នេះអស់សង្ឃឹមយ៉ាងខ្លាំងរហូតដល់គាត់បាត់បង់នូវការមើលឃើញពីគោលបំណងជីវិតដែលគាត់អាចធ្លាប់មានពីមុនមក។ ពេលនេះគាត់រស់នៅក្នុងជីវិតដែលមានតែភាពអាម៉ាស់ និងគួរឱ្យស្អប់។ ភាពខ្ពង់ខ្ពស់ដែលគាត់ធ្លាប់មានពេលនេះវាគ្រាន់តែជាការចង់ចាំពីចម្ងាយប៉ុណ្ណោះ។

> *ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្ដើមខ្វះខាត។ គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ គេប្រើគាត់ឱ្យមើលជ្រូកតាមស្រែចម្ការ។ គាត់ចង់ចម្អែតក្រពះនឹងចំណីដែលគេដាក់ឱ្យជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឱ្យបរិភោគឡើយ។*

ខ្ញុំសង្ឃឹមថាអ្នកមើលឃើញនូវភាពស៊ីគ្នាគ្នារវាងសាច់រឿងនេះ និងសាច់រឿងរបស់មនុស្សជាតិនាពេលបច្ចុប្បន្ននេះ។ នៅពេលមនុស្សពីរនាក់ជួបគ្នា តើពួកគេនិយាយពីអ្វី? «តើអ្នកប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមជីវិត?» ឬ «តើអ្នកធ្វើការអ្វីដែរ?» ឬ «តើអ្នកប្រកបការងារអ្វី?» នៅពេលអ្នកសួរនរណាម្នាក់ថាពួកគេជានរណា ជាធម្មតាពួកគេនឹងប្រាប់អ្នកពី

អ្វីដែលពួកគេធ្វើ។ តើហេតុអ្វីទៅ? ព្រោះនៅក្នុងប្រព័ន្ធនៃបណ្ដាសាលោកិយនេះ យើងសុទ្ធតែបានបាត់បង់នូវអត្តសញ្ញាណរបស់ខ្លួន ហើយកំពុងព្យាយាមស្វែងរកវាទាំងវេទនា។ យើងក៏ប្រឹងចម្លងពីអ្នកណាដែលទាក់ទាញចំណាប់អារម្មណ៍ និងមើលទៅហាក់ដូចជាមានភាពសំខាន់។ ទាំងនេះសុទ្ធតែមកពីការសម្រេចចិត្តរបស់អដាំដែលបានចាកចេញពីផ្ទះរបស់ឪពុក។ នៅក្នុងផ្នត់គំនិតនៃការប្រឹងរស់របស់យើង នោះយើងបានបាត់បង់នូវការមើលឃើញពីលក្ខណៈថាយើងជានរណាឱ្យពិតប្រាកដ។ ប៉ុន្តែ ចូរមានចិត្តក្លាហានឡើង កូនពៅនៅក្នុងសាច់រឿងរបស់យើងមិនស្នាក់នៅក្នុងទ្រុងជ្រូកគគ្រិចទៀតទេ។ ហើយបើយើងតាមដានសាច់រឿងបន្តទៀត ខ្ញុំសង្ឃឹមថាអ្នករកឃើញថា ខ្លួនក៏មិនត្រូវការស្នាក់នៅកន្លែងគគ្រិចបែបនោះដែរ។

ព្រះគម្ពីរចែងថា ថ្ងៃមួយកូនពៅបានភ្ញាក់ខ្លួន និងនឹកចាំពីផ្ទះរបស់ឪពុកខ្លួន ដែលសូម្បីតែអ្នកបម្រើក៏មានរបស់បរិភោគមិនខ្វះផង។ ខ្ញុំនឹកស្រមៃដល់សភាពរបស់គាត់ដែលកំពុងឃ្លានខ្លាំងរហូតនឹកដល់អនុស្សាវរីយ៍ដែលធ្លាប់មានអាហារល្អៗបរិភោគ។ លោកហារ៉ូដជាពូរបស់ខ្ញុំ ធ្លាប់ជាអ្នកកាន់ប៉ុស្តិ៍វិទ្យុទាក់ទងដោយបើកយន្តហោះ B-17 ក្នុងអំឡុងសង្គ្រាមលោកលើកទី២។ គាត់មានកំណើតចេញពីសហគមន៍កសិករមួយ និងជាគ្រួសារកសិករ។ ជារៀងរាល់ថ្ងៃអាទិត្យ ម្ដាយរបស់គាត់តែងតែរៀបចំម្ហូបអាហារយ៉ាងច្រើនដូចជា ម៉ាន់បំពង ដំឡូងចៀន នំប៉័ងធ្វើដោយខ្លួនឯង សណ្ដែកខៀវ និងបន្លែដ៏មានរសជាតិឆ្ងាញ់ជាច្រើនមុខទៀត។ ហើយប្រាកដណាស់ថា ពួកគេតែងតែមាននំនែកធ្វើដោយខ្លួនឯងសម្រាប់ជាបង្អែមលាងមាត់ទៀតផង។ ខ្ញុំដឹងដោយផ្ទាល់ថាអាហារទាំងនោះឆ្ងាញ់យ៉ាងណា ពីព្រោះម្ដាយរបស់គាត់ គឺជាលោកយាយរបស់ខ្ញុំ។

យន្តហោះរបស់ពូខ្ញុំត្រូវបានបាញ់ទម្លាក់ដោយពួកអាល្លឺម៉ង់ក្នុងអំឡុងពេលសង្គ្រាម ហើយគាត់បានចំណាយពេលជាច្រើនខែនៅក្នុងជំរំគុកអាល្លឺម៉ង់។ នៅទីនោះ ស្ទើរតែគ្មានអាហារទាល់តែសោះ។ ថ្ងៃមួយ ខ្ញុំបានសួរពូរបស់ខ្ញុំថាតើគាត់អាចរស់រៀនបានយ៉ាងដូចម្ដេចក្នុងពេលវេលាទាំងនោះ ហើយគាត់ក៏បានប្រាប់ខ្ញុំថា អ្វីដែលគាត់នឹងឃើញនោះ គឺគ្មានអ្វីក្រៅពីការមកផ្ទះវិញ រកមើលមាន់បំពង និងដំឡូងចៀនរបស់ម្ដាយគាត់ទេ។ ខ្ញុំជឿជាក់ថា កូនប្រុសពៅនេះក៏មានបទពិសោធស្រដៀងគ្នា ហើយក៏បានដឹងថាខ្លួនបានបាត់បង់អ្វី។ ប៉ុន្តែគាត់មិនបានទាមទារនូវទ្រព្យសម្បត្តិទៀតទេ ដោយខ្លួនបានទទួលនូវអ្វីគ្រប់យ៉ាងដែលជាទ្រព្យសម្បត្តិរបស់ឪពុកគាត់រួយទៅហើយ។ ដូចនេះ គាត់ក៏នឹកឃើញ

ផែនការមួយ។ គាត់នឹងត្រឡប់ទៅផ្ទះវិញ រួចសុំឪពុកឱ្យព្រមជួលគាត់ជាអ្នកបម្រើ។ នៅក្នុងគំនិតរបស់គាត់ មានតែជម្រើសធ្វើការជាកម្មការ ជាអ្នកស៊ីឈ្នួលតែប៉ុណ្ណោះ។

*ពេលនោះ កូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា "អ្នកបម្រើរបស់ឪពុកអញសុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ សូមលោកឪពុកចាត់ទុកកូនជាអ្នកបម្រើចុះ"។ លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។*

ដូចនេះ គាត់ក៏ដើរសំដៅទៅផ្ទះជាមួយផែនការរបស់ខ្លួន និងបានសុំឪពុកទុកឱកាសឱ្យខ្លួនបានធ្វើការដើម្បីប្តូរកន្លែងស្នាក់នៅ និងមានអាហារសម្រាប់បរិភោគ។ ប៉ុន្តែព្រះគម្ពីរក៏បានចែងអំពីលទ្ធផលដ៏អស្ចារ្យមួយនៅក្នុងសាច់រឿងនេះ។ នៅពេលមកដល់ជិតផ្ទះ ឪពុកមើលឃើញកូនពីចម្ងាយ រួចក៏រត់ទៅរកកូនដោយបានឱបកូនយ៉ាងណែន។ ចាប់ពីចំណុចនេះតទៅ សាច់រឿងនេះគួរតែត្រូវបានហៅថា សាច់រឿងនៃសេចក្តីស្រលាញ់របស់ឪពុក ព្រោះថាឪពុកបានឱបកូន បើទោះបីជាកូននោះមានប្រឡាក់ពេញដោយលាមកជ្រូក។ ការធ្វើបែបនេះ ពួកអ្នកស្តាប់ដែលជាសាសន៍យូដាបានដឹងថា ការឱបនេះនឹងធ្វើឱ្យឪពុកនោះមិនបរិសុទ្ធផ្នែកវិញ្ញាណផងដែរ។ ប៉ុន្តែឪពុកសុខចិត្តក្លាយជាមិនបរិសុទ្ធជំនួសកូនប្រុសរបស់ខ្លួន។ ពេលនោះគាត់ក៏បានហៅគេឱ្យយកសម្លៀកបំពាក់ល្អបំផុតដែលគាត់មាន និងពាក់ឱ្យកូនប្រុសរបស់ខ្លួនដើម្បីគ្របលើភាពកក្វក់របស់កូនពៅ។ គាត់ក៏បានយកចិញ្ចៀនត្រា ដែលតំណាងឱ្យសិទ្ធិអំណាចរបស់គាត់ និងបានបំពាក់លើម្រាមដៃកូនប្រុសរបស់គាត់។ គាត់បានផ្តល់ស្បែកជើងឱ្យកូនពាក់ ដែលបញ្ជាក់ថា ពេលនេះគាត់អាចចូលទៅប្រើប្រាស់ទ្រព្យសម្បត្តិទាំងមូលបាន។ ប៉ុន្តែមានរបស់ចុងក្រោយមួយដែលឪពុកបានឱ្យកូនពៅដែលបណ្តាលឱ្យកូនបងខឹងសម្បានោះ។ ឪពុកបានបង្គាប់ឱ្យគេសម្លាប់កូនគោដែលបានបំប៉នទុកមួយក្បាល និងរៀបចំទទួលសម្រាប់ការវិលត្រឡប់របស់កូនប្រុសគាត់។ បើទោះជាមិនស័ក្តិសម កូនប្រុសពៅត្រូវបានផ្តល់មកវិញនូវតួនាទី និងអត្ថប្រយោជន៍នៃភាពជាកូនប្រុស ដោយបានផ្តល់កិត្តិយសដោយបើកចំហ និងដោយសេរីក្នុងនាមជាកូនប្រុស ហើយក៏ត្រូវបានស្តារនូវតួនាទីរបស់ខ្លួនពីមុនដែលជាកូនប្រុសនៅក្នុងផ្ទះនោះ។

ហ្នឹងហើយ ចុះតើការទាំងអស់នេះមានអ្វីពាក់ព័ន្ធនឹងចំណែកទ្វេដង? គឺពាក់ព័ន្ធគ្រប់យ៉ាង។ ព្រះយេស៊ូប្រើសាច់រឿងមួយនេះដោយកូនប្រុសពៅចាកចេញពីផ្ទះ និងវិលត្រឡប់មកផ្ទះវិញ ព្រោះអ្នកស្តាប់ព្រះអង្គ ដែលមានវប្បធម៌បែបយូដា នឹងយល់នូវអ្វីដែលសាច់រឿងនោះចង់បង្ហាញ និងយល់ពីអ្វីដែលខ្ញុំចង់ប្រាប់អ្នក។ នៅក្នុងវប្បធម៌របស់ពួកយូដា កូនប្រុសច្បងនឹងត្រូវទទួលនូវចំណែកទ្វេដងដោយស្វ័យប្រវត្តិ។ អ្នកនៅចាំទេ កូនប្រុសច្បងមិនបានចាកចេញទេ ប៉ុន្តែជាកូនប្រុសពៅទៅវិញទេដែលបានចាកចេញ និងវិលត្រឡប់មកវិញ។ អ្នកក៏នឹងនៅនឹកចាំថា នៅពេលគាត់បានចាកចេញទៅ គាត់បានយកទៅជាមួយគាត់នូវចំណែកស្របច្បាប់នៃទ្រព្យសម្បត្តិ ដែលជាចំណែកស្របច្បាប់។ ពេលនេះគាត់មិនបានទាមទារបន្ថែមនូវទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀតទេ។ ប៉ុន្តែនៅពេលកូនពៅត្រឡប់មកវិញ ហើយឪពុកបានផ្តល់ឋានៈដល់គាត់ជាកូនប្រុសឡើងវិញ ហើយជាពិសេសគាត់បានយកកូនគោដែលបានបំប៉នទុកដើម្បីជប់លៀងអបអរដល់ការវិលត្រឡប់មកវិញរបស់កូនពៅ នោះកូនច្បងក៏មានចិត្តខឹងសម្បា។ កូនប្រុសច្បងគិតក្នុងចិត្តថា កូនគោនោះជាកម្មសិទ្ធិរបស់ខ្លួនទេ ដ្បិតវាជាផ្នែកមួយនៃចំណែកទ្រព្យសម្បត្តិរបស់គាត់។

នេះជាចំណុចសំខាន់ដែលខ្ញុំចង់លើកមកបង្ហាញ។ ទោះបីជាកូនពៅបានទទួលយកចំណែកនៃទ្រព្យសម្បត្តិរួចទៅហើយក៏ពិតមែន ក៏គាត់ត្រូវបានផ្តល់ឋានៈជាកូនប្រុសមកវិញដែរ ហើយពេលនេះគាត់កំពុងរីករាយនឹងចំណែកទីពីររបស់ខ្លួន។ ចំណុចនេះអាចមានន័យថា តាមពិតគាត់បានទទួលនូវចំណែកនៃទ្រព្យសម្បត្តិទ្វេដង។ ចំពោះការយល់ឃើញរបស់កូនច្បង រឿងនេះមិនយុត្តិធម៌ទេ ហើយគាត់ក៏បានប្រាប់ទៅឪពុកដូច្នេះដោយកំហឹង។ គាត់បានអះអាងថា គាត់មានភាពស្មោះត្រង់រហូតមកដោយបានធ្វើការឱ្យឪពុករាប់ឆ្នាំមកនេះ ហើយប្អូនប្រុសពៅម្នាក់នេះមិនបានធ្វើអ្វីក្រៅតែពីធ្វើឱ្យគ្រួសារអាម៉ាស់។ ចុះហេតុអ្វីបានជាគាត់ទទួលបានចំណែកទ្វេដងទៅវិញ?

ដូចនេះ តើវាយុត្តិធម៌ដែរឬទេ? បើតាមការយល់ឃើញបែបប្រព័ន្ធបណ្តាសាលោកិយ ដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា យើងសុទ្ធតែអាចនិយាយថា វាមិនយុត្តិធម៌ទេ។ យើងប្រហែលជាឈរនៅខាងកូនប្រុសច្បងដែលធ្វើការដោយស្មោះត្រង់ ហើយអាចអះអាងពីភាពអយុត្តិធម៌យ៉ាងច្បាស់លាស់អំពីអ្វីដែលគាត់បានធ្វើសម្រាប់ឪពុក។

ប៉ុន្តែ តើយើងវិនិច្ឆ័យថាអ្វីមួយយុត្តិធម៌លើដោយផ្អែកលើមូលដ្ឋានអ្វី? តើមិនមែនជាឪពុកដែលជាអ្នកវិនិច្ឆ័យ និងសម្រេចចិត្តថាគាត់ចង់បង្ហាញការពេញចិត្តចំពោះនរណាទេឬ? ការបណ្តុះបណ្តាលរបស់ប្រព័ន្ធបណ្តាសាលោកិយដែលយើងមាននេះ សុទ្ធតែអាចបញ្ជាក់ថា ប្រសិនបើឪពុកផ្តល់នូវទ្រព្យសម្បត្តិមួយចំណែកទៀតដល់កូនពៅ នោះកូនប្រុសច្បងនឹងមានចំណែកតិចជាងហើយ។ តែនេះមិនមែនជាបញ្ហាទេ។ ឪពុកមានទ្រព្យសម្បត្តិច្រើនណាស់ សូម្បីតែអ្នកបម្រើក៏មានមិនខ្វះដែរ។ ចុះទំរាំតែកូនប្រុសរបស់គាត់វិញ តើនឹងរឹតតែមានច្រើនប៉ុនណាទៅ។

សាតាំងមិនចង់ឱ្យអ្នកដឹងថាព្រះរបស់យើងអស្ចារ្យប៉ុនណា ឬស្គាល់ថាយើងជានរណានោះទេ។ វាកំពុងនិយាយកុហកអំពីព្រះវរបិតារបស់យើងតាំងពីដើមដំបូងមកម្ល៉េះ។ គោលការណ៍ធានារ៉ាប់រងបានបញ្ជាក់ថា នៅពេលមានគ្រោះមហន្តរាយកើតឡើង រឿងទាំងនេះជាប្រធានស័ក្តិ (គ្រោះធម្មជាតិមិនអានគ្រប់គ្រងបាន)។ ស្ថាប័នផ្នែកសាសនាបានអះអាងថា ព្រះជាម្ចាស់សព្វព្រះហឫទ័យអ្វីដែលចាំបាច់គួរតែមាន។ មនុស្សម្នាអះអាងថា ព្រះជាម្ចាស់ធ្វើរឿងអាក្រក់ដាក់មនុស្សល្អ។ ចំណែកសាតាំងចង់ឱ្យអ្នកងងឹតងងល់មើលមិនឃើញថាខ្លួនឯងជានរណា និងគំនិតរបស់អ្នកមើលមិនសូវឃើញថាព្រះវរបិតារបស់យើងអស្ចារ្យប៉ុនណា និងមិនឱ្យត្រឡប់ទៅរកទ្រង់វិញដោយដួងចិត្តរបស់អ្នកទាំងស្រុង។ ខ្ញុំអាចធានាបានថា នៅពេលអ្នកពិតជាត្រឡប់ទៅរកទ្រង់វិញ នោះអ្នកនឹងបានឃើញនូវការទទួលស្វាគមន៍ដូចដែលគេទទួលកូនពៅនៅក្នុងសាច់រឿងនេះដែរ។ អ្នកអាចពោលថា «តើកូនច្បងជានរណា?» តោះ ចាំមើលថាតើអ្នកអាចរកឃើញចំណុចនេះដែរឬទេ។

> *ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រឡប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចម្រៀងរបាំ គាត់ហៅអ្នកបម្រើម្នាក់មកសួរថា មានការអ្វីកើតឡើង។ អ្នកបម្រើឆ្លើយថា "ប្អូនលោកត្រឡប់មកវិញហើយ។ ឪពុករបស់លោកឱ្យគេកាប់កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រឡប់មកវិញដោយសុខសាន្ត"។*

> *កូនច្បងខឹងណាស់មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរឱ្យចូល។ កូនច្បងនិយាយទៅឪពុកថា "ខ្ញុំបាននៅបម្រើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបទបញ្ជារបស់លោកត្រង់ណាឡើយ តែលោកមិនដែលឱ្យកូន*

*ពពែ ដើម្បីឱ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង។*

*ពេលកូនលោកត្រឡប់មកវិញ លោកបានកាប់កូនគោបំប៉នទទួលវាមើល៍ វានេះបានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី"។*

*ឪពុកនិយាយទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះ រស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះ យើងរកឃើញវិញហើយ»។*

**សាតាំងមិនចង់ឱ្យអ្នកដឹងថាព្រះរបស់យើងអស្ចារ្យប៉ុនណា ឬស្គាល់ថាយើងជានរណានោះទេ។**

កូនច្បងនិយាយថា ប៉ុន្មានឆ្នាំមកនេះ គាត់បានប្រឹងប្រែងធ្វើការសម្រាប់ឪពុក ប៉ុន្តែក្នុងអំឡុងពេលនៃការបម្រើនេះ ឪពុករបស់គាត់មិនដែលផ្តល់អ្វីឱ្យសូម្បីតែកូនពពែមួយយកមកជប់លៀងជាមួយមិត្តភក្តិ។ខ្ញុំសូមបកស្រាយអ្វីដែលគាត់និយាយបន្តិច។ «លោកឪពុកអើយ ពុកពិតជាលម្អៀងណាស់!»

ប៉ុន្តែ សូមកត់សម្គាល់ពីអ្វីដែលឪពុកនិយាយត្រឡប់មកវិញ។ «កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។»

ឈប់សិន!!!

ពេលនេះតើអ្នកអាចរកឃើញថាតើកូនច្បងជានរណាទេ? កូនប្រុសច្បងមានភាពរវល់ធ្វើការខ្លាំងពេកសម្រាប់ឪពុករបស់ខ្លួនដោយមាននូវការយល់ខុសអំពីស្វ័យសុចរិតដើម្បីរីករាយនឹងរបស់ល្អៗនៃឪពុករបស់ខ្លួន។

អ្វីគ្រប់យ៉ាងដែលឪពុកមាន សុទ្ធតែជារបស់គាត់ (កូន) ជាយូរមកហើយ។

អ្នកនិយាយត្រូវហើយ កូនច្បងតំណាងឱ្យក្រឹត្យវិន័យនៃសម្ពន្ធមេត្រីដំបូង។ កូនច្បងមិនអាចរីករាយនឹងអត្ថប្រយោជន៍នៃអ្វីដែលមាននៅក្នុងផ្ទះរបស់ឪពុកខ្លួនទេ ព្រោះគាត់រវល់ខ្លាំងពេកមិនមានពេលសុំការអនុញ្ញាតពីឪពុក។ ទោះបីជាកូនច្បងមានសិទ្ធិទទួល

បានចំណែកទ្វេដងក្តី ក៏មានតែកូនពៅទេដែលបានរីករាយនឹងចំណែកនេះយ៉ាងពិតប្រាកដ។

អ្នកគឺជាកូនពៅនោះហើយ!

អ្នកមាននូវចំណែកទ្វេដង។ អ្នកជាកូនប្រុសដែលទទួលបានដោយមិនផ្អែកលើអ្វីដែលអ្នកបានធ្វើទេ តែផ្អែកលើលក្ខណៈថាអ្នកជានរណានៅក្នុងព្រះគ្រិស្ត - ជាបុត្រាបុត្រីនៃព្រះ ដោយរីករាយនឹងមរតកដែលអ្នកមិនចាំបាច់ធ្វើការដើម្បីបានវាមក តែជាការទទួលបានពីបិតារបស់អ្នកដោយឥតគិតថ្លៃ។

# ជំពូក ៩

# បរិបូរហូរហៀរ!

ខ្ញុំអាចយល់បានថាអ្នកអាចនឹងមានអារម្មណ៍ថាមិនគួរឱ្យជឿលើចំណងជើងនៃជំពូកនេះ ក៏ប៉ុន្តែនេះគឺជាកន្លែងដែលអ្នកនឹងធ្វើដំណើរទៅរក គឺទៅរកភាពបរិបូរហូរហៀរ។ មិនមែនដោយសារតែខ្ញុំបង្ហាញឱ្យអ្នកឃើញពីផែនការរកលុយដែលថ្មីជាងគេ និងទាក់ទាញជាងគេទេ ប៉ុន្តែដោយសារតែក្នុងនាមជាបុត្ររបស់ព្រះជាម្ចាស់ វាគឺជាសិទ្ធិស្របច្បាប់របស់អ្នកក្នុងការរីករាយជាមួយនឹងភាពចម្រុងចម្រើននៃព្រះដំណាក់របស់ព្រះបិតាអ្នក។ គោលគំនិតចំណែកទ្វេដង ការមានច្រើនបរិបូហូរហៀរ អាចមើលទៅហាក់ដូចជាមិនអាចនឹងស្រមើស្រមៃទៅរួចបានក្នុងពេលឥលូវនេះទេបើធៀបនឹងកន្លែងដែលអ្នកមើលឃើញខ្លួនអ្នក ក្នុងជីវិតរបស់អ្នកនៅពេលនេះឡើយ។ ក៏ប៉ុន្តែទីនេះគឺជាកន្លែងដែលអ្នកត្រូវតែចាប់ផ្តើមដំណើរទៅរកសេរីភាពរបស់អ្នក - នៅក្នុងការគិតរបស់អ្នក។ ប្រសិនបើគំនិតរបស់អ្នកមិនស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ អ្នកនឹងមិនដែលរីករាយនៅក្នុងអត្ថប្រយោជន៍ពីទ្រង់ឡើយ។ ដូច្នេះហើយសូមសម្លឹងមើលទៅខ្ពស់ជាងអ្វីដែលអ្នកមើលឃើញនៅជុំវិញអ្នក និង

**គោលគំនិតចំណែកទ្វេដង ការមានច្រើនបរិបូហូរហៀរ អាចមើលទៅហាក់ដូចជាមិនអាចនឹងស្រមើស្រមៃទៅរួចបានក្នុងពេលឥលូវនេះទេបើធៀបនឹងកន្លែងដែលអ្នកមើលឃើញខ្លួនអ្នក ក្នុងជីវិតរបស់អ្នកនៅពេលនេះឡើយ។ ក៏ប៉ុន្តែទីនេះគឺជាកន្លែងដែលអ្នកត្រូវតែចាប់ផ្តើមដំណើរទៅរកសេរីភាពរបស់អ្នក - នៅក្នុងការគិតរបស់អ្នក។**

រៀបចំអ្វីៗទាំងនោះតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូលថាជាកម្មសិទ្ធិអ្នកនៅក្នុងព្រះរាជ្យរបស់ទ្រង់។ សូមឈប់ទាស់នឹងអ្វីដែលព្រះជាម្ចាស់កំពុងមានបន្ទូល ដោយគ្រាន់តែអ្នកមើលវាមិនឃើញនៅក្នុងជីវិតរបស់អ្នក។ ផ្ទុយទៅវិញ សូមចាប់ផ្ដើមទាស់ជាមួយនឹងកាលៈទេសៈផ្សេងៗដោយប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយជឿថាកាលៈទេសៈទាំងនោះមុខជាស្របជាមួយនឹងអ្វីទាំងអស់ដែលព្រះជាម្ចាស់មានបន្ទូលថាជារបស់អ្នក។ ខ្ញុំគ្រាន់តែជាមនុស្សម្នាក់ដូចជាអ្នកដែរ ដែលជាធម្មតាខ្ញុំធ្វើអ្វីដែលគេប្រាប់ឱ្យខ្ញុំធ្វើ។ សូមជឿលើអ្វីដែលព្រះជាម្ចាស់មានបន្ទូល! ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបរាជ័យឡើយ ហើយនឹងនាំការផ្លាស់ប្ដូរទៅកាន់កាលៈទេសៈណាមួយ។ ជាក់ស្ដែង នៅទីនេះមានអ៊ីមែលមួយដែលខ្ញុំបានទទួលពីអ្នកស្ដាប់ម្នាក់ដែលជាអ្នកមិនជឿ គាត់ធ្លាប់ឮរឿងទាំងអស់នេះហើយ ឬក៏គាត់មិនធ្លាប់ឮទេ?

«ខ្ញុំនឹងព្យាយាមយករឿងលំបាកៗក្នុងរយៈពេល ២២ឆ្នាំមករ៉ាយរ៉ាប់នៅក្នុងឃ្លាតែពីរបីនេះតាមដែលអាចធ្វើបាន។ ខ្ញុំ និងស្វាមីខ្ញុំទាំងពីរនាក់ធំឡើងក្នុងគ្រួសារគ្រិស្តបរិស័ទ និងបានចូលរួមនៅក្នុងក្រុមជំនុំជាទៀងទាត់។ យើងថែមទាំងបានធ្វើការជាមួយនឹងយុវជន និងថ្នាក់សិក្សាថ្ងៃអាទិត្យជាដើម។ ពេលដែលយើងបានរៀបការ ហិរញ្ញវត្ថុរបស់យើងក្នុងឆ្នាំដំបូងមានសភាពល្អ...នោះគឺកាលពី២២ឆ្នាំមុន។ តាំងពីពេលនោះមកបញ្ហា «រឿងលុយ» បានក្លាយជាប្រភពជាក់ស្ដែងនៃការឈឺចាប់ និងរឿងលំបាក ហើយជំនឿរបស់ខ្ញុំតែងតែមានភាពរអាក់រអួល ដោយសារតែខ្ញុំមិនអាចយល់បានថាហេតុអ្វី រឿងដែលព្រះបន្ទូលថែងថានឹងកើតឡើង មិនកើតឡើងសោះអ៊ីចឹង។ ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់ស្ថិតនៅអស់កល្ប និងមិនចេះរលួយ ហើយបើទ្រង់នៅតែដដែលទាំងម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត អ៊ីចឹងវាផ្ដល់អ្វីឱ្យខ្ញុំទៅ? តើទ្រង់ជាមរណសាក្សី ជាមនុស្សកុហក ឬជាមនុស្សលេលា!

«រហូតឈានចូលមកដល់ថ្ងៃទី ២៨ មករា ឆ្នាំ២០១៣... ខ្ញុំបានប្រាប់ស្វាមីខ្ញុំថា "បើព្រះជាម្ចាស់មិនបង្ហាញខ្លួន គឺទ្រង់មុខជាដើរចេញឆ្ងាយហើយ"... ខ្ញុំឆ្អែតចិត្តនឹងក្រុមជំនុំក៏ដូចជាព្រះជាម្ចាស់ដែរ។ ពេលខ្ញុំចាកចេញពីផ្ទះដោយមានធុរៈមួយចំនួនត្រូវធ្វើ នៅទីបំផុតស្វាមីរបស់ខ្ញុំបានទទួលការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធ និងបានអញ្ជើញមិត្តល្អម្នាក់របស់យើងមកជជែកគ្នា។ បន្ទាប់ពីគាត់ជជែកគ្នាចប់ គាត់បាននិយាយថាគាត់មានអ្វីម៉្យាងសម្រាប់ឱ្យយើងស្ដាប់នោះគឺ - ហ្គារី ឃីស៊ី។ គាត់បានចែករំលែកនូវទីបន្ទាល់អំពីអ្វីដែលកើត

ឡើងចំពោះគាត់។ ដូច្នេះហើយពេលខ្ញុំត្រលប់មកផ្ទះវិញស្វាមីខ្ញុំបានប្រាប់ខ្ញុំពីអ្វីដែលគាត់បាននិយាយ ហើយប្រាប់ថាគាត់នឹងទៅផ្ទះគាត់នៅថ្ងៃបន្ទាប់ដើម្បីទៅយកអ្វីម្យ៉ាងនោះ។

«ខ្ញុំមិនដឹងថាមានអ្វីកើតឡើងទេ (ដោយសារតែខ្ញុំបានស្តាប់វាឆ្អែតឆ្អន់ហើយពេលគ្រូគង្វាល និងគ្រូបង្រៀននិយាយពីអ្វីៗទាំងអស់ទាក់ទងនឹង «រឿងរ៉ាវខាងវិញ្ញាណ») ក៏ប៉ុន្តែខ្ញុំបានទូរស័ព្ទទៅគាត់ និងបានសួរគាត់ក្រែងគាត់មានពេលទំនេរនៅល្ងាចនោះ។ នៅក្នុងបរិយាកាសក្រាលគ្របទៅដោយព្រិលសក្បុសក្នុងយប់នោះ ខ្ញុំក៏បានធ្វើដំណើរទៅដល់ផ្ទះគាត់។ ពេលខ្ញុំកំពុងបើកឡាន ខ្ញុំបានប្រាប់ព្រះជាម្ចាស់ថា «រឿងដែលកូនធ្វើនេះសមតែជារឿងដែលត្រឹមត្រូវ!»

«នៅថ្ងៃបន្ទាប់ យើងបានចាប់ផ្តើមស្តាប់វា ហើយយើងទាំងពីរនាក់មានអារម្មណ៍ថារំភើបយ៉ាងខ្លាំង។ អ្វីៗទាំងអស់បានចាប់ផ្តើមសមហេតុផល។ គ្រប់ទាំងខទាំងអស់៖ ទាំងជំនឿ និងការប្រកាន់ខ្ជាប់នឹងសេចក្តីប្រកាសរបស់អ្នក។ នៅទីបំផុតបំណែកតូចៗទាំងអស់នៃរូបផ្គុំត្រូវបានដាក់ចូលទៅកាន់កន្លែងរបស់វា។ យើងធ្លាប់បានឮពីព្រះរាជ្យនៃព្រះកាលពីពីរបីឆ្នាំមុន <u>ក៏ប៉ុន្តែ</u>គ្មាននរណាម្នាក់រវល់នឹងរឿងបង្រៀនអំពីដំណើរការសោះឡើយ...មិនបង្រៀនពីរបៀបចូលទៅដល់ចំណុច "គឺវានេះហើយ!" ទេ។ មានតែអ្នកនេះហើយដែលបង្រៀនអំពីវា។

«ដូច្នេះហើយភ្លាមៗនោះ យើងបានអនុវត្តអ្វីដែលយើងបានរៀន...កាលនោះយើងត្រូវការលុយសម្រាប់ការទូទាត់ប្រាក់កម្ចីទិញផ្ទះយើង។ កាលនោះគឺជាថ្ងៃព្រហស្បត្តិ៍ ហើយស្វាមីរបស់ខ្ញុំទើបតែបញ្ចប់កិច្ចការតូចៗមួយចំនួននៅឯផ្ទះឪពុកម្តាយខ្ញុំ...ពួកគាត់ចេះតាមសួរខ្ញុំថាតើពួកគេគួរបង់លុយប៉ុន្មានឱ្យទៅស្វាមីខ្ញុំ (ពួកគាត់បានដឹងថាពួកយើងកំពុងតែលំបាក)។ ខ្ញុំបានប្រាប់ពួកគាត់ថា "ប៉ុន្មានក៏បានដែលប៉ាម៉ាក់ចង់ឱ្យទៅគាត់។" លុយនោះមិនគ្រប់សម្រាប់ទូទាត់ប្រាក់កម្ចីទេ...ក៏ប៉ុន្តែវាជាថ្ងៃព្រហស្បត្តិ៍នៅឡើយ។

«នៅថ្ងៃសុក្រយើងបានដាក់កាលវិភាគណាត់ជួបមួយ ដើម្បីជួបជាមួយមិត្តដែលឱ្យយើងខ្ញុំស៊ីឌី។ កាលនោះមានព្យុះព្រិលធំមួយ ក៏ប៉ុន្តែទាំងស្វាមីខ្ញុំ និងខ្ញុំចង់ទៅអង្គុយជជែកជាមួយគាត់អំពីព្រះរាជ្យនៃព្រះ និងរៀបដែលព្រះរាជ្យដំណើរការ។»

«មុនពេលយើងចាកចេញ គាត់ចង់អធិស្ឋាន ហើយគាត់បានប្រគល់មូលប្បទានបត្រមួយសន្លឹកមកឱ្យយើង...ព្រះជាម្ចាស់បានធ្វើឱ្យគាត់រំភើបចិត្តក្នុងការសាបព្រោះនៅក្នុង

ជីវិតយើង។ វាពិតជាធ្វើឱ្យយើងស្រឡាំងកាំងមែនទែន។ បន្ទាប់មកយើងបានបើកមូលប្បទានបត្រនោះមើល...វាមានចំនួនច្រើនបរិបូរហូរហៀរ ដើម្បីទូទាត់ប្រាក់កម្ចីទិញផ្ទះ និងវិក្កយបត្រតូចៗមួយចំនួនផ្សេងទៀតផងដែរ!

«ខ្ញុំបានប្រាប់ស្វាមីខ្ញុំថានេះជាអ្វីដែលខ្ញុំត្រូវការ! ខ្ញុំបានថតរូបមូលប្បទានបត្រទុកដើម្បីរំឭកខ្ញុំពីភាពស្មោះត្រង់របស់ទ្រង់។ ត្រូវហើយ មារសាតាំងមិនចូលចិត្តអ្វីដែលវាបានឃើញទេ ហើយភ្លាមៗនោះ (ព្រះអើយ គឺភ្លាមៗតែនោះតែម្តង!!!!) វាបានព្យាយាមលួចគ្រាប់ពូជរបស់យើង។ យើងបានសម្រេចចិត្តនេះគឺជាសេចក្តីពិត ហើយយើងនឹងមិននិយាយអ្វីដែលអាចបំផ្លាញអនាគតរបស់យើងឡើយ។ ទ្រង់មិនដែលនឿយហត់ឡើយ...គឺយើងទៅវិញទេដែលប្រកែកនឹងទ្រង់ ហើយលាក់ខ្លួនពីទ្រង់។

«(ឥលូវនេះ មុននឹងខ្ញុំនិយាយបន្តទៀត ខ្ញុំចង់ឱ្យអ្នកដឹងថាខ្ញុំធ្លាប់ជាជនជាតិអ៊ីតាលីដ៏រឹងក្បាលម្នាក់ ដែលឆ្អែតឆ្អន់នឹងការបង្រៀនពីភាពចម្រុងចម្រើនដែលខ្ញុំធ្លាប់បានឮចមក... ហើយស្វាមីរបស់ខ្ញុំក៏បានដឹងរឿងនេះដែរ។ ការអស្ចារ្យដ៏ពិតប្រាកដនោះគឺថាខ្ញុំបានទទួលយកវា និងបានកាន់វាជាប់... ដួនកាលស្វាមីរបស់ខ្ញុំមើលមកខ្ញុំ ហើយឆ្ងល់ថាតើមានអ្វីកើតឡើងឱ្យប្រាកដទៅ!

«យើងបានស្រាយជំនឿរបស់យើង និងបានសាបព្រោះដើម្បីទទួលបានកិច្ចសន្យាមួយសម្រាប់ក្រុមហ៊ុនសំណង់របស់យើងនៅខែ ៣ ឆ្នាំ ២០១៣ សម្រាប់កិច្ចសន្យារហ័សមួយនៃចំនួនទឹកប្រាក់ ១៥០,០០០ដុល្លារ ដើម្បីបង់ថ្លៃវិក្កយបត្រដែលផុតកំណត់ និងបង់ពន្ធជាដើម។ នៅថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១៣ យើងទទួលបានកិច្ចសន្យាពីរដែលមានតម្លៃសរុប ៤៥០,០០០ដុល្លារ ក្នុងពេលត្រឹមតែមួយថ្ងៃ!!!!! រឿងនោះកើតឡើងត្រឹមតែក្នុងរយៈពេលពីរខែក្រោយមកប៉ុណ្ណោះ តាំងពីយើងចាប់ផ្តើមអនុវត្តគោលការណ៍របស់ព្រះរាជ្យនៃព្រះ។

«យើងបានឱ្យកូនៗរបស់យើងចូលរួមជាមួយយើងដែរ ហើយពួកគេបានឃើញអ្វីដែលខ្ញុំហៅថា "គឺវានេះហើយ" ។ ឥលូវនេះពួកគេបានបង្កើតបញ្ជីផ្ទាល់ខ្លួនរបស់គេ និងបានសាបព្រោះចេញពីកូនជ្រូកសន្សំលុយរបស់គេ ដើម្បីដាំគ្រាប់ពូជសម្រាប់អ្វីដែលពួកគេចង់បាន។ យើងដាក់ខគម្ពីរមួយចំនួននៅក្នុងបន្ទប់នីមួយៗ ហើយកូនរបស់យើងដែលមានអាយុ ៥ឆ្នាំតែងទៅមើលខគម្ពីរទាំងនោះ និងប្រកាសថា "ខ្ញុំជឿថា ខ្ញុំបានទទួលវា។"

«ឥលូវនេះយើងពិតជាមានអំណរសប្បាយយ៉ាងខ្លាំង ដែលយើងមានលុយច្រើនជាងមុនដើម្បីឱ្យ និងមានអំណរដែលយើងកាន់តែខិតជិតមកដល់ថ្ងៃដែលយើងអាចរួចផុតពីបំណុលបាន និងថ្ងៃដែលអាចបញ្ចប់កិច្ចការរបស់យើងបាន!

«សូមអរគុណ លោកគ្រូ ហ្គារី សម្រាប់ការចំណាយពេលដើម្បីឆ្លើយតបអ៊ីមែលដែលខ្ញុំបានផ្ញើទៅលោកគ្រូ។ យើងដឹងថាពេលវេលារបស់លោកគ្រូមានកំណត់ ហើយការដែលលោកគ្រូចំណាយពេលឆ្លើយតបនេះបង្ហាញថាលោកគ្រូពិតជាចង់ចែករំលែកសារដ៏អស្ចារ្យពីព្រះរាជ្យរបស់ព្រះជាម្ចាស់នេះខ្លាំងយ៉ាងណា។»

ខ្ញុំតែងទទួលបានសារបែបនេះជារៀងរាល់ថ្ងៃ។ មនុស្សដូចជាអ្នក និងខ្ញុំកំពុងតែស្វែងរកសេចក្តីពិត ទាក់ទងនឹងអត្តសញ្ញាណរបស់ពួកគេនៅក្នុងព្រះគ្រិស្ត ការរៀនសូត្រពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការ និងរីករាយទទួលយកអត្ថប្រយោជន៍ផ្សេងៗ។ ដូច្នេះតើឌ្រិនដា និងខ្ញុំរកឃើញគោលការណ៍ចំណែកទ្វេដងបានដោយរបៀបណាទៅ? នៅក្នុងជំពូកនេះខ្ញុំនឹងប្រាប់អ្នក ហើយខ្ញុំដឹងថាអ្នកនឹងឃើញថារឿងរបស់យើង ជារឿងដែលមានការលើកទឹកចិត្ត។

ពេលឌ្រិនដា និងខ្ញុំបានចាប់ផ្តើមរៀនអំពីច្បាប់ និងគោលការណ៍ផ្សេងៗពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ជីវិតយើងមានការផ្លាស់ប្តូរយ៉ាងខ្លាំងដូចដែលខ្ញុំបានប្រាប់អ្នករួចមកហើយនៅក្នុងផ្នែកមុនៗនៃសៀវភៅនេះ ចាកចេញពីការជីវិតដែលមានត្រឹមតែមួយរស់ៗ ពីការដែលត្រូវដោះស្រាយជាមួយនឹងការវាយប្រហារពីភាពភ័យស្លន់ស្លោ ថ្នាំបំបាត់ភាពតានតឹងចិត្ត និងក្តីអស់សង្ឃឹមដ៏ធំធេង ទៅកាន់ជីវិតមួយប្រកបដោយគោលបំណង និងការផ្គត់ផ្គង់។ យើងបានឃើញរឿងរ៉ាវជាច្រើនបានកើតឡើងម្តងហើយម្តងទៀត ដែលធ្វើឱ្យយើងឈប់បន្តិចសិន ហើយនិយាយថា «តើអូន/បងឃើញទេ? ពិតជាអស្ចារ្យមែន!» យើងបន្តស្វែងរកដំណើរការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ឥតឈប់ឈរ ដូចអ្វីដែលមានចែងក្នុងព្រះគម្ពីរ ហើយយើងនឹងសួរសំណួរជាច្រើនដូចជា «តើការនោះកើតឡើងបានដោយរបៀបណា ហើយហេតុអ្វីបានជាវាកើតឡើង?» ឬ «តើគោលការណ៍អ្វីដែលយើងនឹងចាប់យក?» ទោះបីជាយើងមានភាពរីករាយបរិបូរហូរហៀរ ក៏យើងមើលមិនឃើញពីភាពចំណែកទ្វេដងនេះបានច្បាស់ ដូចជានៅក្នុងរឿងជាច្រើន ដែលខ្ញុំនឹងបង្ហាញឱ្យអ្នកបានដឹង។ កាលនោះយើងកំពុងតែរីករាយជាមួយនឹងចំណែកទ្វេដង ទោះជាយ៉ាងណាក៏ដោយយើងគ្រាន់តែមិនដឹងថាតាមពិតទៅអ្វីដែលយើងកំពុងតែមើលឃើញនោះគឺជាការទ្វេដង រហូតដល់ព្រះ

ជាម្ចាស់នៅតែបន្តបង្កើនការយល់ដឹងរបស់យើងអំពីវាបន្ថែមទៀត។ មុនពេលខ្ញុំពន្យល់ពីរបៀបដែលព្រះជាម្ចាស់បានជួយយើងឱ្យយល់ពីការទ្វេចំណែកតាមរបៀបមួយដ៏ល្អបំផុត ខ្ញុំចង់រំលឹកពីខគម្ពីរគន្លឹះរបស់យើងជាថ្មីម្តងទៀតបន្តិចសិន។ ពាក្យនៅក្នុងឃ្នាបទាំងប៉ុន្មានគឺជាកំណត់ត្រារបស់ខ្ញុំ មិនមែនជាផ្នែកនៅក្នុងខគម្ពីរទេ។)

> *ដូច្នេះព្រះជាម្ចាស់បានតម្រូវទុកឱ្យមានថ្ងៃសម្រាកមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរដែរ ដ្បិតអ្នកណាចូលទៅសម្រាកជាមួយព្រះជាម្ចាស់ [ជំនឿ] អ្នកនោះបានបង្ហើយកិច្ចការរបស់ខ្លួន [ប្រព័ន្ធនៃបណ្តាសាលោកិយនៃកិច្ចការលំបាក ការបង្ខូរញើស និងការមានជីវិតរស់] ដូចព្រះជាម្ចាស់បង្ហើយកិច្ចការរបស់ព្រះអង្គដែរ [ដោយសារតែទ្រង់បានបញ្ចប់កិច្ចការហើយ]។*

ហេប្រឺ ៤៖៩-១០

មកដល់ត្រឹមនេះអ្នកដឹងថាការសម្រាកថ្ងៃសប្ប័ទគឺជាព្រះបន្ទូលសន្យាចំពោះអ្នកជឿព្រះយេស៊ូក្នុងសម្ពន្ធមេត្រីថ្មីទាំងអស់ ហើយវាមិនមែនគ្រាន់តែជារឿងមួយដែលមាននៅក្នុងសម្ពន្ធមេត្រីចាស់ប៉ុណ្ណោះទេ។ ឥលូវនេះអ្នកក៏ដឹងថាថ្ងៃសប្ប័ទមិនអាចកើតឡើងដោយគ្មានភាពបរិបូរហូរហៀរបានទេ ឬដូចដែលយើងបានឃើញនៅក្នុងគម្ពីរនិក្ខមនំជំពូកទី១៦ អំពីចំណែកទ្វេដង។ សូមកុំយល់ច្រឡំថាដំណើរក្នុងចំណែកទ្វេដងមានន័យថា គ្រប់ករណីដែលអ្នកជួបប្រទះអ្នកនឹងមានលុយច្រើនលើសលប់នៅក្នុងដៃ ពេលព្រះជាម្ចាស់ប្រាប់អ្នកឱ្យចាប់ផ្តើមដំណើរការក្នុងគម្រោងណាមួយឱ្យសោះ។

ក្នុងជីវិតរបស់ខ្ញុំមានពេលជាច្រើន ពេលដែលព្រះយេស៊ូបានប្រាប់ខ្ញុំឱ្យឈានទៅមុខក្នុងគម្រោងណាមួយ ពេលខ្ញុំគ្មានលុយទាល់តែសោះនៅក្នុងធនាគារ។ ខ្ញុំបានដឹងនៅពេលក្រោយថាព្រះជាម្ចាស់មិនដែលព្រួយបារម្ភពីរឿងលុយ ហើយបានដឹងថាលុយនោះវាបានមកពីទីណាទេ។ ក៏ប៉ុន្តែទ្រង់មិនអនុញ្ញាតឱ្យវាបង្ហាញចេញមកក្រៅទេ ក្រែងលមារសាតាំងព្យាយាមលួចវាទៅមុនពេលដែលយើងពិតជាត្រូវការវា។ សូមអនុញ្ញាតឱ្យខ្ញុំដាស់តឿនអ្នកឱ្យប្រុងប្រយ័ត្នបន្តិច សូមត្រឹមតែសម្រេចចិត្តឈានទៅមុខក្នុងស្ថានភាពដូច្នោះចុះ ប្រសិនបើអ្នកប្រាកដចិត្តថាអ្នកបានឮវាពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រាប់ឱ្យអ្នកធ្វើដូច្នោះ។ ជាថ្មីម្តងទៀត ប្រសិនបើព្រះយេស៊ូមិនបានប្រាប់អ្នកឱ្យឈានទៅមុខក្នុងគម្រោង

ណាមួយដោយគ្មានលុយឧបត្ថម្ភត្រៀមទុក សូមកុំបន្តឈានទៅមុខឡើយ។ សូមរង់ចាំពេលវេលារបស់ព្រះជាម្ចាស់ និងរង់ចាំរហូតដល់អ្នកអាចរកការផ្គត់ផ្គង់បាន។

ជាទូទៅ ក្នុងនាមយើងជាអ្នកជឿដែលទទួលបានការត្រាស់ហៅឱ្យបង្ហាញចេញនូវភាពហូរហៀរផ្នែកខាងហិរញ្ញវត្ថុនៃជីវិតរបស់យើង។ យើងមិនមែនជាមនុស្សទន់ខ្សោយទេ ក៏ប៉ុន្តែយើងអាចមានចិត្តសប្បុរសគ្រប់ពេលដូចជាព្រះបិតារបស់យើងដែលមានចិត្តសប្បុរសដែរ។ ខ្ញុំនិយាយតែពីរឿងនោះដោយសារតែ ខ្ញុំបានទទួលអីមែលជាច្រើន ពីមនុស្សជាច្រើនដែលបានឈានចេញទៅស្វែងរកអ្វីនៅខាងក្រៅ និងខកខានពេលវេលារបស់ព្រះជាម្ចាស់។ សូមស្តាប់ ដោយគ្រាន់តែព្រះជាម្ចាស់បានបង្ហាញនូវអ្វីម៉្យាងនោះ មិនមែនមានន័យថាវាគឺជាពេលដែលអ្នកត្រូវដើរទៅមុខនោះទេ។ ក្នុងពេលជាច្រើនព្រះជាម្ចាស់បង្ហាញអ្នកនូវអ្វីម៉្យាងដើម្បីផ្តល់ការណែនាំដល់អ្នក និងពេលវេលាសម្រាប់ឱ្យអ្នកត្រៀមខ្លួន។ តាមបទពិសោធខ្ញុំ ពេលវេលាគឺមានសារៈសំខាន់ដូចជាការស្តាប់ការណែនាំតាំងពីដំបូងដែរ។

ពេលព្រះយេស៊ូបានចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់ក្នុងស្រុកកំណើតទ្រង់ បន្ទាប់ពីទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់ពីលោកយ៉ូហានរួចមក និងបន្ទាប់ពីរយៈ៤០ថ្ងៃ ៤០យប់នៅក្នុងវាលរហោស្ថាន ទ្រង់បានទៅចូលទៅក្នុងសាលាប្រជុំក្នុងស្រុករបស់ទ្រង់ និងបានរើសយកខគម្ពីរក្នុងសៀវភៅរបស់ព្យាការីអេសាយ និងបើកសៀវភៅទៅមើលទាំងប្រាំមួយដំបូង និងអានវា។ យើងបានឃើញព្រឹត្តិការណ៍នេះ កត់ត្រាទុកនៅក្នុងសៀវភៅលូកា ៤៖១៨-២១។

> *«ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំឱ្យមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាពហើយប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញវិញ។ព្រះអង្គបានចាត់ខ្ញុំឱ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិនព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា»។*
>
> *លុះអានចប់ហើយ ព្រះយេស៊ូបិទគម្ពីរ ប្រគល់ទៅអ្នកថែរក្សា រួចព្រះអង្គគង់ចុះវិញ។ មនុស្សគ្រប់ៗរូបនៅក្នុងសាលាប្រជុំសម្លឹងមើលព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្តាប់អម្បាញ់មិញ បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»។*

ជាការពិតណាស់ មនុស្សជាច្រើនខឹងសម្បារចំពោះទ្រង់យ៉ាងខ្លាំង ដោយសារតែទ្រង់បានបញ្ជាក់ថាទ្រង់គឺជាមនុស្សម្នាក់ដែលគេសំដៅលើ។ ក៏ប៉ុន្តែសូមយកចិត្តទុកដាក់ជាងមុនបន្តិចត្រង់កន្លែងដែលព្រះយេស៊ូបានឈប់អាន។ ពីខមួយដល់ខពីរនៃសៀវភៅអេសាយ ៦១ ពិតជាបានចែងថា ៖

> *ព្រះវិញ្ញាណរបស់ព្រះជាអម្ចាស់សណ្ឋិតលើខ្ញុំដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់អ្នកដែលត្រូវគេជិះជាន់ជួយថែទាំអ្នកដែលបាក់ទឹកចិត្តប្រកាសប្រាប់ជនជាប់ជាឈ្លើយថាពួកគេនឹងរួចខ្លួនហើយប្រាប់អ្នកជាប់ឃុំឃាំងថាពួកគេនឹងមានសេរីភាពព្រមទាំងប្រកាសពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា និងពីថ្ងៃកំណត់ដែលព្រះរបស់យើងដាក់ទោសមនុស្សអាក្រក់ហើយសម្រាលទុក្ខអស់អ្នកដែលកាន់ទុក្ខ។*

សូមចាំថាព្រះយេស៊ូបានឈប់នៅត្រង់ពាក់កណ្តាលនៃឃ្លាមួយ។ ទ្រង់មិនបានអានត្រង់ «ថ្ងៃកំណត់ដែលព្រះរបស់យើង» តើដោយហេតុអ្វីទៅ? ដោយសារតែទ្រង់ចង់ឈប់មើលសិននៅត្រង់ផ្នែកដំបូងនៃឃ្លាមួយនោះ «ឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា»។ តើឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាកុណាគឺជាអ្វីទៅ? នោះគឺជាឆ្នាំមេត្តាករុណា! អ្វីដែលសំខាន់នោះគឺព្រះយេស៊ូប្រកាសថាអ្វីទាំងអស់ដែលឆ្លុះបញ្ចាំងពីថ្ងៃសប្ប័ទ ឆ្នាំសប្ប័ទ និងមេត្តាករុណា បានបង្ហាញយើងគឺបានបំពេញសព្វគ្រប់ហើយ ហើយតលូវនេះទ្រង់ប្រកាសថាវានៅទីនេះដោយសារតែទ្រង់បានយាងមក។ នៅក្នុងជំពូកទី៦១ នៃសៀវភៅអេសាយទាំងមូល ប្រាប់យើងពីអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់យើង។ ស្របតាមគោលការណ៍ចំណែកទ្វេដង សូមមើលទៅខទី៧ ដល់ខទី ៩។

> *អ្នករាល់គ្នាលែងអាម៉ាស់ និងលែងបាក់មុខទៀតហើយ អ្នករាល់គ្នានឹងទទួលទឹកដីរបស់គេមួយទ្វេជាពីរទុកជាមតិកអ្នករាល់គ្នានឹងមានអំណរសប្បាយអស់កល្បជានិច្ច។ ព្រះអម្ចាស់មានព្រះបន្ទូលថាយើងចូលចិត្តយុត្តិធម៌ហើយស្អប់ការជំរិតជិះជាន់ណាស់។យើងនឹងសងអ្នករាល់គ្នាវិញយ៉ាងត្រឹមត្រូវយើងនឹងចងសម្ពន្ធមេត្រីដែលនៅស្ថិតស្ថេរអស់កល្បជានិច្ចជាមួយអ្នករាល់គ្នា។ ប្រជាជាតិទាំងឡាយនឹងស្គាល់កូនចៅរបស់អ្នករាល់គ្នាហើយពូជពង្សអ្នករាល់គ្នាក៏នឹងមានឈ្មោះល្បីនៅក្នុងចំណោមជាតិសាសន៍នានាដែរ។ អស់អ្នកដែលជួបពួកគេនឹងទទួលស្គាល់ថាពួកគេជាជាតិមួយដែលព្រះអម្ចាស់បានប្រទានពរ។*
>
> អេសាយ ៦១៖៧-៩

ខ្ញុំពិតជាយល់ពីការខ្មាសអៀនដោយសារតែបញ្ហាខ្សត់ខ្សោយផ្នែកហិរញ្ញវត្ថុ។ ហេតុដូច្នេះហើយមានពេលច្រើនដែលខ្ញុំឃើញខ្លួនឯងទទួលការមាក់ងាយ និងសេចក្តីខ្មាសអៀនចំពោះស្ថានភាពហិរញ្ញវត្ថុរបស់យើង។ ខ្ញុំចាំបានថាមានពេលមួយខ្ញុំបានអញ្ជើញមិត្តភក្តិប្រមាណជា ២០នាក់មកជុំគ្នាទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានមួយក្នុងទីក្រុងយើង។ ខ្ញុំមិនចាំទេថាកាលនោះគឺជាឱកាសពិសេសអ្វីទៅដែលយើងជុំគ្នាអបអរ ក៏ប៉ុន្តែខ្ញុំបានយល់ព្រមចេញលុយទាំងអស់សម្រាប់កម្មវិធីនោះ។ ខ្ញុំចាំបានថាក្នុងពេលទទួលទានអាហារនោះគឺពិតជាតឹងតែងណាស់ ដោយសារតែខ្ញុំពិតជាគ្មានលុយសម្រាប់រៀបចំព្រឹត្តិការណ៍បែបនោះទេ។ លុយដែលខ្ញុំកំពុងរង់ចាំឱ្យបង្ហាញខ្លួនមកតាមរយៈកិច្ចព្រមព្រៀងអាជីវកម្មដែលខ្ញុំកំពុងតែធ្វើការលើវានោះត្រូវបានគេពន្យារពេលទៅហើយ។ ឯកាតក្រេឌីតតែមួយគត់ដែលខ្ញុំមានមិនទាន់ត្រូវគេលុបចោលទេ ក៏ប៉ុន្តែវាជាកាតដែលដល់កំណត់ទៅហើយ ហើយខ្ញុំក៏មិនប្រាកដទេថាវានឹងដំណើរការបានម្តងទៀតដែរឬទេ។ រឿងនេះច្បាស់ល្អមហើយថាចុងបញ្ចប់នៃការទទួលទានអាហារនោះ កាតនោះមិនអាចយកមកប្រើការបានទេ។ ខ្ញុំត្រូវតែបន្ទាបខ្លួនទាំងក្តីអាម៉ាស់ ហើយសុំអ្នកចូលរួមក្នុងកម្មវិធីយើងម្នាក់ឱ្យចេញលុយសម្រាប់កម្មវិធីនោះ។

**ដោយគ្រាន់តែព្រះជាម្ចាស់បានបង្ហាញនូវអ្វីម៉្យាងនោះ មិនមែនមានន័យថាវាគឺជាពេលដែលអ្នកត្រូវដើរទៅមុខនោះទេ។ ក្នុងពេលជាច្រើន ព្រះជាម្ចាស់បង្ហាញអ្នកនូវអ្វីម៉្យាងដើម្បីផ្តល់ការណែនាំដល់អ្នក និងពេលវេលាសម្រាប់ឱ្យអ្នកត្រៀមខ្លួន។**

អូហ៍មែនហើយ ខ្ញុំជួបរឿងជាច្រើនដែលកំសត់ៗដូចជារឿងមួយនោះ ក៏ប៉ុន្តែខ្ញុំមិនប្រាកដទេថាអ្នកមាន ក្រដាសជូតមាត់នៅក្បែរខ្លួនគ្រប់ល្មមដើម្បីជូនទឹកភ្នែក នៅពេលដែលស្តាប់រឿងដែលខ្ញុំនិយាយដែរឬទេ។ ក៏ប៉ុន្តែសូមអរព្រះគុណព្រះជាម្ចាស់តាមរយៈព្រះយេស៊ូ មនុស្សគ្រប់គ្នាដែលបានឃើញយើង និងត្រូវទទួលស្គាល់ថាយើងគឺជាប្រជាជនដែលព្រះអម្ចាស់បានប្រទានពរ!

ចំណែកទ្វេដងគឺជារបស់អ្នក ព្រះយេស៊ូគឺជាការសម្រាកក្នុងថ្ងៃសប្ប័ទរបស់អ្នក ហើយទ្រង់គឺជាចំណែកទ្វេដងរបស់អ្នក! ប្រសិនបើអ្នកបានអានសៀវភៅណាមួយរបស់ខ្ញុំពី

មុន នោះអ្នកដឹងថាព្រះអម្ចាស់បានបង្រៀនខ្ញុំច្រើនអំពីព្រះរាជ្យនៃព្រះតាមរយៈការប្រម៉ាញ់សត្វក្តាន់។ ជាការពិតណាស់ការប្រម៉ាញ់សត្វក្តាន់ ប្រៀបដូចជាយានជំនិះដែលព្រះជាម្ចាស់បានប្រើប្រាស់ដើម្បីទាញយកចំណាប់អារម្មណ៍របស់ខ្ញុំជាមួយនឹងព្រះរាជ្យនៃព្រះតាំងពីដំបូង។ ខ្ញុំបានធ្វើការប្រម៉ាញ់សត្វក្តាន់ជាច្រើនឆ្នាំមកហើយដោយគ្មានភាពជោគជ័យសោះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានចំណាយទាំងពេលវេលា និងលុយកាក់នៅក្នុងការខិតខំប្រឹងប្រែងរបស់ខ្ញុំ ក៏ខ្ញុំនៅតែទទួលលទ្ធផលមិនជោគជ័យ និងគ្មានបានសត្វប្រម៉ាញ់សោះ។ និយាយត្រង់ចុះ ខ្ញុំមិនដែលបាញ់សត្វណាមួយបានម្តងនោះឡើយ។ នៅក្នុងឆ្នាំមួយនោះពេលដែលខ្ញុំកំពុងតែគិតអំពីរដូវប្រម៉ាញ់សត្វក្តាន់ដែលនឹងចូលមកដល់ ព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «ហេតុអ្វីបានជាអ្នកមិនឱ្យយើងជួយដល់អ្នកក្នុងការប្រម៉ាញ់ក្តាន់ឆ្នាំនេះ?!» ជាការពិតណាស់ខ្ញុំមិនយល់ទេថាវាមានន័យដូចម្តេច ក៏ប៉ុន្តែទ្រង់បានប្រាប់ខ្ញុំឱ្យយកមូលប្បទានបត្រមួយសន្លឹក និងសរសេរថា «សម្រាប់ឆ្នាំក្តាន់របស់ខ្ញុំក្នុង១៩៨៧ » នៅលើនោះនៅត្រង់ផ្នែកកំណត់ត្រា រួមជាមួយនឹងចំនួនទឹកប្រាក់ជាក់លាក់មួយចំនួន ហើយបន្ទាប់មកផ្ញើទៅកាន់ព័ន្ធកិច្ចមួយដែលទ្រង់បានណែនាំខ្ញុំឱ្យផ្ញើទៅ។ ទ្រង់ក៏បានប្រាប់ខ្ញុំផងដែរឱ្យឌ្រិនដា និងខ្ញុំដាក់ដៃនៅលើមូលប្បទានបត្រនោះ និងប្រកាសខគម្ពីរម៉ាកុស ១១ ៖២៤ ពេលយើងអធិស្ឋានឱ្យមូលប្បទានបត្រនោះ។

**ម៉ាកុស ១១៖២៤** ចែងថា

*ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយឱ្យតែអ្នករាល់គ្នាអធិស្ឋាន*សុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។*

និយាយឱ្យខ្លីទៅ នៅក្នុងឆ្នាំនោះខ្ញុំបានចេញទៅកាន់ដីមួយកន្លែងដែលខ្ញុំមិនដែលស្គាល់ទាល់តែសោះ និងចាប់បានសត្វក្តាន់របស់ខ្ញុំក្នុងរយៈពេលប្រមាណជា ៤០នាទី។ ឌ្រិនដា និងខ្ញុំបានដើរតាមជំហានទាំងនេះអស់រយៈពេល ៣០ឆ្នាំមកហើយ ហើយខ្ញុំតែងតែបរបាញ់សត្វក្តាន់បានក្នុងរយៈ ៣០ ទៅ៤០នាទីជារៀងរាល់ឆ្នាំតាំងពីពេលនោះមក។ ឆ្លងកាត់រយៈពេលជាច្រើនឆ្នាំខ្ញុំបានឃើញព្រះជាម្ចាស់ធ្វើកិច្ចការអស្ចារ្យជាច្រើនអំឡុងពេលដែលយើងធ្វើការបរបាញ់ ហើយខ្ញុំបានរៀនមេរៀនមួយចំនួនអំពីច្បាប់ក្នុងព្រះរាជ្យនៃព្រះតាមរយៈការបរបាញ់សត្វផងដែរ។ (រឿងរ៉ាវពីដំបូងជាច្រើនដែលបានកត់ត្រាទុកក្នុងសៀវភៅ *Faith Hunt* របស់ខ្ញុំ)។

ជាទូទៅខ្ញុំចូលចិត្តការបរបាញ់ដោយប្រើធ្នូក្នុងរដូវស្លឹកឈើជ្រុះដ៏កក់ក្ដៅ បន្ទាប់មកបរបាញ់ដោយកាំភ្លើងនៅក្នុងរដូវរងារនៅក្នុងរដ្ឋអូហៃយ៉ូនេះ។ ចំនួនកំណត់នៃសត្វក្ដាន់ដែលអ្នកអាចបរបាញ់បាននៅក្នុងរដ្ឋអូហៃយ៉ូដូចជារាងច្រើនគួសម ហើយរាល់ឆ្នាំបរបាញ់ក្នុងមួយឆ្នាំៗចំនួនក្ដាន់ដែលបានកំណត់គឺចំនួន៦។ ជាទូទៅទូទឹកកករបស់ខ្ញុំតែងតែពេញទៅដោយសត្វក្ដាន់ពីរ ឬបីក្បាលក្នុងមួយឆ្នាំ។ ដើម្បីអរគុណដល់អ្វីដែលខ្ញុំនឹងប្រាប់អ្នកឱ្យដឹងបន្តិចទៀតនេះ អ្នកត្រូវការដឹងថាអំឡុងពេលបរបាញ់ក្នុងឆ្នាំទាំងនោះ ខ្ញុំមិនដែលបាញ់បានក្ដាន់ពីរចេញពីដើមឈើតែមួយ ក្នុងពេលតែមួយព្រឹក ឬមួយល្ងាចនៃការបរបាញ់ឡើយ។ ផ្ទុយទៅវិញប្រសិនបើអ្នកមិនមែនជាអ្នកបរបាញ់ទេ ខ្ញុំចង់ប្រាប់ថាយើងបរបាញ់ដោយប្រើធ្នូពីការឈរលើដើមឈើ។ ជាធម្មតាពេលខ្ញុំសម្លាប់ក្ដាន់មួយក្បាល ខ្ញុំនឹងចេញពីព្រៃ ហើយត្រលប់មកវិញនៅថ្ងៃផ្សេងទៀត និងបរបាញ់ក្ដាន់មួយទៀត។ ក៏ប៉ុន្តែព្រះអម្ចាស់ចង់បង្រៀនខ្ញុំពីអ្វីម៉្យាងនៅក្នុងការបរបាញ់ពេលល្ងាចដ៏ពិសេសនេះ។

ថ្ងៃនោះគឺជាថ្ងៃបរបាញ់ក្នុងរដូវស្លឹកឈើជ្រុះដ៏ឥតខ្ចោះ មានពពកបាំងថ្ងៃបន្តិចៗ និងមានភ្លៀងរលឹមស្រិចៗស្រក់មកលើដីពីមួយពេលទៅមួយពេល។ កាលនោះគឺពេលល្ងាចថ្ងៃអាទិត្យ ខ្ញុំដូចជាអស់កម្លាំងបន្តិចដោយសារតែកិច្ចការច្រើនមុខនៅក្នុងវេនថ្វាយបង្គំច្រើនក្នុងពេលព្រឹកនោះ ហើយខ្ញុំកំពុងទន្ទឹងចាំដល់ពេលចូលទៅក្នុងព្រៃ។ កាលនោះឌ្រិនដាកំពុងចេញទៅក្រៅដើម្បីទិញរបស់មួយចំនួន ហើយគាត់និងខ្ញុំបានយល់ព្រមគ្នាថាយប់នេះគឺជាពេលវេលាដ៏ល្អដើម្បីយកសត្វដែលយើងបរបាញ់បានមកទុកក្នុងទូទឹកកក។ ខ្ញុំបានស្លៀកពាក់ឈុតខោអាវប៉ារ៉ារបស់ខ្ញុំ និងបានប្រមូលសម្ភារៈរបស់ខ្ញុំក្នុងពេលដែលគាត់ដើរចេញក្រៅទៅរកឡាន។ ខ្ញុំបានចេញមកខាងក្រៅពេលគាត់កំពុងបញ្ឆេះឡាន ដើម្បីបើកចេញទៅ។ ពេលគាត់បញ្ឆេះឡាន គាត់បានបើកកញ្ចក់ឡាន និងនិយាយមកខ្ញុំថា «ចំណែកទ្វេដង»។ ខ្ញុំមិនដឹងទេថាហេតុអ្វីគាត់និយាយបែបនោះ លុះក្រោយមកទើបគាត់ប្រាប់ខ្ញុំថាគាត់បានឮព្រះជាម្ចាស់មានបន្ទូលបែបនោះមកកាន់គាត់ក្នុងពេលនោះ ហើយគាត់មានអារម្មណ៍ថាទ្រង់ដឹកនាំគាត់ឱ្យប្រាប់ខ្ញុំអំពីចឹង។

យើងបានសាបព្រោះសម្រាប់សត្វក្ដាន់ចំនួនបីក្នុងឆ្នាំនោះ ហើយថ្ងៃនេះគឺជាថ្ងៃបរបាញ់ដំបូងសម្រាប់រដូវកាលនោះ។ ខ្ញុំបានថើបគាត់បន្តិច និងប្រាប់គាត់ថាខ្ញុំយល់ស្រប ហើយខ្ញុំបានចេញដំណើរទៅព្រៃ។ ខ្ញុំបរបាញ់នៅក្នុងដីរបស់ខ្ញុំ ដូច្នេះស្គាល់ច្បាស់ពីកន្លែង

ដែលខ្ញុំទៅ។ ពេលខ្ញុំឡើងទៅឈរនៅទីតាំងលើដើមឈើរបស់ខ្ញុំ ខ្ញុំបានបញ្ចេញសំឡេងស្រែកដូចជាសត្វពីរបីដង។ ក្នុងអំឡុងពេល ១៥នាទីមានសត្វក្តាន់ទំហំលេខ៨រត់មក ខ្ញុំបានបាញ់សត្វពីចម្ងាយប្រមាណជាង ៣០ម៉ែត្រ ហើយបាញ់ត្រូវសត្វក្តាន់នោះឱ្យដួលទៅ។ វាពិតជាអស្ចារ្យមែនទែន! ខ្ញុំចុះពីលើដើមឈើហើយដើរតម្រង់ទៅរកក្តាន់នោះ ក៏ប៉ុន្តែបន្ទាប់មកខ្ញុំចាំពីអ្វីដែលគ្រិនដាបាននិយាយអំពីចំណែកទ្វេដង ហេតុដូច្នេះហើយខ្ញុំបានដើរចេញពីសត្វក្តាន់ដួលនោះ ហើយត្រលប់ទៅរកដើមឈើរបស់ខ្ញុំវិញ និងឡើងទៅលើដើមឈើវិញចូលទៅកន្លែងឈររបស់ខ្ញុំ។

ខ្ញុំបានគិតជាមួយនឹងការរំជើបរំជួលទាំងអស់ដែលធ្វើឱ្យខ្ញុំចុះមកក្រោម ដើរទៅមក ហើយបន្ទាប់មកក៏ទៅកាន់កន្លែងឈរវិញ និងឡើងទៅខ្ពស់ ទុកឱ្យមានតែក្លិនទាំងប៉ុន្មានដែលខ្ញុំប្រហែលជាបានធ្វើឱ្យសាយភាយចេញជុំវិញនោះ ដែលតាមធម្មជាតិក្លិននោះនឹងធ្វើឱ្យឱកាសក្នុងការប្រម៉ាញ់បានសត្វមួយទៀតមានកាន់តែស្តួចស្តើង ក្នុងរយៈពេលតែពីរបីនាទីដែលនៅសេសសល់សម្រាប់ការប្រម៉ាញ់ស្របច្បាប់។ ក៏ប៉ុន្តែក្នុងពេល ១៥នាទីនៅលើដើមឈើ មានសត្វឈ្លូសមួយបានដើរចូលមកខាងក្រោមដើមឈើរបស់ខ្ញុំតែម្តង ហើយខ្ញុំក៏បាញ់វាបានត្រូវយ៉ាងល្អឥតខ្ចោះ។ អស្ចារ្យណាស់ការបាញ់ចេញពីដើមឈើតែមួយដល់ទៅពីរដង បាញ់ត្រូវទាំងពីរដង។ ខ្ញុំមិនធ្លាប់ធ្វើបានបែបនេះពីមុនមកទេ។ វាទាក់យកចំណាប់អារម្មណ៍របស់ខ្ញុំ ហើយខ្ញុំបានដឹងថាវាគឺជាចំណែកទ្វេដងដែលគ្រិនដាបានប្រាប់ខ្ញុំនោះហើយ។

សម្រាប់រយៈប្រាំឆ្នាំក្រោយៗទៀត ខ្ញុំបានទទួលបទពិសោធដូចគ្នានេះដែរ។ រាល់ពេលដែលខ្ញុំចេញទៅបរបាញ់ដោយប្រើព្រួញ ខ្ញុំនឹងបាញ់បានក្តាន់ពីរពីដើមឈើតែមួយក្នុងអំឡុងពេលមិនប៉ុន្មាននាទីពីគ្នាទេ។ ខ្ញុំបានដឹងថាវាមិនមែនជារឿងធម្មតាទេ ហើយខ្ញុំបានចាប់ផ្តើមនឹកឃើញពីគោលការណ៍ចំណែកទ្វេដង ដោយដឹងជាថ្មីម្តងទៀតថាព្រះជាម្ចាស់កំពុងតែបង្រៀនខ្ញុំពីមេរៀនមួយផ្សេងទៀតអំពីព្រះរាជ្យរបស់ទ្រង់។

ខ្ញុំតែងតែចូលចិត្តកាំភ្លើងរហូតមក ហើយជាការពិតណាស់ខ្ញុំចូលចិត្តការបរបាញ់។ ខ្ញុំបានប្រមូលកាំភ្លើងផ្ទាល់ខ្លួនទុក ហើយខ្ញុំក៏សប្បាយចិត្តណាស់ដែរជាមួយនឹងកាំភ្លើងជាកម្មសិទ្ធិរបស់ខ្ញុំ។ គ្រិនដា និងខ្ញុំមានដីប្រមាណជាង ២០ហិចតាដែលមានដីព្រៃប្រមាណជាង ១០ហិចតា និងមានដីដែលជាបឹងទឹករាក់ប្រមាណជា ៦ហិចតា។ នៅក្នុងរដូវ

ស្លឹកជ្រុះមួយណាដែលចូលមកដល់ ទឹកបឹងអាចប្រែជាគោកបាន ឬមានទឹកពេញអាស្រ័យទៅលើថាតើរដូវក្តៅអាចមានភ្លៀងធ្លាក់ប៉ុណ្ណា។

នៅក្នុងឆ្នាំពិសេសនេះ រដូវក្តៅហាក់ដូចជាមានភ្លៀងច្រើនបន្តិច ដូច្នេះហើយទឹកបឹងនោះក៏បានពេញប្រៀប ស្របពេលដែលជារដូវសម្បុរសត្វទាចូលមកដល់ល្មម។ ជាធម្មតាតែងតែមានសត្វទាជាច្រើនចូលមកក្នុងបរិវេណបឹង ក្នុងឆ្នាំណាដែលមានទឹកបឹងពេញប្រៀប ក៏ប៉ុន្តែខ្ញុំដូចជាមិនសូវចាប់អារម្មណ៍នឹងវាប៉ុន្មានទេ។ ក៏ប៉ុន្តែឆ្នាំនេះមានហ្វូងសត្វទាដ៏ធំមួយបានចូលមករស់នៅក្នុងបឹង ដែលមានពេញប្រៀបនោះ ហើយខ្ញុំមិនអាចមិនចាប់អារម្មណ៍ពីវាបានទេ។ ទោះបីជាខ្ញុំមិនដែលគិតថានឹងបរបាញ់វាកាលពីមុនក្តី ខ្ញុំគិតថាខ្ញុំនឹងចុះទៅម្តុំបឹងនោះ និងសាកល្បងប្រមាញ់សត្វទាមួយចំនួន។ ជាការពិតណាស់ការបរបាញ់គឺសប្បាយ។ មានទាជាច្រើននៅគ្រប់កន្លែង ហើយក្នុងឆ្នាំនោះយើងយកទាមកចម្អិនជាអាហារពេលល្ងាចពីរបីដងដែរ។

អំឡុងពេលបរបាញ់សត្វទាក្នុងឆ្នាំនោះ ខ្ញុំបានឃើញថាមានច្រើនដងណាស់ដែលសត្វទាជាច្រើនហើរកាត់ពីមុខកាំភ្លើង។ ខ្ញុំបានប្រើប្រាស់ពេលវេលារបស់ខ្ញុំជារៀងរាល់ថ្ងៃជាមួយនឹងកាំភ្លើងដែលខ្ញុំតែងតែប្រើប្រាស់សម្រាប់បាញ់ទន្សាយ និងមាន់ទោ ក៏ប៉ុន្តែពេលទាហោះមកខាងក្រៅត្រង់ចំណុចមុខកាំភ្លើង ខ្ញុំចាំបានថាខ្ញុំបានឮគេនិយាយពីកាំភ្លើងចេញថ្មីមួយប្រភេទដែលបានរចនាឡើងសម្រាប់តែការបរបាញ់សត្វទាប៉ុណ្ណោះ។ កាំភ្លើងទាំងនេះជាប្រភេទកាំភ្លើងស្រោបពណ៌ប៉ារ៉ា និងអាចបាញ់ដោយប្រើគ្រាប់កាំភ្លើងបាញ់សត្វប្រភេទថ្មីដែលមានបង់កាំភ្លើងជាងមុន ហើយអាចឱ្យបាញ់គ្រាប់កាន់តែឆ្ងាយជាងមុន។ ខ្ញុំចាំបានថាខ្ញុំបានគិតថាខ្ញុំគួរតែស្រាវជ្រាវមើលវាពេលខ្ញុំមានពេល។

និយាយអីចឹង រឿងនេះក៏កើតឡើងគឺខ្ញុំបានទៅហាងលក់ទំនិញសម្ភារៈកីឡាមួយខែក្រោយពីរដូវបរបាញ់ទាបានបញ្ចប់ ស្របពេលដែលខ្ញុំបានទាក់ចិត្តនឹងកាំភ្លើងមួយឈុតដែលជាប្រភេទកាំភ្លើងខ្យល់ (waterfowl gun)។ ខ្ញុំមើលឈុតកាំភ្លើងនោះបន្តិច ក៏ប៉ុន្តែពេលឃើញតម្លៃ ២,០០០ដុល្លារបិទនៅលើវា និងស្ថានភាពដែលខ្ញុំមិនត្រូវការកាំភ្លើងទេក្នុងរយៈពេល ១០ខែរហូតដល់រដូវបរបាញ់ទាចូលមកដល់ម្តងទៀត ខ្ញុំក៏បានសម្រេចចិត្តថារង់ចាំសិនមិនទាន់ទិញទេ។ ក៏ប៉ុន្តែខ្ញុំបាននិយាយឮៗដោយមិនបានគិតឡើងថា «ព្រះអម្ចាស់អើយ កូនចង់បានឈុតកាំភ្លើងនោះ។» ខ្ញុំមិនគិតអ្វីច្រើនសោះអំពីវាពេលខ្ញុំដើរចេញពីហាងលុះពីរបីសប្តាហ៍ក្រោយពេលខ្ញុំកំពុងនិយាយនៅក្នុងការប្រជុំផ្នែកលក់មួយរបស់ក្រុមហ៊ុន

វាមិនមែនជាការប្រជុំក្នុងក្រុមជំនុំទេ គឺជាការប្រជុំផ្នែកលក់របស់ក្រុមហ៊ុន។ ពេលខ្ញុំធ្វើបទបង្ហាញចប់ ប្រធាននាយកប្រតិបត្តិបានអរគុណខ្ញុំសម្រាប់អ្វីដែលខ្ញុំនិយាយ និងបាននិយាយថា «យើងចង់អរគុណដល់លោកដែលមានប្រសាសន៍ក្នុងយប់នេះជាមួយនឹងអំណោយមួយ។» ខ្ញុំពិតមានការភ្ញាក់ផ្អើលខ្លាំងពេលគាត់បានយកកាំភ្លើងតែមួយដែលខ្ញុំបានមើលនៅក្នុងហាងលក់ទំនិញសម្ភារៈកីឡាត្រឹមតែពីរបីសប្ដាហ៍មិននេះឯង។ ពិតជាអស្ចារ្យណាស់ «ព្រះអម្ចាស់អើយ កូននឹងទទួលយករបស់នោះ» ហើយការដែលខ្ញុំបានឱ្យកាំភ្លើងខ្លះទៅគេក្នុងពេលកន្លងមក បាននាំមកនូវការប្រមូលផលមួយនោះឯង។

នៅក្នុងសៀវភៅទីមួយនៃស៊េរីសៀវភៅនេះដែលមានចំណងជើងថា *បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក ៖ អំណាចនៃភក្ដីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់* ខ្ញុំនិយាយអំពីគោលការណ៍ដែលនាំឱ្យកាំភ្លើងនោះបានបង្ហាញខ្លួនឡើង។ ខ្ញុំហៅវាថាជាគោលការណ៍កណ្ដៀវ ហើយគោលការណ៍នេះអាចរកឃើញនៅក្នុងគម្ពីរម៉ាកុស ៤៖២៦-២៩។ ខ្ញុំសូមសំណូមពរឱ្យអ្នកទិញសៀវភៅនេះមួយក្បាលប្រសិនបើអ្នកមិនទាន់អានវា។ កាំភ្លើងមួយដើមនោះយ៉ាងអស្ចារ្យដោយពិតប្រាកដមែន ក៏ប៉ុន្តែវាមិនមែនជារឿងពិតដែលខ្ញុំចង់ផ្ដោតលើនោះទេ។ ក៏ប៉ុន្តែវាយ៉ាយរាប់ពីរឿងដែលខ្ញុំចង់ប្រាប់ដល់អ្នក។

ក្រោយពេលដែលកាំភ្លើងនោះបានបង្ហាញខ្លួនមក ហើយពេលខ្ញុំបានដឹងពីរបៀបដែលខ្ញុំបានដាក់ការប្រមូលផលនោះឱ្យមានចលនា ខ្ញុំបានគិតអស់ពេលមួយថ្ងៃអំពីកាំភ្លើងផ្សេងៗទៀតដែលខ្ញុំចង់បាន។ ចុងក្រោយ ខ្ញុំបានសាបព្រោះកាំភ្លើងរាប់សិបដើម ហេតុដូច្នេះហើយខ្ញុំបានគិតថាខ្ញុំចង់ធ្វើការពិសោធជាមួយនឹងច្បាប់នៃព្រះរាជ្យនៃព្រះ។ កាំភ្លើងតែមួយប្រភេទដែលខ្ញុំគ្មានក្នុងចំណោមកាំភ្លើងដែលបានប្រមូលទុកនោះគឺកាំភ្លើងស្នប់ (over and under shotgun)។ ទាំងនោះគឺជាកាំភ្លើងដ៏ស្រស់ស្អាត ហើយជាទូទៅកាំភ្លើងនោះក៏មិនមែនមានតម្លៃថោកដែរ។ ហេតុដូច្នេះហើយខ្ញុំនិយាយថា «ព្រះអម្ចាស់អើយកូនចង់មានកាំភ្លើងស្នប់ដ៏ស្រស់ស្អាតទាំងនោះមួយ!»

ប្រមាណជាមួយខែក្រោយមក មានដៃគូព័ន្ធកិច្ចម្នាក់បានទូរស័ព្ទមកខ្ញុំ ហើយគាត់បាននិយាយថាគាត់ចង់ទិញកាំភ្លើងមួយដើមឱ្យខ្ញុំ គឺជាកាំភ្លើងស្នប់មួយ។ ខ្ញុំរំភើបមែនទែន ហើយគាត់បាននិយាយថាគាត់នឹងផ្ញើវាមកតាមប្រអប់សំបុត្រ។ ហើយជាការពិតមែនពីរបីថ្ងៃក្រោយមកខ្ញុំទទួលបានកាំភ្លើងស្នប់ដ៏ស្រស់ស្អាតចំនួនពីរនៅក្នុងប្រអប់សំបុត្រខ្ញុំ ពិតជាកាំភ្លើងដ៏ស្រស់ស្អាតណាស់! សូមចំណាំថាខ្ញុំទទួលបានកាំភ្លើងចំនួនពីរ។

ខ្ញុំបានគិតថា «ពិតជាអស្ចារ្យមែន»។ ខ្ញុំបានទូរស័ព្ទទៅដៃគូព័ន្ធកិច្ចម្នាក់នោះ និងបានអរគុណដល់គាត់ចំពោះកាំភ្លើងដ៏ស្រស់ស្អាតដែលគាត់បានផ្ញើមក។ ប្រមាណជាពីរបីថ្ងៃក្រោយទៀតក៏បានផ្ញើកាំភ្លើងមកពីរទៀត។ ពេលដែលខ្ញុំទូរស័ព្ទទៅអរគុណគាត់ម្តងទៀត គាត់បាននិយាយថា «ខ្ញុំពិតជារីករាយណាស់ដែលលោកបានទូរស័ព្ទមកអរគុណខ្ញុំដោយផ្ទាល់ ខ្ញុំចង់ផ្ញើកាំភ្លើងទៅឱ្យលោកពីរបន្ថែមទៀត។» ខ្ញុំពិតជារំភើបគ្មានពាក្យថ្លែងជាមួយនឹងអំណោយទាំងនោះ ក៏ប៉ុន្តែខ្ញុំក៏បានចាប់ផ្តើមមើលឃើញពីគំរូមួយនៅត្រង់នេះ។ គឺម្តងទទួលបានកាំភ្លើងពីរ។ ស្តាប់ទៅហាក់ដូចជាចំណែកទ្វេដង។

ប្រមាណជាពីរខែមុន ពេលខ្ញុំកំពុងបង្រៀននៅក្នុងក្រុមជំនុំមួយនាពេលព្រឹក ហើយបន្ទាប់មកខ្ញុំត្រូវទៅបង្រៀននៅក្នុងទីក្រុងដដែលនោះនៅឯក្រុមជំនុំមួយផ្សេងទៀតក្នុងយប់នោះ។ បន្ទាប់ពីចប់វេនថ្វាយបង្គំពេលព្រឹក មានបុរសម្នាក់បានដើរឡើងមកជួបខ្ញុំ និងនិយាយថា «ខ្ញុំនឹងផ្ញើកាំភ្លើងស្វ័យប្រវត្តិ Browning ដ៏ស្រស់ស្អាតមួយដែលខ្ញុំមានទៅឱ្យលោក។» ជាថ្មីម្តងទៀតខ្ញុំពិតជារំភើបមែនទែន។ មានរឿងមួយដែលគួរឱ្យចម្លែកគឺ ក្នុងវេនថ្វាយបង្គំពេលល្ងាចក្នុងក្រុមជំនុំផ្សេងមួយទៀត មានបុរសម្នាក់បានដើរមករកខ្ញុំ ហើយនិយាយថា «ខ្ញុំបានទិញកាំភ្លើងវែងម៉ាកថ្មីមួយ ដែលខ្ញុំនៅទុកវាក្នុងប្រអប់វានៅឡើយ ហើយខ្ញុំចង់ប្រគល់វាឱ្យលោក។» វាគឺជាកាំភ្លើងដែលមានកែវឆ្លុះ Marlin 30/30 ដ៏ស្រស់ស្អាតមួយ ជាកាំភ្លើងដែលខ្ញុំតែងតែស្ងើចសរសើរ ក៏ប៉ុន្តែមិនដែលមានវាពីមុនមកទេ។ ជាថ្មីម្តងទៀត ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ ក៏ប៉ុន្តែកាលនោះខ្ញុំបានយល់ពីគោលការណ៍ចំណែកទ្វេដង។

ជាថ្មីម្តងទៀត មិនបានប៉ុន្មានសប្តាហ៍ក្រោយពីនោះ មានរឿងដូចគ្នានោះបានកើតឡើង ក្នុងថ្ងៃតែមួយខ្ញុំបានទទួលកាំភ្លើងពីរដើម។ និយាយទៅ ខ្ញុំអាចនិយាយបានថាខ្ញុំគឺជាបុរសដែលបានប្រកបដោយព្រះពរជាមួយនឹងកាំភ្លើងដ៏ល្អៗពិតប្រាកដមែន។ ក៏ប៉ុន្តែវាក៏ដូចជារឿងនីមួយៗដែលខ្ញុំនិយាយប្រាប់ដែរ ខ្ញុំតែងតែសួរថា «តើរឿងនោះកើតឡើងបានដោយរបៀបណា?» ជាការពិតណាស់ ខ្ញុំបានប្រាប់អ្នករួចមកហើយថាខ្ញុំបានសាបព្រោះកាំភ្លើងជាច្រើនក្នុងពេលអតីតកាល ក៏ប៉ុន្តែខ្ញុំមិនដែលនិយាយថា «ព្រះអម្ចាស់អើយកូននឹងយករបស់មួយនោះ។» រហូតពេលនោះចូលមកដល់។ ជាថ្មីម្តងទៀតនេះគឺជាគោលការណ៍កណ្តៀវដែលអ្នកត្រូវដឹង។ ក៏ប៉ុន្តែពេលឆ្លងកាត់គោលការណ៍កណ្តៀវហួសទៅ ខ្ញុំបានជាប់នៅក្នុងចំណែកទ្វេគុណក្នុងរបៀបដ៏ពិសេស និងច្បាស់ៗ ហើយខ្ញុំចង់ដឹងឱ្យប្រាកដថា

ខ្ញុំធ្វើរឿងនោះបានដោយរបៀបណា។ ខ្ញុំជឿថាព្រះអម្ចាស់បានបង្ហាញខ្ញុំថាក្នុងចំណោមយើងមានមនុស្សជាច្រើនដែលខកខានមិនបានដឹងពីទិដ្ឋភាពដ៏សំខាន់នៃការប្រមូលយកផលពីព្រះរាជ្យនៃព្រះនេះ ហើយខ្ញុំនឹងចំណាយពេលខ្លះនៅក្នុងជំពូកបន្ទាប់ដើម្បីនិយាយពីប្រធានបទនោះ។ ក៏ប៉ុន្តែមុនពេលដែលខ្ញុំធ្វើវា ខ្ញុំគ្រាន់តែត្រូវការចែករំលែកជាមួយអ្នកនូវរបៀបដែលរឿងជាច្រើននៅបន្តកើតឡើងក្នុងឆ្នាំមួយនោះ។

បន្ទាប់ពីខ្ញុំបានទទួលកាំភ្លើងតាមប្រអប់សំបុត្រមក រឿងមួយនេះក៏បានកើតឡើង ហើយវាគឺជារឿងមួយក្នុងចំណោមរឿងដ៏អស្ចារ្យជាច្រើន ដែលបានកើតឡើងស្របតាមការមើលឃើញចំណែកទ្វេដងបង្ហាញខ្លួននៅក្នុងរបៀបច្បាស់លាស់មួយ ពិតប្រាកដមួយ ហើយគ្មានសំណួរអ្វីច្រើនត្រូវសួរទេថានេះជាឧទាហរណ៍របស់ចំណែកទ្វេដង។ រឿងនេះមានពាក់ព័ន្ធនឹងយានជំនិះផ្សេងៗរបស់ខ្ញុំជាពិសេសគឺរថយន្ត Escalade គុជខ្យងពណ៌សរបស់ខ្ញុំ ដែលបានទទួល ហើយខ្ញុំបាននិយាយប្រាប់អ្នកកាលពីពីរបីជំពូកមុននេះ។ ដូចដែលខ្ញុំបាននិយាយពីមុនហើយនៅក្នុងសៀវភៅនេះថាឌ្រិនដា និងខ្ញុំមិនសូវជាចាប់អារម្មណ៍នឹងរឿងឡានប៉ុន្មានទេ។ ជាទូទៅយើងគ្រាន់តែបើកវារហូតដល់ថ្ងៃដែលវា លែងដំណើរការ ឬវាចាស់ពេកប្រើលែងកើតប៉ុណ្ណោះ។

ហើយជាថ្មីម្តងទៀតនៅក្នុងរឿងនេះ ខ្ញុំត្រូវតែប្រាប់អ្នកថាឌ្រិនដា និងខ្ញុំបានឱ្យឡានមួយចំនួនទៅគេកាលពីមុន ហើយយើងមិនបានទាមទារចង់បានអ្វីតាមរយៈជំនឿយើង ដែលយើងជឿថាធ្វើដើម្បីនឹងប្រមូលផលនៅពេលក្រោយពីការឱ្យមួយនោះទេ។ ក៏ប៉ុន្តែប្រសិនបើអ្នកនៅចាំរឿងនោះ ចាំពេលដែលយើងបានបើកឡាន Escalade ដែលយើងបានជួលអំឡុងពេលសន្និបាតរបស់យើង និងបាននិយាយថា «យើងចូលចិត្តឡាននេះ យើងគិតថាយើងគួរតែទិញឡាននេះមួយ» យើងមិនបានរំពឹងថាមាននរណាម្នាក់ទាក់ទងមកយើង និងនិយាយថាគេចង់ទិញឡាននោះមួយឱ្យយើងទេ។ ក៏ប៉ុន្តែជាការពិតណាស់ គឺរឿងបែបនោះបានកើតឡើងយ៉ាងពិតប្រាកដមែន។ ហើយនិយាយដោយត្រង់ចុះយើងមិនដែលប្រាប់នរណាម្នាក់ទេថាយើងចង់បានឡានដូចនេះមួយ។ ហេតុដូច្នេះហើយដូចដែលខ្ញុំបានប្រាប់អ្នកមុននេះ ឡាន Escalade ប្រភេទខ្លីពណ៌គុជខ្យងពណ៌ស បានបង្ហាញខ្លួនឡើងមក ហើយវាគ្រាន់តែជារឿងដែលពិតជាអស្ចារ្យមែន។ ខ្ញុំចូលចិត្តវាខ្លាំងណាស់។

ប៉ុន្តែវាមានកំណត់ចំណាំមួយផ្នែកទៀតកាន់តែអស្ចារ្យដែលទើបតែកើតឡើងនៅរដូវក្ដៅមុននេះ។ យើងប្រើប្រាស់ឡាន Escalade មួយនេះបានប្រហែលមួយឆ្នាំកន្លះ ហើយគិតមកត្រឹមរដូវក្ដៅមុននេះ ដែលក្នុងថ្ងៃមួយនោះខ្ញុំបានចាប់អារម្មណ៍ថាភ្លើងសញ្ញាដែលបង្ហាញថាម៉ាស៊ីនវាត្រូវការការត្រួតពិនិត្យបានបំភ្លឺឡើង។ ខ្ញុំគិតថា «គ្មានអ្វីធំដុំទេ» ប៉ុន្តែខ្ញុំនៅតែចង់ឆែកមើលដែរ ដូច្នេះខ្ញុំបានរកគេឱ្យជួយត្រួតពិនិត្យវា។ ពួកគេបានប្រាប់ថាវាពិតជាគ្មានអ្វីធំដុំឡើយ។ ឧបករណ៍ចាប់សញ្ញាចាប់បានូវដំណក់ប្រេងតូចមួយនៅក្នុងបំពង់ផ្សែង ប៉ុន្តែវាមិនបង្កបញ្ហាអ្វីទេ។ ម៉ាស៊ីនវានៅអាចដំណើរការបានយ៉ាងល្អ។ ខ្ញុំបានសួរថា ហេតុអ្វីបានជាវាទៅចាប់បានដំណក់ប្រេងទៅវិញ។ ដោយសារតែឡាន Escalade របស់ខ្ញុំមានប្រើប្រាស់ប្រព័ន្ធនៃបំពង់បញ្ចេញផ្សែងដែលទិញមកពីទីផ្សារ ទើបពួកគេគិតថានោះប្រហែលជាហេតុផលដែលធ្វើឱ្យវាមានលោតសញ្ញាត្រួតពិនិត្យ។ ត្រឡប់មកវិញ ពួកគេបាននិយាយថាម៉ាស៊ីនរបស់វាគ្មានបញ្ហាអ្វីឡើយ ហើយខ្ញុំគួរតែរំពឹងថាវានៅអាចដំណើរការបានយូរទៀត។

**ខ្ញុំព្យាយាមដេញតាមស្ដេច និងព្រះរាជ្យរបស់ទ្រង់ ដែលនៅក្នុងព្រះរាជ្យមួយនេះ ខ្ញុំបានបរិបូរ គឺជាចំណែកថ្ងៃដង!**

ថ្ងៃមួយ នៅក្នុងការសន្ទនាធម្មតាមួយ ខ្ញុំបានប្រាប់ទៅបុរសដែលបានផ្ដល់យានជំនិះឱ្យមកខ្ញុំអំពីបញ្ហានៃភ្លើងសញ្ញាមួយនោះ។ គាត់បាននិយាយថា «ត្រូវហើយ ខ្ញុំក៏បានឃើញរឿងបែបនេះកើតឡើងនៅលើឡាន GMC ដទៃទៀតដែរ។» លើសពីនេះទៅទៀតគាត់បានបន្តថា «វាជារឿងទូទៅទៅហើយសម្រាប់ឡានចាស់ៗ។» គាត់បានបន្ថែមទៀតថាវាគ្មានផ្ដល់ផលប៉ះពាល់ទៅដល់ឡានអ្វីឡើយ គឺថាអ្នកអាចប្រើប្រាស់វាបានប្រហែលជា ១០ឆ្នាំ ឬលើសពីនេះទៀតដោយគ្មានបញ្ហា។

គាត់បានដឹងថាឌ្រិនដា និងខ្ញុំមានផ្ទះនៅរដ្ឋផ្លរីដា ដែលខ្ញុំទើបតែទិញ។ ខ្ញុំស្ទើរតែតាំងស្មារតីទៅហើយនៅពេលដែលគាត់និយាយថា «ខ្ញុំសូមប្រាប់ដូចនេះទៅចុះ ចូរលោកបើកឡានមួយនេះទៅរដ្ឋផ្លរីដា និងប្រើវានៅទីនោះទៅ ហើយខ្ញុំនឹងទិញឡានមួយទៀតសម្រាប់លោកក្នុងការប្រើប្រាស់នៅទីនេះក្នុងរដ្ឋអូហៃយ៉ូ។» ត្រូវហើយ ឥលូវនេះខ្ញុំមានគុជខ្យងពណិសចំនួនពីរ ដែលជាឡាន Escalades ដែលល្អគ្រប់ចំណុច លើកលែងតែរឿងទាក់ទងទៅនឹងប្រដាប់ចាប់សញ្ញាដែលខ្ញុំបានជួបប្រទះមុនហ្នឹង។ ពួកវាទាំងពីរពិតជាល្អ

គ្រប់ចំណុច! ម្តងទៀត វាគឺមួយក្នុងចំណោមពេលវេលា ទាំងនោះ «តើអ្នកបានឃើញវាដែរឬទេ?» ឌ្រិនដា និងខ្ញុំបានក្តិចខ្លួនឯង នៅពេលកំពុងបើកបរយានជំនិះដ៏ស្រស់ស្អាតទាំងនោះ។ យើងមិនបានចេញលុយសម្រាប់ពួកវាណាមួយឡើយ។ នៅក្នុងស្ថានភាពមួយនេះ យើងអាចដឹងបានថាវាគឺជាចំណៃទ្វេគុណ។

ខ្ញុំមិនមែនប្រាប់អ្នករាល់គ្នានូវរឿងមួយនេះដើម្បីជាការអួតដាក់អ្នករាល់គ្នាឡើយ តែមិត្តអើយ ខ្ញុំបានទទួលពរ! ខ្ញុំកំពុងតែរីករាយជាមួយនឹងចំណែកទ្វេដង ដែលឥឡូវនេះអ្នកទាំងអស់គ្នាបានដឹងហើយថាវាគឺជាភាពពេញបរិបូរ។ ខ្ញុំមានកាំភ្លើងសុវត្ថិភាពពរពេញទៅដោយកាំភ្លើង ដែលពេញបរិបូរ។ ខ្ញុំបានទទួលឡាន Escalades ដូចគ្នាពីរគ្រឿងដោយមិនបាច់ចំណាយលុយ។ ខ្ញុំគិតថាអ្នកច្បាស់ជាយល់ស្របដែលហើយដែលថាវាជាអ្វីដែលបរិបូរ! ប៉ុន្តែមិនមែនបានន័យថាខ្ញុំលើកទឹកចិត្តឱ្យអ្នករាល់គ្នាផ្តោតទៅលើសម្ភារៈនិយមឡើយ។ ខ្ញុំមិនឱបក្រសោបជាមួយនឹងសម្ភារៈទាំងនោះឡើយ ហើយខ្ញុំក៏មិនទៅថ្វាយបង្គំ ឬដេញតាមចាប់យកវាដែរ។ តែខ្ញុំព្យាយាមដេញតាមស្តេច និងព្រះរាជ្យរបស់ទ្រង់ ដែលក្នុងព្រះរាជ្យមួយនេះ ខ្ញុំបានបរិបូរ ដែលវាគឺជាចំណែកទ្វេដងនោះឯង!

ចាំបន្តិច ខ្ញុំមិនទាន់បានបញ្ចប់នូវការថ្លែងទីបន្ទាល់ពីភាពជាព្រះ និងចំណែកទ្វេដងនៅឡើយទេ។

ប្រពន្ធខ្ញុំមានបំណងចង់បានផ្ទះនៅជាប់នឹងឆ្នេរសមុទ្រអស់រយៈពេល ២០ឆ្នាំមកហើយ។ ទេ ខ្ញុំសូមនិយាយវាឡើងវិញម្តងទៀត។ គាត់ចង់បានជាវាតាំងពីដើមមក! គាត់ស្រលាញ់សមុទ្រជាខ្លាំង! ទោះជាយ៉ាងណាក្តី គាត់បានមើលថែនូវធនធានសមុទ្រអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ តាំងពីដើមឡើយ នៅពេលដែលមានផ្ទះដែលគាត់ពេញចិត្ត លុយរបស់យើងតែងតែត្រូវបានរៀបចំទុកសម្រាប់ការធ្វើព័ន្ធកិច្ច ហើយយើងក៏បន្តរង់ចាំ។ ហើយឆ្នាំនេះ ខ្ញុំបានកំពុងអធិស្ឋាននៅជាន់ក្រោម ស្របពេលដែលខ្ញុំកំពុងជិះកង់ (stationary bike) ស្រាប់តែព្រះជាម្ចាស់បានធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាខ្លាំងដោយទ្រង់មានបន្ទូលថា «ចូរប្រាប់ឌ្រិនដាឱ្យធ្វើដំណើរទៅរដ្ឋផ្លរីដា ទៅកាន់តំបន់មួយនោះដែលគាត់បានផ្ទះនៅទីនោះ ហើយប្រាប់គាត់ឱ្យទិញផ្ទះជាប់ឆ្នេរសមុទ្រនៅក្នុងសប្តាហ៍នេះ។» សប្តាហ៍នេះ? វាពិតជាមានភាពប្រញាប់ប្រញាល់បន្តិចមែននៅក្នុងព្រលឹងខ្ញុំ ពេលដែលខ្ញុំបានឮរឿងនេះ។ ដូច្នេះខ្ញុំបានប្រាប់ឌ្រិនដាអំពីអ្វីដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំ ហើយពួកយើង

បានទាក់ទងទៅកាន់មិនតភក្តិយើងម្នាក់ដែលរស់នៅក្នុងទីក្រុងនោះក្នុងការបើកឡានជូនគ្រិនដាជិះជុំវិញពីរទៅបីថ្ងៃដើម្បីដើរមើលផ្ទះ។ គាត់ក៏បានយល់ព្រម។

ហើយគ្រិនដាបានមើលអ៊ីនធើណិត ហើយបង្កើតបញ្ជីឈ្មោះផ្ទះចំនួន ២៥ ដែលគាត់ចង់ទៅមើល។ ពេលសរសេរឈ្មោះផ្ទះទាំងនោះហើយ គ្រិនដាបានបង្រួមនូវបញ្ជីឈ្មោះផ្ទះពី ២៥ មកនៅត្រឹមតែ៥ ដែលអាចទិញបាន និងផ្ទះមួយដែលគាត់ពេញចិត្តប៉ុណ្ណោះ។ នៅក្នុងពេលនោះ ខ្ញុំចូលរួមមើលផ្ទះជាមួយគាត់យ៉ាងឆាប់រហ័ស ហើយគាត់បានបង្ហាញខ្ញុំនូវផ្ទះទាំង ៥ និងផ្ទះមួយដែលគាត់ពេញចិត្ត។ ពួកយើងបានពង្រួមបញ្ជីពី ៥ មកនៅត្រឹមតែ ២ ប៉ុណ្ណោះ គឺផ្ទះមួយដែលគាត់ចូលចិត្ត និងផ្ទះមួយទៀតដែលស្រស់ស្អាតខ្លាំង ប៉ុន្តែមិនស្អាតដល់ផ្ទះដែលគាត់ពេញចិត្តឡើយ។ ខ្ញុំត្រូវតែសារភាពនូវរឿងមួយនេះ នៅពេលដែលខ្ញុំបានឃើញផ្ទះដែលគាត់ពេញចិត្តហើយ ខ្ញុំបានដឹងយ៉ាងច្បាស់ថានេះគឺជាផ្ទះរបស់គ្រិនដាមែន ហើយចុងក្រោយយើងក៏បានស្នើសុំទិញផ្ទះនោះ។ ម្ចាស់ផ្ទះបានទទួលយកសំណើរយើង ហើយយើងបានចុះកុងត្រាទិញផ្ទះថ្មីនោះជាមួយគ្នា។

ពីរបីអាទិត្យក្រោយមក នៅពេលដែលយើងកំពុងសម្រាកនៅក្នុងផ្ទះរបស់យើងនៅក្នុងរដ្ឋអូហៃយ៉ូ គ្រិនដាបានដកដង្ហើមធំហើយនិយាយថា «នេះគឺជាផ្ទះរបស់អូន!» ខ្ញុំបានឆ្លើយទៅវិញថា «បងដឹងហើយថានេះជាផ្ទះរបស់អូន ព្រះជាម្ចាស់បានប្រាប់បងឱ្យទិញផ្ទះជាប់សមុទ្រសម្រាប់អូននៅសប្តាហ៍ដែលបងជូនអូនទៅកាន់សមុទ្រនោះ។»

គាត់តបថា «មិនមែនទេ បងមិនយល់ទេ នោះគឺពិតជាផ្ទះរបស់អូនមែន!» គាត់ព្យាយាមពន្យល់ថាគាត់បានស្វែងរកផ្ទះនៅក្នុងតំបន់នោះជាច្រើនឆ្នាំមកហើយ ហើយថ្ងៃមួយគាត់បានឃើញរូបភាពនៃផ្ទះដែលយើងបានទិញនោះនៅលើការផ្សព្វផ្សាយរបស់ក្រុមហ៊ុនអចលនទ្រព្យ។ គាត់បានពេញចិត្តនឹងវាតាំងតែពីពេលដែលគាត់បានឃើញវាទៅហើយ។ គាត់ស្រលាញ់នូវអ្វីគ្រប់យ៉ាងដែលវាមាន ទាំងប្រភេទស្ថាបត្យកម្មតំបន់មេឌីទែរ៉ាណេរបស់ប្រទេសអេស្ប៉ាញ ទាំងគម្រោងគ្រប់ជាន់ ទាំងទីតាំង គឺគ្រប់យ៉ាងទាំងអស់។ គាត់ថែមទាំងចាំថាគាត់បានចង្អុលលើវាហើយនិយាយថា «ព្រះជាម្ចាស់អើយ កូនចង់បានផ្ទះនេះ!» គាត់បានដឹងថាផ្ទះនោះគឺពិតជាថ្លៃខ្លាំងណាស់ ហើយលុយរបស់យើងបានប្រើប្រាស់សម្រាប់គម្រោងផ្សេងទៅហើយ ដូច្នេះគាត់ក៏បន្តរកមើលផ្ទះផ្សេងដែលមានតម្លៃល្មមសម្រាប់លុយដែលយើងមាននៅពេលនោះ។ ប៉ុន្តែគ្មានផ្ទះណាផ្សេងទៀតឡើយ ហើយ

យើងមិនដែលបានឈានទៅដល់ការចុះកុងត្រាសូម្បីតែម្តង។ យើងគ្រាន់តែដូចជាមិនទាន់មានសន្តិភាពអំពីផ្ទះណាមួយឡើយ។

អ្នកគួតែដឹងហើយថាយើងបានសាបព្រោះគ្រាប់ពូជសម្រាប់ផ្ទះនៅឆ្នេរសមុទ្រមួយនេះអស់រយៈពេលជាងពីរឆ្នាំទៅហើយ។ ហើយការសារភាពដែលពួកយើងមាននៅក្នុងពេលនេះគឺ យើងមានផ្ទះនៅឆ្នេរសមុទ្រមួយនៅក្នុងតំបន់នេះ យើងបានទទួលវារួចទៅហើយ ហើយយើងទទួលបានតាំងពីថ្ងៃដែលយើងបានសាបព្រោះនោះឯង។ ខ្ញុំអាចចាំពីទីកន្លែង និងពេលដែលយើងបានចាប់ដៃគ្នា និងបានព្រមព្រៀងគ្នាថានឹងទិញផ្ទះនៅឆ្នេរសមុទ្រឱ្យឌ្រិនដា។ ហើយឥឡូវនេះពេលដែលយើងបានចុះកុងត្រាហើយ ឌ្រិនដាស្រាប់តែនឹកឃើញរូបភាពដែលគាត់បានឃើញកាលពីពីរឆ្នាំមុន ហើយដឹងថាវាជាផ្ទះតែមួយ គឺផ្ទះរបស់គាត់!

បន្ទាប់ពីបានសាកសួរពីប្រវត្តិនៃផ្ទះហើយ យើងបានដឹងថាម្ចាស់ផ្ទះបានព្យាយាមលក់ផ្ទះនោះអស់រយៈពេលពីរទៅបីឆ្នាំទៅហើយ ប៉ុន្តែគ្មានអ្នកទិញទេ ទើបគាត់ដកការផ្សព្វផ្សាយលក់ចេញទៅ។ ពេលនោះហើយដែល ឌ្រិនដាបានឃើញរូបនោះនៅក្នុងបញ្ជីរបស់ក្រុមហ៊ុនអចលនៈទ្រព្យ។ ប៉ុន្តែម្ចាស់ផ្ទះបានសម្រេចចិត្តដាក់វាបញ្ចូលទៅក្នុងបញ្ជីលក់ម្តងទៀត ហើយវាក៏អាចជាហេតុផលដែលធ្វើឱ្យខ្ញុំបានប្រាប់ឌ្រិនដាឱ្យប្រញាប់ទៅមាត់សមុទ្រដោយនិយាយថា «អូននឹងទិញផ្ទះនៅក្នុងអាទិត្យនេះ។» គាត់នឹងប្រាប់អ្នកថាវាមិនមែនជារបៀបដែលខ្ញុំតែងចាយលុយនោះទេ។ អ្វីៗទាំងអស់គឺអាស្រ័យទៅលើពេលវេលាដែលត្រឹមត្រូវ។ តែពេលនោះលុយខ្ញុំមិនត្រូវជាប់យកទៅប្រើប្រាស់ក្នុងគម្រោងណាមួយឡើយ ហើយខ្ញុំអាចប្រើលុយខ្ញុំដើម្បីទិញផ្ទះនោះបាន។ ខ្ញុំប្រាកដណាស់ថាច្បាស់ជាមានមនុស្សជាច្រើនដែលកំពុងតែមើលផ្ទះនឹងដូចគ្នា ហើយវាហើយជាហេតុផលដែលយើងត្រូវរួសរាន់ទិញផ្ទះនោះ។ អ្វីដែលអស្ចារ្យនោះគឺតម្លៃផ្ទះមិនបានឡើងលើសពីតម្លៃដែលយើងបានឃើញនៅក្នុងបញ្ជីតាំងពីពីរឆ្នាំមុននោះទេ។ ខ្ញុំជឿថាព្រះជាម្ចាស់បានរក្សាទុកផ្ទះនោះឱ្យគាត់។

ក៏ប៉ុន្តែផ្នែកដែលនិយាយពីចំណែកទ្វេដងនៃរឿង គឺស្ថិតនៅត្រង់នេះ។ នៅពេលស្ថិតក្នុងដំណាក់កាលរង់ចាំចុះកុងត្រាទិញផ្ទះនៅឡើយ ម្តាយរបស់ឌ្រិនដា បានទូរស័ព្ទមកយើង។ ពួកគាត់មានផ្ទះមួយនៅក្នុងប្រទេសកាណាដា ៣២ឆ្នាំទៅហើយ។ ពួកយើងធ្លាប់បានទៅលេងផ្ទះនោះជាញឹកញាប់បានច្រើនឆ្នាំដែរ។ ហើយពួកយើងក៏ស្រលាញ់ផ្ទះនោះ

និងទីតាំងនោះដែរ។ ផ្ទះនោះជាផ្ទះក្បែរទឹក នៅលើកោះមួយ។ និយាយទៅ សមុទ្រនៅចម្ងាយប្រមាណជាជាង ៩ម៉ែត្រពីរានហាលខាងក្រោយផ្ទះប៉ុណ្ណោះ។ ឪពុកម្ដាយរបស់ឌ្រិនដា មានវ័យចំណាស់ទៅហើយ ហើយពួកគាត់ក៏សម្រេចចិត្តថាគាត់មិនចង់ចេញថ្លៃថែទាំ និងការចំណាយទៅផ្ទះដែលនៅឆ្ងាយទៀតទេ។ ពួកគាត់មករកយើង ហើយសួរយើងថាតើយើង ចង់ទិញផ្ទះនោះឬទេ ហើយខ្ញុំបានឆ្លើយថាអត់ទេ។ វាត្រូវចំណាយពេលបើកបរប្រហែល ៣១ម៉ោងពីរដ្ឋអូហៃយ៉ូដើម្បីទៅកាន់ទីនោះ ដូច្នេះទោះជាខ្ញុំស្រលាញ់កន្លែងនោះក៏ដោយ តែខ្ញុំគិតថាខ្ញុំមិនអាចទៅកន្លែងនោះបានញឹកញាប់ឡើយ ដោយសារតែរយៈពេលដែលត្រូវធ្វើដំណើរ។ ដូច្នេះ ពួកគេក៏ដាក់ផ្ទះនោះចូលទៅក្នុងបញ្ជី របស់ភ្នាក់ងារអចលនៈទ្រព្យ ប៉ុន្តែអស់រយៈពេលពីរឆ្នាំទៅហើយគ្មានអ្នកណាម្នាក់ចាប់អារម្មណ៍ចង់ទិញផ្ទះនោះឡើយ។

ដូច្នេះនៅពេលនេះ ដែលយើងកំពុងតែរង់ចាំបញ្ចប់ការធ្វើកុងត្រាផ្ទះជាប់ឆ្នេរសមុទ្ររបស់យើង ពួកគាត់បានទូរស័ព្ទមក ហើយប្រាប់ថាពួកគាត់បានព្យាយាមលក់ហើយ តែមិនបានជោគជ័យទេ ហើយពួកគាត់ចង់ទម្លាក់តម្លៃមកត្រឹមពាក់កណ្ដាល ប្រសិនបើពួកយើងចង់ទិញវាទុកជាកម្មសិទ្ធិរបស់គ្រួសារ។ ពេលខ្ញុំគិតអំពីរឿងនោះ ថាកូនៗរបស់ខ្ញុំធំៗហើយ ពួកគេអាចទៅលេងកន្លែងនោះបាន ហើយវាពិតជាកន្លែងដ៏ស្រស់ស្អាតមួយ។ ដូច្នេះឌ្រិនដា និងខ្ញុំបានអធិស្ឋានអំពីកិច្ចការនោះ និងបាននិយាយគ្នាថាពួកយើងនឹងទិញវា។ យើងក៏មានលុយគ្រប់គ្រាន់នៅក្នុងដៃដើម្បីទិញវាតែម្ដង។ ម្យ៉ាងវិញទៀត ពួកយើងបានទិញយន្តហោះមួយសម្រាប់ក្រុមហ៊ុនរបស់ខ្ញុំកាលពីឆ្នាំមុន ដែលអាចជួយឱ្យយើងធ្វើដំណើរត្រឹមតែ ៥ម៉ោងប៉ុណ្ណោះ មិនចាំបាច់ជិះឡានដែលត្រូវចំណាយពេលរហូតទៅដល់ ៣១ម៉ោងទេ។ វាអាចជួយយើងឱ្យទៅទីនោះបានកាន់តែលឿន។

**ចូរកុំគិតថាចំណែកទ្វេដងគឺគ្រាន់តែជាការដែលទទួលបាននូវអ្វីមួយ ត្រឹមតែមួយទ្វេរជាពីរឡើយ។ តាមពិតទៅ ចំណែកទ្វេដងគឺមានន័យជាសាមញ្ញថាជាការមានភាពពេញបរិបូរ។**

បន្ទាប់ពីពេលដែលយើងបានបញ្ចប់កិច្ចការទិញផ្ទះទាំងពីរនោះ មានពេលមួយខ្ញុំបានអង្គុយនៅក្នុងការិយាល័យខ្ញុំ ហើយស្រាប់តែនឹកឃើញថា «នេះហើយទេតើ ដែលជាចំណែកទ្វេដង!» ប្រពន្ធរបស់ខ្ញុំមានក្ដីស្រមៃចង់បានផ្ទះនៅក្បែរសមុទ្រជាច្រើនឆ្នាំណាស់

មកហើយ។ ឥលូវនេះ នៅក្នុងអំឡុងពេលត្រឹមតែពីរខែ គាត់បានទទួលផ្ទះមួយដែលស្ថិតនៅភាគខាងកើតនៃសហរដ្ឋអាមេរិកដែលមានអាកាសធាតុកក់ក្តៅនៅរដូវរងា តែក្តៅខ្លាំងនៅរដូវក្តៅ។ ប៉ុន្តែផ្ទះនៅប្រទេសកាណាដាវិញ គឺល្អឥតខ្ចោះសម្រាប់រដូវក្តៅ ហើយប្រែជាត្រជាក់ខ្លាំងនៅរដូវរងា។ យើងក៏បានឃើញថាគាត់មានផ្ទះនៅឆ្នេរសមុទ្រសម្រាប់រដូវទាំងពីរតែម្តង ពិតជាអស្ចារ្យណាស់។ យើងពិតជាបានសួរគ្នាថា «តើអូន/បង បានឃើញឬទេ?» នៅពេលដែលយើងបានបញ្ចប់ការទិញផ្ទះទាំងពីរនោះ។ ខ្ញុំគិតថាអ្នកក៏យល់ស្របដែរថា វាមានរូបរាង និងក្លិនដូចជាចំណែកទ្វេដងពិតមែន។ ពិតជាអស្ចារ្យណាស់!

ខ្ញុំបានបង្ហាញឧទាហរណ៍មួយចំនួនហើយទាក់ទងទៅនឹងវិធីដែលព្រះជាម្ចាស់បាននាំយករបស់មកឱ្យយើងទ្វេដង ដែលឌ្រិនដា និងខ្ញុំជឿថាព្រះជាម្ចាស់បានប្រើ ដើម្បីឱ្យយើងមើលឃើញពីដំណើរការរបស់ចំណែកទ្វេដង។ ប៉ុន្តែខ្ញុំចង់ឱ្យប្រាកដថាអ្នកមិនបានគិតថាចំណែកទ្វេដង គឺគ្រាន់តែជាការដែលទទួលបាននូវរឿងតែពីរតែប៉ុណ្ណោះទេ។ តាមពិតទៅចំណែកទ្វេដងគឺមានន័យជាសាមញ្ញថា ការទទួលបាននូវភាពពេញបរិបូរ។ ព្រះជាម្ចាស់បានប្រើប្រាស់នូវឧទាហរណ៍ប្លែកពីគេ អំពីការទទួលបានរបស់ចំនួនពីរដើម្បីឱ្យខ្ញុំចាប់អារម្មណ៍អំពីចំណែកទ្វេដង។ ដូច្នេះទោះជាវាជាអ្វីក៏ដោយ ឱ្យតែវាជាការដែលផ្តត់ផ្គង់ជាបរិបូរ នោះវាគឺជាចំណែកទ្វេដងហើយ។ ខ្ញុំសង្ឃឹមថាអ្នកយល់ពីសេចក្តីពិតនៃចំណែកទ្វេដង និង ការសម្រាកក្នុងថ្ងៃសប្ប័ទ។ ជីវិតពិតជាអស្ចារ្យណាស់នៅក្នុងព្រះរាជ្យរបស់ទ្រង់! នៅពេលដែលខ្ញុំសរសេរជំពូកនេះ ខ្ញុំកំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្ញុំក្នុងប្រទេសកាណាដា ហើយកំពុងមើលទៅសមុទ្រតាមមាត់បង្អួច។ វាមានសត្វរំពេ និងទាជាច្រើនកំពុងលេងនៅតាមឆ្នេរចំងាយប្រហែលជាត្រឹមតែជាង ២២ម៉ែត្រពីផ្ទះប៉ុណ្ណោះ។ មានសេចក្តីសុខសាន្តគ្មានការខំប្រឹងប្រែង គ្មានជំពាក់អ្វី ហើយវាជាព្រះពរ។ ខ្ញុំកំពុងតែធ្វើកិច្ចការដែលបានប្រគល់មកឱ្យខ្ញុំ គឺការចែកចាយពីដំណឹងល្អអំពីព្រះរាជ្យរបស់បិតាខ្ញុំ ហើយជាកូនប្រុសម្នាក់នៅក្នុងផ្ទះរបស់ទ្រង់ ជាប្រជាជនម្នាក់នៅក្នុងព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ ហើយខ្ញុំកំពុងតែរីករាយក្នុងការទទួលបានចំណែកទ្វេដងនេះ!

ឌ្រិនដា និងខ្ញុំអាចសរសេររឿងជាច្រើនអំពីរបៀបដែលព្រះរាជ្យរបស់ព្រះ និងច្បាប់ដែលគ្រប់គ្រងព្រះរាជ្យ បានជះឥទ្ធិពលមកលើជីវិតរបស់ពួកយើង រួមទាំងមនុស្សរាប់ពាន់អ្នកដែលបានផ្ញើអ៊ីមែលមកកាន់យើង ទាំងប្រាប់រឿងរបស់គេដល់យើងផង។ ដូចដែលខ្ញុំបានចែកចាយដូច្នេះដែរ អ្នកទាំងអស់គ្នាអាចអាននូវរឿងទាំងនេះនៅក្នុងព្រះគម្ពីរបាន

ប៉ុន្តែការដែលឃើញរឿងរ៉ាវក្នុងព្រះគម្ពីរ កើតឡើងពិតមែននៅចំពោះមុខយើង គឺជារឿងដែលរំភើបជាង។

ខ្ញុំចង់បន្ថែមការកត់សម្គាល់មួយទៀតនៅត្រង់នេះ។ រឿងនេះស្ដាប់ទៅពិតជាដូចការលេងល្បែងអីចឹង ក្នុងការដែលខ្ញុំនិយាយប្រាប់អ្នកដទៃពីរបៀបដែលព្រះជាម្ចាស់បានប្រទានពរ មកកាន់ឌ្រីនដា និងខ្ញុំ និងដំណើរដែលពួកយើងបានឆ្លងកាត់។ ពេលខ្លះក៏មានអ្នកយល់ច្រឡំដែរ។ ជួនការពួកគេគិតថាពួកយើងកំពុងតែមានអំនួត និងធ្វើការអួតអាងប៉ុណ្ណោះ។ ហើយពេលខ្លះទៀតក៏មានអ្នកយល់ច្រឡំថាពួកយើងបានយកតង្វាយរបស់ពួកគេមកប្រើប្រាស់សម្រាប់ខ្លួនឯង។ ប៉ុន្តែសូមយល់ថាឌ្រីនដា និងខ្ញុំមិនបានយកលុយដែលបានបកពីការផ្សព្វផ្សាយតាមទូរទស្សន៍ ហើយយើងមិនបានយកលុយពីការលក់ធនធានរបស់យើងដែរ។ ក៏ប៉ុន្តែវាប្រាកដណាស់ថាយើងទទួលបានប្រាក់ខែ ពីក្រុមជំនុំដែលយើងធ្វើជាគ្រូគង្វាល។ យើងក៏មានមុខជំនួញរបស់យើង ហើយវាតែងតែមានដំណើរការជានិច្ច ព្រះជាម្ចាស់ក៏បានប្រទានព្រះពរទៅក្នុងមុខជំនួញទាំងនោះដែរ។ ខ្ញុំគ្រាន់តែចង់ឱ្យអ្នករាល់គ្នាយល់ពីបំណងនៃការដែលពួកយើងចែករំលែកពីរឿងផ្ទាល់ខ្លួនរបស់យើង។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវការប្រាប់អ្នកពីអ្វីដែលយើងបានឃើញ អ្វីដែលពិតជាបានកើតឡើង និងអ្វីដែលព្រះបានបង្រៀនពួកយើងអំពីព្រឹត្តិការណ៍ទាំងអស់នោះឡើយ។ ចំពោះលទ្ធផលដែលខ្ញុំកំពុងតែចែករំលែកជាមួយអ្នករាល់គ្នា គឺមិនមែនជាលទ្ធផលរបស់ហ្គារី និងឌ្រីនដាឃីស៊ី ឡើយ ពួកយើងមិនល្អដល់ម្លឹងទេ! អ្វីដែលពួកយើងបានឃើញ និងរីករាយជាមួយនោះគឺជាលទ្ធផលដែលបានមកពីព្រះបិតា និងព្រះរាជ្យរបស់ទ្រង់នៅក្នុងជីវិតរបស់ពួកយើង។ ពួកយើងចែករំលែកពីរឿងទាំងអស់នេះ ព្រោះតែពួកយើងចង់ឱ្យអ្នកទាំងអស់គ្នាយល់តែប៉ុណ្ណោះ! ពួកយើងបានចាប់ផ្ដើមពីគ្មានអ្វីសោះ ហើយហេតុផលដែលខ្ញុំសរសេរសៀវភៅមួយនេះឡើងសម្រាប់អ្នកទាំងអស់គ្នា! ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាបានដឹងអំពីរបៀបដែលវាបានកើតឡើង ដើម្បីឱ្យអ្នកយល់ និងទទួលបាននូវអ្វីដែលព្រះមានសម្រាប់អ្នករាល់គ្នាដែរ។

សូមយល់ថាខ្ញុំជាមនុស្សដែល មិនចូលចិត្តភាពក្រីក្រដែលមានចិត្តឆេះឆួលឡើយ។ ក្នុងអំឡុងពេលប្រាំបួនឆ្នាំនោះ ខ្ញុំបានរស់នៅក្នុងភាពស្មុគស្មាញ និងភាពភ័យខ្លាចដែលអាចប្រៀបបានទៅនឹងការរស់នៅក្នុងស្ថាននរកនៅផែនដីដូច្នេះដែរ។ ខ្ញុំសង្ឃឹមថាអ្នកនឹងអាចចងចាំបានថាការសម្រាកថ្ងៃសប្ប័ទគឺជារបស់អ្នករាល់គ្នា និងជារបស់ខ្ញុំផងដែរ!

នៅក្នុងជំពូកបន្ទាប់ខ្ញុំនឹងជួយឱ្យអ្នករាល់គ្នាយល់ពីរបៀបនៃការចូលទៅកាន់ការសម្រាកក្នុងថ្ងៃសប្ប័ទ។

គ្រាន់តែជាកំណត់ចំណាំបន្ថែមមួយ សម្រាប់ជំពូកនេះតែប៉ុណ្ណោះ។ គឺថានៅពេលដែលខ្ញុំបានសរសេរបញ្ចប់ប្រយោគខាងលើ លេខារបស់ខ្ញុំបានចូលមកដល់ ហើយប្រាប់ខ្ញុំថាមានប្រអប់មួយទើបតែបានបញ្ជូនមកដល់។ ខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលបើកវា ខ្ញុំបានឃើញកាំភ្លើងពីរដើមដ៏ស្រស់ស្អាត។ វាគឺពិតជារឿងមួយដែលជួយលើកទឹកចិត្តយ៉ាងខ្លាំង! ប្រៀបបីដូចជាព្រះជាម្ចាស់បានបានដាក់ពាក្យថា «អាម៉ែន» ពីលើអ្វីដែលខ្ញុំទើបតែបាននិយាយរួច។

បន្ទាប់ពីសៀវភៅនេះបានបញ្ជូនទៅបោះពុម្ព ហើយខ្ញុំបានទទួលសៀវភៅពីឡានដំបូង ដែលដឹកសៀវភៅមក ខ្ញុំពិតជាសប្បាយរីករាយក្នុងការបង្រៀនអំពីគោលការណ៍ទាំងអស់នេះជាលើកទីមួយនៅក្នុងសន្និបាត បដិវត្តន៍អាត្លង់តា (Atlanta Revolution) របស់យើង។ ខ្ញុំក៏រីករាយផងដែរក្នុង ដែលបានចែករំលែកសៀវភៅថ្មីរបស់ខ្ញុំជាមួយពួកគេ។ នៅពេលដែលខ្ញុំត្រៀមខ្លួនរួចរាល់នឹងដើរចូលទៅក្នុងសាលប្រជុំដើម្បីធ្វើការអធិប្បាយ លេខារបស់ខ្ញុំបានហៅខ្ញុំ ហើយប្រាប់ខ្ញុំថាបុរសម្នាក់ដែលបានឱ្យកាំភ្លើងមួយគូដំបូងមកខ្ញុំបានទូរស័ព្ទមកខ្ញុំ និងប្រាប់ថាគាត់មានរឿងចង់និយាយជាមួយខ្ញុំឥឡូវនេះ។ ដូចនេះខ្ញុំក៏បានទូរស័ព្ទទៅគាត់វិញជាប្រញាប់។ គាត់បានពន្យល់ទាំងមានចិត្តរំភើបថាគាត់ទើបតែបានទៅការិយាល័យ UPS ហើយបានផ្ញើកាំភ្លើងពីរដើមទៀតមកឱ្យខ្ញុំ! គាត់ក៏បានផ្ញើកាំភ្លើងមួយទៅឌ្រិនដាដែរ ហើយដោយគាត់បានដឹងថាឌ្រិនដាមិនទៅបរបាញ់ទេនោះ គាត់បានផ្ញើជាលុយ ១៥០០ ដុល្លារទៅឌ្រិនដា ដែលសុទ្ធតែជាលុយក្រដាស ១០០ដុល្លារ។ ខ្ញុំបានភ្ញាក់ផ្អើលជាខ្លាំង។ ខ្ញុំមានអារម្មណ៍ថាវាជាអ្វីដែលព្រះបានប្រទានឱ្យដើម្បីបញ្ជាក់ជាថ្មីម្តងទៀតពីអ្វីដែលខ្ញុំបានធ្វើ និងជារបៀបមួយដែលប្រាប់ខ្ញុំឱ្យនៅតែធ្វើវាបន្តទៅទៀត។ មនុស្សទាំងអស់គួតែដឹងអំពីកិច្ចការនេះ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឱ្យអ្នកបានដឹងពីវាដូចគ្នា។ ហើយនៅពេលដែលខ្ញុំមកដល់ផ្ទះ ខ្ញុំពិតជារំភើបណាស់ក្នុងការបើកប្រអប់នោះ។ ឌ្រិនដានិងខ្ញុំបានទទួលកាំភ្លើងខ្លីជាគូនឹងគ្នា ប្រភេទ Browning over-and-under shotguns ស្រស់ស្អាតជាងគេដែលខ្ញុំធ្លាប់បានឃើញ។ កាំភ្លើងទាំងពីរជារបស់ថ្មីទាំងអស់។ ខ្ញុំក៏បានទទួលកាំភ្លើង Browning ស្វ័យប្រវត្តិពណ៌មាសលេខ ២០ ហើយឌ្រិនដាបានទទួលលុយ ១៥០០ ដុល្លារជារបស់គាត់។ នោះហើយគឺជាចំណែកទ្វេដង!

អ្នកប្រហែលជាឆ្ងល់ហើយថាហេតុអ្វីបានជាត្រូវមានកាំភ្លើងច្រើនដូច្នេះ។ ខ្ញុំទទួលស្គាល់ថាខ្ញុំពិតជាមានកាំភ្លើងស្អាតៗជាច្រើន ពួកវាក៏មិនមែនជារបស់ថោកៗដែរ ហើយក៏បានសួរសំណួរដូចគ្នានេះដែរ។ ព្រះជាម្ចាស់អនុញ្ញាតឱ្យខ្ញុំដឹងថាទ្រង់បានបញ្ជូនកាំភ្លើងជាច្រើនដែលមានតម្លៃថ្លៃ និងស្រស់ស្អាតមកខ្ញុំ ដើម្បីឱ្យខ្ញុំបានឃើញថាតើធនធានដែលទ្រង់មានច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណា ហើយការផ្តល់ឱ្យរបស់ទ្រង់វាលើសពីសេចក្តីរំពឹងរបស់ខ្ញុំប៉ុណ្ណា គឺលើសពីអ្វីដែលខ្ញុំរំពឹងទុក និងលើសពីអ្វីដែលខ្ញុំត្រូវការដើម្បីឱ្យតាបានរស់ទៅទៀត។ ខ្ញុំបានទទួលវា! ខ្ញុំក៏បានឃើញវា។

# ជំពូក ១០

# អាថ៌កំបាំងនៃចំណែកទ្វេដង

ពេលនេះ ខ្ញុំបាននិយាយក្តោបលើអ្វីដែលជាការសម្រាកនៅថ្ងៃសប្ប័ទ និងរបៀបដែលអាចធ្វើទៅបានតាមរយៈចំណែកទ្វេដង។ សំណួរដែលអ្នកគួរតែនឹកឃើញនោះគឺ «តើខ្ញុំអាចចូលក្នុងចំណែកទ្វេដងបានយ៉ាងដូចម្ដេច?» មែនហើយ ខ្ញុំពិតជារីករាយណាស់ដែលអ្នកបានសួរ! ដើម្បីឆ្លើយសំណួរនេះ ចូរយើងត្រលប់ទៅមើលសាច់រឿងដែលព្រះយេស៊ូបានប្រទាននំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយដល់បុរសចំនួន ៥,០០០ នាក់។

*ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សិស្សនាំគ្នាចូលមកគាល់ព្រះយេស៊ូ ទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ ថ្ងៃក៏ជិតលិចផង សូមប្រាប់អ្នកទាំងនេះឱ្យត្រឡប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះ តាមភូមិជិតៗនេះ»។*

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ!»។ គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីររយដួង ទៅទិញម្ហូបអាហារឱ្យគេបរិភោគឬ?»។*

*ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»។*

*កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។*

*ព្រះយេស៊ូបង្គាប់ពួកសិស្សឱ្យប្រាប់បណ្ដាជន អង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉័ងប្រទានឱ្យពួកសិស្ស ដើម្បីឱ្យគេ*

*ចែកបណ្តាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឱ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំបុ័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំបុ័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

ម៉ាកុស ៦៖៣៥-៤៤

**មាននូវវិធីដ៏ប្រសើរជាងនេះដើម្បីរស់នៅ ជាជាងការគ្រាន់តែចង់បានមួយឆ្អែត។ អ្នកមិនអាចកសាងបានច្រើនជាមួយនឹងផ្នត់គំនិតដែលចង់ឆ្អែតបានទេ។ និមិត្តនៅតែត្រូវបានដាក់ដែនកំណត់ក្នុងកម្រិតនៃការបានឆ្អែតដោយផ្តោតលើតែថ្ងៃនេះ។**

មុននេះ យើងបានជជែកអំពីសាច់រឿងនេះ ប៉ុន្តែនៅត្រង់នេះយើងឃើញមានគន្លឹះសំខាន់ៗអំពីចំណែកទ្វេដង។ នៅក្នុងសាច់រឿងនេះ ព្រះយេស៊ូបានពហុគុណ ប្រកបដោយអំណាចអធិធម្មជាតិនូវនំបុ័ង និងត្រី ហើយមនុស្សទាំងនោះបានសុទ្ធតែ បានបរិភោគរហូតដល់ពួកគេឆ្អែតស្កប់ស្កល់។ ខ្ញុំសូមធ្វើការសន្និដ្ឋានថា នៅទីនោះមានមនុស្សប្រហែល ២០,០០០នាក់ ដោយរាប់បញ្ចូលទាំងស្ត្រី និងកុមារ ហើយការ ដែលមានមនុស្សជាច្រើនដែលត្រូវបានចម្អែតដោយនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយរហូតដល់គ្រប់គ្នាបានឆ្អែត គឺជារឿងដ៏អស្ចារ្យមួយដែលកើតឡើងពីព្រះយ៉ាងច្បាស់ណាស់។ ដោយការនេះ យើងអាចអបអរនូវព្រះរាជ្យនៃព្រះ និងអបអរចំពោះរបៀបដែលការនេះដំណើរការឡើង។ ប៉ុន្តែការគ្រាន់តែធ្វើឱ្យមនុស្សមានអាហារបរិភោគ មិនមែនជារូបភាពទាំងស្រុងនៃអ្វីដែលបានកើតឡើងទេ ហើយប្រសិនបើអ្នកឈប់ត្រឹមនេះ នោះអ្នកនឹងខកខាននូវចំណែកទ្វេដង។ ចូរជីកកកាយស្វែងយល់បន្ថែមទៀត។

*អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ <u>ពួកសិស្សប្រមូលនំបុ័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។</u> ក្នុងចំណោមអ្នកដែលបរិភោគនំបុ័ងមានប្រុសៗចំនួនប្រាំពាន់នាក់។*

ដូចនេះ តើអត្ថបទនេះប្រាប់យើងពីអ្វីខ្លះ? គឺថា ក្រោយពេលគ្រប់គ្នាបានឆ្អែតហើយ គេនៅប្រមូលបាននំបុ័ង និងត្រីបាន១២ល្អីទៀត។ និយមន័យនៃពាក្យ ចំណែកទ្វេ

ដង គឺជាការមានលើសពីគ្រប់គ្រាន់។ សូមធ្វើការគិតមើលពីភាពខុសគ្នានៅក្នុងសម្បជញ្ញៈរបស់យើងបន្តិចមើល។ ខ្ញុំចង់ឱ្យអ្នកឃើញច្បាស់ក្នុងគំនិតរបស់អ្នកអំពីខគម្ពីរគួរជាទីជាប់ចិត្តដែលនិយាយពីចំណែកទ្វេដង។ ត្រង់ចំណុចនេះ ខ្ញុំមិនមានពេលច្រើនសម្រាប់ធ្វើការពណ៌នាឱ្យស៊ីជម្រៅពីរបៀបដែលព្រះយេស៊ូបាននាំឫទ្ធានុភាពនៃព្រះរាជ្យចូលទៅក្នុងស្ថានភាពនោះ ដើម្បីបញ្ចប់ផ្នែកទីមួយនៃសាច់រឿងនេះ ពោលគឺ មនុស្ស ៥,០០០នាក់បានឆ្អែត។ ប៉ុន្តែ អ្នកអាចឃើញនូវសេចក្តីពន្យល់ពេញលេញនៅក្នុងសៀវភៅទីមួយនៃសៀវភៅស៊េរីនេះ ដែលសៀវភៅនោះមានចំណងជើងថា *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃភក្តីភាពក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។*

ផ្ទុយទៅវិញ ខ្ញុំចង់ផ្តោតលើចំណែកទ្វេដង ជាភាពហូរហៀរ និងរបៀបដែលវាបានកើតឡើងនៅក្នុងសាច់រឿង។ មែនហើយ វាជាសាច់រឿងដ៏អស្ចារ្យមួយ ពោលគឺមនុស្សប្រមាណ ២០,០០០នាក់បានឆ្អែត ពិតជាអស្ចារ្យមែន! ប៉ុន្តែនៅក្នុងព្រះរាជ្យនៃព្រះមាននូវរបស់ជាច្រើនជាជាងបានត្រឹមតែមួយចម្អែត យ៉ាងណាក្តីអ្នកប្រាកដជាត្រូវការបានឆ្អែតមុននឹងអ្នកអាចបន្តទៅរកភាពហូរហៀរបាន។ ការបានឆ្អែតគឺជារឿងដ៏គាប់ប្រសើរ ចុះតើថ្ងៃស្អែកនោះបានអ្វីវិញ? អ្វីដែលខ្ញុំកំពុងព្យាយាមនិយាយនោះគឺថា ប្រសិនបើគោលដៅរបស់អ្នកត្រឹមតែបានឆ្អែត ចុះពេលអ្នកស្រេកឃ្លានម្តងទៀតនឹងមានអ្វីកើតឡើងទៅ? គ្រិស្តបរិស័ទជាច្រើនស្ថិតក្នុងសភាពបានត្រឹមតែឆ្អែត តែបានខកខាននូវចំណែកទ្វេដង។ គឺចំណែកទ្វេដងនេះហើយដែលនាំយកនូវការសម្រាកថ្ងៃសប្ប័ទរបស់ព្រះជាម្ចាស់។ ការបានឆ្អែត គឺបានដោះស្រាយតែបណ្តោះអាសន្នប៉ុណ្ណោះ។ វាមិនបានដោះស្រាយបញ្ហារឿងផ្គត់ផ្គង់នោះឡើយ។ ដោយដឹងថា អ្នកនឹងស្រេកឃ្លានម្តងទៀត ទោះពេលភ្លាមៗនេះអ្នកមិនទាន់ឃ្លានក៏ដោយ ក៏នៅតែបើទ្វារឱ្យសេចក្តីភ័យខ្លាច ដោយបង្កឱ្យអ្នកប្រឹងស្រវារកការងារដោយមាននូវផ្នត់គំនិតបានត្រឹមតែឆ្អែត។ ទេ វាមាននូវវិធីរស់នៅដែលប្រសើរជាងការគ្រាន់តែចង់បានត្រឹមមួយចម្អែត។ អ្នកមិនអាចកសាងបានច្រើនដោយប្រើមានផ្នត់គំនិតបានត្រឹមតែឆ្អែតនោះទេ។ និមិត្តនៅតែមានដែនកំណត់នៅក្នុងកម្រិតបានត្រឹមឆ្អែតដែលគ្រាន់តែផ្តោតលើថ្ងៃនេះ។ ការយកការឆ្អែតមកធ្វើជាគោលដៅគឺនៅតែជាគោលដៅនៃការបានត្រឹមមួយរស់នៅក្នុងប្រព័ន្ធនៃបណ្តាសាលោកិយ ដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា។

ការបានឆ្អែតគ្រប់គ្រាន់តែសម្រាប់ថ្ងៃនេះប៉ុណ្ណោះ រីឯចំណែកទ្វេដងអាចកសាងសម្រាប់ថ្ងៃស្អែកបាន!

ខ្ញុំសូមលើកយកឧទាហរណ៍មួយមកបង្ហាញអ្នកអំពីរបៀបដែលវប្បធម៌ និងក្រុមជំនុំភាគច្រើនគិត។ ចូរសួរនរណាម្នាក់ពីរបៀបដែលពួកគេកំពុងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួន នោះអ្នកនឹងទទួលបានចម្លើយជាច្រើន ប្រហែលជាមានចម្លើយជាច្រើនដែលមិនសូវល្អផង។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបានចម្លើយល្អ គឺប្រាកដជាចេញពីបុគ្គលដែលនិយាយថា «ពួកយើងរៀបចំបានយ៉ាងល្អ» រួចចូរសួរពួកគេថា «អឺចឹង តើអ្នកបានបង់ថ្លៃផ្ទះរួចអស់បានយូរប៉ុនណាហើយ?» នោះពួកគេប្រហែលជាសម្លឹងមើលអ្នក រួចក៏ពោលថា «នែ៎ក ផ្ទះខ្ញុំមិនទាន់បង់រួចទេ។ ខ្ញុំចង់ថា ពួកយើងកំពុងបង់លើវិក្កយបត្រចំណាយទាំងអស់ ហើយក៏សល់លុយខ្លះៗនៅក្នុងធនាគារដែរ។» អ្នកក៏ពោលថា «ល្អហើយអឺចឹង! អ្នកពិតជាធ្វើបានល្អណាស់។ ប្រាប់ខ្ញុំបានទេថា អ្នកមានប្រាក់ក្នុងគណនីធនាគារលើសពី ១០,០០០ដុល្លារដែរឬទេ?» ប្រាកដណាស់ ខ្ញុំគិតថាថាគ្មាននរណាម្នាក់សួរសំណួរនេះទេ ប៉ុន្តែប្រសិនបើអ្នកពិតជាសួរមែន នោះពួកគេនឹងឆ្លើយ គឺពួកគេនឹងឆ្លើយថា «អត់ទេ គឺពួកយើងមានតែ ៨០០ដុល្លារទេ។» ស្លាប់ហើយ មនុស្សទាំងនេះគិតថា ខ្លួនរៀបចំចាត់ចែងហិរញ្ញវត្ថុបានល្អ ដោយសារតែពួកគេមានរថយន្តល្អ មានផ្ទះស្អាត ហើយមានប្រាក់ខ្លះក្នុងគណនីធនាគារ។ ពួកគេកំពុងរស់នៅបែបផែនជីវិតដែលបានត្រឹមមួយឆ្អែត។ ប៉ុន្តែវាមាននូវអ្វីដែលច្រើនជាងនេះទៀត! ចុះបើបានបង់ថ្លៃរួចដោយមានទឹកប្រាក់ ១០០,០០០ដុល្លារ ក្នុងគណនីធនាគារ ឬ ៥០០ ០០០ដុល្លារក្នុងគណនីធនាគារវិញ យ៉ាងម៉េចដែរ? នោះប្រាកដជារូបភាពនៃជីវិតដែលបង្ហាញពីភាពលើសពីគ្រប់គ្រាន់សម្រាប់មនុស្សភាគច្រើន។ ការបានឆ្អែត គឺប្រសើរ និងចាំបាច់ណាស់ ប៉ុន្តែការមាននំប៉័ង និងត្រី១២ល្អីនៅក្នុងឃ្លាំងម្ហូបអាហារ គឺលើសពីគ្រប់គ្រាន់ហើយ ហើយនោះគឺមានសន្តិភាពហើយ!

នៅថ្ងៃមួយ ខ្ញុំបានអង្គុយពិភាក្សាជាមួយអតិថិជនម្នាក់ដោយជជែកអំពីហិរញ្ញវត្ថុរបស់គាត់។ នៅពេលខ្ញុំកំពុងពិនិត្យមើលពីបំណុលរបស់គាត់ ខ្ញុំសម្គាល់ឃើញថា គាត់មានប្រាក់បំណុលប្រមាណ ៥០,០០០ដុល្លារនៅក្នុងកាតបំណុលឥណទានរបស់គាត់។ ហើយនៅពេលខ្ញុំកំពុងពិនិត្យមើលទ្រព្យសកម្មរបស់គាត់ ខ្ញុំសម្គាល់ឃើញថា គាត់មានប្រាក់សុទ្ធ ៥០,០០០ដុល្លារនៅក្នុងគណនីចរន្តរបស់គាត់។ ខ្ញុំក៏និយាយថា «លោកចូ ខ្ញុំដូចជាវង្វេងខួរអស់ហើយ។ លោកមានប្រាក់សុទ្ធសម្រាប់បង់ថ្លៃជំពាក់ក្នុងកាតបំណុលឥណទានរបស់លោកគ្រប់ល្មម។ អត្រាការប្រាក់ក្នុងកាតបំណុលឥណទានរបស់លោកមានរហូតដល់ទៅ ១៨%ឯណោះ ហើយគណនីចរន្តរបស់លោកវិញបានការប្រាក់តែ ១%ទេ។ សូមលោកយកប្រាក់សុទ្ធរបស់លោកទៅសងថ្លៃជំពាក់ក្នុងកាតឥណទាននោះទៅ!» ប៉ុន្តែ អ្នកដឹងថាយ៉ាង

ម៉េចទេ? លោកចូនិយាយថា គាត់មិនចង់ធ្វើបែបហ្នឹងទេ។ ខ្ញុំអង្គុយទាំងតាំងស្មារតី ហើយសួរគាត់ថាហេតុអ្វី។ គាត់ក៏និយាយថា ការមានប្រាក់សុទ្ធនៅក្នុងគណនីចរន្តរបស់គាត់ធ្វើឱ្យគាត់មានអារម្មណ៍ថាមានសុវត្ថិភាព និងមានភាពមានបានជាងមុនផ្នែកហិរញ្ញវត្ថុ។ ខ្ញុំក៏សម្លឹងមើលគាត់។ «លោកចង់មានន័យថាវាធ្វើឱ្យលោកមានអារម្មណ៍ថាមានបានឬ? មើលនែ៎លោក។ ទោះបីជាលោកមានប្រាក់ ៤០,០០០ដុល្លារនៅក្នុងគណនីចរន្តរបស់លោកក៏ដោយ ក៏លោកមិនមានប្រាក់ ៤០,០០០ដុល្លារដែរ ព្រោះថាលោកនៅជំពាក់ក្រុមហ៊ុនកាតឥណទានចំនួន ៤០,០០០ដុល្លារ។ ការយល់ឃើញរបស់លោកមិនត្រូវទេ ហើយលោកត្រូវខាតបង់លុយជាច្រើនដោយសារការជឿលើផ្នត់គំនិតនេះ។»

ពួកយើងបានជជែកអស់មួយម៉ោង ហើយគាត់មិនអាចយល់ពីមូលហេតុដែលគាត់គួរគិតគូរយ៉ាងហោចណាស់ក៏ត្រូវដាក់ប្រាក់មួយភាគធំក្នុងគណនីចរន្តរបស់គាត់មកសងបំណុលដែរ ដែលការនេះបានរំឭកដល់ខ្ញុំថាគាត់បានប្រឹងប្រែងធ្វើវា។ មួយម៉ោងក្រោយមក ខ្ញុំក៏បោះបង់ រួចក៏ត្រលប់ទៅផ្ទះវិញ។ គាត់ត្រូវបានបញ្ឆោតហើយ ការដែលគាត់ព្យាយាមទុកប្រាក់នៅក្នុងគណនីចរន្តនោះ គាត់គ្មានសុវត្ថិភាពទេ។ អូហ៎ ខ្ញុំដឹងថាវាធ្វើឱ្យមានអារម្មណ៍ល្អនៅពេលបានឃើញសារសរសេរនៅក្នុងប្រអប់សំបុត្រដែលបង្ហាញថា មានប្រាក់ ៤០,០០០ដុល្លារនៅក្នុងធនាគារ។ ប៉ុន្តែដើម្បីបានឃើញពីរូបភាពពិតប្រាកដថាគាត់នៅកន្លែងណា នោះគាត់ចាំបាច់ត្រូវបើកបញ្ជីគណនីបំណុលឥណទានដែរ។

ការបានឆ្អែតគឺជារឿងគាប់ប្រសើរ ហើយវាក៏អាចល្បួងអ្នកឱ្យធ្លាក់ចូលទៅក្នុងគំនិតខុសឆ្គងអំពីសុវត្ថិភាពផងដែរ។ អ្នកត្រូវក្រឡេកមើលទិសដៅឱ្យបានច្បាស់បន្តិច និងដឹងថាអ្វីដែលអ្នកទើបតែបានធ្វើនោះនឹងមិនអាចផ្គត់ផ្គង់សម្រាប់អ្វីដែលអ្នកត្រូវការក្នុងរយៈពេលប៉ុន្មានម៉ោងខាងមុខនោះទេ។ អ្នកនឹងស្រេកឃ្លានម្តងទៀត។ ប្រសិនបើអ្នកគ្រាន់តែចង់បានដំណោះស្រាយរហ័ស ដែលជាការបានឆ្អែតរហ័សអំពីការផ្គត់ផ្គង់ នោះអ្នកនឹងខកខាននូវរឿងម្យ៉ាងដែលអាចផ្លាស់ប្តូរជីវិតរបស់អ្នក - ដែលរបស់ម្យ៉ាងនោះគឺ ចំណែកទ្វេដង។

នៅពេលដែលយើងទាំងអស់គ្នាបានធំធាត់ឡើងនៅក្នុងប្រព័ន្ធនៃបណ្តាសាលោកិយ ដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា នោះយើងសុបិនដល់រឿងមួយ នោះគឺការឈប់! ខ្ញុំបានរៀបរាប់ពីចំណុចនេះនៅក្នុងជំពូកមុន។ យើងមិនបានសុបិនចង់បានការងារបន្ថែម ឬឱកាសផ្សេងទៀតទេ និយាយដោយត្រង់ទៅ គឺដោយសារយើងបានឆ្អែត

ឆ្អន់នឹងជីវិត ហើយគ្រាន់តែរង់ចាំរហូតដល់ពេលវិស្សមកាលបន្ទាប់។ អ្នកឃើញទេ ទាសករមិនបានសុបិនចង់បានការងារបន្ថែមទៀតទេ។ ទាសករសុបិនចង់បានតែការម្យ៉ាង នោះគឺរាត្រីថ្ងៃសុក្រ មិនមែនព្រឹកថ្ងៃចន្ទទេ។ តើហេតុអ្វីទៅ? គឺដោយសារតែទាសករសុបិនចង់បានតែរឿងម្យ៉ាង នោះគឺការឈប់។ សូមស្ដាប់បន្តិច ភាពជន់ជោរ និងផ្នត់គំនិត «ដែលមិនអាចរង់ចាំឱ្យឈប់បាន» នឹងមិនដែលនាំអ្នកទៅដល់កន្លែងណាមួយឡើយ។ ទោះបីជាមានទេវតាមកដល់គ្រែដំណេករបស់អ្នក ហើយប្រាប់អ្នកពីគំនិតមួយមកពីព្រះជាម្ចាស់ នោះផ្នត់គំនិតរបស់អ្នកនៅតែធ្វើឱ្យអ្នកស្ទាក់ស្ទើរដដែល។ សូមសរសេរចំណុចនេះទុក។

អ្នកត្រូវមើលទៅឱ្យបានឆ្ងាយហួសពីភាពស្កប់ស្កល់ ដើម្បីចាប់យកចំណែកទ្វេដង!

ឃ្លានេះគឺជាកូនសោចូលទៅកាន់ចំណែកទ្វេដង។ ខ្ញុំដឹងថា ពេលនេះស្ដាប់ទៅមិនសូវសមហេតុផលប៉ុន្មានទេ ប៉ុន្តែនឹងសមហេតុផលនៅពេលក្រោយ។ ដើម្បីបង្ហាញដល់អ្នកពីអ្វីដែលខ្ញុំចង់និយាយនោះ ខ្ញុំសូមក្រឡេកមើលទៅសាច់រឿងមួយទៀតអំពីការផ្គត់ផ្គង់អាហារដល់មនុស្ស ៥,០០០នាក់ ដែលមានចែងក្នុងគម្ពីរយ៉ូហានម្តង ជាជាងមើលក្នុងគម្ពីរម៉ាកុស។ នៅក្នុងការយល់ឃើញពីសាច់រឿងក្នុងគម្ពីរយ៉ូហាន យើងរកឃើញសាច់រឿងដូចគ្នា ប៉ុន្តែវាមានបង្ហាញនូវព័ត៌មានលម្អិតមួយចំនួនដែលគម្ពីរម៉ាកុសមិនមាន។

> *ព្រះយេស៊ូយកនំបុ័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឱ្យអ្នកអង្គុយនៅទីនោះ។ រីឯត្រីវិញ ព្រះអង្គក៏ធ្វើដូច្នោះដែរ ព្រះអង្គប្រទានឱ្យគេ តាមតែម្នាក់ៗចង់បាន។ លុះគេបានបរិភោគឆ្អែតហើយ ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សថា៖ «ចូរប្រមូលនំបុ័ងដែលនៅសល់ កុំឱ្យបាត់មួយដុំសោះឡើយ»។*
>
> *យ៉ូហាន ៦៖១១-១២*

ក្នុងសាច់រឿងគម្ពីរនេះ យើងមើលឃើញថា គឺជាអង្គព្រះយេស៊ូដែលបានប្រាប់ពួកគេឱ្យទៅប្រមូលដុំនំបុ័ង ឬបំណែកនៅសល់នានា ហើយមិនឱ្យបាត់មួយដុំសោះឡើយ។ ខ្ញុំចង់ឱ្យអ្នកយល់ពីចំណុចនេះ។ ទ្រង់ត្រូវតែប្រាប់ពួកគេឱ្យធ្វើបែបនេះ ដោយសារតែពួកគេមិនបានមើលឃើញឱកាស។ សូមសាកយកចិត្តរបស់ពួកគេដាក់លើចិត្តរបស់អ្នកទៅមើល។ អ្នកបានឆ្អែត ហើយឆ្អែតស្កប់ស្កល់ផង ហើយអ្នកចង់តែទម្រេតខ្លួនគេងប៉ុណ្ណោះ។ ដោយសារតែការហ្វឹកហាត់ពីប្រព័ន្ធបណ្ដាសាផែនដីរបស់អ្នក និងគំនិតបែបទាសកររបស់អ្នក នោះពេលដែលអ្នកបានឆ្អែតហើយ គឺជាពេលដែលត្រូវឈប់។ ឃើញទេ

គំនិតបែបទាសករធ្វើការតែពេលចាំបាច់ប៉ុណ្ណោះ ហើយនៅពេលមិនចាំបាច់វិញ គឺពេលដែលបានឆ្អែត នោះវាឈប់ធ្វើការតែម្តង។ ព្រះយេស៊ូត្រូវតែប្រាប់ពួកគេឱ្យប្រមូលអ្វីដែលនៅពីមុខពួកគេ។ បំណែកនៅសល់នានានៅជុំវិញពួកគេពាសពេញដី តែពួកគេមិនខិតខំរើសបំណែកនំនៅសល់ទាំងនោះឡើយ។ ប៉ុន្តែនៅក្នុងគំនិតរបស់ពួកគេ អ្វីដែលជាបំណែកនៅសល់នោះមិនមានតម្លៃអ្វីក្រៅតែពីបន្សល់ទុកឱ្យពួកបក្សីស៊ីទេឬ?

ព្រះយេស៊ូកំពុងព្យាយាមបង្រៀនពួកគេពីអ្វីមួយ ជាអ្វីដែលសំខាន់ខ្លាំង។ ព្រះយេស៊ូបានមានបន្ទូលប្រាប់ ក្រោយទ្រង់ប្រាប់ពួកគេឱ្យប្រមូលបំណែកនៅសល់នានាដោយថា មិនត្រូវឱ្យបាត់មួយដុំសោះឡើយ! ប៉ុន្តែ តើឃ្លានេះមានន័យដូចម្តេច? គ្រប់គ្នាបានឆ្អែត គ្រប់គ្នាបានស្កប់ស្កល់ ហើយគ្មាននរណាម្នាក់ចង់បាននំប៉័ង និងត្រីបន្ថែមទៀតទេ មែនហើយ យ៉ាងហោចណាស់ក៏បានឆ្អែតក្នុងពេលនេះដែរ។ ប៉ុន្តែចំណុចត្រង់នេះហើយដែលជាបញ្ហា ពោលគឺមិនមានការសម្រាកថ្ងៃសប្ប័ទដោយគ្មានការប្រមូលទុកច្រើនជាងអ្វីដែលអ្នកត្រូវការនោះឡើយ។ នៅពេលសាសន៍អ៊ីស្រាអែលប្រមូលនំម៉ាណានៅថ្ងៃទីប្រាំមួយ ពួកគេត្រូវបានចង្អុលបង្ហាញឱ្យធ្វើការប្រមូលទុកឱ្យបានច្រើនជាងចំនួនដែលពួកគេត្រូវការ។ ការដែលពួកគេបានប្រមូលទុកច្រើនជាងចំនួនចាំបាច់នៅថ្ងៃនោះ បានក្លាយជាការផ្គត់ផ្គង់របស់ពួកគេនៅថ្ងៃទីប្រាំពីរ ដែលជាថ្ងៃសម្រាក។ ព្រះយេស៊ូកំពុងបង្រៀនសិស្សរបស់ទ្រង់ឱ្យមើលលើសពីបានចម្អែត ហើយឱ្យចេះមើលឃើញនូវការផ្គត់ផ្គង់ពេញលេញរបស់ព្រះរាជ្យនៃព្រះ។ សូមបញ្ជាក់ម្តងទៀតថា អ្នកមិនអាចកសាងដោយភាពបានឆ្អែតស្កប់ស្កល់ទេ តែអ្នកអាចកសាងដោយចំណែកទ្វេដងបាន។ ភាពបានឆ្អែតស្កប់ស្កល់បានហូបនំប៉័ងសម្រាប់ថ្ងៃនេះ ប៉ុន្តែចំណែកនៅសល់១២ល្អីផ្តល់នូវជម្រើសសម្រាប់អ្នកនៅថ្ងៃស្អែក។

នេះជាគោលការណ៍សំខាន់ដែលខ្ញុំចង់ឱ្យអ្នកឃើញ។

ទោះបីជាពួកសិស្សមិនបានឃើញបំណែកនៅសល់នានារហូតដល់ព្រះយេស៊ូបានចង្អុលប្រាប់ក៏ដោយ **ក៏ព្រះជាម្ចាស់បានប្រទាននូវការសម្រាកថ្ងៃសប្ប័ទ ដែលជាចំណែកទ្វេដងរួចទៅហើយដែរ**។ ពួកគេគ្រាន់តែមិនបានមើលឃើញប៉ុណ្ណោះ។ ព្រះរាជ្យនៃព្រះបានផ្គត់ផ្គង់នូវអាហារ ពហុគុណនំប៉័ង និងត្រី ព្រមទាំងបានចម្អែតមនុស្សទាំងនោះរួចហើយ ប៉ុន្តែព្រះរាជ្យនៃព្រះតែងតែផ្គង់ផ្គង់នូវចំណែកទ្វេដង។ ព្រះជាម្ចាស់នឹងមិនដែល

គ្រាន់តែផ្គត់ផ្គង់សម្រាប់តែបានឆ្អែតស្កប់ស្កល់ប៉ុណ្ណោះទេ **ទ្រង់នឹងតែងតែផ្គត់ផ្គង់លើសពីគ្រប់គ្រាន់**។ បញ្ហានោះគឺថា អ្នកប្រហែលជាមើលមិនឃើញ!

*ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ព្រះអង្គនឹងប្រទានមកយ៉ាងបរិបូរហូរហៀរ។ ព្រះជាម្ចាស់នឹងវាល់ឱ្យអ្នក តាមរង្វាល់ដែលអ្នកវាល់ឱ្យអ្នកដទៃ»។*

លូកា ៦៖៣៨

ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ព្រះអង្គនឹងប្រទានមក... តែខគម្ពីរនេះមិនចប់ត្រឹមនេះទេ។ រង្វាល់ដែលអ្នកបានឱ្យទៅគេ នឹងត្រូវបានឱ្យមកអ្នកវិញ ដែលនេះគឺជាការផ្គត់ផ្គង់សម្រាប់អ្នកនៅថ្ងៃនោះ។

ប៉ុន្តែខគម្ពីរនេះថែងបន្តថា «យ៉ាងបរិបូរហូរហៀរ!» ចំនួនយ៉ាងបរិបូរហូរហៀរនេះហើយគឺជាចំណែកទ្វេដង។ ព្រះជាម្ចាស់តែងតែផ្គត់ផ្គង់នូវចំណែកទ្វេដង មិនមែនគ្រាន់តែបានមួយគ្រាន់នោះទេ!!! ប៉ុន្តែ ប្រសិនបើអ្នកមិនបានដឹងពីចំណុចនេះទេ ហើយស្បៀងរបស់អ្នកកំពុងតែហូរហៀរ នោះអ្នកប្រហែលជាគ្រាន់តែទុកឱ្យវាហូរធ្លាក់ទៅដី ដោយសារអ្នកផ្តោតតែលើចំណែកមួយចម្អែតនៅមុខអ្នក និងមិនប្រុងប្រៀបត្រង់យកចំណែកហូរហៀរនោះទេ។ ការធ្វើបែបនេះ អ្នកអាចបរាជ័យ និងរីករាយនឹងចំណែកទ្វេដង។ ប៉ុន្តែប្រសិនបើអ្នកដឹងពីរបៀបដែលព្រះរាជ្យនៃព្រះដំណើរការ ដោយដឹង និងរំពឹងចង់បានការផ្គត់ផ្គង់ពេញលេញ នោះអ្នកនឹងបានប្រុងប្រៀបធ្វើសកម្មភាព និងចាប់យកនូវគ្រប់យ៉ាងដែលព្រះជាម្ចាស់ផ្គត់ផ្គង់។

ខ្ញុំសូមបង្ហាញឧទាហរណ៍មួយទៀតដល់អ្នក។

*លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្តិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។ ពេលលោកស៊ីម៉ូន-ពេត្រុសឃើញដូច្នោះ គាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងឱ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជា*

*មនុស្សបាប»។ លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅជាមួយ ភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ រីឯលោកយ៉ាកុប និងលោកយ៉ូហាន ជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។*

លូកា ៥៖៥-១០

នេះជាចំណែកមួយនៃសាច់រឿងដែលយើងបានអានមុននេះ។ លោកពេត្រុសមានទូកពីរដែលហៀបនឹងលិចទៅជាមួយនឹងត្រី ដោយសារតែព្រះរាជ្យនៃព្រះ។ ការនេះមានលក្ខណៈផ្ទុយពីការយល់ដឹងពីការនេសាទត្រីរបស់គាត់ ហើយវាបានធ្វើឱ្យគាត់ភ្ញាក់ផ្អើលជាខ្លាំង។ ប៉ុន្តែនៅពេលក្រោយ តើនឹងមានអ្វីកើតឡើងបើព្រះយេស៊ូមានបន្ទូលថា «នែ៎ពេត្រុស ចូរចេញទៅចុះ នោះអ្នកនឹងអាចបានត្រីបានច្រើនតាមតែចិត្តចង់»? តើអ្នកគិតថា គាត់នឹងយកទូកពីរមកដែរឬទេ? ខ្ញុំពិតជាចង់ដឹងណាស់។ គាត់អាចនឹងប្រមូលយកទូកឱ្យបានច្រើនតាមតែអាចធ្វើបាន ដោយខ្ចីពីមិត្តភក្តិរបស់គាត់។ ហេតុអ្វីទៅ? ពីព្រោះគាត់នឹងមាននូវការរំពឹងទុកផ្សេង និងចំណេះដឹងពីរបៀបដែលព្រះរាជ្យនៃព្រះដំណើរការ។

អ្វីដែលជាការពិភាក្សាទាំងមូលនេះ គឺដើម្បីធ្វើឱ្យប្រាកដថាអ្នកបានយល់ថា អ្នកមិនបានមើលឃើញគ្រប់ទាំងការផ្គត់ផ្គង់ដែលព្រះជាម្ចាស់កំពុងបញ្ជូនមកទេ។ ជាការពិតណាស់ ភាគច្រើនការផ្គត់ផ្គង់នោះនឹងមិនមែនស្ថិតក្នុងទម្រង់ជាសាច់ប្រាក់ដុល្លារជាក់ស្តែងទេ។ ប៉ុន្តែវានឹងស្ថិតក្នុងលក្ខណៈជាគំនិត ជំនួបដែលមកពីព្រះ និងការចង្អុលបង្ហាញពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ប្រសិនបើយើងមិនបានត្រៀមខ្លួនដោយការយល់ដឹងត្រឹមត្រូវអំពីចំណែកទ្វេដងទេ យើងនឹងជាប់ក្នុងអន្ទាក់នៃចំណែកទាំងនោះ ដោយសារតែការបណ្តុះបណ្តាលពីការរស់រាន តាមបណ្តាសាលោកិយរបស់យើង។

នៅក្នុងសាច់រឿងអំពីការពហុគុណនំប៉័ង ព្រះយេស៊ូកំពុងព្យាយាមបង្រៀនសិស្សរបស់ទ្រង់ពីរបៀបដែលព្រះរាជ្យនៃព្រះដំណើរការ ពីអ្វីដែលត្រូវរំពឹងទុក និងអ្វីដែលត្រូវនឹកគិតជាមុន។ ដោយសារតែផ្នត់គំនិតបែបទាសកររបស់ពួកគេមិនបានមើលឃើញនូវសក្តានុពលនៃនំប៉័ងទាំងអស់ដែលនៅរាយប៉ាយ នោះទ្រង់ត្រូវតែបង្វឹកពួកគេឱ្យចេះសម្លឹងមើល៖ «តើអ្នកបានឃើញអ្វីខ្លះ? មើលន៎! អ្នកមើលមិនឃើញពីអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានរៀបចំសម្រាប់អ្នកទេ។»

ខ្ញុំចង់រំឭកអ្នកនូវបទគម្ពីរក្នុងនិក្ខមនំ ជំពូក១៦ ដ្បិតនៅមានចំណុចមួយទៀតដែលខ្ញុំចង់លើកឡើង។

*ចាប់ពីពេលនោះមក រៀងរាល់ព្រឹក ពួកគេរើសអាហារល្មមដែលខ្លួនអាចបរិភោគឆ្អែត។ ពេលថ្ងៃរះពេញកម្ដៅ អាហារដែលនៅសល់ក៏រលាយបាត់អស់។ នៅថ្ងៃទីប្រាំមួយ ពួកគេរើសអាហារពីរដងច្រើនជាង គឺពីរកូនល្អីក្នុងម្នាក់ៗ។ មេដឹកនាំទាំងអស់របស់សហគមន៍មករាយការណ៍ជម្រាបលោកម៉ូសេ។ លោកប្រាប់ពួកគេវិញថា៖ «ព្រះអម្ចាស់បានបញ្ជាមកដូច្នេះមែន។ ស្អែកជាថ្ងៃសប្ប័ទ ជាថ្ងៃដ៏វិសុទ្ធដែលត្រូវញែកថ្វាយព្រះអម្ចាស់ ចូរចម្អិនអ្វីដែលអ្នករាល់គ្នាត្រូវចម្អិន ចូរស្ងោរអ្វីដែលអ្នករាល់គ្នាត្រូវស្ងោរ ហើយទុកអាហារដែលលើសរហូតព្រឹកស្អែក»។*

*ដូច្នេះ ពួកគេទុកអាហាររហូតដល់ព្រឹកស្អែក តាមបង្គាប់របស់លោកម៉ូសេ។ អាហារទាំងនោះពុំមានស្អុយរលួយ ឬមានដង្កូវចោះឡើយ។ លោកម៉ូសេមានប្រសាសន៍ថា៖ «ថ្ងៃនេះ ចូរបរិភោគអាហារទាំងនេះចុះ ដ្បិតថ្ងៃនេះជាថ្ងៃសប្ប័ទ សម្រាប់គោរពព្រះអម្ចាស់។ ថ្ងៃនេះ អ្នករាល់គ្នានឹងពុំឃើញមានអ្វីនៅខាងក្រៅទេ។ អ្នករាល់គ្នាអាចរើសអាហារនេះក្នុងរយៈពេលប្រាំមួយថ្ងៃ ប៉ុន្តែនៅថ្ងៃទីប្រាំពីរដែលជាថ្ងៃសប្ប័ទនឹងគ្មានអ្វីរើសទេ»។*

*ទោះជាយ៉ាងនេះក្ដី នៅថ្ងៃទីប្រាំពីរ ក៏មានប្រជាជនខ្លះចេញពីជំរំ ដើម្បីទៅរើសអាហារ តែពួកគេរកពុំបានសោះ។ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «តើអ្នករាល់គ្នានៅតែពុំព្រមស្ដាប់បទបញ្ជា និងវិន័យរបស់យើងដល់កាលណាទៀត? ត្រូវចងចាំថា យើងជាព្រះអម្ចាស់ បានប្រគល់ថ្ងៃសប្ប័ទឱ្យអ្នករាល់គ្នា ហេតុនេះហើយបានជានៅថ្ងៃទីប្រាំមួយ យើងឱ្យអ្នករាល់គ្នាមានអាហារមួយជាពីរ។ នៅថ្ងៃទីប្រាំពីរ ម្នាក់ៗនៅក្នុងជំរំរបស់ខ្លួន គឺមិនត្រូវចេញទៅក្រៅឡើយ»។ ហេតុនេះ ប្រជាជននាំគ្នាឈប់សម្រាក នៅថ្ងៃទីប្រាំពីរ។*

និក្ខមនំ ១៦៖២១-៣០ (នំម៉ាណា)

ដូចអ្វីដែលយើងទើបបាននិយាយអីចឹង ចំណែកទ្វេដងគឺជាអ្វីដែលបង្កើតឱ្យមានការសម្រាកនៅថ្ងៃសប្ប័ទអាចកើតឡើងបាន។ ប៉ុន្តែគួរឱ្យភ្ញាក់ផ្អើល ទោះបីព្រះជាម្ចាស់បានផ្គត់ផ្គង់ចំណែកទ្វេដងនៅថ្ងៃទីប្រាំមួយរួចស្រេចទៅហើយក្ដី ក៏ពួកគេជាច្រើននាក់បាន

ចេញទៅស្វែងរកវា និងរកមិនឃើញសោះនៅថ្ងៃសប្ប័ទ។ គឺមិនមែនដោយសារព្រះជាម្ចាស់មិនស្មោះត្រង់ក្នុងការផ្គត់ផ្គង់ទេ។ ពួកគេគ្រាន់តែមិនបានមើលឃើញ ដោយសារតែពួកគេមិនមានការយល់ដឹងត្រឹមត្រូវអំពីចំណែកទ្វេដងដែលបានផ្តល់ឱ្យពួកគេរួចរាល់នៅថ្ងៃទីប្រាំមួយ។ ពួកគេបានប្រមូលគ្រប់គ្រាន់ល្មមសម្រាប់តែមួយថ្ងៃប៉ុណ្ណោះ ពោលគឺធ្វើដូចសព្វមួយដងដែរ។ ពេលនេះ ដោយបានស្រេកឃ្លាននៅថ្ងៃទីប្រាំពីរ ពួកគេរកមិនឃើញមានអ្វីសោះ។ ប្រហែលជាពួកគេយល់ឃើញថា ព្រះជាម្ចាស់បានធ្វើឱ្យពួកគេខកចិត្ត។ ប៉ុន្តែព្រះជាម្ចាស់មិនបានធ្វើឱ្យពួកគេខកចិត្តទេ គឺពួកគឺគ្រាន់តែមិនបានដឹងពីគោលការណ៍នៃចំណែកទ្វេដងប៉ុណ្ណោះ។ ប្រសិនបើពួកគេបានដឹង ពួកគេអាចមានការរៀបផែនការផ្សេងពីនេះ។

តើមានមនុស្សប៉ុន្មាននាក់ក្នុងពេលសព្វថ្ងៃនេះដែលនៅតែដើរចុះឡើងដោយព្យាយាមស្វែងរកអ្វីដែលពួកគេត្រូវការ ដោយមិនបានដឹងថាព្រះជាម្ចាស់បានបញ្ជូនរបស់នោះមករួចស្រេចទៅហើយ? ខ្ញុំគិតថា វាជារឿងដែលពិតជាគួរឱ្យចាប់អារម្មណ៍នៅក្នុងបទគម្ពីរនេះ គឺថាព្រះជាម្ចាស់ទ្រង់ព្រះពិរោធនឹងពួកគេដែលពួកគេមិនបានប្រមូលទុកឱ្យបានគ្រប់គ្រាន់!!!! ខ្ញុំឆ្ងល់ណាស់ថាតើការនេះនឹងត្រូវបង្រៀននៅក្នុងក្រុមជំនុំដោយរបៀបណាទៅ។

*ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» ព្រះអង្គក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្តីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ ដោយយើងជួយគេ។*

២កូរិនថូស ៩៖១០-១១

ត្រង់ចំណុចនេះ លោកប៉ូលពិតជានិយាយចំៗ ដោយគាត់បានពន្យល់ពីព្រះរាជ្យនៃឥទ្ធិពលរបស់ព្រះជាម្ចាស់ដែលកំពុងត្រូវបានធ្វើឱ្យមានភាពមានបាននៅក្នុងគ្រប់មធ្យោបាយ ដើម្បីឱ្យអ្នកអាចមានមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក។ បងប្អូនអើយ ការនេះទាមទារឱ្យមាននូវចំណែកទ្វេដង។ អ្នកមិនអាចមានចិត្តសទ្ធាជ្រះថ្លាលើគ្រប់ជំពូកបានដោយគ្មានភាពលើសពីគ្រប់គ្រាន់ឡើយ។

នៅក្នុងជំពូកមុន ខ្ញុំបានចែករំលែកជាមួយអ្នកពីរបៀបដែលអាជីវកម្មរបស់ខ្ញុំបានដំណើរការចាប់តាំងពីអាជីវកម្មប្រតិបត្តិការក្នុងកម្រិតផលិតកម្មដែលមានទឹកប្រាក់ ៣ ទៅ ៤ លានដុល្លារក្នុងមួយឆ្នាំ ជាមួយនឹងអ្នកលក់ម្នាក់ក្នុងចំណោមអ្នកលក់របស់យើង ដើម្បីប្រតិបត្តិការក្នុងទំហំទឹកប្រាក់ ១១លានដុល្លារជាមួយនឹងអ្នកលក់ដដែល។ ការកើនឡើងនេះបានកើតឡើងត្រឹមតែរយៈពេលមួយឆ្នាំប៉ុណ្ណោះ។ ខ្ញុំក៏បានប្រាប់អ្នកពីរបៀបដែលការនោះបានកើតឡើងដែរ ថាព្រះជាម្ចាស់បានប្រទាននូវសុបិនមួយមកខ្ញុំ ហើយមានបន្ទូលប្រាប់ខ្ញុំពីរបៀបត្រូវធ្វើវា។ ប៉ុន្តែពេលនេះខ្ញុំត្រូវប្រាប់អ្នកពីអ្វីដែលទ្រង់មានបន្ទូលប្រាប់ខ្ញុំព្រោះពេលនេះវានឹងស្តាប់ទៅសមហេតុផលចំពោះអ្នក។ នៅក្នុងសុបិននោះ ទ្រង់បានបង្ហាញឱ្យឃើញពាក្យចំនួនបី។ ហ្នឹងហើយ គឺមានតែបីពាក្យទេ។ ពាក្យទាំងបីនោះហើយដែលបានផ្លាស់ប្តូរចំណូលរបស់ខ្ញុំរាប់សែនដុល្លារក្នុងឆ្នាំនោះ ដោយខ្ញុំមិនបានធ្វើទីផ្សារបន្ថែម ឬធ្វើការផ្សព្វផ្សាយបន្ថែមលើសពីអ្វីដែលខ្ញុំកំពុងធ្វើនាពេលនោះទេ។ ខ្ញុំមិនបានកែប្រែអ្វីៗអំពីប្រតិបត្តិការក្រុមហ៊ុនរបស់ខ្ញុំឡើយ លើកលែងតែកែប្រែខ្លួនខ្ញុំ។ ពាក្យទាំងបីនោះបានផ្តល់នូវការបង្ហាត់បង្ហាញដើម្បីផ្លាស់ប្តូរពីរបៀបដែលខ្ញុំកំពុងធ្វើអ្វីមួយ ហើយវាបានផ្លាស់ប្តូរអាជីវកម្មខ្ញុំ និងចំណូលរបស់ខ្ញុំឱ្យកើនជាងមុនបួនដង។ អ្នកអាចនឹងសួរថា «តើពាក្យទាំងបីនេះមានអ្វីខ្លះ?» តាមពិតទៅ វាជាពាក្យសាមញ្ញទេគឺ **ឆក់យក ឱកាស ឱ្យបានពេញលេញ**!

មែនហើយ គឺពាក្យ ឆក់យកឱកាសឱ្យបានពេញលេញ។ «មានតែប៉ុណ្ណឹង? បីពាក្យហ្នឹងបានសម្រេចការងារទាំងអស់នោះ?» ហ្នឹងហើយ គឺពាក្យទាំងបីនេះឯង។ នៅពេលអ្នកបានយល់ថា ព្រះជាម្ចាស់តែងតែបញ្ជូននូវចំណែកទ្វេដងប្រកបដោយការផ្គត់ផ្គង់ នោះអ្នកនឹងយល់ពីអ្វីដែលទ្រង់កំពុងមានបន្ទូលប្រាប់ខ្ញុំ។

ក្រុមហ៊ុនរបស់ខ្ញុំ ពោលគឺដូចក្រុមហ៊ុនផ្នែកលក់ផ្សេងទៀតដែរ គឺក្រុមហ៊ុនយើងបានបង្កើតប្រាក់ចំណេញដោយការជួយមនុស្ស កាលណាក្រុមហ៊ុនជួយមនុស្សបានកាន់តែប្រសើរ នោះក្រុមហ៊ុនក៏កាន់តែរកប្រាក់បានច្រើនដែរ។ ទោះបីនេះជារឿងពិតក្តី វាក៏ជាការពិតដែរដែលថាមានក្រុមហ៊ុនផ្នែកលក់ជាច្រើនបរាជ័យក្នុងការបំពេញនូវតម្រូវការរបស់អតិថិជនរបស់ខ្លួន មិនថាតាមរយៈការពិនិត្យតាមដានមិនបានល្អ និងសេវាកម្មអតិថិជនអន់ ឬកង្វះខាតផ្នែកតាមស្វះស្វែងរក និងកង្វះនូវការរក្សាអតិថិជនថ្មីសម្រាប់ក្រុមហ៊ុន។ ចំពោះករណីរបស់យើង ពួកយើងពិតជារវល់ខ្លាំងណាស់ ហើយទោះវាមិនមែនជារឿង

អាក្រក់ក្តី  ក៏ពេលខ្លះយើងមិនបានផ្តល់នូវពេលវេលាឆ្លើយតបបានរហ័សបំផុតដូចដែលខ្ញុំចង់ធ្វើ សម្រាប់អតិថិជនរបស់យើងទេ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំធ្វើការជាមួយអតិថិជនជាវិយោគិន ហើយខ្ញុំស្រលាញ់ការងារនេះណាស់។

**ព្រះអម្ចាស់កំពុងប្រាប់ខ្ញុំថា ភាពហូរហៀរ ការសម្រាកថ្ងៃសប្ប័ទ មាននៅទីនោះស្រាប់ទៅហើយ ព្រះអង្គបានប្រទានមករួចហើយ។ គឺគ្រាន់តែខ្ញុំមិនបានមើលឃើញប៉ុណ្ណោះ!**

ប៉ុន្តែដោយសារតែកាលវិភាគខ្ញុំមមាញឹកពេក នៅពេលអតិថិជនជាវិនិយោគិនល្អៗទូរស័ព្ទមក ហើយប្រាប់ខ្ញុំឱ្យទូរសព្ទត្រលប់ទៅវិញដោយផ្ទាល់ ក៏ពេលខ្លះខ្ញុំមិនបានទូរស័ព្ទឆ្លើយតបទៅវិញក្នុងរយះពេល២៤ម៉ោងដែរ។ ចេតនារបស់ខ្ញុំគឺល្អទេ ប៉ុន្តែខ្ញុំគ្រាន់តែមិនបានធ្វើវាប៉ុណ្ណោះ។

ដូចអ្នកដឹងស្រាប់ហើយ នៅពេលមនុស្សធ្វើការចោទសួរ នោះគឺក្រុមហ៊ុនជាអ្នកផ្តល់ចម្លើយ ដែលនឹងធ្វើឱ្យអាជីវកម្មរបស់គេប្រសើរឡើង។ ពេលខ្លះ ការយឺតយ៉ាវក្នុងការទូរសព្ទត្រលប់ទៅកាន់អតិថិជនល្អៗដើម្បីពិភាក្សាពីតម្រូវការវិនិយោគរបស់ពួកគេក៏អាចជាការហួសពេលដែរ។

ពួកគេអាចបានទូរស័ព្ទទៅកាន់នរណាម្នាក់ទៀតដែលអាចឆ្លើយសំណួររបស់ពួកគេបាន។ មានរឿងជាច្រើនដែលអាចនាំទៅរកបញ្ហាបាន ប៉ុន្តែដំណោះស្រាយនឹងមាននៅជាមួយចម្លើយនៅពេលដែលមនុស្សចង់ដឹង។

ដូចនេះ នៅពេលព្រះអម្ចាស់ប្រទាននូវពាក្យទាំងបីនេះមកខ្ញុំ នោះខ្ញុំបានដឹងថាវាមានន័យអ្វីខ្លះ។ ខ្ញុំត្រូវតែក្រឡេកមើលទៅអ្វីៗក្នុងសភាពខុសគ្នា ប្រសិនបើខ្ញុំពិតជានឹងត្រូវឡើងលើឆាកនោះ ក្នុងចំណោមអ្នកខ្លាំងទាំង១០នាក់ និងទទួលបានប្រាក់បន្ថែម ១០០,០០០ដុល្លារ។ ខ្ញុំត្រូវតែឆក់យកឱកាសឱ្យបានពេញលេញ! ដូចនេះខ្ញុំបានធ្វើការផ្លាស់ប្តូរក្នុងរបៀបដែលខ្ញុំធ្វើកិច្ចការនានា។ ខ្ញុំបានបង្កើតវិន័យថា ប្រសិនបើមាននរណាទូរសព្ទមកចង់ប្រឹក្សាផ្នែកវិនិយោគ នោះខ្ញុំនឹងទូរសព្ទត្រលប់ទៅវិញក្នុងរយះពេលប៉ុន្មាននាទីក្រោយ ប្រសិនបើអាចធ្វើទៅបាន ហើយខ្ញុំនឹងទៅជួបពួកគេភ្លាមៗ។ អតិថិជនរបស់ខ្ញុំស្ថិតនៅពាសពេញប្រទេស ហើយការប្តេជ្ញានេះជាការប្តេជ្ញាចិត្តមួយដែលនឹងពិបាកធ្វើមែនទែន។ ប៉ុន្តែខ្ញុំបានប្តេជ្ញាចិត្តចំពោះវា។ ខ្ញុំបានទូរសព្ទទៅអ្នកគ្រប់គ្រងក្រុមហ៊ុន និងប្រាប់គាត់ពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល រួចប្រាប់គាត់ឱ្យប្រាប់អ្នកតំណាងខ្ញុំទាំងអស់ឱ្យមាន

ឥរិយាបថដូចៗគ្នាក្នុងការឆក់យកឱកាសនីមួយៗ នៅពេលមានអតិថិជនលេចចេញមក។ កន្លងផុតមួយឆ្នាំនោះ ពួកយើងបានធ្វើការងារដែលមានតម្លៃ ១១លានដុល្លារ ដែលតម្រូវឱ្យឈរលេខរៀងក្នុងចំណោមក្រុមហ៊ុនកំពូលៗទាំង១០សម្រាប់ការលក់នោះ។ លើសពីនោះ យើងក៏បានបង្កើតឱ្យមានសុវត្ថិភាពលើអាជីវកម្មបន្ថែមក្នុងតម្លៃរាប់លានដុល្លារសម្រាប់អ្នកលក់របស់យើង។

នេះជាការបង្ហាញចេញដ៏ធំមួយ។ ពួកយើងមិនបានធ្វើអ្វីឱ្យខុសពីមុនទេ គឺគ្រាន់តែប្រតិកម្មតបរហ័យបែបសាមញ្ញៗនៅពេលយើងមានអតិថិជនដែលចង់និយាយជាមួយយើងប៉ុណ្ណោះ។ ឃើញទេ ព្រះអម្ចាស់កំពុងប្រាប់ខ្ញុំថា ភាពហូរហៀរ ដែលជាការសម្រាកថ្ងៃសប្ប័ទ មាននៅទីនោះស្រាប់ហើយ ព្រះអង្គបានផ្គត់ផ្គង់រួចស្រេចទៅហើយ។ ខ្ញុំគ្រាន់តែមើលមិនឃើញប៉ុណ្ណោះ!

ដូច្នេះ វាមិនមែនជាច្បាប់របស់ព្រះរាជ្យនៃព្រះពីចំណែកទ្វេដងនៃរបៀបដែលត្រូវអនុម័តចំណែកទ្វេដងអ្វីនោះទេ។ ចំណែកទ្វេដងគឺមាននៅទីនោះរួចស្រេចទៅហើយ។ ព្រះជាម្ចាស់តែងតែផ្គត់ផ្គង់ក្នុងកម្រិតនៃចំណែកទ្វេដង។

## ព្រះជាម្ចាស់មិនដែលបញ្ជូនការផ្គត់ផ្គង់សម្រាប់តែថ្ងៃនេះទេ។ ទ្រង់តែងតែបញ្ជូនចំណែកទ្វេដង<u>មកជាមួយគ្នា</u>!

ជាថ្មីម្តងទៀត បញ្ហារបស់ពួកយើងគឺថា ពួកយើងគ្រាន់តែមិនបានមើលឃើញចំណែកទ្វេដងប៉ុណ្ណោះ។

## <u>ប៉ុន្តែបញ្ហាធំជាងនេះនោះគឺថា យើងថែមទាំងមិនបានដឹងថាត្រូវរកមើលផង!!!</u>

ខ្ញុំពេញចិត្តត្រង់ឃ្លាដែលព្រះយេស៊ូមានបន្ទូលថា «មិនត្រូវឱ្យបាត់មួយដុំសោះឡើយ!» ព្រះជាម្ចាស់បានបញ្ជូនវាមកទាំងអស់ហើយ ហើយទ្រង់ចង់ឱ្យអ្នកមានវា។ ព្រះអង្គទ្រង់ខូចព្រះហឫទ័យដែលមនុស្សបានចេញមករកនំម៉ាណានៅថ្ងៃទីប្រាំពីរ នៅពេលដែលព្រះអង្គបានបញ្ជូនវាមករួចស្រេចទៅហើយ។ ព្រះអង្គបានរំឭកលោកម៉ូសេថា ព្រះអង្គបានបញ្ជូនវាមកនៅថ្ងៃទីប្រាំមួយ ដូចនេះពួកគេអាចប្រមូលយក និងរីករាយនឹងការសម្រាកនៅថ្ងៃសប្ប័ទ។ និយាយឱ្យងាយយល់ ព្រះអង្គកំពុងប្រាប់ពួកគេថា «ថ្ងៃសប្ប័ទ

មិនមែនសម្រាប់យើងទេ វាគឺសម្រាប់អ្នករាល់គ្នា។ ហេតុនេះទើបយើងបញ្ជូនចំណែកទ្វេដងមកឱ្យអ្នករាល់គ្នា។» អ្នកក៏អាចនឹងឮព្រះយេស៊ូមានបន្ទូលដូចគ្នាដែរ។ «នែ៎អ្នកទាំងអស់គ្នា ចូររើសយកបំណែកនៅសល់ទាំងនោះ ហើយយកទាំងអស់ចុះ។ ព្រះជាម្ចាស់បានបញ្ជូនមកឱ្យអ្នករាល់គ្នារើសយក ដើម្បីឱ្យអ្នកអាចរីករាយនូវចំណែកទ្វេដង ហើយអាចមានការសម្រាកបាន។»

នៅក្នុងសាច់រឿងព្រះយេស៊ូប្រទាននំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយដល់បុរស ៥,០០០នាក់ ពួកសិស្សមិនបានមើលឃើញនូវបំណែកនៅសល់ទាំងនោះទេ។ ពួកគេថែមទាំងមិនរកមើលទៀតផង។ ប៉ុន្តែព្រះយេស៊ូបានប្រាប់ពួកគេពីអ្វីដែលត្រូវរកមើល ហើយការប្រមូលផលនោះមិនបានខកខានឡើយ។ ថ្ងៃនេះ ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវតែជួយយើងឱ្យមើលឃើញលើសពីការត្រឹមបានឆ្អែតស្កប់ស្កល់ និងចាប់យកចំណែកទ្វេដង។ ទ្រង់នឹងចង្អុលបង្ហាញប្រាប់យើងថា យើងនឹងមិនរកឃើញទេប្រសិនបើយើងសួររកពីទ្រង់នោះ។ គន្លឹះសំខាន់ដែលខ្ញុំសង្ឃឹមថាអ្នកបានរៀនសូត្រកន្លងមកនេះនោះគឺ ចំណែកទ្វេដងបានផ្តល់មកអ្នករួចស្រេចទៅហើយ អ្នកគ្រាន់តែត្រូវចាប់យកប៉ុណ្ណោះ។

ដោយសារតែចំណែកទ្វេដងគឺជាច្រកគេចចេញតែមួយពីប្រព័ន្ធនៃបណ្តាសាលោកិយ ដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា សាតាំងស្អប់វាណាស់។ អូហ៎ វាអាចព្យាយាមបញ្ចុះបញ្ចូលគ្រិស្តបរិស័ទថា បើពួកគេគ្រាន់តែអាចបង់ថ្លៃទឹកភ្លើង ធ្វើការងារពីរកន្លែងដើម្បីឱ្យមានលំនឹង នោះពួកគេកំពុងធ្វើបានត្រឹមត្រូវហើយ។ ប៉ុន្តែគ្រិស្តបរិស័ទម្នាក់ដែលមានប្រាក់ផ្គត់ផ្គង់ដល់ព្រះរាជ្យនៃព្រះ និងរស់នៅរស់នៅដោយមានសេរីភាពផុតពីភាពភ័យខ្លាច និងការបារម្ភផ្នែកហិរញ្ញវត្ថុ ពោលគឺមនុស្សនេះហើយដែលគេចង់បញ្ឈប់។ ចេតនារបស់សាតាំង គឺដើម្បីធ្វើឱ្យអ្នកដាច់ខ្យល់រាល់ថ្ងៃនៃជីវិតរបស់អ្នក និងជាប់ជាទាសករទៅនឹងបែបផែនជីវិតដែលបានត្រឹមមួយរស់ ដោយអ្នកគ្មានឥទ្ធិពលអ្វីសោះ។ លុយគឺជាឥទ្ធិពល! សាតាំងចង់បញ្ឈប់អ្នកពីព្រះពររបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដណាស់។ នេះជាមូលហេតុដែលថាអ្វីដែលខ្ញុំនឹងប្រាប់អ្នកនោះសំខាន់ខ្លាំងណាស់សម្រាប់ឱ្យអ្នកស្វែងយល់។

## ចំណែកទ្វេដងត្រូវបានលាក់បាំង!

ហ្នឹងហើយ គឺដល់ពេលដែលត្រូវឱ្យពួកសិស្សបានសម្រាកខ្លះហើយ។ នោះក៏ជាមូលហេតុមួយដែលពួកគេមើលមិនឃើញពីភាពហូរហៀរនោះដែរ។ ជាការពិតណាស់ ដូចអ្វីដែលយើងបាននិយាយ ពួកគេមិនមែនកំពុងរកមើលទេ តែពិតជានៅមានកត្តាមួយផ្សេងទៀត។ ជាធម្មតាអ្នកមិនរើសយកចំណែកដែលសល់ទេ! ខ្ញុំចង់មានន័យថា នៅក្នុងគំនិតរបស់គេ បំណែកនំប៉័ង និងត្រីដែលនៅពាសពេញនោះគឺគ្រាន់តែជាបំណែកសល់ប៉ុណ្ណោះ។

**ចេតនារបស់សាតាំងគឺដើម្បីឱ្យអ្នកដាច់ម៉ែរាល់ថ្ងៃនៃជីវិតរបស់អ្នក និងជាប់ជាទាសករទៅនឹងបែបផែនជីវិតដែលបានត្រឹមមួយរស់ ដោយអ្នកគ្មានឥទ្ធិពលអ្វីសោះ។**

ហេតុអ្វីបានជាកាក់ដែលពេត្រុសត្រូវយកទៅបង់ពន្ធនោះបានលាក់នៅក្នុងមាត់ត្រីទៅវិញ? តើនរណានឹងគិងថាត្រូវរកនៅកន្លែងនោះទៅ? តើនរណាដែលនឹងគិតថា ទូកចំនួនពីររបស់អ្នកនេសាទអាជីពដែលបាននេសាទត្រីពេញមួយយប់ដោយមិនបានអ្វីសោះ បែរជារកបានត្រីច្រើនបំផុតក្នុងជីវិតរបស់គេដោយសារតែពាក្យរបស់គ្រូម្នាក់? តើនរណាដែលនឹងគិតថា ស្ត្រីម្នាក់ដែលបានចែងក្នុងគម្ពីរពង្សាវតារក្សត្រ ជំពូក២ ខ៤ ដែលគ្មានប្រាក់នោះ ដោយគ្មានអ្វីនៅក្នុងផ្ទះរបស់នាងក្រៅតែពីប្រេងបន្តិច ហើយហៀបនឹងប្រកាសថានឹងត្រូវអស់អាហារ តែបែរជាមានប្រេងជាច្រើនដែលបានបង់ថ្លៃបំណុលទាំងអស់របស់នាង និងបានឱ្យនាងរស់នៅដោយមិនមានជាប់បំណុលផង? គឺគ្មាននរណាម្នាក់នឹងគិតបែបនេះហើយ។ តើនរណានឹងគិតថា លោកហ្គារី ឃីស៊ី ដែលបានបញ្ចប់ការសិក្សាត្រឹមជាសិស្សចុងក្រោយបន្ទាប់ពីសិស្សបាតថ្នាក់ប៉ុណ្ណោះ នឹងក្លាយជាសេដ្ឋីនៅថ្ងៃនេះ ហើយបាននិយាយទៅកាន់មនុស្សរាប់ពាន់នាក់នៅជុំវិញពិតពលោកជារៀងរាល់ថ្ងៃដែរឬទេ? គឺគ្មាននរណាម្នាក់គិតឃើញទេ! នៅក្នុងសាច់រឿងទាំងអស់នេះ ព្រះយេស៊ូប្រើប្រាស់រឿងដែលឥតរំពឹងទុកដើម្បីផ្លាស់ប្ដូរស្ថានភាពនៅជុំវិញ។

ប្រសិនបើភាពហូរហៀរ ដែលជាចំណែកទ្វេដង មាននូវភាពច្បាស់លាស់ណាស់ ដោយនៅបង្ហាញដោយបើកចំហ នោះសាតាំងអាចបានឃើញវា ហើយនឹងបានព្យាយាមស្ទាក់ចាប់ និងលួចយកទៀតផង។ ហេតុនេះហើយទើបព្រះជាម្ចាស់មិនបង្ហាញពីកំណប់

របស់ទ្រង់ដោយបើកចំហ។ កំណប់ទាំងនោះនៅលាក់កំបាំង។ សាតាំងស្អប់ការដែលអ្នកបានឆ្អែតស្កប់ស្កល់ និងរីករាយនូវការផ្គត់ផ្គង់ តែវាពិតជាស្អប់ខ្លាំងបើសិនអ្នកឈានជើងចូលទៅក្នុងភាពហូរហៀរ និងការសម្រាកនៅថ្ងៃសប្ប័ទ។

ខ្ញុំសូមបង្ហាញអ្នកនូវអ្វីមួយដែលអ្នកចាំបាច់ត្រូវយល់ពាក់ព័ន្ធនឹងរបៀបដែលព្រះជាម្ចាស់ធ្វើការនៅក្នុងពិភពផែនដី។

> *យើងប្រៀនប្រដៅអំពីប្រាជ្ញារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបង្កប់ន័យទុកតាមគម្រោងការដ៏លាក់កំបាំងរបស់ព្រះអង្គ តាំងពីមុនកំណើតពិភពលោកមកម៉្លេះ គឺព្រះអង្គបានគ្រោងទុកថានឹងប្រទានសិរីរុងរឿងមកយើង។ គ្មាននរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងមនុស្សលោកនេះ បានស្គាល់ប្រាជ្ញារបស់ព្រះអង្គទេ។ ប្រសិនបើគេពិតជាបានស្គាល់មែន គេមិនឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនោះឡើយ។*

១កូរិនថូស ២៖៧-៨

បទគម្ពីរនេះបានបង្ហាញយើងយ៉ាងច្បាស់ថា ប្រសិនបើសាតាំងបានដឹងពីផែនការរបស់ព្រះជាម្ចាស់ នោះវាប្រាកកដជាបានផ្លាស់ប្តូរវិធីសាស្ត្ររបស់វាមិនខាន! ហេតុនេះទើបព្រះជាម្ចាស់ត្រូវធ្វើការដោយអាថិកំបាំង។ សាតាំងនឹងតែងប្រតិកម្មចំពោះអ្វីដែលលេចចេញមកច្បាស់ៗ។ ការផ្គត់ផ្គង់ដ៏ហូរហៀររបស់អ្នកមិនអាចធ្វើឱ្យឃើញច្បាស់ៗមិនថារហូតដល់ពេលអ្នកនឹងបានចាប់យក ឬប្រមូលផលទេ គឺដោយសារតែមូលហេតុដូចគ្នានេះ។ ខ្ញុំមានសុភាសិតមួយដែលខ្ញុំតែងនិយាយរាប់ឆ្នាំមកហើយ។ កំណប់របស់ព្រះជាម្ចាស់គឺមានភាពអាថិកំបាំង មិនមែនលាក់បាំងពីអ្នកទេ គឺលាក់ទុកសម្រាប់អ្នក។

## លាក់*ពី*អ្នកដើម្បីទុក*ឱ្យ*អ្នក!

មនុស្សជាច្រើនបានប្រាប់ខ្ញុំថា ពួកគេសង្ឃឹមថា ព្រះជាម្ចាស់នឹងមិនចាំរហូតដល់កណ្តាលអគ្រាត្រដើម្បីនាំយកចម្លើយរបស់ទ្រង់នោះទេ។ ប៉ុន្តែបងប្អូនអើយ ព្រះជាម្ចាស់មិនអន្ទះសាទេ។ ទ្រង់ជ្រាបថាពេលណាដល់ថ្ងៃបង់ថ្លៃវិក្កយបត្រ ហើយការដែលព្រះជាម្ចាស់មិនបង្ហាញឱ្យឃើញព្រះហស្តរបស់ទ្រង់ឱ្យបានលឿននោះគឺដើម្បីជាប្រយោជន៍ដល់អ្នក ដែលសាតាំងមិនសូវបានស្ទាក់ចាប់យក។

*យើងនឹងប្រគល់មាសប្រាក់ដែលគេកប់ទុកក្នុងទីងងឹតមកឱ្យអ្នក ព្រមទាំងប្រគល់ទ្រព្យសម្បត្តិដែលគេទុកក្នុងទីលាក់កំបាំងមកឱ្យអ្នកដែរ។ ដូច្នេះ អ្នកនឹងដឹងថាយើងពិតជាព្រះអម្ចាស់ ជាព្រះរបស់ជនជាតិអ៊ីស្រាអែល ដែលហៅអ្នកមកតាមឈ្មោះរបស់អ្នក។*

អេសាយ ៤៥៖៣

ទ្រព្យសម្បត្តិត្រូវគេទុកក្នុងទីលាក់កំបាំងមែនទេ? នេះប្រសើរជាងសាច់រឿងអស្ចារ្យរបស់ហូលីវូដទៅទៀត។ ខ្ញុំសូមប្រាប់ពីឧទាហរណ៍មួយដល់អ្នកពីរបៀបដែលព្រះជាម្ចាស់បានជួយខ្ញុំឱ្យចាប់យកចំណែកទ្វេដងនៅក្នុងជីវិតធុរកិច្ចរបស់ខ្ញុំ។ ប៉ុន្មានឆ្នាំមុន ខ្ញុំកំពុងអង្គុយមើលបញ្ជីប្រាក់ចំណេញ-ចំណាយរបស់ខ្ញុំក្នុងឆ្នាំនោះសម្រាប់ក្រុមហ៊ុនសេវាកម្មហិរញ្ញវត្ថុរបស់ខ្ញុំ។ ទោះជាខ្ញុំស្កប់ស្កល់ក៏ដោយ ដោយខ្ញុំលែងជាប់ជំពាក់បំណុល និងមានប្រាក់មួយចំនួននៅក្នុងធនាគារ ក៏ខ្ញុំក៏ដឹងដែរថា នៅមានអ្វីច្រើនជាងនេះទៀត។ ខ្ញុំបានឃើញគម្រោងជាច្រើនដែលខ្ញុំចង់ឧបត្ថម្ភនៅក្នុងព្រះរាជ្យនៃព្រះ មានរឿងជាច្រើនដែលត្រូវធ្វើ ហើយទាំងអស់នេះសុទ្ធតែត្រូវចំណាយប្រាក់។

ពេលខ្ញុំបានអធិស្ឋានសម្រាប់ការនេះ ព្រះអម្ចាស់បានចាប់ផ្ដើមដោះស្រាយជាមួយខ្ញុំអំពីពាក្យថា *បំណែកនៅសល់*។ ដំបូង ខ្ញុំមិនបានយល់ពីអ្វីដែលទ្រង់កំពុងមានបន្ទូលទេ ប៉ុន្តែក្រោយមក ខ្ញុំបានអធិស្ឋានសម្រាប់ការនេះ និងបានស្ដាប់ រួចខ្ញុំក៏បានយល់។ បំណែកនៅសល់ដូចមានសរសេរក្នុងសាច់រឿងដែលយើងទើបនឹងបានអានរួចនេះ ត្រូវបានគេមើលរំលង។ បើនិយាយពីតម្លៃ បំណែកនៅសល់ទាំងនេះត្រូវគេចាត់ទុកថា ឥតតម្លៃ មិនថាដោយសារកម្លាំងដែលត្រូវប្រើដើម្បីធ្វើឱ្យពួកគេចាប់យកបំណែកនៅសល់ទាំងនោះត្រូវបានគេយល់ថាមិនមានតម្លៃ ឬតម្លៃរបស់វាស្ថិតលើប្រព័ន្ធគុណតម្លៃដែលហួសសម័យ។ ឬអាចជាការយល់ខុស និងមានដែនកំណត់អំពីសក្តានុពលនៃបំណែកនៅសល់ ដែលបានដាក់ដែនកំណត់លើសក្តានុពលក្នុងការប្រើប្រាស់នៃបំណែកនៅសល់ ដែលបានកំណត់នូវការយល់ដឹងរបស់ពួកគេអំពីការកើនឡើងដែលអាចទៅរួចនៅលើតម្លៃ ចេញពីការយល់ឃើញនាពេលបច្ចុប្បន្នរបស់ពួកគេ។

ខ្ញុំជឿជាក់ថា អ្នកបានឮមនុស្សនិយាយជាច្រើនដងថា «នេះជារបៀបដែលយើងតែងតែធ្វើកន្លងមក»។ ហ្នឹងហើយ ខ្ញុំអាចប្រាប់អ្នកបានថា ចំណែកទ្វេដងប្រហែលជានឹងមិនមកដោយរបៀបនោះទេ។

នៅពេលខ្ញុំមើលទិន្នន័យ ព្រះជាម្ចាស់បានបើកភ្នែកខ្ញុំឱ្យឃើញនូវបំណែកនៅសល់ជាច្រើនដែលខ្ញុំបានបន្សល់ទុកនៅលើតុ ដែលខ្ញុំគួរតែរើសវាទុក។ អាទិភាពមួយក្នុងចំណោមអាទិភាពផ្សេងៗទៀតដែលយើងធ្វើជាមួយអតិថិជនរបស់យើងម្នាក់ៗនោះគឺ ត្រូវធ្វើឱ្យបានគ្រប់ជ្រុងជ្រោយនៃព័ត៌មានបុគ្គលលើពួកគេដើម្បីឱ្យឃើញថា តើពួកគេអាចមានទ្រព្យអ្វីខ្លះ ក៏ដូចជាមើលថាពួកគេមានបំណុលអ្វីខ្លះ។ បន្ទាប់មក ទើបពួកយើងធ្វើការវិភាគរកមើលប្រាក់ណាខ្លះដែលយើងអាចកំណត់ឡើងវិញដើម្បីឈានទៅរកការលុបបំបាត់បំណុល។ ជាការពិតណាស់ យើងសរសេរចុះស្ថានភាពនៃប្រាក់កម្ចីដែលមានទ្រព្យបញ្ចាំ និងអត្រាការប្រាក់ ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌប្រាក់កម្ចីលើក្រដាសបញ្ជីទិន្នន័យ។ ពេលនោះ យើងក៏បានធ្វើការផ្តល់ប្រឹក្សាយោបល់ដល់អតិថិជនរបស់យើងដើម្បីទទួលយកលក្ខខណ្ឌឥណទានមកទប់ទល់នឹងការលោះផ្ទះដើម្បីបញ្ចប់លើការចំណាយលើឥណទានដែលមានអត្រាការប្រាក់ខ្ពស់ ដោយបានទម្លាក់អត្រាការប្រាក់ដើមក្នុងអត្រា ២១%មកនៅសល់ត្រឹម ៦%។ ប្រាក់សន្សំដែលបានពីការរៀបចំនេះ បានជួយដល់គ្រួសារជាមធ្យមពី ៥០០ដុល្លារ ទៅ ៦០០ដុល្លារក្នុងមួយខែនៅក្នុងលំហូរចរន្តសាច់ប្រាក់។ នៅពេលស្ថានភាពនេះបានលេចចេញឡើង យើងនឹងបញ្ជូនអតិថិជនរបស់យើងត្រលប់ទៅធានាគាររបស់ខ្លួនដើម្បីធានានូវកម្ចីរួម។

នៅពេលខ្ញុំកំពុងសិក្សាពីទិន្នន័យរបស់ខ្ញុំ ព្រះវិញ្ញាណដ៏វិសុទ្ធបានចង្អុលបង្ហាញពីបញ្ហាប្រាក់កម្ចីមានទ្រព្យបញ្ចាំឱ្យខ្ញុំបានឃើញ។ «ហេតុអ្វីបានជាអ្នកមិនដោះស្រាយកិច្ចការប្រាក់កម្ចីមានទ្រព្យបញ្ចាំនោះ?» នៅពេលខ្ញុំគិតដល់ចំណុចនេះ ខ្ញុំក៏យល់ថាស្តាប់ទៅទំនងម្យ៉ាងដែរ។ យើងទទួលបានទំនុកចិត្តពីអតិថិជនរួចទៅហើយ ពួកយើងមានទិន្នន័យស្រាប់ ហើយចុងក្រោយ យើងជាម្នាក់ដែលធ្វើការស្នើឱ្យពួកគេរៀបចំហិរញ្ញវត្ថុដោះស្រាយបំណុលឡើងវិញជាមុន។

ដើម្បីដោះស្រាយផ្នែកនៃអាជីវម្មនេះ នឹងតម្រូវឱ្យខ្ញុំរៀនពីអាជីវកម្មថ្មីទាំងស្រុង ត្រូវប្រលងជាប់បានបណ្ណអនុញ្ញាត និងចូលរៀនថ្នាក់បណ្តុះបណ្តាល និងធ្វើរឿងជាច្រើនទៀត។ ខ្ញុំមិនមានពេលធ្វើរឿងទាំងអស់នេះទេ។ ប៉ុន្តែពេលខ្ញុំបន្តអធិស្ឋានអំពីការនេះ ព្រះអម្ចាស់បានបង្ហាញខ្ញុំឱ្យជួលគេរៀបចំ និងចាត់ចែងក្រុមហ៊ុនកម្ចីប្រាក់ដែលមានទ្រព្យបញ្ចាំ នោះខ្ញុំក៏បានធ្វើបែបនេះ។ ដោយការរ៉ាប់រងនូវការងារប្រាក់កម្ចីមានទ្រព្យបញ្ចាំដោយខ្លួនឯងនៅក្នុងឆ្នាំដំបូងបាននាំឱ្យយើងមានប្រាក់ចំណូលសុទ្ធបន្ថែម ១៦០,០០០ដុល្លារ។ នេះ

ជាប្រាក់ដែលខ្ញុំមិនអាចមានបានទេប្រសិនបើខ្ញុំមិនស្ដាប់ព្រះវិញ្ញាណដ៏វិសុទ្ធចង្អុលបង្ហាញពីបំណែកនៅសល់ដែលខ្ញុំបានត្រឹមតែសម្លឹង តែមិនដែលបានឃើញនោះ។

ខ្ញុំបានចេញទៅចាប់យករបស់ជាច្រើនទៀត ជាបំណែកនៅសល់ដែលព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំ។ ដោយសារតែគំនិតគិតទុកជាមុនរបស់ខ្ញុំដែលខ្ញុំបានរៀន ឬបានឮពីអ្នកឯទៀតៗនិយាយថា ផ្នែកមួយនេះមិនស័ក្តិសមនឹងចូលទៅទេ នោះបំណែកនៅសល់មួយដែលខ្ញុំកំពុងមើលរំលងនោះ បានក្លាយជាជោគជ័យដ៏ធំមួយសម្រាប់ពួកយើង។ ទីបំផុត នៅពេលខ្ញុំបានអង្គុយចុះ និងពិនិត្យមើលលើផ្នែកនេះ ខ្ញុំដឹងថា ព័ត៌មានទាំងអស់ដែលខ្ញុំបានឮពីផ្នែកនៃផលិតផលនេះគឺមិនត្រឹមត្រូវ ហើយតាមពិតទៅ វាស័ក្តិសមយ៉ាងល្អបំផុតសម្រាប់ក្រុមហ៊ុនរបស់យើង។ តាមពិតទៅ បំណែកដែលនៅសល់នោះបានបង្កើតឱ្យមានចំណូលបន្ថែមច្រើនជាងគំរូអាជីវកម្មស្នូលដែលមានស្រាប់ទៅទៀត ដោយរកប្រាក់ចំណូលបានរាប់លានដុល្លារ។ និយាយឱ្យចំទៅ វាជាបំណែកនៅសល់ដែលមានតម្លៃរាប់លានដុល្លារ!

ដូចនេះ ខ្ញុំសូមប្រាប់អ្នកឱ្យបានច្បាស់បន្តិច។ ចំណែកទ្វេដងត្រូវបានចាប់យកតាមរយៈការបើកបង្ហាញ! ការបើកបង្ហាញគឺជាអ្វីមួយយ៉ាងសាមញ្ញដែលព្រះវិញ្ញាណដ៏វិសុទ្ធកំពុងបង្ហាញដល់អ្នកថា អ្នកនឹងមិនបានដឹងដោយខ្លួនឯងទេ។ ដូចនេះព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញ ឬបើកភ្នែករបស់អ្នកឱ្យឃើញអ្វីមួយ ជាអ្វីដែលអ្នកមិនបានដឹងដោយខ្លួនឯង។ ការនេះត្រូវបានហៅថាជាចំណេះដឹងដែលត្រូវបានបើកសម្តែង។

## ការបើកសម្តែងគឺជាកូនសោចូលទៅកាន់ចំណែកទ្វេដង!

ហេតុនេះ ក៏មានមនុស្សខ្លះសួរខ្ញុំថា «តើខ្ញុំស្ដាប់ឮព្រះវិញ្ញាណដ៏វិសុទ្ធដោយរបៀបណាទៅ? តើខ្ញុំអាចស្ដាប់ឮពីរបៀបត្រូវចាប់យកគំនិត និងឱកាសដែលបានលាក់ទុកបានយ៉ាងដូចម្ដេចទៅ?» ពិតជាសំណួរល្អមែន។ ក្នុងសៀវភៅនេះ ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីនិយាយស៊ីជម្រៅពាក់ព័ន្ធនឹងការស្ដាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ទេ។ ដូចនេះ ខ្ញុំនឹងណែនាំអ្នកឱ្យមើលសៀវភៅមួយទៀតដែលខ្ញុំសរសេរ ដែលសៀវភៅនេះមានចំណងជើងថា *ការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ*។ អ្នកអាចរកទិញសៀវភៅនេះនៅលើគេហទំព័រលក់ទំនិញ អាម៉ាហ្សូន (Amazon) ឬតាមរយៈគេហទំព័ររបស់ពួកយើង។ នៅក្នុងសៀវភៅនោះ អ្នកនឹង ឃើញព័ត៌មានបន្ថែមទៀតពាក់ព័ន្ធនឹងរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការ

ដើម្បីបង្ហាញ យើងនូវផែនការលាក់កំបាំងរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងអាចចម្រុងចម្រើននៅក្នុងពិភពផែនដីនេះ ដែលនៅក្បែរសាតាំងនេះឯង ហើយគ្មានអ្វីមួយដែលសាតាំងអាចធ្វើបានឡើយ ។ ប៉ុន្តែ ដើម្បីនាំអ្នកចូលទៅកាន់ទិសដៅត្រឹមត្រូវ ចូរយើងក្រឡេកមើលខគម្ពីរ **១កូរិនថូស ១៤:២**

*អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះនិយាយទៅកាន់ព្រះជាម្ចាស់ មិនមែននិយាយទៅកាន់មនុស្សទេ ដ្បិតគ្មាននរណាយល់ន័យ ព្រោះព្រះវិញ្ញាណនាំចិត្តអ្នកនោះឱ្យថ្លែងពីសេចក្តីដ៏លាក់កំបាំង។*

**ខ៤** ចែងថា

*អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះកសាងតែខ្លួនឯងប៉ុណ្ណោះ។*

ពាក្យថា កសាង មានន័យថា នាំយកនាំការបង្ហាត់បង្ហាញ ឬការយល់ដឹង។ ខ្ញុំត្រូវការសេចក្តីនេះ ហើយលោកអ្នកក៏ដូចគ្នាដែរ។ នៅពេលព្រះគម្ពីរនិយាយត្រង់ពាក្យនេះស្តីពីការនិយាយភាសាចម្លែកអស្ចារ្យ ឬដូចអ្វីដែលលោកប៉ូលបានពណ៌នានោះ ពោលគឺការអធិស្ឋាននៅក្នុងព្រះវិញ្ញាណ នោះខ្ញុំចង់លើកទឹកចិត្តអ្នកថា មិនថាអ្នកបានស្តាប់ឮអ្វីអំពីតួនាទីនៃព្រះវិញ្ញាណដ៏វិសុទ្ធទេ មិនថាមាននរណាម្នាក់បានប្រាប់អ្នកថា វាបានកន្លងផុតហួសទៅហើយតាំងពីជំនាន់ពួកសាវ័កមកម៉្លេះ ឬថា ការនេះមកពីអារក្សទេ នោះសូមអ្នកអានព្រះគម្ពីរមើលចុះ! ការអធិស្ឋាននៅក្នុងព្រះវិញ្ញាណ គឺជាការដែលព្រះវិញ្ញាណអធិស្ឋានតាមរយៈអ្នកនៅក្នុងពិភពផែនដីនេះ ដើម្បីនាំយកនូវបំណងព្រះហឫទ័យរបស់ព្រះអង្គឱ្យបានចូលទៅដោយមិនឱ្យអារក្សដឹងថាកំពុងមានអ្វីកើតឡើង។ ការអធិស្ឋាននៅក្នុងព្រះវិញ្ញាណគឺជាកូនសោដ៏សំខាន់ដើម្បីស្តាប់ឮនូវការបើកបង្ហាញពីស្ថានសួគ៌ ហើយខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យសិក្សាស្វែងយល់ពីអ្វីដែលខ្ញុំបាននិយាយ។ ហើយប្រសិនបើអ្នកមានសំណួរអ្វី សូមអានសៀវភៅរបស់ខ្ញុំចុះ ហើយខ្ញុំដឹងថាវានឹងជួយអ្នកឱ្យទទួលបាននូវចំណេះដឹងបន្ថែមទៀតអំពីតួនាទីដ៏អស្ចារ្យនៃព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់យើង។

ខ្ញុំចង់ធ្វើសេចក្តីសន្និដ្ឋានសរុបសៀវភៅនេះដោយលើកយកខគម្ពីរចំនួនពីរ ដែលធ្វើការសរុបជំពូកនេះ។

*ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ហួសពីសេចក្តីសុំ និងហួសពីអ្វីៗដែលយើងនឹកគិត ដោយសារឫទ្ធានុភាពរបស់ព្រះអង្គដែលបំពេញសកម្មភាពនៅក្នុង*

*យើង។ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គក្នុងក្រុមជំនុំ និងក្នុងព្រះគ្រិស្ត យេស៊ូ នៅគ្រប់ជំនាន់ អស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។*

អេភេសូ ៣៖២០-២១

អ្នកមិនដែលអាចសុំអ្វីមួយដែលអ្នកមិនដែលគិតដល់ឡើយ។ បច្ចុប្បន្ននេះ ខ្ញុំមានយន្តហោះពីរគ្រឿង យន្តហោះខ្នាតតូចជាងនោះ ខ្ញុំប្រើដើម្បីជិះកម្សាន្តលេង ហើយយន្តហោះសម្រាប់ធុរកិច្ចរបស់ខ្ញុំ ខ្ញុំប្រើវាសម្រាប់ហោះហើរទៅកាន់គ្រប់កន្លែងក្នុងប្រទេសដែលខ្ញុំទៅ។ នៅពេលខ្ញុំពិចារណារឿងរកទិញយន្តហោះសម្រាប់ផ្នែកធុរកិច្ច ខ្ញុំពិតជាតាំងស្មារតីនឹងតម្លៃរបស់វា។ យន្តហោះមិនថោកទេ! ខ្ញុំចាប់ផ្តើមគិតឡើងវិញ ដោយត្រិះរិះថា «ខ្ញុំអាចធ្វើដោយមិនចាំបាច់មានយន្តហោះខ្នាតអាជីវកម្ម។ សរុបមក វាពិតជាថ្លៃណាស់។» ប៉ុន្តែខ្ញុំបានហោះហើរជារៀងរាល់សប្តាហ៍ដោយប្រើជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរពាណិជ្ជកម្ម ហើយខ្ញុំត្រូវធ្វើដំណើរហោះហើរចំនួន២៣ដងក្នុងមួយខែ។ ខ្ញុំពិតជានឿយណាយណាស់។ មែនហើយ ខ្ញុំអាចនិយាយថា ខ្ញុំមាននូវការផ្គត់ផ្គង់។ ការធ្វើដំណើរតាមយន្តហោះរបស់ខ្ញុំត្រូវបានគេចេញថ្លៃចំណាយឱ្យ គឺគ្មានបញ្ហារឿងទឹកប្រាក់ដែលត្រូវបង់នោះទេ។ ប៉ុន្តែដំណើរតាមជើងយន្តហោះរបស់ខ្ញុំគ្មានអ្វីក្រៅតែពីការអង្គុយសម្រាកលើនោះទេ។ ជើងហោះហើរត្រូវបានលុប ឬមានភាពយឺតយ៉ាវ ហើយពិតជារញ៉េរញ៉ៃណាស់។ នេះមិនមានជាការសម្រាកថ្ងៃសប្ប័ទដែលខ្ញុំត្រូវការទេ។

ទីបំផុតខ្ញុំសារភាពថា ខ្ញុំកំពុងដាក់កំហិតលើព្រះជាម្ចាស់ត្រង់ចំណុចនេះ។ ទ្រង់ជាព្រះនៃចំណែកទ្វេដង។ ឌ្រិនដា និងខ្ញុំមានភាពស្ទាក់ស្ទើរក្នុងការទិញយន្តហោះអស់រយៈពេលជាងមួយឆ្នាំ គួរឱ្យស្តាយដែរ។ ទីបំផុត ព្រះជាម្ចាស់បានឱ្យយើងចាប់អារម្មណ៍លើយន្តហោះមួយនោះ ហើយមានបន្ទូលប្រាប់យើងថាទ្រង់បានព្យាយាមយកយន្តហោះនោះមកឱ្យយើងក្នុងរយៈពេលពីរឆ្នាំហើយ! ពួកយើងបានកែប្រែចិត្តគំនិត និងបានធ្វើការសម្រេចចិត្ត។ ពួកយើងបានសាបព្រោះគ្រាប់ពូជសម្រាប់យន្តហោះប្រភេទអាជីវកម្មដែលយើងចង់បាន និងត្រូវការ ហើយនៅពេលពួកយើងបានរៀបធ្វើកិច្ចការនេះ ពួកយើងក៏ទិញបានយន្តហោះនោះក្នុងរយៈពេលពីរខែ។ ក្នុងអំឡុងពេលនោះ ព្រះជាម្ចាស់បានប្រទាននូវចំណេះដឹង និងព្រះទ័យសន្តោសលើដំណោះស្រាយអាជីវកម្មមួយចំនួន ហើយខ្ញុំក៏មានប្រាក់ពេលខ្ញុំត្រូវការ។

មែនហើយ ព្រះជាម្ចាស់គឺជាព្រះនៃចំណែកទ្វេដង។ តើវាបានធ្វើឱ្យមានភាពខុសគ្នាដែរឬទេ? ហ្នឹងហើយ ភាពខុសគ្នានៅក្នុងជីវិតរបស់ខ្ញុំដែលអាចហោះហើរលើយន្តហោះផ្ទាល់ខ្លួនរបស់ខ្ញុំបើធៀបទៅនឹងការហោះហើរដោយប្រើក្រុមហ៊ុនជើងហោះហើរខ្នាតពាណិជ្ជកម្មនោះ គឺដូចទៅនឹងការជិះម៉ូតូ ឬបើកឡានទៅកន្លែងណាត់ជួបក្នុងចម្ងាយ ជាង ៨០គ.មអឺចឹង។ និយាយមែនណា! ហើយព្រះជាម្ចាស់កំពុងព្យាយាមយកវាឱ្យខ្ញុំក្នុងរយៈពេលពីរឆ្នាំ ខណៈពេលដែលខ្ញុំទើបតែសម្លឹងមើលភាពស្កប់ស្កល់ និងមើលមិនឃើញពីចំណែកទ្វេដងដែលព្រះជាម្ចាស់បានផ្តត់ផ្គង់មកខ្ញុំរួចស្រេច។ ខ្ញុំគ្រាន់តែត្រូវមើលឱ្យឃើញតែប៉ុណ្ណោះ។

អ្នកអាចនឹងធ្វើការបើករថយន្តយ៉ាងឥតសំចៃដែលវាត្រូវការជួសជុល ហើយអ្នកបន់ឱ្យតែវាអាចបញ្ឆេះកើតពេលអ្នកក្រោយពីគេងវិញ។ សូមឈប់សម្លឹងមើលតែគណនីធនាគារដែលគ្មានទឹកប្រាក់ និងធ្វើការសម្រេចចិត្តត្រឹមមួយរស់ដោយផ្អែកលើភាពគ្មានប្រាក់កាក់នោះ។ ផ្ទុយទៅវិញ សូមឱ្យព្រះជាម្ចាស់នៃចំណែកទ្វេដងបង្ហាញអ្នកពីបំណែកនៅសល់ ជាអ្វីដែលនៅលាក់កំបាំងដែលអ្នកត្រូវដឹងដើម្បីឱ្យមានសេរីភាព ហើយរីករាយនឹងសេចក្តីសុខសាន្ត និងការសម្រាកនៅថ្ងៃសប្ប័ទ។ ទ្រង់ប្រទាននូវផែនការដល់អ្នក ព្រមទាំងបង្ហាញអ្នកនូវរបៀបធ្វើវា ប្រសិនបើអ្នកគ្រាន់តែទូលសុំទ្រង់។ ដូចព្រះយេស៊ូមានបន្ទូលថា «កុំឱ្យបាត់មួយដុំសោះឡើយ!» ចំណែកទ្វេដងបានប្រទានមកអ្នករួចស្រេចទៅហើយ!

> *ដូច្នេះ ព្រះជាម្ចាស់បានតម្រូវទុកឱ្យមានថ្ងៃសម្រាកមួយទៀត សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរដែរ ដ្បិតអ្នកណាចូលទៅសម្រាកជាមួយព្រះជាម្ចាស់ អ្នកនោះបានបង្ហើយកិច្ចការរបស់ខ្លួន ដូចព្រះជាម្ចាស់បង្ហើយកិច្ចការរបស់ព្រះអង្គដែរ។*

ហេប្រឺ ៤៖៩-១០

ខ្ញុំជឿជាក់ថាសៀវភៅនេះបានក្លាយជាព្រះពរមួយសម្រាប់លោកអ្នក ហើយក៏ជាការដើរជាមួយព្រះអម្ចាស់យេស៊ូគ្រិស្តផងដែរ។ ដូចខ្ញុំបានរៀបរាប់ក្នុងសៀវភៅនេះអ៊ីចឹងសៀវនេះជាស្នាដៃសៀវភៅទីពីរក្នុងស៊េរីសៀវភៅ «បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក»។ ស៊េរីសៀវភៅនេះមានចំនួនសរុបប្រាំក្បាល ដូចនេះ សូមលោកអ្នកបន្តតាមដានរកមើលសៀវភៅបន្តបន្ទាប់ទៀតនៅក្នុងគេហទំព័ររបស់ពួកយើង។ ហើយអ្នកក៏អាចពិចារណាក្នុងការចង់ចូលរួមជាសមាជិកនៃក្រុមបដិវត្តន៍ ដែលជាកម្មវិធីបង្ហាត់បង្ហាញរបស់ពួកយើងផងដែរ។ លោកអ្នកក៏អាចរកមើលព័ត៌មានបន្ថែមនៅលើគេហទំព័ររបស់ពួកយើងទាក់ទងនឹងការបដិវត្តក្រុម ផងដែរ។

លោក ហ្គារី និងអ្នកស្រី ឌ្រិនដា ឃីស៊ី ជាម្ចាស់និងជាអ្នកដឹកនាំក្រុមហ៊ុនហិរញ្ញវត្ថុ Forward Financial Group នៅក្រុង ញូវ អាល់បានី រដ្ឋអូហៃយ៉ូ 1-(800)-815-0818.

លោក ហ្គារី និងអ្នកស្រី ឌ្រិនដា ឃីស៊ី គឺជាគ្រូគង្វាលនៃក្រុមជំនុំជីវិតនៃជំនឿ (Faith Life Church) នៅក្រុងញូវ អាល់បានី រដ្ឋអូហៃយ៉ូ។

សម្រាប់ធនធានផ្សេងៗបន្ថែមទៀតដែលបានរៀបចំដោយ លោក ហ្គារី និងអ្នកស្រី ឌ្រិនដា ឃីស៊ី សូមចូលទៅកាន់គេហទំព័រ

FaithLifeNow.com, GaryKeesee.com, or Drenda.com

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក
## អំណាចនៃការសម្រាក

**តើអ្នកនឿយហត់មែនទេ?**

**នឿយហត់ក្នុងការរត់ក្នុងកងរង្វង់ ក្នុងទ្រុងកណ្ដុរមែនទេ?**

**នឿយហត់ក្នុងការមានអារម្មណ៍ថា ជាប់គាំងមែនទេ?**

**នឿយហត់ក្នុងការបារម្ភមែនទេ?**

**នឿយហត់ក្នុងការមិនសប្បាយរីករាយមែនទេ?**

**អ្នកមិនចាំបាច់រស់នៅតាមរបៀបនោះទៀតទេ។**

សូមចូលរួមជាមួយលោកគ្រូ ហ្គារី ឃីស៊ី ក្នុងដំណើរដ៏អស្ចារ្យនៃរបកគំហើញនេះ និងរៀនពីប្រព័ន្ធថ្មីមួយ ជាប្រព័ន្ធមួយដែលនឹងធ្វើបដិវត្តន៍ជីវិតរបស់អ្នកទាំងស្រុង ដូចអ្វីដែលបានកើតឡើងបន្ទាប់ពីរយៈពេល ៩ ឆ្នាំដ៏វែងអន្លាយនៃការរស់នៅក្នុង*ភាពនឿយហត់* និងនៅចុងបំផុតនៃខ្សែព្ធរខាងហរិញ្ញវត្ថុ រាងកាយ និងអារម្មណ៍របស់របស់គាត់។

សូមរកឱ្យឃើញនូវ ៖

១. របៀបដែលអ្វីៗគ្រប់យ៉ាងបានផ្លាស់ប្តូរសម្រាប់ លោកគ្រូហ្គារី - របៀបដែលគាត់ចាកចេញពីភាពអស់សង្ឃឹមទាំងស្រុងក្នុងផ្នែកហិរញ្ញវត្ថុ ផ្នែករាងកាយ ឆ្ពោះទៅរកសុខុមាលភាព និងភាពពេញលេញ និងការទិញឡានដោយប្រើលុយសុទ្ធ ការសាងសង់ផ្ទះដោយមិនជាប់បំណុល ការចាប់ផ្តើមក្រុមហ៊ុនជាច្រើន និងការបង្រៀនដល់មនុស្សរាប់រយ រាប់ពាន់នាក់ អំពីព្រះរាជ្យដ៏មានជីវិត ... *អំពីការរស់នៅក្នុងជីវិតនៃសម្រាក*។

២. របៀបអ្វីៗគ្រប់យ៉ាងអាចផ្លាស់ប្តូរសម្រាប់អ្នកដែរ និងរបៀបដែលអ្នកអាចរស់នៅក្នុងជីវិតនៃការសម្រាក។

ទោះបីជាមនុស្សគ្រប់រូបដែលអ្នកស្គាល់កំពុងតែរស់នៅក្នុងជីវិតដែលនឿយហត់ និងកំពុងរត់យ៉ាងលំបាកដើម្បីតែចង់មានជីវិតរស់ ក៏ប៉ុន្តែអ្នកមិនចាំបាច់ត្រូវរស់នៅក្នុងរបៀបនោះទេ។

តាមរយៈការយល់ពីគោលការណ៍គន្លឹះរបស់ការសម្រាកក្នុងថ្ងៃសប្ប័ទ អ្នកអាចឃើញពីលទ្ធផលពិតប្រាកដនៅក្នុងជីវិតអ្នក។ អ្នកអាច *រស់នៅ* ក្នុងទីកន្លែងមួយដែលតម្រូវការរបស់អ្នកទទួលបានការបំពេញ ហើយមានសេរីភាពចេញពីកងរង្វង់ក្នុងទ្រុងកណ្ដុរ មានសេរីភាពក្នុងការស្វែងរក និងចម្រើនឡើងក្នុងគោលបំណង និងចំណង់ចំណូលចិត្តរបស់អ្នក ជាកន្លែងដែលអ្នកកំពុងចម្រុងចម្រើនលើសពីការនៅរស់រានមានជីវិត និងកន្លែងដែលអ្នកកំពុងបង្ហាញពីលទ្ធផល ទៅកាន់ពិភពលោក ដែលខុសប្លែកពីអ្វីដែលពួកគេបានឃើញទូទៅ។

សូមកុំនៅជាប់គាំង។ សូមកុំបន្តរស់នៅក្នុងភាពនឿយហត់។

សូមរកឱ្យឃើញនូវរបៀបរស់នៅថ្មី!



លោកហ្គារី ឃីស៊ី គឺជាអ្នកនិពន្ធ វាគ្មិន សហគ្រិន អ្នកជំនាញហិរញ្ញវត្ថុ និងជាគ្រូគង្វាលដែលមានចិត្តឆេះឆួលក្នុងការជួយមនុស្សឱ្យមានជ័យជម្នះក្នុងជីវិត ជាពិសេសទាក់ទងនឹងជំនឿ ក្រុមគ្រួសារ និងហិរញ្ញវត្ថុ។ លោកហ្គារី និងអ្នកស្រី ឌ្រិន ដា ជាភរិយាបានបង្កើតអាជីវកម្មដ៏ជោគជ័យជាច្រើន ព្រមទាំងជាស្ថាបនិកព័ន្ធកិច្ច Faith Life Now ដែលផលិតកម្មវិធីទូរទស្សន៍ចំនួនពីររួមមាន *Fixing the Money Thing* និង *Drenda* សន្និបាតជុំវិញពិភពលោក ព្រមទាំងធនធានអនុវត្តជាច្រើន។ ក្រុមគ្រួសារឃីស៊ី ក៏ជាគ្រូគង្វាលនៅក្នុងក្រុមជំនុំ Faith Life Church នៅក្បែរទីក្រុង កូឡុំបឹស រដ្ឋអូហៃយ៉ូ។

P. O. Box 779, New ALBANY, OH 43054
1.888.391.LIFE | garykeesee.com